ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# លទ្ធផលអង្កេតភពផែនដី
# នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២៣

## ( តំបន់ឆ្នេរសមុទ្រខេត្តកំពត និង ខេត្តកែប )

រៀបចំដោយ៖

អង្គភាពក្រុមសង្កេតការណ៍ភពផែនដី

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ

ខែមករា ឆ្នាំ២០២៤

# និមិត្តសញ្ញា
# ក្រុមសង្កេតការណ៍ភពផែនដីកម្ពុជា
( Cambodia GEO )

# បុព្វកថា

ខ្ញុំមានសេចក្ដីសោមនស្សរីករាយជាខ្លាំង សូមបង្ហាញជូននូវសមិទ្ធផលថ្មីមួយទៀតដែលវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការសម្រេចបាន នៅក្នុងអាណត្តិទី៧ របស់រាជរដ្ឋាភិបាលកម្ពុជា គឺរបាយការណ៍លទ្ធផលនៃអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ ដែលបានសិក្សាទៅលើខេត្តស្ថិតនៅតំបន់ឆ្នេរសមុទ្រចំនួន២រួមមាន ខេត្តកំពត និងខេត្តកែប បន្ទាប់ពីស្ថានភាពឆ្លងនៃជំងឺរាតត្បាតកូវីដ-១៩ បានធ្លាក់ចុះ។ អង្កេតភពផែនដីឆ្នាំ២០២៣ គឺជាការអង្កេតលើកទី៥ ដែលបានអនុវត្តក្រោមថវិកាកម្មវិធីនៃគម្រោងអង្កេតភពផែនដីឆ្នាំ២០២៣ របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការរបស់រាជរដ្ឋាភិបាលកម្ពុជា បន្ទាប់ពីប្រទេសកម្ពុជាបានចូលជាសមាជិកទី១០៤ នៃក្រុមសង្កេតការណ៍ភពផែនដីនៅឆ្នាំ២០១៧ រួចមក។

គម្រោងការងារអង្កេតភពផែនដីឆ្នាំ២០២៣នេះ បានប្រមូលទិន្នន័យនូវសូចនាករចម្បងៗមួយចំនួនរួមមានស្ថានភាពលក្ខណៈប្រជាសាស្ត្រ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ឆ្នេរសមុទ្រនៃខេត្តគោលដៅចំនួន២គឺ ខេត្តកំពតនិងខេត្តកែប។ វិធីសាស្ត្រនៃការប្រមូលទិន្នន័យនៃអង្កេតនេះ គឺត្រូវបានធ្វើឡើងតាមរយៈការសម្ភាសប្រធានភូមិ និងមេគ្រួសារនៅក្នុងខេត្តគោលដៅខណៈដែលប្រទេសកម្ពុជាយើងពុំទាន់មានផ្កាយរណប និងពុំមានប្រទេសណាមួយបានផ្ដល់នូវទិន្នន័យតាមរយៈផ្កាយរណបនៅឡើយ។

ខ្ញុំសូមសម្ដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនចំពោះ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើឱ្យប្រទេសជាតិមានសុខសន្តិភាព និងការឯកភាពជាតិទូទាំងប្រទេសតាមរយៈនយោបាយ «**ឈ្នះ ឈ្នះ**» ដែលបានផ្ដល់ឱកាសដល់ការងារប្រមូលទិន្នន័យប្រកបដោយជោគជ័យ។ ក្រៅពីជោគជ័យខាងលើនេះ ក៏នៅមានជោគជ័យធំៗចំនួន២ទៀតគឺ ទី១ គោលនយោបាយចាក់វ៉ាក់សាំងកូវីដ-១៩សម្រាប់ប្រជាជនកម្ពុជា ទូទៅ និងទី២ ជោគជ័យកម្រិតអន្តរជាតិនៃព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍លើកទី៣២ និងកីឡាជនមានពិការភាពអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣ ដែលព្រះរាជាណាចក្រកម្ពុជាបានធ្វើជាម្ចាស់ផ្ទះ។

ខ្ញុំសូមសម្ដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនចំពោះ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានដឹកនាំរាជរដ្ឋាភិបាលទទួលបានលទ្ធផលយ៉ាងត្រចះត្រចង់ក្នុងរយៈពេលនៃការដឹកនាំដែលមានរយៈពេលខ្លី ព្រមទាំងរក្សានូវស្នាដៃរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលជាស្ថាបនិកសន្តិភាព និងឯកភាពជាតិទូទាំងប្រទេសតាមរយៈនយោបាយ «**ឈ្នះ ឈ្នះ**» ដែលនឹងស័ក្តិសមជាមគ្គុទេសបន្តវេននៃព្រះរាជាណាចក្រកម្ពុជាទៅអនាគត ដោយឈរលើយុទ្ធសាស្ត្របញ្ចកោណជាត្រីវិស័យនៃការដឹកនាំប្រទេស និងមានចក្ខុវិស័យប្រកបដោយគតិបណ្ឌិត។

ខ្ញុំសូមគោរពថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន អតីតទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ** ដែលបានគាំទ្រ និងបានផ្តល់អនុសាសន៍ល្អៗតាំងពីចំណុចចាប់ផ្តើមនៃការកកើតគម្រោងអង្កេតភពផែនដីនៅឆ្នាំ២០១៩ រហូតមកដល់ឆ្នាំ២០២៣នេះ បានដំណើរការបានយ៉ាងល្អ និងទទួលជោគជ័យជាបន្តបន្ទាប់។

ខ្ញុំកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមដឹកនាំគម្រោងអង្កេតភពផែនដី ឯកឧត្តម លោកជំទាវ លោក លោកស្រីនិងមន្ត្រីពាក់ព័ន្ធទាំងអស់របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងមន្ត្រីរបស់មន្ទីរផែនការខេត្តកំពត និងខេត្តកែប ដែលបានចូលរួមក្នុងការប្រមូលទិន្នន័យតាមតំបន់គោលដៅនៅក្នុងខេត្តទាំង២ ខាងលើនេះ ប្រកបដោយជោគជ័យ។

ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា រាជរដ្ឋាភិបាលកម្ពុជានឹងទទួលបាននូវសារៈប្រយោជន៍ពីលទ្ធផលនៃការធ្វើអង្កេតនេះ តាមរយៈការប្រាស់ទិន្នន័យក្នុងអង្កេតភពផែនដីឆ្នាំ២០២៣នេះ ដើម្បីរៀបចំធ្វើផែនការ និងរៀបចំគោលនយោបាយទាក់ទងទៅនឹងការតាមដាន ត្រួតពិនិត្យលក្ខណៈប្រជាសាស្ត្រ ផ្នែកបរិស្ថាន ការពារគ្រោះមហន្តរាយ ការប្រែប្រួលអាកាសធាតុ និងមានវិធានការណ៍សមស្របទាក់ទងនឹងបញ្ហាដែលរកឃើញទាំងអស់នេះ បន្ថែមពីលើទិន្នន័យដែលបានមកពីប្រភពដទៃទៀតប្រកបដោយប្រសិទ្ធភាពខ្ពស់។ ចំពោះអ្នកប្រើប្រាស់ទិន្នន័យទាំងឡាយ ក៏ដូចជាអ្នកស្រាវជ្រាវ អ្នកវិភាគ និងអង្គការក្រៅរដ្ឋាភិបាលនានា ក៏អាចទទួលបាននូវផលប្រយោជន៍ពីលទ្ធផលការអង្កេតនេះផងដែរ នៅក្នុងការស្វែងយល់អំពីលក្ខណៈប្រជាសាស្ត្រ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុនៅក្នុងខេត្តគោលដៅទាំងពីរខាងលើ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ចន្ទ ២ កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២៤

រដ្ឋមន្ត្រី

ប៊ិន ត្រាំឈៃ

# អារម្ភកថា

របាយការណ៍លទ្ធផលនៃអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣នេះ បានផលិតដោយក្រុមការងារនៃក្រុមសង្កេតការណ៍ភពផែនដី ដែលស្ថិតនៅក្រោមវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។ ចាប់តាំងពីប្រទេសកម្ពុជាបានចូលជាសមាជិកទី១០៤ នៃក្រុមសង្កេតការណ៍ភពផែនដីនៅឆ្នាំ២០១៧មក គម្រោងអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជា បានអនុវត្តសកម្មភាពការងារចាប់តាំងពីឆ្នាំ២០១៩ រហូតមកដល់ឆ្នាំ២០២៣នេះ ក្រុមសង្កេតការណ៍ភពផែនដីនៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ បានផលិតចេញនូវរបាយការណ៍លទ្ធផលស្តីពីអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាបានចំនួន៥មកហើយ ដោយផ្អែកលើការចុះស្រង់ទិន្នន័យជាក់ស្តែងនៅតាមបណ្តាខេត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងទិន្នន័យដែលបានផលិតដោយក្រសួងស្ថាប័នពាក់ព័ន្ធមួយចំនួន។ ទិន្នន័យដែលបានចុះស្រង់នៅតាមបណ្តាខេត្តចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២១ មានខេត្តចំនួន៥ ដែលជាប់បឹងទន្លេសាប គឺខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង សៀមរាប និងខេត្តកំពង់ធំ។ នៅក្នុងឆ្នាំ២០២២កន្លងទៅ បានចុះស្រង់ទិន្នន័យនៅក្នុងខេត្តកោះកុង និងខេត្តព្រះសីហនុ និងនៅក្នុងឆ្នាំ២០២៣នេះ គឺបានចុះស្រង់ទិន្នន័យនៅក្នុងខេត្តកំពត និងខេត្តកែប នៅក្នុងការអនុវត្តគម្រោងអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣។ ថវិកាសម្រាប់អនុវត្តគម្រោងខាងលើនេះ គឺបានមកពីការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈថវិកាកម្មវិធីប្រចាំឆ្នាំរបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។

គោលបំណងចម្បងនៃអង្កេតនេះ គឺដើម្បីប្រមូលនូវសូចនាករសំខាន់ៗទាក់ទងនឹងប្រជាសាស្ត្របរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ តាមរយៈការសម្ភាសមេភូមិ និងមេគ្រួសារ នៅក្នុងភូមិមួយចំនួនដែលបានជ្រើសរើសធ្វើការសម្ភាស និងការប្រមូលទិន្នន័យពីបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធដែលបានផលិត ជំនួសឱ្យការទទួលបានទិន្នន័យពីផ្កាយរណប និងឧបករណ៍ថតរូបភាពផ្សេងៗដែលថតពីលើអាកាស ខណៈដែលបច្ចុប្បន្នការប្រមូលទិន្នន័យបែបនេះ នូវពុំទាន់មានលទ្ធភាពធ្វើទៅបាន។ លទ្ធផលអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣នេះ រួមមានរបាយការណ៍លទ្ធផលអង្កេតជាឯកសារសៀវភៅបោះពុម្ព និងឯកសារជាអេឡិចត្រូនិក ហើយក៏មានដាក់ចូលនៅក្នុងគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការផងដែរ។

ខ្ញុំសូមគោរពថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន អតីតទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ** ដែលបានផ្តល់អនុសាសន៍ល្អៗ និងជំរុញលើកទឹកចិត្តដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលបានចូលរួមនៅក្នុងការអនុវត្តគម្រោងរហូតទទួលបានជោគជ័យ។

ខ្ញុំសូមគោរពថ្លែងអំណរគុណជូនចំពោះ **លោកជំទាវ ហង់ លីណា** អតីតប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ និងបច្ចុប្បន្នជារដ្ឋលេខាធិការក្រសួងផែនការ ដែលបានយកចិត្តទុកដាក់ និងបានណែនាំដល់មន្ត្រីចុះស្រង់ទិន្នន័យ និងកែច្នៃទិន្នន័យឱ្យមានគុណភាពល្អ **ឯកឧត្តមបណ្ឌិត ម៉េង គីមហ៊ា** អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ និងជាប្រធានក្រុមការងារដឹកនាំគម្រោងអង្កេតភពផែនដី និងឯកឧត្តមប្រធានមន្ទីរផែនការខេត្តកំពត និងខេត្តកែប ដែលបានសហការល្អនៅក្នុងអំឡុងពេលចុះស្រង់ទិន្នន័យនៅក្នុងខេត្តទាំង២ខាងលើ។

តាងនាមឱ្យវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ខ្ញុំសូមបង្ហាញជូននូវរបាយការណ៍លទ្ធផលនៃអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ ដែលជាសមិទ្ធផលថ្មីមួយទៀតរបស់វិទ្យាស្ថានជាតិស្ថិតិ ជូនដល់ស្ថាប័នអន្តរជាតិ ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះតម្រូវការលទ្ធផលនៃទិន្នន័យជាឯកសារសៀវភៅបោះពុម្ព និងឯកសារជាអេឡិចត្រូនិក ដែលប្រមូលបានពីការធ្វើអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣នេះ ពីគ្រប់មជ្ឈដ្ឋាននៃអ្នកប្រើប្រាស់ទិន្នន័យទាំងឡាយ។

ថ្ងៃ ចន្ទ ២កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២៤

**អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ**

ទ្រី ឫទ្ធា

# ពាក្យបំព្រួញ និងអក្សរកាត់

| | |
|---|---|
| CDB | Commune Database<br>ទិន្នន័យមូលដ្ឋានឃុំ/ សង្កាត់ |
| COVID-19 | Coronavirus Disease 2019<br>ជំងឺឆ្លងវីរុសកូរ៉ូណា ២០១៩ |
| CSPro | Census and Survey Processing System<br>ប្រព័ន្ធកែច្នៃជំរឿន និងអង្កេត |
| GDP | Gross Domestic Products<br>ផលិតផលក្នុងស្រុកសរុប |
| GEO | Group on Earth Observations<br>ក្រុមសង្កេតការណ៍ភពផែនដី |
| NASA | National Aeronautics and Space Administration<br>រដ្ឋបាលអវកាស និងអវកាសនាវាវិជ្ជាជាតិ |
| SDGs | Sustainable Development Goals<br>គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| UN | United Nations<br>អង្គការសហប្រជាជាតិ |
| UNFCCC | United Nations Framework Convention on Climate Change<br>អនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| UNTAC | United Nations Transitional Authority of Cambodia<br>អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជា |
| WHO | World Health Organization<br>អង្គការសុខភាពពិភពលោក |
| WWI | World War I<br>សង្គ្រាមលោកលើកទី១ |
| WWII | World War II<br>សង្គ្រាមលោកលើកទី២ |

# មាតិកា

ទំព័រ

និមិត្តសញ្ញាក្រុមសង្កេតការណ៍ភពផែនដីកម្ពុជា....i
បុព្វកថា....ii
អារម្ភកថា....iv
**ជំពូក ១ សេចក្តីផ្តើម**....១
១.១ សេចក្តីផ្តើម....១
១.២ គោលបំណង....២
១.៣ វិធីសាស្ត្រប្រមូលទិន្នន័យ....២
១.៤ ការកែច្នៃទិន្នន័យ....៣
១.៥ សារៈប្រយោជន៍....៣
**ជំពូក ២ ស្ថានភាពទូទៅផ្អែកលើទិន្នន័យទី២ និងផ្កាយរណប**....៤
២.១ ស្ថានភាពទូទៅផ្អែកលើទិន្នន័យទី២....៤
២.១.១ ប្រជាសាស្ត្រ....៤
២.១.២ ទីប្រជុំជន គ្រួសារ អគារ និងលំនៅដ្ឋាន....៣១
២.១.៣ បរិស្ថាន ទឹកស្អាត និងបង្គន់អនាម័យ....៤០
២.១.៤ ស្ថានភាពគ្រោះមហន្តរាយ....៦២
២.១.៥ ការប្រែប្រួលអាកាសធាតុ....៩៣
២.២. ស្ថានភាពទូទៅផ្អែកលើទិន្នន័យពីផ្កាយរណប....១១១
២.២.១ ផ្ទៃដីគ្របដណ្តប់....១១១
២.២.២ ស្ថានភាពផ្ទៃដីគ្របដណ្តប់ពីឆ្នាំ ២០១៧ ដល់២០២២ សម្រាប់ប្រទេសកម្ពុជា....១១៩
២.២.៣ ស្ថានភាពផ្ទៃដីគ្របដណ្តប់ប្រទេសផ្សេងៗឆ្នាំ២០២២....១២០
**ជំពូក ៣ ការវិភាគលទ្ធផលផ្អែកលើទិន្នន័យទី១**....១២៤
៣.១ ព័ត៌មានទូទៅ....១២៤
៣.១.១ គ្រួសារ....១២៤
៣.១.២ ទំហំគ្រួសារ....១២៨
៣.១.៣ ចំណាកស្រុក....១៣០
៣.១.៤ ការចូលរួមកម្លាំងពលកម្ម....១៣៤

៣.២ បរិស្ថាន ........................................................................................ ១៣៨
៣.២.១ បង្គន់អនាម័យ................................................................................. ១៣៩
៣.២.២ សេវាប្រមូលសំរាម ទីតាំងទុកដាក់សំរាម និង ផលប៉ះពាល់ពីការចាក់សំរាម... ១៤០
៣.២.៣ ផលប៉ះពាល់ពីកាកសំណល់រោងសិប្បកម្ម ឬ រោងចក្រការបង្ហូរកាកសំណល់ចូលក្នុងទឹក និងការបាញ់ថ្នាំសម្លាប់សត្វល្អិត.................................. ១៤១
៣.៣ គ្រោះមហន្តរាយ ..........................................................................................១៤២
៣.៣.១ ការទទួលព័ត៌មានអំពីគ្រោះមហន្តរាយ ........................................... ១៤៣
៣.៣.២ ប្រភេទនៃគ្រោះមហន្តរាយ........................................................... ១៤៤
៣.៣.៣ ការប៉ាន់ស្មានការខូចខាតដោយសារគ្រោះមហន្តរាយ......................... ១៤៦
៣.៤ ការប្រែប្រួលអាកាសធាតុ ..........................................................................១៤៧
៣.៤.១ ស្ថានភាពទឹកភ្លៀង..........................................................................១៤៧
៣.៤.២ ស្ថានភាពសីតុណ្ហភាព....................................................................១៤៧
**ជំពូក ៤ របកគំហើញ និង សន្និដ្ឋាន**.................................................................១៥១
៤.១ របកគំហើញ ................................................................................................ ១៥១
៤.១.១ របកគំហើញផ្អែកលើទិន្នន័យទី១ ................................................... ១៥១
៤.១.២ របកគំហើញផ្អែកលើទិន្នន័យទី២.....................................................១៥២
៤.១.៣ របកគំហើញផ្អែកលើទិន្នន័យតាមផ្កាយរណប..................................... ១៥៦
៤.២ សន្និដ្ឋាន ..................................................................................................១៥៧
**ឯកសារយោង** ..................................................................................................១៥៨
**ឧបសម្ព័ន្ធ** ........................................................................................................១៦២

# បញ្ជីតារាង


| តារាងលេខ | ចំណងជើងតារាង | ទំព័រ |
|---|---|---|
| តារាង១. | បញ្ជីភូមិគោលដៅសម្រាប់ធ្វើការសម្ភាសន៍ស្រង់ទិន្នន័យនៅក្នុងខេត្តខេត្តកំពត និងខេត្តកែប | ៣ |
| តារាង២. | ចំនួនប្រជាជនពិភពលោក ២០២២ ២០៣០ និង២០៥០ | ៥ |
| តារាង៣. | ចំនួនប្រជាជននិងចំនួនគ្រួសារសរុប ពីឆ្នាំ ១៩៩៨ ដល់ ២០៣៥ គិតជានាក់ | ១១ |
| តារាង៤. | ចំនួនអ្នកមានការងារធ្វើបណ្ដាខេត្តស្ថិតក្នុងតំបន់ឆ្នេរសមុទ្រ | ២៥ |
| តារាង៥. | ចំនួនអ្នកគ្មានការងារធ្វើបណ្ដាខេត្តស្ថិតក្នុងតំបន់ឆ្នេរសមុទ្រ | ២៦ |
| តារាង៦. | ចំនួនជនសកម្មសេដ្ឋកិច្ច និងអសកម្មសេដ្ឋកិច្ចបណ្ដាខេត្តស្ថិតក្នុងតំបន់ឆ្នេរសមុទ្រ | ២៨ |
| តារាង៧. | ចំនួនអ្នកចូលរួមកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ច | ៣០ |
| តារាង៨. | ចំនួនគ្រួសារ និង អគារ ខេត្តកំពត កែប និង កម្ពុជា | ៣៦ |
| តារាង៩. | ចំនួនលំនៅដ្ឋានតាមប្រភេទ | ៣៧ |
| តារាង១០. | ចំនួនគ្រួសារដែលពាក់ព័ន្ធនឹងបរិស្ថានឆ្នាំ២០២១ ខេត្តកំពត និងខេត្តកែប | ៤៣ |
| តារាង១១. | បរិមាណការប្រមូលសំណល់រឹងទីក្រុង ការចោលសំរាមខុសច្បាប់ និងការកែច្នៃឡើងវិញ ឆ្នាំ ២០១៥ | ៤៨ |
| តារាង១២. | ចំនួនផ្ទៃដីតំបន់ការពារធម្មជាតិ | ៥២ |
| តារាង១៣. | ចំនួនដែលបានកើតឡើង និងការបាត់បង់នៃគ្រោះមហន្តរាយធម្មជាតិឆ្នាំ ២០២១ | ៦៣ |
| តារាង១៤. | ចំនួនការខូចខាតដោយខ្យល់កន្ត្រាក់ គិតឆមាសទី១ ឆ្នាំ២០២៣ | ៦៧ |
| តារាង១៥. | ចំនួនគ្រួសារ និងជនរងគ្រោះដោយខ្យល់ព្យុះ | ៦៨ |
| តារាង១៦. | ចំនួនការខូចខាតដោយរន្ទះបាញ់ គិតត្រឹម ៦ខែ ឆ្នាំ២០២៣ | ៦៨ |
| តារាង១៧. | ចំនួនផលប៉ះពាល់ដោយគ្រោះទឹកជំនន់ គិតត្រឹម ៦ខែ ឆ្នាំ២០២៣ | ៧០ |
| តារាង១៨. | ចំនួនការខូចខាតដោយសារទឹកជំនន់ ឆ្នាំ២០២១ | ៧១ |
| តារាង១៩. | ការខូចខាតដោយគ្រោះអគ្គីភ័យគិតត្រឹម ៦ខែ ឆ្នាំ២០២៣ | ៧៤ |
| តារាង២០. | ចំនួនប្រជាជន និង ចំនួនអ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១ | ៨២ |
| តារាង២១. | ចំនួនអ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី២ | ៨៨ |
| តារាង២២. | កម្ពស់ទឹកអប្បបរមាប្រចាំឆ្នាំតាមស្ថានីយ៍ពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០២២ គិតជាម៉ែត្រ | ១០៦ |

| តារាងលេខ | ចំណងជើងតារាង | ទំព័រ |
|---|---|---|
| តារាង២៣. | កម្ពស់ទឹកអតិបរមាប្រចាំឆ្នាំតាមស្ថានីយ៍ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២២ គិតជាម៉ែត្រ | ១០៧ |
| តារាង២៤. | ការខាតបង់ផ្នែកសេដ្ឋកិច្ចបែងចែកតាមវិស័យ ឆ្នាំ២០០៩ | ១០៩ |
| តារាង២៥. | បញ្ជីភូមិ និងចំនួនគ្រួសារដែលត្រូវសម្ភាសន៍ | ១២៤ |
| តារាង២៦. | ចំនួនមេគ្រួសារ បែងចែកតាមក្រុមអាយុ | ១២៧ |
| តារាង២៧. | ចំនួនសមាជិកអចិន្ត្រៃយ៍ និង សមាជិកចំណាកស្រុក | ១៣០ |
| តារាង២៨. | ចំនួនសមាជិកធ្វើការតាមវិស័យសេដ្ឋកិច្ច | ១៣៥ |
| តារាង២៩. | ចំនួនសមាជិកគ្រួសារចូលរួមកម្លាំងពលកម្មតាមផ្នែកការងារ | ១៣៧ |
| តារាង៣០. | ចំនួនគ្រួសារទទួលរងគ្រោះតាមប្រភេទនៃគ្រោះមហន្តរាយ | ១៤៤ |
| តារាង៣១. | ចំនួនអ្នកឆ្លងជំងឺកូវីដ១៩ | ១៤៥ |
| តារាង៣២. | ការប៉ាន់ស្មានការខូចខាតដោយសារគ្រោះមហន្តរាយឆ្នាំ២០២៣ | ១៤៦ |
| តារាង៣៣. | ចំនួនមេគ្រួសារដែលបានផ្តល់ចម្លើយទាក់ទងអាកាសធាតុ | ១៤៨ |
| តារាង៣៤. | Z score table | ១៥០ |

# បញ្ជីក្រាហ្វិក

| ក្រាហ្វិក លេខ | ចំណងជើងក្រាហ្វិក | ទំព័រ |
|---|---|---|


| | | |
|---|---|---|
| ក្រាហ្វិក១. | និន្នាការចំនួនប្រជាជនពិភពលោកពីឆ្នាំ១៩៦០ ដល់ ឆ្នាំ២០៣៥ | ៤ |
| ក្រាហ្វិក២. | និន្នាការចំនួនប្រជាជនសរុបទូទាំងប្រទេសកម្ពុជា | ៨ |
| ក្រាហ្វិក៣. | និន្នាការចំនួនប្រជាជនតាមតំបន់ក្នុងប្រទេសកម្ពុជា | ៩ |
| ក្រាហ្វិក៤. | និន្នាការចំនួនប្រជាជនសម្រាប់ខេត្តកំពត និងខេត្តកែប | ១០ |
| ក្រាហ្វិក៥. | ចំនួនជនអន្តោប្រវេសន៍អន្តរជាតិតាមតំបន់សំខាន់ៗពីឆ្នាំ ២០០៥ ដល់ ២០២០(លាននាក់) | ១៦ |
| ក្រាហ្វិក៦. | ចំនួនជនអន្តោប្រវេសន៍អន្តរជាតិដែលបានផ្ញើប្រាក់មកក្រុមគ្រួសារពីឆ្នាំ ២០១៩ ដល់ ២០២០(សកល និងប្រទេសមានចំណូលទាប និងមធ្យម) | ១៦ |
| ក្រាហ្វិក៧. | ការផ្លាស់ប្តូរទីលំនៅពីមុនទូទាំងប្រទេស | ១៨ |
| ក្រាហ្វិក៨. | ការផ្លាស់ប្តូរទីលំនៅតាមតំបន់ទូទាំងប្រទេស | ១៩ |
| ក្រាហ្វិក៩. | ការផ្លាស់ប្តូរទីលំនៅតាមតំបន់ឆ្នាំ ២០១៩ | ២០ |
| ក្រាហ្វិក១០. | ការផ្លាស់ប្តូរទីលំនៅខេត្តកំពត និងខេត្តកែបឆ្នាំ ២០១៩ | ២១ |
| ក្រាហ្វិក១១. | មូលហេតុនៃការផ្លាស់ប្តូរទីលំនៅសម្រាប់ទូទាំងប្រទេស | ២២ |
| ក្រាហ្វិក១២. | មូលហេតុនៃការផ្លាស់ប្តូរទីលំនៅខេត្តកំពត និងខេត្តកែប ឆ្នាំ ២០១៩ | ២៣ |
| ក្រាហ្វិក១៣. | ភាគរយអ្នកមានការងារធ្វើតាមបណ្តាខេត្តនៅក្នុងតំបន់ឆ្នេរសមុទ្រ | ២៥ |
| ក្រាហ្វិក១៤. | ភាគរយអ្នកគ្មានការងារធ្វើតាមបណ្តាខេត្តនៅក្នុងតំបន់ឆ្នេរ | ២៦ |
| ក្រាហ្វិក១៥. | ភាគរយជនសកម្មសេដ្ឋកិច្ច និងអសកម្មសេដ្ឋកិច្ចនៅទូទាំងប្រទេស | ២៧ |
| ក្រាហ្វិក១៦. | ភាគរយជនសកម្មសេដ្ឋកិច្ច និងអសកម្មសេដ្ឋកិច្ចខេត្តកែប | ២៨ |
| ក្រាហ្វិក១៧. | ភាគរយជនសកម្មសេដ្ឋកិច្ច និងអសកម្មសេដ្ឋកិច្ចខេត្តកំពត | ២៩ |
| ក្រាហ្វិក១៨. | ភាគរយការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យសេដ្ឋកិច្ច | ៣០ |
| ក្រាហ្វិក១៩. | និន្នាការចំនួនប្រជាជនសរុប និងចំនួនប្រជាជនរស់នៅទីប្រជុំជនទូទាំងពិភពលោក | ៣២ |
| ក្រាហ្វិក២០. | ភាគរយចំនួនប្រជាជនរស់នៅទីប្រជុំជននៅលើពិភពលោក និងចំនួនប្រជាជនរស់នៅទីប្រជុំជនកម្ពុជា | ៣៤ |
| ក្រាហ្វិក២១. | ភាគរយចំនួនប្រជាជនរស់នៅតំបន់ទីប្រជុំជន | ៣៥ |
| ក្រាហ្វិក២២. | ចំនួនគ្រួសារ និងអគារ | ៣៦ |

| ក្រាហ្វិកលេខ | ចំណងជើងក្រាហ្វិក | ទំព័រ |
|---|---|---|
| ក្រាហ្វិក២៣. | ចំនួនលំនៅដ្ឋាន និងចំនួនគ្រួសារសរុប ខេត្តកំពត កែប និងកម្ពុជា | ៣៨ |
| ក្រាហ្វិក២៤. | ភាគរយតាមប្រភេទលំនៅដ្ឋានខេត្តកំពត កែប និងកម្ពុជា | ៣៩ |
| ក្រាហ្វិក២៥. | ភាគរយគ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះឆ្នាំ២០២១ | ៤៣ |
| ក្រាហ្វិក២៦. | សមត្ថភាពប្រព្រឹត្តិកម្មសំណល់រាវ-ទឹកកខ្វក់ | ៤៥ |
| ក្រាហ្វិក២៧. | បរិមាណសំរាម សំណល់រឹងទីប្រជុំជន ដែលបានចាក់នៅទីលានប្រចាំឆ្នាំ នៅទូទាំងប្រទេស | ៤៦ |
| ក្រាហ្វិក២៨. | បរិមាណសំណល់រឹងនៅរាជធានីភ្នំពេញ | ៤៦ |
| ក្រាហ្វិក២៩. | ភាគរយបរិមាណសំណល់រឹងនៅរាជធានីភ្នំពេញឆ្នាំ២០១៥ | ៤៧ |
| ក្រាហ្វិក៣០. | បរិមាណសំណល់រឹងទីក្រុងឆ្នាំ២០១៥ | ៤៨ |
| ក្រាហ្វិក៣១. | ភាគរយការផ្តល់សេវា ដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជននៅក្រុង ស្រុក ទាំង១៨៥ទូទាំងប្រទេស ឆ្នាំ២០១៧ | ៤៩ |
| ក្រាហ្វិក៣២. | តំបន់ការពារ | ៥០ |
| ក្រាហ្វិក៣៣. | ភាគរយតាមប្រភេទតំបន់ការពារធម្មជាតិ | ៥៣ |
| ក្រាហ្វិក៣៤. | ប្រភេទព្រៃឈើ | ៥៤ |
| ក្រាហ្វិក៣៥. | ការប្រែប្រួលគម្របព្រៃឈើ | ៥៤ |
| ក្រាហ្វិក៣៦. | តំបន់វាលភក់ | ៥៥ |
| ក្រាហ្វិក៣៧. | ភាគរយគ្រួសារ តាមទីតាំងប្រភពទឹកទទួលទាន ឆ្នាំ២០១៩ | ៥៨ |
| ក្រាហ្វិក៣៨. | ភាគរយគ្រួសារមានទឹកស្អាតប្រើប្រាស់ | ៥៩ |
| ក្រាហ្វិក៣៩. | បរិមាណទឹកកខ្វក់បញ្ចេញពីរាជធានីភ្នំពេញ ឆ្នាំ២០០៦ ដល់ ២០១៧ | ៦០ |
| ក្រាហ្វិក៤០. | ភាគរយចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | ៦១ |
| ក្រាហ្វិក៤១. | ចំនួនដែលបានកើតឡើង និងការបាត់បង់នៃគ្រោះមហន្តរាយធម្មជាតិ ឆ្នាំ២០២១ | ៦៤ |
| ក្រាហ្វិក៤២. | ចំនួនជនរងគ្រោះដោយអគ្គីភ័យ ខ្យល់កន្ត្រាក់ និង រន្ទះបាញ់ | ៦៦ |
| ក្រាហ្វិក៤៣. | ចំនួនការខូចខាតដោយខ្យល់កន្ត្រាក់ គិតត្រឹមឆមាសទី១ ឆ្នាំ២០២៣ | ៦៧ |
| ក្រាហ្វិក៤៤. | ចំនួនការខូចខាតដោយរន្ទះបាញ់ គិតត្រឹម ៦ខែ ឆ្នាំ២០២២ និង ឆ្នាំ២០២៣ | ៦៩ |

| ក្រាហ្វិកលេខ | ចំណងជើងក្រាហ្វិក | ទំព័រ |
|---|---|---|
| ក្រាហ្វិក៤៥. | ចំនួនការខូចខាតដំណាំកសិកម្មដោយសារទឹកជំនន់ គិតត្រឹម៦ខែ ឆ្នាំ ២០២២ និងឆ្នាំ២០២៣ | ៧១ |
| ក្រាហ្វិក៤៦. | ចំនួនគ្រួសារ និងផ្ទៃដីដែលរងផលប៉ះពាល់ដោយសារគ្រោះរាំងស្ងួតទូទាំងប្រទេស ឆ្នាំ២០២១ | ៧៣ |
| ក្រាហ្វិក៤៧. | ចំនួនអគ្គីភ័យដែលកើតឡើង (ឆេះផ្ទះ ឆេះផ្សារ) ឆ្នាំ២០២១ | ៧៥ |
| ក្រាហ្វិក៤៨. | ស្ថានភាពជំងឺកូវីដ១៩ទូទាំងពិភពលោកគិតត្រឹមថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២៣ | ៧៦ |
| ក្រាហ្វិក៤៩. | ស្ថានភាពនៃចាក់វ៉ាក់សាំងជំងឺកូវីដ១៩ទូទាំងពិភពលោក | ៧៧ |
| ក្រាហ្វិក៥០. | ស្ថានភាពជំងឺកូវីដ១៩នៅកម្ពុជា | ៧៩ |
| ក្រាហ្វិក៥១. | ស្ថានភាពចាក់វ៉ាក់សាំងជំងឺកូវីដ១៩នៅកម្ពុជា និងពិភពលោក | ៨០ |
| ក្រាហ្វិក៥២. | ចំនួនអ្នកស្លាប់ និង រងរបួសក្នុងសង្គ្រាមលោកលើកទី១ និងលើកទី២ | ៨១ |
| ក្រាហ្វិក៥៣. | ចំនួនប្រជាជនសរុបក្នុងអំឡុងពេល WWI | ៨៤ |
| ក្រាហ្វិក៥៤. | ចំនួនអ្នកស្លាប់ និងទាហានរងរបួសសរុបក្នុងអំឡុងពេល WWI | ៨៥ |
| ក្រាហ្វិក៥៥. | ភាគរយចំនួនអ្នកស្លាប់តាមចំណាត់ថ្នាក់ក្នុង WWI (1914-1921) | ៨៦ |
| ក្រាហ្វិក៥៦. | ភាគរយចំនួនទាហានសម្រាប់ក្រុម Entente Powers ក្នុង WWI | ៨៦ |
| ក្រាហ្វិក៥៧. | ភាគរយចំនួនទាហានសម្រាប់ក្រុម Central Powers ក្នុង WWI | ៨៧ |
| ក្រាហ្វិក៥៨. | ចំនួនអ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី២ | ៨៩ |
| ក្រាហ្វិក៥៩. | ចំនួនគ្រាប់មីន និងអាវុធជាតិផ្ទុះដែលបានកម្ទេច (១៩៩២២០២៣) | ៩០ |
| ក្រាហ្វិក៦០. | ចំនួនជនរងគ្រោះដោយគ្រាប់មីន និង ដោយសារគ្រាប់ | ៩១ |
| ក្រាហ្វិក៦១. | ប្រភេទជនរងគ្រោះដោយគ្រាប់មីន និង ដោយសារគ្រាប់ | ៩១ |
| ក្រាហ្វិក៦២. | ចំនួនជនរងគ្រោះដោយគ្រាប់មីន និង ដោយសារគ្រាប់ពីឆ្នាំ១៩៩២ - ២០២៣ តាមរាជធានី ខេត្ត | ៩២ |
| ក្រាហ្វិក៦៣. | ការយល់ដឹងអំពីអត្ថន័យការប្រែប្រួលអាកាសធាតុ និង អាកាសធាតុសកល នៅកម្ពុជា | ៩៥ |
| ក្រាហ្វិក៦៤. | ការយល់ដឹងអំពីស្ថានភាពអាកាសធាតុតាមប្រភេទ និងតាមតំបន់នៅកម្ពុជា | ៩៦ |
| ក្រាហ្វិក៦៥. | កត្តាចម្បងដែលនាំឲ្យមានការប្រែប្រួលអាកាសធាតុនៅកម្ពុជា | ៩៧ |

| ក្រាហ្វិក លេខ | ចំណងជើងក្រាហ្វិក | ទំព័រ |
|---|---|---|
| ក្រាហ្វិក៦៦. | ការបំភាយឧស្ម័នផ្ទះកញ្ចក់តាមវិស័យ | ៩៨ |
| ក្រាហ្វិក៦៧. | កម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំ តាមស្ថានីយគិតជាមីលីម៉ែត្រ | ៩៩ |
| ក្រាហ្វិក៦៨. | ចំនួនថ្ងៃមានភ្លៀងក្នុងឆ្នាំគិតជាមធ្យមតាមស្ថានីយ | ១០០ |
| ក្រាហ្វិក៦៩. | សីតុណ្ហភាពអប្បបរមា | ១០១ |
| ក្រាហ្វិក៧០. | សីតុណ្ហភាព អតិបរមា | ១០២ |
| ក្រាហ្វិក៧១. | ស្ថានភាពកម្ពស់ទឹកនៅទន្លេមេគង្គពីឆ្នាំ ២០១១ដល់២០២២ | ១០៣ |
| ក្រាហ្វិក៧២. | ស្ថានភាពកម្ពស់ទឹកអតិបរមានៅទន្លេមេគង្គពីឆ្នាំ ១៩៩២ ដល់ ២០២២ | ១០៤ |
| ក្រាហ្វិក៧៣. | ស្ថានភាពកម្ពស់ទឹកអប្បបរមានៅទន្លេមេគង្គពីឆ្នាំ២០១១ ដល់ ឆ្នាំ ២០២២ | ១០៥ |
| ក្រាហ្វិក៧៤. | កម្ពស់ទឹកអប្បបរមាប្រចាំឆ្នាំតាមស្ថានីយ៍ពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០២២ | ១០៦ |
| ក្រាហ្វិក៧៥. | កម្ពស់ទឹកអតិបរមាប្រចាំឆ្នាំតាមស្ថានីយ៍ពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០២២ | ១០៧ |
| ក្រាហ្វិក៧៦. | ភាគរយនៃការខាតបង់ផ្នែកសេដ្ឋកិច្ចបែងចែកតាមវិស័យ ឆ្នាំ២០០៩ | ១១០ |
| ក្រាហ្វិក៧៧. | ភាគរយស្ថានភាពនៃផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាឆ្នាំ២០១៧ ដល់ ឆ្នាំ ២០២២ | ១១៩ |
| ក្រាហ្វិក៧៨. | ប្រៀបធៀបភាគរយស្ថានភាពនៃផ្ទៃដីគ្របដណ្តប់ជាមួយប្រទេសជិតខាង ឆ្នាំ២០២២ | ១២៣ |
| ក្រាហ្វិក៧៩. | ភាគរយចំនួនមេភូមិដែលបានសម្ភាសន៍ | ១២៥ |
| ក្រាហ្វិក៨០. | ភាគរយមេគ្រួសារដែលបានសម្ភាសន៍ | ១២៦ |
| ក្រាហ្វិក៨១. | បង្ហាញអំពីភាគរយមេគ្រួសារតាមក្រុមអាយុនិងភេទ | ១២៧ |
| ក្រាហ្វិក៨២. | បង្ហាញអំពីចំនួនសមាជិកគ្រួសារគិតជាមធ្យមឆ្នាំ១៩៩៨, ២០០៨ និង ឆ្នាំ២០១៩ | ១២៨ |
| ក្រាហ្វិក៨៣. | បង្ហាញអំពីចំនួនសមាជិកគ្រួសារគិតជាមធ្យមឆ្នាំ២០២៣ (ការសម្ភាសន៍ជាក់ស្តែង) | ១២៩ |
| ក្រាហ្វិក៨៤. | ភាគរយសមាជិកគ្រួសារធ្វើចំណាកស្រុកក្នុងនិងក្រៅប្រទេសបែងចែកតាមភេទ | ១៣១ |
| ក្រាហ្វិក៨៥. | ចំនួនសមាជិកគ្រួសារបានធ្វើចំណាកស្រុកទៅតាមរាជធានីខេត្ត និង តាមភេទ | ១៣២ |

| ក្រាហ្វិកលេខ | ចំណងជើងក្រាហ្វិក | ទំព័រ |
|---|---|---|
| ក្រាហ្វិក៨៦. | ភាគរយសមាជិកចំណាកស្រុកក្នុងប្រទេសតាមមូលហេតុ | ១៣៣ |
| ក្រាហ្វិក៨៧. | ចំនួនសមាជិកចំណាកស្រុកក្រៅប្រទេសតាមប្រទេស | ១៣៤ |
| ក្រាហ្វិក៨៨. | មូលហេតុនៃការធ្វើចំណាកស្រុកទៅក្រៅប្រទេស | ១៣៤ |
| ក្រាហ្វិក៨៩. | ភាគរយការចូលរួមកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចទាំងពីរភេទ | ១៣៥ |
| ក្រាហ្វិក៩០. | ភាគរយការចូលរួមកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចទាំងភេទប្រុស | ១៣៦ |
| ក្រាហ្វិក៩១. | ភាគរយការចូលរួមកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចទាំងភេទស្រី | ១៣៦ |
| ក្រាហ្វិក៩២. | ភាគរយសមាជិកគ្រួសារធ្វើការតាមផ្នែកនៃការងារ | ១៣៧ |
| ក្រាហ្វិក៩៣. | បង្ហាញអំពីភាគរយនៃគ្រួសារយល់ថាមានផលប៉ះពាល់បរិស្ថាន | ១៣៨ |
| ក្រាហ្វិក៩៤. | ភាគរយគ្រួសារដែលប្រើប្រាស់បង្គន់អនាម័យ | ១៣៩ |
| ក្រាហ្វិក៩៥. | ភាគរយគ្រួសារដែលទទួលសេវាសំរាម | ១៤០ |
| ក្រាហ្វិក៩៦. | ភាគរយគ្រួសារដែលមានទីតាំងទុកដាក់សំរាម និងផលប៉ះពាល់ពីការចាក់សំរាម | ១៤១ |
| ក្រាហ្វិក៩៧. | ភាគរយគ្រួសសារទទួលរងផលប៉ះពាល់ពី ការបង្ហូរកាកសំណល់ចូលក្នុងទឹក ការកាប់បំផ្លាញព្រៃឈើ និងការកាប់បំផ្លាញព្រៃលិចទឹក | ១៤២ |
| ក្រាហ្វិក៩៨. | ភាគរយគ្រួសារដែលទទួលគ្រោះមហន្តរាយនៅឆ្នាំ២០២៣ ក្នុងភូមិគោលដៅ | ១៤៣ |
| ក្រាហ្វិក៩៩. | ប្រភពព័ត៌មាននៃគ្រោះមហន្តរាយ | ១៤៤ |
| ក្រាហ្វិក១០០. | ភាគរយគ្រួសារទទួលរងគ្រោះមហន្តរាយតាមប្រភេទនៃគ្រោះមហន្តរាយឆ្នាំ២០២៣ | ១៤៥ |
| ក្រាហ្វិក១០១. | ភាគរយនៃការខូចខាតដោយសារគ្រោះមហន្តរាយឆ្នាំ២០២៣ | ១៤៦ |
| ក្រាហ្វិក១០២. | ស្ថានភាពទឹកភ្លៀង | ១៤៧ |
| ក្រាហ្វិក១០៣. | ស្ថានភាពសីតុណ្ហភាព | ១៤៨ |
| ក្រាហ្វិក១០៤. | លទ្ធផលនៃការគណនា p-value | ១៤៩ |

# បញ្ជីផែនទី


| ផែនទីលេខ | ចំណងជើងផែនទី | ទំព័រ |
|---|---|---|
| ផែនទី១. | បង្ហាញអំពីផែនទីប្រទេសកម្ពុជា និងរូបភាពប្រជាជនដែលជាយុវវ័យនៅទូទាំងប្រទេស | ៧ |
| ផែនទី២. | ដង់ស៊ីតេប្រជាជនតាមរាជធានីខេត្ត ឆ្នាំ១៩៩៨ | ១២ |
| ផែនទី៣. | ដង់ស៊ីតេប្រជាជនតាមរាជធានីខេត្ត ឆ្នាំ២០០៨ | ១៣ |
| ផែនទី៤. | ដង់ស៊ីតេប្រជាជនតាមរាជធានីខេត្ត ឆ្នាំ២០១៩ | ១៣ |
| ផែនទី៥. | ដង់ស៊ីតេប្រជាជនតាមក្រុង ស្រុក ខេត្តកំពត ឆ្នាំ២០១៩ | ១៤ |
| ផែនទី៦. | ដង់ស៊ីតេប្រជាជនតាមក្រុង ស្រុក ខេត្តកែប ឆ្នាំ២០១៩ | ១៤ |
| ផែនទី៧. | ផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជា និងប្រទេសផ្សេងៗទៀតឆ្នាំ២០២២ | ១១១ |
| ផែនទី៨. | ផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាឆ្នាំ២០២២ | ១១២ |
| ផែនទី៩. | ផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាឆ្នាំ ២០១៧ | ១១៣ |
| ផែនទី១០. | ផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាឆ្នាំ ២០១៨ | ១១៤ |
| ផែនទី១១. | ផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាឆ្នាំ ២០១៩ | ១១៥ |
| ផែនទី១២. | ផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាឆ្នាំ ២០២០ | ១១៦ |
| ផែនទី១៣. | ផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាឆ្នាំ ២០២១ | ១១៧ |
| ផែនទី១៤. | ផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជា និងផ្ទៃដីតំបន់ភាគខាងត្បូងប្រទេសវៀតណាមឆ្នាំ២០២២ | ១១៨ |
| ផែនទី១៥. | ផ្ទៃដីគ្របដណ្តប់ប្រទេសវៀតណាមឆ្នាំ២០២២ | ១២០ |
| ផែនទី១៦. | ផ្ទៃដីគ្របដណ្តប់ប្រទេសឡាវឆ្នាំ២០២២ | ១២១ |

# បញ្ជីឧបសម្ព័ន្ធ


| ឧបសម្ព័ន្ធ | ចំណងជើងឧបសម្ព័ន្ធ | ទំព័រ |
| --- | --- | --- |
| ឧបសម្ព័ន្ធ១ | បញ្ជីសំណួរការចុះស្រង់ទិន្នន័យនៅក្នុងខេត្តកែប និងខេត្តកំពតសម្រាប់ អនុវត្តគម្រោងការងារក្រុមសង្កេតការណ៍ភពផែនដី នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២៣ (សម្រាប់មេភូមិ) | ១៦២ |
| ឧបសម្ព័ន្ធ២ | បញ្ជីសំណួរការចុះស្រង់ទិន្នន័យនៅក្នុងខេត្តកែប និងខេត្តកំពតសម្រាប់ អនុវត្តគម្រោងការងារក្រុមសង្កេតការណ៍ភពផែនដី នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២៣ (សម្រាប់មេគ្រួសារ) | ១៦៦ |
| ឧបសម្ព័ន្ធ៣ | តារាង Standard Normal Curve Areas | ១៧៣ |

# ជំពូក ១
# សេចក្តីផ្តើម

## ១.១សេចក្តីផ្តើម

ប្រទេសកម្ពុជា គឺត្រូវបាននាយកលេខាធិការនៃលេខាធិការដ្ឋានក្រុមសង្កេតការណ៍ភពផែនដី ប្រកាសជាផ្លូវការចូលជាសមាជិកទី១០៤ នៃក្រុមសង្កេតការណ៍ភពផែនដីនៅក្នុងអំឡុងពេលកិច្ចប្រជុំពិភាក្សាលើកទី១៤ ដែលបានប្រារព្ធធ្វើពីថ្ងៃទី ២៥ ដល់ ២៦ ខែ តុលា ឆ្នាំ២០១៧ នៅទីក្រុងវ៉ាស៊ីនតោនសហរដ្ឋអាមេរិក ដែលមានវត្តមាន **ឯកឧត្តម ជុំ ប៊ុនរ៉ុង** ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនសហរដ្ឋអាមេរិកតំណាងឱ្យប្រទេសកម្ពុជា ព្រមទាំងមានការចូលរួមពីលេខាទី១របស់ស្ថានទូត និងមន្ត្រីជាន់ខ្ពស់របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ តាមរយៈសំណើរបស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**ចុះថ្ងៃទី ២៣ ខែមករា ឆ្នាំ ២០១៧ ទៅនាយកលេខាធិការនៃលេខាធិការដ្ឋានក្រុមសង្កេតការណ៍ភពផែនដី (GEO) ដែលមានទីស្នាក់ការនៅទីក្រុងហ្សឺណែវប្រទេសស្វីស។ បន្ទាប់ពីបានចូលជាសមាជិកក្រុមសង្កេតការណ៍ភពផែនដីជាផ្លូវការរួចមក អង្គភាពក្រុមសង្កេតការណ៍ភពផែនដីស្ថិតក្រោមវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការត្រូវបានបង្កើតឡើង ដើម្បីងាយស្រួលធ្វើកិច្ចការងារផ្សេងៗជាមួយអគ្គលេខាធិការដ្ឋានក្រុមសង្កេតភពផែនដី ដែលមានទីស្នាក់ការកណ្តាលនៅទីក្រុងហ្សឺណែវប្រទេសស្វីស។ ការងារសំខាន់របស់ប្រទេសជាសមាជិកក្រុមសង្កេតការភពផែនដី គឺសិក្សាស្រាវជ្រាវប្រមូលទិន្នន័យ និងវិភាគទិន្នន័យដែលប្រមូលដោយផ្ទាល់តាមរយៈការសម្ភាសន៍នៅតាមតំបន់គោលដៅដែលត្រូវបានសិក្សាស្រាវជ្រាវ និងបានតាមរយៈផ្កាយរណប ឬ ឧបករណ៍ផ្សេងៗ ដែលថតរូបភាពពីលើអាកាស សម្រាប់ធ្វើការតាមដានត្រួតពិនិត្យលើផលប៉ះពាល់បរិស្ថាន គ្រោះមហន្តរាយ ការប្រែប្រួលអាកាសធាតុ និងតាមដានទូវការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជាផងដែរ។ នៅពេលបច្ចុប្បន្ននេះ ចំពោះប្រទេសកម្ពុជាយើងពុំទាន់មានផ្កាយរណប ឬ ឧបករណ៍ថតពីលើអាកាសនោះទេ ឬ ទទួលបានការចែករំលែកទិន្នន័យពីផ្កាយរណបពីបណ្តាប្រទេសផ្សេងទៀតដែលមានផ្កាយរណបនោះឡើយ។ ហេតុដូច្នេះជំនួសការប្រមូលទិន្នន័យត្រូវបានធ្វើតាមរយៈការសម្ភាសន៍មេភូមិ និង មេគ្រួសារដែលរស់នៅក្នុងតំបន់គោលដៅដែលត្រូវសិក្សានោះវិញ។ សម្រាប់ការអនុវត្តការងារជំហានទី១ នៅឆ្នាំ២០១៩ អង្គភាពក្រុមសង្កេតការណ៍ភពផែនដី បានអនុវត្តគម្រោងសកម្មភាពការងារដែលបានផ្តោតទៅលើខេត្ត៥នៅជាប់បឹងទន្លេសាបរួមមាន ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង សៀមរាប និងខេត្តកំពង់ធំ ដោយប្រើប្រាស់ថវិកាជរដ្ឋាភិបាលកម្ពុជាតាមរយៈថវិកាកម្មវិធីរបស់

ក្រសួងផែនការដែលមានចំនួនកំណត់។ នៅក្នុងការអនុវត្តការងារជំហានទី២ ឆ្នាំ ២០២០ គឺបានចុះស្រង់ទិន្នន័យអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជា នៅក្នុងតំបន់ខ្ពង់រាបនៅក្នុងខេត្ត៣ រួមមានខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង ដែលគម្រោងត្រូវអនុវត្តចំនួន៥ខេត្តដូចឆ្នាំ២០១៩ ដែរ តែដោយសារបញ្ហាជំងឺឆ្លងកូវីដ ១៩ ត្រូវបានរាជរដ្ឋាភិបាលឲ្យកាត់សកម្មភាព ៥០ភាគរយ។នៅក្នុងឆ្នាំ ២០២១ នេះ រាជរដ្ឋាភិបាលបានកាត់ថវិកាគ្រប់គម្រោងទាំងអស់ ៣៧,៥% លើគម្រោងដែលបានកាត់ ៥០% ប៉ុន្តែសកម្មចុះស្រង់ទិន្នន័យនៅក្នុងខេត្តចំនួន២ ដែលស្ថិតនៅក្នុងតំបន់ខ្ពង់រាបគឺ ខេត្តកំពង់ធំ និងខេត្តសៀមរាប ពុំទាន់បានអនុវត្តនៅឆ្នាំ ២០២០ ហើយបានបន្តអនុវត្តនៅក្នុងឆ្នាំ២០២១ វិញ។ នៅក្នុងឆ្នាំ ២០២២ ដោយសារថវិកាកម្មវិធីអនុវត្តគម្រោងសម្រាប់ការចុះស្រង់ទិន្នន័យនៅតំបន់ឆ្នេរសមុទ្រមានកម្រិតគឺត្រូវបានអនុវត្តបានតែ២ខេត្តប៉ុណ្ណោះ គឺនៅក្នុងខេត្តកោះកុង និងខេត្តព្រះសីហនុ ហើយនៅក្នុងឆ្នាំ២០២៣ នេះ ខេត្តកំពត និងខេត្តកែបទើបត្រូវបានអនុវត្ត។

## ១.២ គោលបំណង

គោលបំណងសំខាន់នៃការអនុវត្តគម្រោងអង្កេតភពផែនដីឆ្នាំ២០២៣នេះ គឺការកសាងប្រព័ន្ធទិន្នន័យស្ថិតិដែលទាក់ទងផ្នែកបរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុសម្រាប់តំបន់ឆ្នេរសមុទ្រនៅក្នុងខេត្តចំនួន២គឺខេត្តកែប និងខេត្តកំពត ដើម្បីចូលរួមតាមដានលើការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

## ១.៣ វិធីសាស្ត្រប្រមូលទិន្នន័យ

ទិន្នន័យសម្រាប់ធ្វើការវិភាគនេះ គឺបានមកពីការប្រមូលទិន្នន័យពីរប្រភេទ គឺទិន្នន័យទី១ និងទិន្នន័យទី២។វិធីសាស្ត្រនៃការប្រមូលទិន្នន័យទី១ គឺត្រូវបានប្រមូលតាមរយៈការធ្វើសម្ភាសន៍មេភូមិ និងមេគ្រួសារនៅក្នុងភូមិគោលដៅនៃខេត្តទាំង ២គឺខេត្តកែប និងខេត្តកំពតដែលស្ថិតនៅតំបន់ឆ្នេរសមុទ្រ។ កម្រងសំណួរសម្រាប់សម្ភាសន៍មានពីរ គឺកម្រងសំណួរទី១ គឺសម្រាប់សម្ភាសន៍មេភូមិ និងកម្រងសំណួរទី២ គឺសម្រាប់សម្ភាសន៍មេគ្រួសារ។ ភូមិគោលដៅដែលមានចំនួន១០ភូមិ និងចំនួនមេគ្រួសារ ៦០០នាក់ ស្ថិតនៅក្នុងខេត្ត២នៅក្នុងតំបន់ឆ្នេរសមុទ្រ គឺត្រូវបានធ្វើសម្ភាសន៍។ ទិន្នន័យទី ២ គឺត្រូវបានប្រមូលពីក្រសួងបរិស្ថាន ក្រសួងធនធានទឹក និង គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មន្ទីរផែនការខេត្តកែប និងមន្ទីផែនការខេត្តកំពត ព្រមទាំងទិន្នន័យផ្សេងៗទៀតពីស្ថាប័នដែលមានការពាក់ព័ន្ធដទៃទៀត ដែលបានផលិតចេញជារបាយការណ៍ផ្ទាល់របស់ស្ថាប័នដែលពាក់ព័ន្ធនឹងសូចនាករខាងលើ។

តារាង ១. បញ្ជីភូមិគោលដៅសម្រាប់ធ្វើការសម្ភាសន៍ស្រង់ទិន្នន័យនៅក្នុងខេត្តកំពត និងខេត្តកែប។

| ល.រ | ខេត្ត | ស្រុក | ឃុំ | ភូមិ | ចំនួនគ្រួសារ | ចំនួនគ្រួសារត្រូវសម្ភាសន៍ |
|---|---|---|---|---|---|---|
| ១ | កែប | ដំណាក់ចង្អើរ | ពងទឹក | អរដូង | 348 | 60 |
| | | | | ព្រៃកតាកុយ | 289 | 60 |
| | | | | ភ្នំលាវ | 894 | 60 |
| | | | | រនេស | 303 | 60 |
| | | | | ចំការបី | 391 | 60 |
| ២ | កំពត | | ព្រៃឃ្មុំ | ព្រៃតុម្ព | 404 | 60 |
| | | | | បឹងតារោង | 252 | 60 |
| | | | ត្រពាំងធំ | ត្រពាំងជ្រៃ | 196 | 60 |
| | | | | ក្រាំង | 162 | 60 |
| | | | | ស្វាយធំ | 221 | 60 |
| សរុប | | | | | 3,460 | 600 |

## ១.៤ ការកែច្នៃទិន្នន័យ

ទិន្នន័យដែលបានមកពីការធ្វើសម្ភាសន៍តាមរយៈមេភូមិ និងមេគ្រួសារនៅតាមភូមិគោលដៅនៅក្នុងខេត្តទាំង២ ដែលស្ថិតនៅក្នុងតំបន់ឆ្នេរសមុទ្រ គឺត្រូវបានវាយបញ្ចូលទៅក្នុងកុំព្យូទ័រដោយប្រើប្រាស់កម្មវិធី CSPro 7.7 សម្រាប់ការត្រួតពិនិត្យកំហុស និងការទាញទិន្នន័យផលិតជាតារាងសម្រាប់ធ្វើការវិភាគក្នុងការសរសេររបាយការណ៍វិភាគលទ្ធផលចុងក្រោយផងដែរ។ ចំពោះកម្មវិធី Microsoft Excel គឺត្រូវបានប្រើប្រាស់សម្រាប់ការធ្វើក្រាហ្វិក និងការគណនាផ្សេងៗ។ កម្មវិធី Microsoft Word គឺសម្រាប់សរសេររបាយការណ៍វិភាគទិន្នន័យ និងបោះពុម្ពជាឯកសារចុងក្រោយ។

## ១.៥ សារៈប្រយោជន៍

របាយការណ៍វិភាគទិន្នន័យដែលប្រមូលបាននេះ គឺមានសារៈសំខាន់ដល់អ្នកសិក្សាស្រាវជ្រាវ អ្នកធ្វើផែនការ និងអ្នករៀបចំគោលនយោបាយផ្សេងៗ ជាពិសេសរាជរដ្ឋាភិបាលមានទិន្នន័យបន្ថែមទៀតសម្រាប់រៀបចំគោលនយោបាយ ដែលទាក់ទងទៅនឹងការត្រួតពិនិត្យតាមដានការប្រែប្រួលនៃលក្ខណៈប្រជាសាស្ត្រ បរិស្ថានគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុតាមតំបន់នីមួយៗនៅក្នុងប្រទេសកម្ពុជា និងមានវិធានការបង្ការនូវហានិភ័យផ្សេងៗ ដែលអាចកើតមានឡើងដោយសារគ្រោះមហន្តរាយធម្មជាតិ និងការប្រែប្រួលអាកាសធាតុជាដើម។

# ជំពូក ២
# ស្ថានភាពទូទៅផ្អែកលើទិន្នន័យទី២ និងផ្កាយរណប

## ២.១ ស្ថានភាពទូទៅផ្អែកលើទិន្នន័យទី២

### ២.១.១ ប្រជាសាស្ត្រ

ប្រជាសាស្ត្រ គឺសំដៅដល់ចរិតលក្ខណៈរបស់ប្រជាជន រួមមាន រចនាសម្ព័ន្ធអាយុ ចំណាកស្រុក ការចូលរួមកម្លាំងពលកម្មក្នុងវិស័យសេដ្ឋកិច្ច ការអប់រំ លទ្ធភាពបង្កើតកូន និងការប្រើប្រាស់សម្ភារៈនៅក្នុងគ្រួសារជាដើម។ ការអភិវឌ្ឍប្រទេសក៏ជាផ្នែកមួយដែលធ្វើឲ្យមានបម្រែបម្រួលប្រជាសាស្ត្រផងដែរ។

#### ក. និន្នាការចំនួនប្រជាជនពិភពលោក

ក្រាហ្វិក ១. បង្ហាញអំពីចំនួននិន្នាការចំនួនប្រជាជនពិភពលោកពីឆ្នាំ១៩៦០ ដល់ឆ្នាំ ២០៣៥។ តាមនិន្នាការនេះ បានបង្ហាញថា ប្រជាជនទូទាំងពិភពលោកនឹងកើនឡើងជាងពីរដងពី ២.៩៩៦ លាននាក់ នៅឆ្នាំ១៩៦០ ដល់ចំនួន ៧.៨០៥ លាននាក់ឆ្នាំ ២០២០ និងបានកើនឡើងជិត ៣ដង នៅឆ្នាំ២០៣៥ តាមកាប៉ាន់ស្មាន។ ការកើនឡើងចំនួនប្រជាជននឹងមានផលប៉ះពាល់យ៉ាងច្រើនដល់ការប្រើប្រាស់នូវធនធានធម្មជាតិ និងផលប៉ះពាល់បរិស្ថាន ប្រសិនបើមិនបានគ្រប់គ្រងឲ្យបានត្រឹមត្រូវ។

**ក្រាហ្វិក ១. និន្នាការចំនួនប្រជាជនពិភពលោកពីឆ្នាំ១៩៦០ ដល់ ឆ្នាំ២០៣៥**




ប្រភព៖ United Nations, Department of Economic and Social Affairs, Population Division (2022). World Population Prospects 2022, Online Edition.

តារាង ២. បង្ហាញអំពីចំនួនប្រជាជនពិភពលោកបែងចែកតាមតំបន់នៃ ឆ្នាំ ២០២២ ឆ្នាំ២០៣០ និង ឆ្នាំ២០៥០។ ក្នុងចំណោមតំបន់ទាំងអស់ ចំនួនប្រជាជនដែលស្ថិតនៅតំបន់អាស៊ីប៉ែកខាងកើត និង អាស៊ីអាគ្នេយ៍ មានចំនួនប្រជាជនច្រើនជាងគេ និងចំនួនប្រជាជនតិចជាងគេគឺតំបន់អូសេអានី ដោយ មិនរាប់បញ្ចូលប្រទេសអូស្ត្រាលី និងញ៉ូវស៊ីឡែនទាំងនៅក្នុងឆ្នាំ២០២២, ឆ្នាំ២០៣០ និងនៅឆ្នាំ២០៥០។ នៅឆ្នាំ២០៥០ ចំនួនប្រជាជននៅក្នុងអាស៊ីកណ្តាល និងអាស៊ីខាងត្បូងបានកើនឡើងខ្ពស់ជាងគេ ខណៈ ដែលឆ្នាំ២០២២ និង២០៣០ ចំនួនប្រជាជនតិចជាងចំនួនប្រជាជនអាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍។ ទិន្នន័យលម្អិត មានបង្ហាញក្នុងតារាង ១ ដូចខាងក្រោម។

**តារាង ២.** ចំនួនប្រជាជនពិភពលោក ២០២២ ២០៣០ និង២០៥០

| Region | Population (in millions) 2022 | 2030 | 2050 |
|---|---|---|---|
| **World** | **7,942** | **8,512** | **9,687** |
| Sub-Saharan Africa | 1,152 | 1,401 | 2,094 |
| Northern Africa and Western Asia | 549 | 617 | 771 |
| Central and Southern Asia | 2,075 | 2,248 | 2,575 |
| Eastern and South-Eastern Asia | 2,342 | 2,372 | 2,317 |
| Latin America and the Caribbean | 658 | 695 | 749 |
| Australia/New Zealand | 31 | 34 | 38 |
| Oceania* | 14 | 15 | 20 |
| Europe and Northern America | 1,120 | 1,129 | 1,125 |
| Least developed countries | 1,112 | 1,328 | 1,914 |
| Landlocked developing countries | 557 | 664 | 947 |
| Small island developing States | 74 | 79 | 87 |

*excluding Australia and New Zealand

ប្រភព÷ United Nations, Population Division, Department of Economic and Social Affairs, World Population Prospects 2022, Summary of Results, New York, 2022.

សំគាល់÷ Population of the world, SDGs regions and selected groups of countries, 2022, 2030 and 2050 according to the medium scenario

## ខ. និន្នាការចំនួនប្រជាជនកម្ពុជា

ចំនួនប្រជាជនសរុបនៅក្នុងព្រះរាជាណាចក្រកម្ពុជា បានបង្ហាញតាមរយៈការធ្វើជំរឿនប្រជាជន ឆ្នាំ១៩៦២ មានចំនួន៥,៧ លាននាក់ បានកើនឡើងដល់ចំនួន ១១,៤ លាននាក់ ផ្អែកតាមការធ្វើជំរឿន ប្រជាជនឆ្នាំ១៩៩៨ រយៈពេល៣៦ឆ្នាំនេះប្រជាជនកម្ពុជា បានកើនឡើងជាង២ដងស្មើនឹងចំនួន៧,៧ លាននាក់ ។ ចំនួនប្រជាជនក្នុងរយៈពេល១០ឆ្នាំ គិតចាប់ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ ២០០៨ មានការកើនឡើង ប្រហែលចំនួន ២លាននាក់ (៩,៥%) ហើយក្នុងរយៈពេល ១១ឆ្នាំ គិតចាប់ពីឆ្នាំ ២០០៨ ដល់ឆ្នាំ២០១៩ កើនឡើងចំនួន ១,៩លាននាក់ (១៤,១%) នឹងត្រូវបានគេរំពឹងទុកថានៅឆ្នាំ ២០៣៥ ចំនួនប្រជាជនកម្ពុជា អាចកើនដល់ ១៩,៨លាននាក់។

ស្ថានភាពប្រជាជនកម្ពុជា មានការកើនឡើងពីចំនួន ១១លាននាក់ ក្នុងឆ្នាំ ១៩៩៨ ដល់ជិត១៦លាននាក់ នៅក្នុងឆ្នាំ២០១៧ ហើយកំពុងមានបម្រែបម្រួលប្រជាសាស្ត្រមួយល្អប្រសើរដល់ការអភិវឌ្ឍន៍ប្រទេស ដោយសាររចនាសម្ព័ន្ធអាយុរបស់ប្រជាជនកម្ពុជានាពេលបច្ចុប្បន្នកំពុងស្ថិតក្នុងដំណាក់កាលភាគលាភប្រជាសាស្ត្រដ៏មានសក្ដានុពលសេដ្ឋកិច្ច ដែលមានចំនួនច្រើនលើសលប់នៃប្រជាជនក្នុងវ័យធ្វើការងារខណៈដែលប្រទេសមួយចំនួននៅលើពិភពលោក ចំនួនប្រជាជនស្ថិតនៅក្នុងវ័យធ្វើការងារមាននិន្នាការថយចុះ តែចំនួនអ្នកនៅដែលស្ថិតនៅក្នុងបន្ទុកមានការកើនឡើងវិញ។ ម្យ៉ាងវិញទៀត នៅក្នុងរយៈពេល២៥ឆ្នាំនេះ ប្រទេសកម្ពុជាបានទទួលនូវការរីកចម្រើនគួរឱ្យកត់សំគាល់ក្នុងការធានាលទ្ធភាពទទួលបានសុខភាពបន្តពូជសម្រាប់ស្ត្រី យុវវ័យ និងគូស្វាមីភរិយាផងដែរ (ព្រឹត្តិបត្រព័ត៌មានអគ្គលេខាធិការប្រជាជន និងការអភិវឌ្ឍន៍ឆ្នាំ២០២០)។ បើទោះបីជាស្ថានភាពប្រជាជនកម្ពុជា ដែលកំពុងស្ថិតក្នុងផលលាភប្រជាសាស្ត្រល្អប្រសើរក្តី ក៏ការកើនឡើងចំនួនប្រជាជនអាចមានផលប៉ះពាល់ដល់ធនធានធម្មជាតិ បរិស្ថាន ការងារ និងសន្តិសុខស្បៀង។ លើសពីនេះទៀត តម្រូវលំនៅដ្ឋានបន្ថែម និងសេវាសង្គមផ្សេង។ ម្យ៉ាងវិញទៀត ប្រសិនបើប្រជាជនដែលស្ថិតក្នុងវ័យផលិត ឬម្យ៉ាងទៀតអាចនិយាយថាជាផលលាភប្រជាសាស្ត្រនោះមិនមានការងារធ្វើ ឬ ការប្រព្រឹត្តនូវអំពើមិនល្អក៏អាចជះឥទ្ធិពលដល់សង្គមជាតិធ្ងន់ធ្ងរផងដែរ។

សរុបមក ស្ថានភាពនៃបម្រែបម្រួលប្រជាជនកម្ពុជា កំពុងស្ថិតក្នុងដំណាក់កាលភាគលាភប្រជាសាស្ត្រដ៏មានសក្ដានុពលសេដ្ឋកិច្ច ប្រសិនបើការការរៀបក្រុមមនុស្សដែលស្ថិតក្នុងវិស័យផលិតបានល្អប្រសើរ។ តែផ្ទុយទៅវិញ ប្រសិនបើការការរៀបចំក្រុមមនុស្សដែលស្ថិតក្នុងវិស័យផលិតមិនបានល្អនឹងបាត់ឱកាសនេះ ហើយក្រុមមនុស្សនេះក៏អាចធ្វើអំពើមិនគប្បីប្រសិនបើការគ្រប់គ្រងមិនបានល្អ។

## ផែនទី១. បង្ហាញអំពីផែនទីប្រទេសកម្ពុជា និងរូបភាពប្រជាជនដែលជាយុវវ័យនៅទូទាំងប្រទេស



ក្រាហ្វិក ២. បង្ហាញអំពី និន្នាការនៃការកើនឡើងពីចំនួនប្រជាជនអំឡុងពេលការធ្វើជំរឿនឆ្នាំ ១៩៦២ មានចំនួនប្រជាជន ៥,១ លាននាក់ បានកើនឡើង ១១,៤លាននាក់ នៅពេលធ្វើជំរឿនឆ្នាំ ១៩៩៨ បានកើនឡើងដល់ពេល ១៣,៤លាននាក់ នៅពេលធ្វើជំរឿនឆ្នាំ ២០០៨ និង ១៥,៣លាននាក់ ផ្អែកតាមលទ្ធផលជំរឿនឆ្នាំ ២០១៩ ហើយរំពឹងថានឹងកើនឡើងដល់ ១៩,៨លាននាក់នៅឆ្នាំ២០៣៥។

### ក្រាហ្វិក ២. និន្នាការចំនួនប្រជាជនសរុបទូទាំងប្រទេសកម្ពុជា




*ប្រភព៖ ១. ទិន្នន័យឆ្នាំ ១៩៦២, ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៦២, ១៩៩៨, ២០០៨ និង ២០១៩*

*២. ទិន្នន័យឆ្នាំ ១៩៩៦ ផ្អែកលើទិន្នន័យអង្កេតប្រជាសាស្ត្រឆ្នាំ ១៩៩៦*

*៣. ទិន្នន័យឆ្នាំ ២០០៤ និង ២០១៣ ផ្អែកលើអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ ២០០៤ និង ២០១៣*

*៤. ទិន្នន័យឆ្នាំ ២០២៥, ២០៣០ និង ២០៣៥ ផ្អែកលើទិន្នន័យចំណោលប្រជាជនឆ្នាំ ២០២០ ដោយប្រើប្រាស់ទិន្នន័យជំរឿនប្រជាជនឆ្នាំ ២០១៩។*

ចំនួនប្រជាជនកម្ពុជាក្នុងរយៈពេល៣៦ឆ្នាំ ពីឆ្នាំ១៩៦២ ដល់១៩៩៨ បានកើនឡើង ៥,៧ លាននាក់ ស្មើនឹង ៥០% នៃចំនួនប្រជាជនឆ្នាំ១៩៦២។ នៅក្នុងរយៈពេល ១០ ឆ្នាំពីឆ្នាំ១៩៩៨ ដល់ ឆ្នាំ២០០៨ បានកើនឡើងចំនួន ២ លាននាក់ ស្មើនឹង ១៧,៥% នៃចំនួនប្រជាជនឆ្នាំ ២០០៨។ នៅក្នុងរយៈពេល ១១ឆ្នាំ ពីឆ្នាំ២០០៨ ដល់ ឆ្នាំ២០១៩ បានកើនឡើងចំនួន១,៩ លាននាក់ ស្មើនឹង ១៤,២%នៃចំនួនប្រជាជនឆ្នាំ២០០៨។ នៅក្នុងរយៈ ៥៧ ឆ្នាំ គិតពីឆ្នាំ១៩៦២ ដល់ ឆ្នាំ២០១៩ ចំនួនប្រជាជនបានកើនឡើងជិត ៣ដង នៃចំនួនប្រជាជនទូទាំងប្រទេស ឆ្នាំ១៩៦២។ នៅឆ្នាំ២០៣៥ តាមការធ្វើចំណោលប្រជាជនឆ្នាំ២០២០ ដោយផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ២០១៩ អាចនឹងកើនឡើងដល់ ១៩,៨ លាននាក់។

## ១១. និន្នាការចំនួនប្រជាជនកម្ពុជាតាមតំបន់

ប្រទេសកម្ពុជាបានបែងចែកសណ្ឋានដីចំនួន ៤តំបន់ រួមមាន ទី១. តំបន់ទំនាបកណ្តាល ទី២. តំបន់ទន្លេសាប ទី៣. តំបន់ឆ្នេរសមុទ្រ និងទី៤. តំបន់ខ្ពង់រាប និងភ្នំ។ ទំហំផ្ទៃដីនៃតំបន់ទាំង៤នោះគឺ តំបន់ខ្ពង់រាបនិងភ្នំ មានទំហំផ្ទៃដីចំនួន ៦៨.០៦១ គីឡូម៉ែត្រការ៉េ ធំជាងគេស្ថិតក្នុងលំដាប់ទី១ បន្ទាប់មក តំបន់ទន្លេសាបមានទំហំផ្ទៃដីចំនួន ៦៧.៦៦៨ គីឡូម៉ែត្រការ៉េ ស្ថិតក្នុងលំដាប់ទី២ តំបន់ទំនាបកណ្តាលមាន ទំហំផ្ទៃដីចំនួន ២៥.០៦៩គីឡូម៉ែត្រការ៉េ ស្ថិតក្នុងលំដាប់ទី៣ និងតំបន់ឆ្នេរសមុទ្រមានទំហំផ្ទៃដីចំនួន ១៧.២៣៧គីឡូម៉ែត្រការ៉េ ស្ថិតក្នុងលំដាប់ទី៤។តំបន់ដែលមានភាគរយចំនួនប្រជាជនរស់នៅច្រើនជាង គេតំបន់ទំនាបកណ្តាល និង តិចជាងគេគឺតំបន់ឆ្នេរសមុទ្រ។ចំនួនប្រជាជននៅក្នុងតំបន់ទំនាបកណ្តាល មានចំនួនប្រហែល ៥,៩លាននាក់ នៅឆ្នាំ១៩៩៨ នឹងកើនដល់ ៩,៧ លាននាក់ នៅឆ្នាំ ២០៣៥ ខណៈ ដែលចំនួនក្នុងតំបន់ទន្លេសាបមានចំនួនប្រហែល ៣,៥លាននាក់នៅឆ្នាំ ១៩៩៨ នឹងកើនដល់ ៦,២ លាននាក់ នៅឆ្នាំ ២០៣៥ តំបន់ខ្ពង់រាប និងភ្នំមានចំនួនប្រហែល ១,២លាននាក់នៅឆ្នាំ ១៩៩៨ នឹងកើន ដល់ ២,៥ លាននាក់ នៅឆ្នាំ ២០៣៥ និង តំបន់ឆ្នេរសមុទ្រមានចំនួនប្រហែល ៨៤៤ ពាន់ នាក់នៅឆ្នាំ ១៩៩៨ នឹងកើនដល់ ១,៤ លាននាក់ នៅឆ្នាំ២០៣៥។ ក្រាហ្វិក ៣បង្ហាញអំពីនិន្នាការចំនួនប្រជាជន តាមតំបន់ក្នុងប្រទេសកម្ពុជា។

**ក្រាហ្វិក ៣. និន្នាការចំនួនប្រជាជនតាមតំបន់ក្នុងប្រទេសកម្ពុជា**




*ប្រភព៖ ១. ទិន្នន័យឆ្នាំ ១៩៦២, ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៦២, ១៩៩៨, ២០០៨ និង ២០១៩*
*២. ទិន្នន័យឆ្នាំ ១៩៩៦ ផ្អែកលើទិន្នន័យអង្កេតប្រជាសាស្ត្រឆ្នាំ ១៩៩៦*
*៣. ទិន្នន័យឆ្នាំ ២០០៤ និង ២០១៣ ផ្អែកលើអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ ២០០៤ និង ២០១៣*
*៤. ទិន្នន័យឆ្នាំ ២០២០ ផ្អែកលើទិន្នន័យចំណោលប្រជាជនឆ្នាំ ២០២០ ដោយប្រើប្រាស់ទិន្នន័យជំរឿនប្រជាជនឆ្នាំ ២០១៩។*

## ១២. និន្នាការចំនួនប្រជាជនខេត្តកំពត និងខេត្តកែប

ខេត្តកំពត និងខេត្តកែប ជាខេត្តដែលស្ថិតក្នុងតំបន់ឆ្នេរសមុទ្រ។ ខេត្តកំពតមានផ្ទៃដីចំនួន ១.៩៣៨ គីឡូម៉ែត្រការ៉េ និងមានចំនួនប្រជាជននៅឆ្នាំ ២០១៩ ប្រហែល ៥៩៣.៨២៩ នាក់។ ខេត្តកែបមានផ្ទៃដីចំនួន ៣៣៦ គីឡូម៉ែត្រការ៉េនិងមានចំនួនប្រជាជននៅឆ្នាំ ២០១៩ ប្រហែល ៤២.៦៦៥នាក់ ផ្អែករបាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩។ ក្រាហ្វិក ៤ បង្ហាញពីនិន្នាការចំនួនប្រជាជនខេត្តកំពត និង ខេត្តកែបពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០៣៥។ ចំនួនប្រជាជន ខេត្តកំពតបានកើនឡើងពីចំនួន៥២៨.៤០៥នាក់ នៅក្នុងឆ្នាំ១៩៩៨ ដល់ចំនួន ៥៨៥,៨៥០នាក់ នៅឆ្នាំ២០០៨ ក្នុងរយៈពេល១០ឆ្នាំ និងនៅក្នុងឆ្នាំ ២០១៩ គឺបានកើនចំនួនពី ៥៨៨.០៦៦នាក់ ហើយរំពឹងថានៅឆ្នាំ២០៣៥ ចំនួនប្រជាជនកើនដល់ ៧៥៩.៥៤៤នាក់។ ចំនួនប្រជាជនខេត្តកែបបានកើនឡើងពីចំនួន ២៨.៦៦០នាក់ នៅក្នុងឆ្នាំ១៩៩៨ ដល់ចំនួន ៣៥.៧៥៣នាក់ នៅឆ្នាំ ២០០៨ ក្នុងរយៈពេល១០ឆ្នាំ និង នៅក្នុងឆ្នាំ ២០១៩ គឺបានកើនចំនួនពី ៤១.៥៣៩នាក់ ហើយរំពឹងថានៅឆ្នាំ២០៣៥ ចំនួនប្រជាជនកើនដល់ ៥៤.៥៧១ នាក់។

**ក្រាហ្វិក ៤. និន្នាការចំនួនប្រជាជនសម្រាប់ខេត្តកំពត និងខេត្តកែប**




*ប្រភព៖ ១. ទិន្នន័យឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៦២, ១៩៩៨, ២០០៨ និង ២០១៩*

*២. ទិន្នន័យឆ្នាំ ២០០៤ និង ២០១៣ ផ្អែកលើអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ ២០០៤ និង ២០១៣*

*៣. ទិន្នន័យឆ្នាំ ២០២៥, ២០៣០ និង ២០៣៥ ផ្អែកលើទិន្នន័យចំណោលប្រជាជនឆ្នាំ ២០២០ ដោយប្រើប្រាស់ទិន្នន័យជំរឿនប្រជាជនឆ្នាំ ២០១៩។*

## តារាង ៣. ចំនួនប្រជាជននិងចំនួនគ្រួសារសរុប ពីឆ្នាំ ១៩៩៨ ដល់ ២០៣៥ គិតជានាក់

| ឆ្នាំ | ចំនួនប្រជាជន | | ចំនួនគ្រួសារ | |
|---|---|---|---|---|
| | កំពត | កែប | កំពត | កែប |
| 1998 | 528,405 | 28,660 | 104,993 | 5,369 |
| 2004 | 596,000 | 33,000 | 116,863 | 6,471 |
| 2008 | 585,850 | 35,753 | 130,084 | 7,236 |
| 2013 | 611,557 | 38,700 | 132,947 | 8,413 |
| 2019 | 588,066 | 41,539 | 143,402 | 9,605 |
| 2020 | 623,836 | 44,821 | 152,155 | 10,932 |
| 2021 | 633,535 | 45,518 | 154,521 | 11,102 |
| 2022 | 643,128 | 46,207 | 156,860 | 11,270 |
| 2023 | 652,602 | 46,888 | 159,171 | 11,436 |
| 2024 | 661,951 | 47,559 | 161,451 | 11,600 |
| 2025 | 671,170 | 48,222 | 163,700 | 11,761 |
| 2026 | 680,273 | 48,876 | 165,920 | 11,921 |
| 2027 | 689,264 | 49,522 | 168,113 | 12,078 |
| 2028 | 698,126 | 50,158 | 170,275 | 12,234 |
| 2029 | 706,832 | 50,784 | 172,398 | 12,386 |
| 2030 | 715,356 | 51,396 | 174,477 | 12,536 |
| 2031 | 723,983 | 52,016 | 176,581 | 12,687 |
| 2032 | 732,714 | 52,644 | 178,711 | 12,840 |
| 2033 | 741,550 | 53,278 | 180,866 | 12,995 |
| 2034 | 750,493 | 53,921 | 183,047 | 13,151 |
| 2035 | 759,544 | 54,571 | 189,886 | 13,643 |

*ប្រភព៖ ១. ទិន្នន័យឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩*
*២. ទិន្នន័យឆ្នាំ ២០០៤ និង ២០១៣ ផ្អែកលើអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ ២០០៤ និង ២០១៣*
*៣. ទិន្នន័យឆ្នាំ ២០២០ និង ២០៣៥ ផ្អែកលើទិន្នន័យចំណោលប្រជាជនឆ្នាំ ២០២០*

## គ. ដង់ស៊ីតេប្រជាជន

ដង់ស៊ីតេប្រជាជនជាសូចនាករមួយយ៉ាងសំខាន់ សម្រាប់ពិនិត្យមើលរបាយប្រជាជនតាមតំបន់ រាជធានី ខេត្ត ។ ដង់ស៊ីតេចំនួនប្រជាជនទូទាំងប្រទេសនៅឆ្នាំ១៩៩៨ មានដង់ស៊ីតេចំនួន ៦៤នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ហើយបានកើនឡើង ៧៥ ក្នុងមួយគីឡូម៉ែត្រការ៉េ និង កើនឡើងដល់ ៨៦នាក់ក្នុងមួយគីឡូម៉ែត្រការរ៉េនៅឆ្នាំ២០១៩ ខណៈដែលខេត្តទាំង ៣ មានដង់ស៊ីតេចំនួន ៥៣ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ នៅឆ្នាំ១៩៩៨ នឹងកើនឡើងដល់ ៦៤ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េនៅឆ្នាំ២០១៩។ ចំណែក ឯនៅក្នុងតំបន់បឹងទន្លេសាបមានដង់ស៊ីតេចំនួន ៥៧ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េក្នុងឆ្នាំ២០០៨ និង បានកើនឡើង ៦២នាក់ក្នុងមួយគីឡូម៉ែត្រការ៉េក្នុងឆ្នាំ២០១៩។ ចំណែកឯខេត្តទាំង ៥ ជាប់បឹងទន្លេសាបមានដង់ស៊ីតេចំនួន ៦៣ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ហើយបានកើនឡើងដល់ ៧៣នាក់ក្នុងមួយគីឡូម៉ែត្រការ៉េនៅក្នុងឆ្នាំ២០១៩ ខណៈខេត្តទាំង ៣ មារួមមាន ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបងមានចំនួន ៧០ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ។

**ផែនទីទី២. ដង់ស៊ីតេប្រជាជនតាមរាជធានីខេត្ត ឆ្នាំ១៩៩៨**




ប្រភព: លទ្ធផលចុងក្រោយជំរឿនទូទៅនូវប្រជារាស្ត្រ ឆ្នាំ១៩៩៨

## ផែនទី៣. ដង់ស៊ីតេប្រជាជនតាមរាជធានីខេត្ត ឆ្នាំ២០០៨




ប្រភព: លទ្ធផលចុងក្រោយជំរឿនទូទៅនូវប្រជារាស្ត្រ ឆ្នាំ ២០០៨

## ផែនទី៤. ដង់ស៊ីតេប្រជាជនតាមរាជធានីខេត្ត ឆ្នាំ២០១៩




ប្រភព: របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ២០១៩

## ផែនទី៥. ដង់ស៊ីតេប្រជាជនតាមក្រុង ស្រុក ខេត្តកំពត ឆ្នាំ២០១៩




## ផែនទី៦. ដង់ស៊ីតេប្រជាជនតាមក្រុង ស្រុក ខេត្តកែប ឆ្នាំ២០១៩




ប្រភព៖ របាយការណ៍ការជាតិស្ដីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩។

## ឃ. ការបំលាស់ទីកន្លែងរស់នៅ

ការបំលាស់ទីកន្លែងរស់នៅរបស់មនុស្ស គឺបានកើតឡើងគ្រប់ប្រទេសទាំងអស់នៅលើពិភពលោក។ ការផ្លាស់ប្តូរទីកន្លែងរស់នៅ គឺអាចផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយទៀតក្នុងខេត្តដដែលឬ ពីប្រទេសមួយទៅប្រទេសមួយទៀត ដែលបណ្តាលមកពីហេតុផលផ្សេងៗដូចជាការស្វែងរកការងារធ្វើ គ្រោះធម្មជាតិ សង្គ្រាម ការប្រែប្រួលអាកាសធាតុដែលមិនអាចធ្វើការកសិកម្មបាន ឬ ហេតុផលផ្សេងៗទៀត។ សូចនាករការបំលាស់ទីកន្លែងរស់នៅ ឬចំណាកស្រុក ដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ គឺមានគោលបំណងចង់បង្ហាញអំពីស្ថានភាពនៃការបំលាស់ទីកន្លែងរស់នៅ ឬចំណាកស្រុករបស់ប្រជាជននៅលើពិភពលោក និងនៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅក្នុងខេត្តកំពត និងខេត្តកែបផងដែរ។

## ឃ១. ស្ថានភាពបំលាស់ទីកន្លែងរស់នៅរបស់ប្រជាជនពិភពលោក

ប្រជាជននៅលើពិភពលោក គឺបានធ្វើចំណាកស្រុកទៅក្រៅប្រទេសមានចំនួនប្រហែល ១៨១ លាននាក់ ស្មើនឹងចំនួន ៣,៦% នៃចំនួនប្រជាជននៅលើពិភពលោក ផ្អែកតាមទិន្នន័យរបស់អង្គការសហប្រជាជាតិទទួលបន្ទុកអន្តោប្រវេសន៍។ នៅក្នុងចំណោមប្រជាជនអន្តោប្រវេសន៍ ១៨១ លាននាក់ មានចំនួនមនុស្សប្រុសចំនួនប្រហែល ១៤៦ លាននាក់ ស្មើនឹង៣,៧%នៃចំនួនមនុស្សប្រុសសរុបលើពិភពលោក និងចំនួនមនុស្សស្រី ១៣៥លាននាក់ស្មើនឹង៣,៥%នៃចំនួនមនុស្សស្រីសរុបលើពិភពលោក ។ ជនអន្តោប្រវេសន៍ដែលជាកម្មករមានចំនួន ១៦៩លាននាក់ និងជនអន្តោប្រវេសន៍ដែលស្លាប់និងបាត់បង់មានចំនួន ៣.៩០០ នាក់។ ប្រទេសមានប្រាក់ចំណូលទាប និងមធ្យម ដែលទទួលបានប្រាក់ផ្ញើពីក្រៅប្រទេសមកប្រទេសខ្លួន មានចំនួនប្រហែល ៥៤០ពាន់លានដុល្លារ ក្នុងចំណោមប្រាក់ផ្ញើទៅក្រៅប្រទេសសរុប ៧០២ពាន់លានដុល្លារ នៅក្នុងឆ្នាំ ២០២០ ទាបជាងឆ្នាំ ២០១៩ ដែលមានចំនួន ៥៤៨ពាន់លានដុល្លារ និងប្រាក់ផ្ញើសរុប ៧១៩ពាន់លានដុល្លារ។ នៅក្នុងក្រាហ្វិក ៥ បង្ហាញអំពីអន្តោប្រវេសន៍អន្តរជាតិតាមតំបន់សំខាន់ៗពីឆ្នាំ ២០០៥ ដល់ ២០២០ ខាងក្រោមបានបង្ហាញថា ចំនួនជនអន្តោប្រវេសន៍ដែលកំពុងរស់នៅតំបន់អាស៊ី និងអឺរ៉ុបមានចំនួនច្រើនជាងគេ និងតិចជាងគេស្ថិតក្នុងតំបន់មហាសមុទ្រ។

### ក្រាហ្វិក ៥. ចំនួនជនអន្តោប្រវេសន៍អន្តរជាតិតាមតំបន់សំខាន់ៗពីឆ្នាំ ២០០៥ ដល់ ២០២០ (លាននាក់)




*Source*: UN DESA, 2021a.

### ក្រាហ្វិក ៦. ចំនួនជនអន្តោប្រវេសន៍អន្តរជាតិដែលបានផ្ញើប្រាក់មកក្រុមគ្រួសារពីឆ្នាំ ២០១៩ ដល់ ២០២០ (សកល និងប្រទេសមានចំណូលទាប និងមធ្យម)




សំគាល់÷ ប្រទេសមានចំណូលទាបនិងមធ្យមបានទទួលប្រាក់ផ្ញើជាលក្ខណៈអន្តរជាតិ

ប្រភព÷ UN Migration, *World Migration Report 2022*, 2022, UN Migration.

## ឃ២. ការបំលាស់ទីកន្លែងរស់នៅរបស់ប្រទេសកម្ពុជា

សូចនាករការបំលាស់ទីកន្លែងរស់នៅដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ គឺមានគោលបំណងចង់បង្ហាញអំពីការបំលាស់ទីកន្លែងរស់នៅរបស់ប្រជាជន ដែលភាគច្រើនគឺការផ្លាស់ប្តូរទីកន្លែងរស់នៅដោយសារបញ្ហាសេដ្ឋកិច្ច។ ប្រជាជនកម្ពុជាភាគច្រើន គឺជាអ្នកប្រកបរបរកសិកម្ម តែដោយសារកំណើនប្រជាជន សំណង់លំនៅដ្ឋានមានការកើនឡើង ហើយផ្ទៃដីកសិកម្មត្រូវបានរួមតូច ដោយសារការអភិវឌ្ឍន៍ផ្នែកនគរូបនីយកម្ម ប្រជាជនដែលមានចំណេះដឹងតិចតួច ដែលចេះតែធ្វើការងារកសិកម្ម ហើយពុំមានផ្ទៃដីគ្រប់គ្រាន់សម្រាប់ធ្វើកសិកម្ម បានស្វែងរកទីកន្លែងរស់នៅថ្មី ដែលពួកគាត់គិតថាមានភាពប្រសើរជាងមុន ជាពិសេសនៅតំបន់ប៉ៃកញ្ញសាន ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តដទៃទៀត។ ខេត្តកំពង់ធំ និងខេត្តសៀមរាប កាលពីមុន គឺជាខេត្តសម្បូរព្រៃឈើ ត្រី និង ដីកសិកម្មទូលំទូលាយ ព្រមទាំងមានស្ថានភាពភូមិសាស្ត្រល្អ ដល់ប្រជាជនដែលចង់ប្រកបរបរកសិកម្មអាចរស់នៅបាន។ ដូច្នេះ ប្រជាជនភាគច្រើននៅតំបន់ទំនាបកណ្តាល បានផ្លាស់ប្តូរទីកន្លែងរស់នៅតំបន់ទាំងនោះ។ ការផ្លាស់ប្តូរទីកន្លែងរស់នៅ ឬ ការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនកម្ពុជា គឺត្រូវបានកំណត់ជាដំណើរការនៃការផ្លាស់ប្តូរកន្លែងរស់នៅពីទីតាំងភូមិសាស្ត្រមួយទៅទីតាំងភូមិសាស្ត្រមួយទៀត។ យោងតាមអនុសាសន៍របស់អង្គការសហប្រជាជាតិ បានឲ្យគ្រប់ប្រទេសទាំងអស់លើពិភពលោកបញ្ចូលសូចនាករនេះទៅក្នុងតារាងបញ្ជីសំណួរនៃការធ្វើជំរឿនប្រជាជន ដើម្បីសិក្សាអំពីចរិតលក្ខណៈនៃការផ្លាស់ប្តូរលំនៅដ្ឋាន។ ជាក់ស្តែងផងដែរ រាជរដ្ឋាភិបាលកម្ពុជាមានទិន្នន័យ សម្រាប់ការរៀបចំគោលនយោបាយជាតិទាក់ទងការផ្តល់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងរកវិធីសាស្ត្រណាទប់ស្កាត់ការផ្លាស់ប្តូរទីកន្លែងរស់នៅរបស់ប្រជាជន តាមរយៈការអភិវឌ្ឍ និងបង្កើតការងារនៅក្នុងស្រុក ឬ នៅទីតាំងជិតលំនៅដ្ឋានរបស់ពួកគាត់តែម្តង ។ នៅឆ្នាំ១៩៩៨ ប្រជាជនទូទាំងប្រទេសមានការផ្លាស់ប្តូរលំនៅដ្ឋានមានចំនួន ៣១ភាគរយ ហើយបានកើនឡើង ៣៥ភាគរយនៅឆ្នាំ២០០៤ ប៉ុន្តែនៅឆ្នាំ ២០០៨ បានធ្លាក់ចុះមកត្រឹម ២៦,៥ភាគរយ និងបានកើនឡើងវិញនៅឆ្នាំ២០១៣ មានចំនួន ២៨,៩ភាគរយ និងបានធ្លាក់ចុះមកត្រឹម ២១,៥ភាគរយនៅឆ្នាំ២០១៩។ សូចនាករនេះ ប្រសិនបើពិនិត្យឲ្យស៊ីជម្រៅ វាមានទំនាក់ទំនងទៅការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងមូលដ្ឋានផ្ទាល់ ដូចជាការងារកសិកម្មដែលជាការងារជាប្រពៃណីរបស់ប្រជាជនកម្ពុជាភាគច្រើន ដែលពួកគាត់បានធ្វើរាប់ជំនាន់មកហើយ តែដោយសារដីកសិកម្មរួមតូច ពួកគាត់ត្រូវធ្វើចំណាកស្រុកទៅតំបន់ផ្សេង ជាពិសេសតំបន់ដែលសម្បូរព្រៃឈើ ដើម្បីធ្វើកសិកម្ម ពួកគាត់ត្រូវកាប់ព្រៃឈើ រានយកដី ដែលធ្វើឲ្យប៉ះពាល់បរិស្ថាន ប៉ះពាល់ដល់ជីវចម្រុះផ្សេងៗ គួបផ្សំនឹងការបាត់បង់ព្រៃឈើស្រាប់ផងនោះ បានធ្វើឲ្យព្រៃឈើមានការបាត់បង់បន្ថែមទៀត ដែលបណ្តាលឲ្យមានការប្រែប្រួលអាកាសធាតុ ទឹកជំនន់ គ្រោះរាំងស្ងួតជាដើម។

## ក្រាហ្វិក ៧. ការផ្លាស់ប្តូរទីលំនៅពីមុនទូទាំងប្រទេស




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨
- របាយការណ៍ទូទៅនៃការធ្វើអង្កេតប្រជារាស្ត្រកម្ពុជា អង្កេតចន្លោះជំរឿន ឆ្នាំ២០០៤
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨
- របាយការណ៍ចុងក្រោយ អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣
- របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ២០១៩។

ស្ថានភាពនៃការផ្លាស់ប្តូរទីលំនៅដ្ឋានរបស់ប្រជាជនកម្ពុជា នៅតាមតំបន់ទីប្រជុំជន គឺមានចំនួនច្រើនជាងតំបន់ជនបទទាំងនៅឆ្នាំ ២០០៨ និង ២០១៣ ។ នៅឆ្នាំ២០០៨ ប្រជាជនដែលបានផ្លាស់ប្តូរលំនៅដ្ឋានមានចំនួន ៥៩,៧ភាគរយ ហើយបានថយចុះនៅឆ្នាំ ២០១៣ ដែលមានចំនួន ៤៩,៤ភាគរយ ខណៈដែលតំបន់ជនបទនៅឆ្នាំ២០០៨ មានចំនួន ១៨,៩ ភាគរយ ហើយបានកើនឡើងដល់ ២៣,៣ ភាគរយ នៅឆ្នាំ២០១៣ និងបានធ្លាក់ចុះមកត្រឹម ១២,៤ភាគរយ នៅឆ្នាំ២០១៩។

### ក្រាហ្វិក ៨. ការផ្លាស់ប្តូរទីលំនៅតាមតំបន់ទូទាំងប្រទេស




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨

- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨
- របាយការណ៍ចុងក្រោយ អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣
- របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ២០១៩។

ក្រាហ្វិក ៩ បង្ហាញពីនិន្នាការនៃការផ្លាស់ប្តូរទីកន្លែងរស់នៅខុសពីមុន ដែលបច្ចុប្បន្នគាត់កំពុងរស់នៅខេត្តដែលធ្វើជំរឿន។ ផ្អែកតាមទិន្នន័យជំរឿនទូទៅប្រជាជន នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩ ចំនួនអ្នកដែលមានលំនៅដ្ឋានខុសពីមណ្ឌលជំរឿន នៅក្នុងតំបន់ទំនាបកណ្តាលមានចំនួនប្រហែល ១.៧៩៤.២០១នាក់ (៥៤%) តំបន់ទន្លេសាប ៩០៤.៨០៧ នាក់ (២៧%) តំបន់ខ្ពង់រាប និងភ្នំ ៣៦៣.៧៤១នាក់ (១១%) តំបន់ឆ្នេរសមុទ្រ ២៧៤.៩២០នាក់ (៨%)។

### ក្រាហ្វិក ៩. ការផ្លាស់ប្តូរទីលំនៅតាមតំបន់ឆ្នាំ ២០១៩




ប្រភព: របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ ២០១៩។

ក្រាហ្វិក ១០. បង្ហាញអំពីស្ថានភាពនៃការផ្លាស់ប្តូរទីលំនៅក្នុងខេត្តកំពត និងខេត្តកែប ឆ្នាំ ២០១៩។ ខេត្តកំពតមានអ្នកដែលផ្លាស់ប្តូរទីលំនៅពីមុន ហើយកំពុងរស់នៅក្នុងខេត្តកំពតមានចំនួន ៩.៤៦០នាក់ ស្មើនឹង ២៣% នៃចំនួនអ្នកផ្លាស់ប្តូរលំនៅដ្ឋានសរុបនៅក្នុងតំបន់ឆ្នេរសមុទ្រ ខណៈដែលខេត្តកែបមានអ្នកដែលផ្លាស់ប្តូរទីលំនៅពីមុន ហើយកំពុងរស់នៅក្នុងខេត្តកែបមានចំនួន៦២.៧១៤នាក់ ស្មើនឹង ៣%នៃចំនួនអ្នកផ្លាស់ប្តូរលំនៅដ្ឋានសរុបក្នុងតំបន់ឆ្នេរសមុទ្រ។ បើប្រៀបរវាងខេត្តកែប និង ខេត្តកំពត ខេត្តកែបតិចជាងខេត្តកំពត ២០%។

### ក្រាហ្វិក ១០. ការផ្លាស់ប្ដូរទីលំនៅខេត្តកំពត និងខេត្តកែបឆ្នាំ ២០១៩




ប្រភពៈ របាយការណ៍ការជាតិស្ដីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ ២០១៩។

នៅក្នុងឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩ មូលហេតុចម្បងនៃការផ្លាស់ប្ដូរទីកន្លែងរស់នៅរបស់ប្រជាជនមានចំនួនច្រើនជាងគេក្នុងចំណោមមូលហេតុដទៃទៀតនៃការផ្លាស់ប្ដូរលំនៅដ្ឋាន។ នៅឆ្នាំ ១៩៩៨ មូលហេតុគ្រួសារផ្លាស់ប្ដូរលំនៅដ្ឋានមានចំនួន ៣៧,០ ភាគរយ បានកើនឡើងដល់ ៣៧,៩ ភាគរយ នៅឆ្នាំ ២០០៨ និងកើនឡើងដល់ ៣៨,៩ភាគរយ ។ មូលហេតុរៀបអាពាហ៍ពិពាហ៍នៅឆ្នាំ ២០១៩ មានចំនួនច្រើនជាង ឆ្នាំ ២០០៨ ចំនួន ៥,១ ភាគរយ ហើយមូលហេតុ កូនកំព្រាក៏មានចំនួនថយចុះពី ៥,៦ ភាគរយ នៅឆ្នាំ ២០០៨ មកត្រឹម ០,២ ភាគរយ នៅឆ្នាំ ២០១៩។ មូលហេតុនៃការស្វែងរកការងារធ្វើបានធ្លាក់ចុះបន្តិចនៅឆ្នាំ ២០០៨ មានចំនួន ២១,៥ភាគរយ បានធ្លាក់ចុះ មកត្រឹម ១៩,៦ ភាគរយ ខណៈនៅឆ្នាំ ១៩៩៨ មានចំនួន ១៤,៥ ភាគរយ។ មូលហេតុផ្សេងៗ គឺបានបញ្ចូលនូវមូលហេតុផ្លាស់លំនៅដ្ឋានក្រៅពីមូលហេតុរៀបរាប់ខាងលើ។

## ក្រាហ្វិក ១១. មូលហេតុនៃការផ្លាស់ប្តូរទីលំនៅសម្រាប់ទូទាំងប្រទេស




ប្រភពៈ - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩

នៅក្នុងក្រាហ្វិក ១២ បង្ហាញអំពីមូលហេតុនៃការផ្លាស់ប្តូរលំនៅដ្ឋាននៅក្នុងខេត្តកំពត និងខេត្តកែប។ នៅក្នុងខេត្តកំពត ចំនួនប្រជាជនដែលផ្លាស់ប្តូរទីលំនៅពីមុនមានចំនួន ៦២.៧១៤នាក់ ប្រហែល១១% នៃប្រជាជនសរុប។ នៅក្នុងនោះមូលហេតុរៀបអាពាហ៍ពិពាហ៍មានចំនួនជាង ៥% និង គ្រួសារផ្លាស់ប្តូរលំនៅដ្ឋានមានចំនួនជិត៥%។ នៅក្នុងខេត្តកែប ចំនួនប្រជាជនដែលផ្លាស់ប្តូរទីលំនៅពីមុនមានចំនួន ៩.៤៦០នាក់ ប្រហែល២២% នៃប្រជាជនសរុប។ នៅក្នុងនោះមូលហេតុរៀបអាពាហ៍ពិពាហ៍មានចំនួនជាង ៧% និង គ្រួសារផ្លាស់ប្តូរលំនៅដ្ឋានមានចំនួនជិត ៧% ប្រហាប្រហែលគ្នា ខណៈដែលមូលហេតុដោយការសិក្សាមានចំនួន ២% និង ស្វែងរកការងារមានចំនួន ៣%។

# ក្រាហ្វិក ១២. មូលហេតុនៃការផ្លាស់ប្តូរទីលំនៅខេត្តកំពត និងខេត្តកែប ឆ្នាំ ២០១៩



## ខ. ការងារ និងសេដ្ឋកិច្ច




ការងារ និងសេដ្ឋកិច្ច នឹងត្រូវបានលើកយកមកបង្ហាញអំពីសកម្មភាពពលកម្ម និងការងាររបស់ប្រជាជនកម្ពុជា ដែលជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំគោលនយោបាយសេដ្ឋកិច្ច និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្សេងៗ។ គោលបំណងសំខាន់គឺធ្វើចំណាត់ថ្នាក់ប្រជាជនទាក់ទងអ្នកមានការងារធ្វើ អត់ការងារធ្វើ ជនសកម្មសេដ្ឋកិច្ច និងជនអសកម្មសេដ្ឋកិច្ច។ អ្នកមានការងារធ្វើសំដៅអ្នកដែលបានធ្វើការងារចាប់ពី៦ ខែ ឡើង ហើយផ្ទុយទៅវិញបើអ្នកធ្វើការងារតិចជាងនេះ និងកំពុងរកការងារធ្វើត្រូវបានចាត់ទុកអ្នកគ្មានការងារធ្វើ។ ជនសកម្មសេដ្ឋកិច្ច គឺជាចំនួនសរុបនៃជនមានការងារធ្វើ និងជនអត់ការងារធ្វើ ខណៈដែលជនអសកម្មសេដ្ឋកិច្ចគឺរាប់បញ្ចូលអ្នកធ្វើការជាមេផ្ទះ សិស្ស និសិត្ស អ្នកនៅក្នុងបន្ទុក អ្នកទទួលប្រាក់ចំណូលផ្សេងៗជាដើម។

### ខ១. អ្នកមានការងារធ្វើ

ជនមានការងារធ្វើ ត្រូវបានកំណត់ចំពោះជនទាំងឡាយណា ដែលបានធ្វើការងារចាប់ពី ៦ខែឡើងទៅនៅក្នុងវិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម។ រូបភាព ២.១៨ បង្ហាញអំពីចំនួនប្រជាជនដែលមានការងារធ្វើតាមរាជធានីខេត្ត និងទូទាំងប្រទេសនៅឆ្នាំ ១៩៩៨ ២០០៨ និងឆ្នាំ ២០១៩ ។

ក្រាហ្វិក ១៣. បង្ហាញអំពីភាគរយនៃអ្នកមានការងារធ្វើនៅតាមបណ្ដាខេត្តស្ថិតក្នុងតំបន់ឆ្នេរសមុទ្ររួមមាន ខេត្តកំពត កែប ព្រះសីហនុ និងខេត្តកោះកុង។ នៅឆ្នាំ ១៩៩៨ ភាគរយអ្នកមានការងារធ្វើខ្ពស់គឺខេត្តកំពតមាន ៥០,៤% និងទាបជាងគេគឺខេត្តព្រះសីហនុមាន ៤១,៨% ខណៈឆ្នាំ២០០៨ ខេត្តដែលមានភាគរយខ្ពស់គឺខេត្តកំពត និងខេត្តមានភាគរយទាបគឺខេត្តព្រះសីហនុដដែល និងឆ្នាំ២០១៩ មាននិន្នាការប្រហាក់ប្រហែលនេះដែរ។

**ក្រាហ្វិក ១៣. ភាគរយអ្នកមានការងារធ្វើតាមបណ្ដាខេត្តនៅក្នុងតំបន់ឆ្នេរសមុទ្រ**




**តារាង ៤. ចំនួនអ្នកមានការងារធ្វើបណ្ដាខេត្តស្ថិតក្នុងតំបន់ឆ្នេរសមុទ្រ**

| ខេត្ត | ចំនួនអ្នកមានការងារធ្វើ | | |
|---|---|---|---|
| | **1998** | **2008** | **2019** |
| កំពត | 230,411 | 308,490 | 344,190 |
| កោះកុង | 44,755 | 53,325 | 65,792 |
| ព្រះសីហនុ | 62,239 | 101,739 | 173,989 |
| កែប | 12,136 | 18,673 | 22,892 |
| **កម្ពុជា** | **4,845,762** | **6,935,246** | **8,626,777** |

*ប្រភព៖ ទិន្នន័យឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩*

## ១២. អ្នកគ្មានការងារធ្វើ

ជនគ្មានការងារធ្វើ ត្រូវបានកំណត់ជនទាំងឡាយណាដែលគ្មានការងារធ្វើហើយកំពុងរកការងារធ្វើ និងជនខ្លះមានការងារធ្វើខ្លះតែមិនគ្រប់៦ខែហើយកំពុងរកការងារធ្វើ។ ក្រាហ្វិក ១៤ បង្ហាញអំពីអ្នកគ្មានការងារធ្វើតាមបណ្ដាខេត្តនៅក្នុងតំបន់ឆ្នេរ។ នៅឆ្នាំ ១៩៩៨ អត្រាអ្នកគ្មានការងារធ្វើខ្ពស់ជាងគេគឺខេត្តកោះកុង (៤,៧%) និងទាបជាងគេគឺខេត្តកែប (១,០%)។ នៅឆ្នាំ ២០០៨ អត្រាអ្នកគ្មានការងារធ្វើមានអត្រាខ្ពស់ជាងគេគឺខេត្តកោះកុង (១,៦%) និង ទាបជាងគេគឺខេត្តកែប (០,២%) និន្នាការដូចឆ្នាំ ១៩៩៨ ដែរ។ នៅឆ្នាំ ២០១៩ អត្រាអ្នកគ្មានការងារធ្វើខ្ពស់ជាងគេគឺខេត្តព្រះសីហនុ (៤,៥%) និង ខេត្តកោះកុង (០,៥%) មានអត្រាទាបជាងគេ ។

**ក្រាហ្វិក ១៤. ភាគរយអ្នកគ្មានការងារធ្វើតាមបណ្ដាខេត្តនៅក្នុងតំបន់ឆ្នេរ**




*ប្រភព៖ ទិន្នន័យឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩*

**តារាង ៥. ចំនួនអ្នកគ្មានការងារធ្វើបណ្ដាខេត្តស្ថិតក្នុងតំបន់ឆ្នេរសមុទ្រ**

| ខេត្ត | 1998 | 2008 | 2019 |
|---|---|---|---|
| ព្រះសីហនុ | 5,571 | 2,209 | 13,059 |
| កោះកុង | 4,711 | 1,719 | 545 |
| កែប | 252 | 74 | 522 |
| កំពត | 8,861 | 4,288 | 5,360 |
| **កម្ពុជា** | **273,183** | **118,152** | **122,810** |

## ១៣. សកម្មសេដ្ឋកិច្ច និងអសកម្មសេដ្ឋកិច្ច

ជនសកម្មសេដ្ឋកិច្ច គឺត្រូវបានកំណត់សម្រាប់អ្នកដែលមានការធ្វើ និងអ្នកគ្មានការងារធ្វើ ដែលបានពន្យល់ខាងលើ។ ជនអសកម្មសេដ្ឋកិច្ចត្រូវបានកំណត់ជនសកម្មសេដ្ឋកិច្ចដែលរួមមាន អ្នកធ្វើការងារផ្ទះ សិស្ស និសិត្ស អ្នកនៅក្នុងបន្ទុក អ្នករស់នៅដោយទទួលប្រាក់ចំណូលពីការជួលអចលនៈទ្រព្យ និងផ្សេងៗ។

ក្រាហ្វិក ១៥ បានបង្ហាញថា នៅទូទាំងប្រទេសនៅឆ្នាំ ១៩៩៨ ភាគរយជនសកម្មសេដ្ឋកិច្ចមាន ៥១% បានកើនឡើង ៥៩% នៅឆ្នាំ ២០០៨ និងបានបន្តកើនឡើងដល់៦២% ខណៈដែលជនអសកម្មសេដ្ឋកិច្ច នៅឆ្នាំ ១៩៩៨ មាន៤៩%នៅឆ្នាំ២០០៨ បានធ្លាក់ចុះមក ៤១% និងបន្តធ្លាក់ចុះ ៣៨% នៅឆ្នាំ២០១៩។

**ក្រាហ្វិក ១៥. ភាគរយជនសកម្មសេដ្ឋកិច្ច និងអសកម្មសេដ្ឋកិច្ចនៅទូទាំងប្រទេស**




*ប្រភព៖ ទិន្នន័យឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩*

### តារាង ៦. ចំនួនជនសកម្មសេដ្ឋកិច្ច និងអសកម្មសេដ្ឋកិច្ចបណ្ដាខេត្តស្ថិតក្នុងតំបន់ឆ្នេរសមុទ្រ

| ខេត្ត | ជនសកម្មសេដ្ឋកិច្ច | | | ជនអសកម្មសេដ្ឋកិច្ច | | |
|---|---|---|---|---|---|---|
| | 1998 | 2008 | 2019 | 1998 | 2008 | 2019 |
| ព្រះសីហនុ | 67,810 | 103,948 | 187,048 | 80,998 | 96,072 | 100,075 |
| កោះកុង | 49,466 | 55,044 | 66,337 | 50,340 | 49,414 | 47,971 |
| កែប | 12,388 | 18,747 | 23,414 | 12,350 | 13,203 | 15,060 |
| កំពត | 239,272 | 312,778 | 349,550 | 218,134 | 213,887 | 189,325 |
| **កម្ពុជា** | **5,118,945** | **7,053,398** | **8,749,587** | **4,851,919** | **4,969,669** | **5,352,465** |

ក្រាហ្វិក ១៦ បានបង្ហាញថាភាគរយជនសកម្មសេដ្ឋកិច្ច នៅក្នុងខេត្តកែប នៅក្នុងឆ្នាំ ១៩៩៨ មានចំនួន ៥០% បានកើនឡើងដល់ ៥៩% នៅឆ្នាំ២០០៨ ហើយបានបន្តកើនឡើងដល់ ៦១ នៅឆ្នាំ ២០១៩ ខណៈដែលជនអសកម្មសកម្មសេដ្ឋកិច្ចមាននិន្នាការថយចុះពី ៥០%%នៅឆ្នាំ ១៩៩៨ មក ៣៩%នៅឆ្នាំ២០១៩។

### ក្រាហ្វិក ១៦ ភាគរយជនសកម្មសេដ្ឋកិច្ច និងអសកម្មសេដ្ឋកិច្ចខេត្តកែប




*ប្រភព៖ ទិន្នន័យឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩*

ក្រាហ្វិក ១៧ បានបង្ហាញថាភាគរយជនសកម្មសេដ្ឋកិច្ចជនសកម្មសេដ្ឋកិច្ចនៅឆ្នាំ១៩៩៨ មានចំនួន ៥២% បានកើនដល់ ៥៩% នៅឆ្នាំ២០០៨ និងបន្តកើនឡើងដល់ ៦៥% នៅឆ្នាំ២០១៩ ខណៈដែលភាគរយជនអសកម្មសេដ្ឋកិច្ចនៅឆ្នាំ ១៩៩៨ មាន ៤៨% បានធ្លាក់ចុះមកត្រឹម៣៥% នៅឆ្នាំ២០១៩។

**ក្រាហ្វិក ១៧. ភាគរយជនសកម្មសេដ្ឋកិច្ច និងអសកម្មសេដ្ឋកិច្ចខេត្តកំពត**




*ប្រភព៖ ទិន្នន័យឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩*

## ខ៤.ការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យសេដ្ឋកិច្ច

ក្រាហ្វិក ១៨ បង្ហាញអំពីការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យសេដ្ឋកិច្ចនៅ។ និន្នាការជារួមការចូលរួមក្នុងវិស័យកិសិកម្មនៅទូទាំងប្រទេសមានចំនួន៧៧,២% នៅឆ្នាំ១៩៩៨ បានធ្លាក់មកត្រឹម ៥៤%នៅឆ្នាំ២០១៩ ខណៈដែលការចូលរួមកម្លាំងពលកម្មក្នុងវិស័យឧស្សាហកម្ម មានការកើនឡើងពី៤,៤% នៅឆ្នាំ១៩៩៨ បានកើនដល់ ១៨,៨% និងវិស័យសេវាកម្មបានកើនឡើងពី១៨,៤% នៅឆ្នាំ ១៩៩៨ ទៅ ២៦,៥% នៅឆ្នាំ២០១៩។ ខេត្តកំពតការចូលរួមកម្លាំងពលកម្មក្នុងវិស័យកសិកម្មបានធ្លាក់ចុះពី ៨៧,៥% មកត្រឹម ៧២,៦% ពីឆ្នាំ១៩៩៨ ទៅឆ្នាំ២០១៩ និងការចូលរួមកម្លាំងពលកម្មក្នុងវិស័យឧស្សាហកម្មបានកើនពី ១,៨% ទៅ ២,៧% និងការចូលរួមវិស័យសេវាកម្មក៏បានកើឡើងពី ១០,៧% ទៅ ១៦,២% ពីឆ្នាំ១៩៩៨ ទៅ ឆ្នាំ២០១៩។ ចំណែកខេត្តកែប ការចូលរួមកម្លាំងពលកម្មក្នុងវិស័យកសិកម្មបានធ្លាក់ចុះពី ៨២,០% មកត្រឹម ៥០,៩% ពីឆ្នាំ១៩៩៨ ទៅឆ្នាំ២០១៩ និងការចូលរួមកម្លាំងពលកម្មក្នុងវិស័យឧស្សាហកម្មបានកើនពី២,២៨% ទៅ៤,៥% និងការចូលរួមវិស័យសេវាកម្ម ក៏បានកើឡើងពី ១៥,៨% ទៅ ៣៤,៤% ពីឆ្នាំ១៩៩៨ ទៅឆ្នាំ២០១៩។

## ក្រាហ្វិក ១៨. ភាគរយការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យសេដ្ឋកិច្ច




*ប្រភព៖ ទិន្នន័យឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩*

## តារាង ៧. ចំនួនអ្នកចូលរួមកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ច

| ខេត្ត | ចំនួនអ្នកចូលរួមកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ច | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | កសិកម្ម | | | ឧស្សាហកម្ម | | | សេវាកម្ម | | |
| | 1998 | 2008 | 2019 | 1998 | 2008 | 2019 | 1998 | 2008 | 2019 |
| ព្រះសីហនុ | 33,072 | 48,208 | 51,424 | 7,687 | 15,214 | 50,654 | 23,013 | 38,861 | 80,862 |
| កោះកុង | 22,896 | 34,090 | 29,883 | 3,355 | 3,671 | 15,303 | 19,074 | 15,801 | 20,763 |
| កែប | 9,970 | 14,772 | 11,706 | 271 | 834 | 3,358 | 1,918 | 3,108 | 7,916 |
| កំពត | 202,504 | 266,013 | 251,103 | 4,116 | 8,348 | 38,809 | 24,835 | 34,732 | 55,932 |
| **កម្ពុជា** | **7,541,964** | **5,028,963** | **4,731,989** | **432,496** | **597,020** | **1,629,876** | **1,794,916** | **1,335,031** | **2,296,927** |

### ២.១.២ ទីប្រជុំជន គ្រួសារ អគារ និងលំនៅដ្ឋាន






## គ. ទីប្រជុំជន

### គ១. និន្នាការប្រជាជនពិភពលោកដែលរស់នៅទីប្រជុំជន

តំបន់ទីប្រជុំជន ការបង្កើតបានជាតំបន់ទីប្រជុំជនមួយដោយការប្រមូលផ្តុំទីប្រជុំជនតូចៗ ដែលមានទីតាំងជាប់គ្នា គឺសំដៅលើលំនៅដ្ឋានដែលមានប្រជាជនរស់នៅ និងមានដង់ស៊ីតេប្រជាជនខ្ពស់ និងមានការកសាងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។ តំបន់ទីប្រជុំជនត្រូវបានបង្កើតតាមរយៈការធ្វើនគរូបនីយកម្ម និងត្រូវបានចាត់តាមចំណាត់ថ្នាក់មានដូចជាទីក្រុង ទីប្រជុំជន និងតំបន់ជាយក្រុង។ ការកំណត់និយមន័យនៃតំបន់ទីប្រជុំជនក៏ត្រូវបានកំណត់និយមន័យខុសៗគ្នា ទៅតាមស្ថានភាពប្រជាសាស្ត្រ និងលក្ខណៈសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ។ ចំនួនប្រជាជនជាង ៤,៤ពាន់លាននាក់ ដែលកំពុងរស់នៅក្នុងតំបន់ទីប្រជុំជន ស្មើនឹង ៥៦,៥៨% [1] ក្នុងឆ្នាំ២០២១។ ក្រាហ្វិក ១៩ បង្ហាញអំពីនិន្នាការចំនួនប្រជាជនសរុប និងចំនួនប្រជាជនរស់នៅទីប្រជុំជនទូទាំងពិភពលោក ពីឆ្នាំ២០០០ ដល់ ២០៣៥។ តាមនិន្នាការនេះ បានបង្ហាញថា ចំនួនប្រជាជនដែលរស់នៅទីប្រជុំជននឹងកើនឡើងពី ៣ ពាន់លាននាក់ នៅឆ្នាំ២០០០ កើនដល់ជាង៥ ពាន់លាននាក់ ស្មើនឹង ៦៣% នៃចំនួនប្រជាជនសរុបទូទាំងពិភពលោក នៅឆ្នាំ២០៣៥ ខាងមុខ។

**ក្រាហ្វិក១៩. និន្នាការចំនួនប្រជាជនសរុប និងចំនួនប្រជាជនរស់នៅទីប្រជុំជនទូទាំងពិភពលោក(គិតជាពាន់នាក់)**




ប្រភព÷ United Nations, Department of Economic and Social Affairs, Population Division (2022*). World Population Prospects 2022*, Online Edition

[1] © 2010-2022 Macrotrends LLC*, World Urban Population 1960-2022* , [website], 2022, https://www.macrotrends.net/countries/WLD/world/urban-population, (accessed 12 January 2022).

## ក២. និន្នាការប្រជាជនកម្ពុជាដែលរស់នៅទីប្រជុំជន

ការកើនឡើងនូវនគរូបនីយកម្ម នៅលើពិភពលោកបានធ្វើឲ្យមានការយកចិត្តទុកដាក់យ៉ាងខ្លាំងសម្រាប់ពិភពលោកនិងតាមប្រទេសនីមួយៗ ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍។ ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាបានកែសម្រួលតំបន់រដ្ឋបាលញឹកញាប់ចាប់តាំងពីឆ្នាំ១៩៩៨ មកទល់បច្ចុប្បន្ន។ ការកែសម្រួលតំបន់រដ្ឋបាលនេះ ក៏ជាកត្តាមួយដែលធ្វើឲ្យមានការកើនឡើងនូវតំបន់ទីប្រជុំជន ដោយសារតំបន់មួយចំនួនក្លាយជាក្រុង ដែលគោលដៅសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគ្រប់ផ្នែក និងលំនៅដ្ឋានទៀតផង។ ដូច្នេះផ្ទៃដីស្រែមួយចំនួនត្រូវបានបង្វែរមុខងារពីដីកសិកម្មទៅជាដីសម្រាប់ការសាងសង់នៅពេលអនាគត។ កន្លងមកការកំណត់តំបន់ទីប្រជុំជនពុំមាននិយមន័យច្បាស់លាស់នៅឡើយទេ ។ នៅឆ្នាំ១៩៩៨ ទីប្រឹក្សាជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨ បានកំណត់ស្រុកដែលស្ថិតក្នុងទីរួមខេត្តជាទីប្រជុំជន ។ នៅឆ្នាំ២០០៤ ជំនាញការរបស់មូលនិធិអង្គការសហប្រជាជាតិសម្រាប់ប្រជាជននៅឆ្នាំ២០០៤ បានកំណត់និយមន័យទីប្រជុំជនដោយកំណត់យក ៣ លក្ខខណ្ឌគឺ÷

១) ចំនួនប្រជាជនទាបបំផុតចាប់ពី ២.០០០ នាក់ឡើង ក្នុងមួយឃុំ

២) ដង់ស៊ីតេប្រជាជនក្នុងមួយគីឡូម៉ែត្រការ៉េចាប់ពី ២០០នាក់ ឡើង

៣) ភាគរយបុរសធ្វើការក្នុងវិស័យកសិកម្មទាបជាង ៥០ភាគរយ

នៅឆ្នាំ២០១១ និយមន័យលក្ខខណ្ឌទីប្រជុំជនបានកែសម្រួលនៅលក្ខខណ្ឌទី៣ គឺ ភាគរយបុរសធ្វើការក្នុងវិស័យកសិកម្មទាបជាង ៥០ភាគរយ ទៅជាភាគរយប្រជាជនទាំងពីរភេទធ្វើការនៅក្នុងវិស័យកសិកម្មទាបជាង ៥០ភាគរយ ហើយលក្ខខណ្ឌទី១ និង លក្ខខណ្ឌទី២គឺរក្សានៅដដែល។ លក្ខខណ្ឌដែលបានធ្វើបច្ចុប្បន្នភាពនៅឆ្នាំ២០១១ រួមមាន÷

១) ចំនួនប្រជាជនទាបបំផុតចាប់ពី ២.០០០ នាក់ឡើង ក្នុងមួយឃុំ

២) ដង់ស៊ីតេប្រជាជនក្នុងមួយគីឡូម៉ែត្រការ៉េចាប់ពី ២០០នាក់ ឡើង

៣) ភាគរយចំនួនប្រជាជនទាំងពីរភេទធ្វើការក្នុងវិស័យកសិកម្មទាបជាង ៥០ភាគរយ

ក្រាហ្វិក ២០ បង្ហាញថា ភាគរយចំនួនប្រជាជនរស់នៅទីប្រជុំជននៅលើពិភពលោក និងចំនួនប្រជាជនរស់នៅទីប្រជុំជនកម្ពុជា។ ភាគរយចំនួនប្រជាជនរស់នៅតំបន់ទីប្រជុំជននៅទូទាំងពិភពលោកនៅឆ្នាំ២០១៩ មានចំនួន ៥៥,៧% និងភាគរយចំនួនប្រជាជនរស់នៅទីប្រជុំជនមានចំនួន ៣៩,៤%។ បើប្រៀបធៀបភាគរយចំនួនប្រជាជនដែលរស់នៅទីប្រជុំជនទូទាំងពិភពលោក និងភាគរយចំនួនប្រជា

ជនដែលរស់នៅទីប្រជុំជនសម្រាប់ប្រទេសកម្ពុជាគឺ ភាគរយចំនួនប្រជាជនដែលរស់នៅទីប្រជុំជនទូទាំងពិភពលោក មានចំនួនភាគរយខ្ពស់ជាងភាគរយប្រជាជនដែលរស់នៅទីប្រជុំជន របស់កម្ពុជាចំនួនប្រហែល១៦% ក្នុងឆ្នាំដូចគ្នា។ នៅឆ្នាំ ២០៣៥ ភាគរយប្រជាជនរស់នៅទីប្រជាជនសម្រាប់ពិភពលោកនឹងកើនដល់ ៦៣% ខណៈដែលកម្ពុជាអាចកើនដល់ ៤៤%។

**ក្រាហ្វិក ២០. ភាគរយចំនួនប្រជាជនរស់នៅទីប្រជុំជននៅលើពិភពលោក និងចំនួនប្រជាជនរស់នៅទីប្រជុំជនកម្ពុជា**




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨

- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨
- របាយការណ៍ចុងក្រោយ អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣
- របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ២០១៩
- United Nations, Department of Economic and Social Affairs, Population Division (2022). World Population Prospects 2022, Online Edition.
- Population Projection in Cambodia 2020.

នៅក្នុងក្រាហ្វិក ២១. បង្ហាញអំពីភាគរយនៃចំនួនប្រជាជន ដែលរស់នៅតំបន់ទីប្រជុំជន។ និន្នាការជារួមគឺមានការកើនឡើង ជាក់ស្តែងចំនួនប្រជាជនដែលរស់នៅតំបន់ទីប្រជុំជនបានកើនឡើង ពី ១៨,៣ ភាគរយនៅឆ្នាំ១៩៩៨ កើនដល់ ៣៩,៤ ភាគរយ នៅឆ្នាំ២០១៩ សម្រាប់នៅទូទាំងប្រទេសកម្ពុជា។ ខេត្តកំពតបានកើនឡើង៨,៦ ភាគរយនៅឆ្នាំ ១៩៩៨ កើនដល់ ១០,២ភាគរយនៅឆ្នាំ ២០១៩ ខណៈដែលខេត្តកែប បានកើនឡើងចំនួន ១៤,០ ភាគរយ នៅឆ្នាំ ១៩៩៨ កើនដល់ ៧៩,៥ភាគរយ នៅឆ្នាំ២០១៩។ កត្តាសំខាន់ៗនៃការកើនឡើងនៃភាគរយចំនួនប្រជាជនដោយសារកត្តាមួយចំនួនគឺកំណើនប្រជាជន ការអភិវឌ្ឍន៍នគរូបនីយកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងការផ្លាស់ប្តូរតំបន់រដ្ឋបាល។ម្យ៉ាងទៀត ប្រជាជនបានមករស់នៅទីប្រជុំជនដើម្បីស្វែងរកការងារធ្វើ ដែលពួកគាត់គិតថាមានលក្ខណៈល្អប្រសើរជាងកន្លែងជនបទ។

**ក្រាហ្វិក ២១. ភាគរយចំនួនប្រជាជនរស់នៅតំបន់ទីប្រជុំជន**




ប្រភពៈ - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ ២០១៩។

## ខ. គ្រួសារ និងអគារ

សូចនាករចំនួនគ្រួសារ គឺជាសូចនាករមួយមានសារៈសំខាន់ណាស់ទាក់ទងទៅនឹងការផ្តល់សេវាផ្សេងៗដូចជាអគ្គិសនី ទឹកស្អាត បង្គន់អនាម័យ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត។ ចំនួនគ្រួសារសរុបនៅឆ្នាំ ១៩៩៨ មានចំនួន ២,១៦ លានគ្រួសារ ហើយបានកើនឡើងរហូតដល់ ៣,៥៥ លានគ្រួសារ នៅ

ឆ្នាំ២០១៩ សម្រាប់ទូទាំងប្រទេស។ ចំនួនអគារនៅទូទាំងប្រទេស ប្រហែលជាង ២លានអគារ នៅឆ្នាំ១៩៩៨ និងបានកើនឡើងដល់  ៣,៦ លានអគារនៅឆ្នាំ ២០១៩។ ខេត្តកំពតនៅឆ្នាំ ១៩៩៨ មានចំនួនគ្រួសារ ១០៤.៩៩៨ ដែលមានចំនួនអគារប្រមាណ ១០៤.៩៩៣ និងនៅឆ្នាំ ២០១៩ មានអគារប្រហែល ៤១៤.៨១៩ អគារ បើគិតជាចំនួនអគារគិតជាមធ្យមមានប្រមាណ ៩៩ ភាគរយ នៃចំនួនគ្រួសារធៀបនឹងចំនួនគ្រួសារសរុប។ ខេត្តកែបនៅឆ្នាំ១៩៩៨ មានចំនួនគ្រួសារ ៥.៣៦៩ ដែលមានចំនួនអគារប្រមាណ ៥.៣៦៩  និងនៅឆ្នាំ ២០១៩ មានអគារប្រហែល ៩.៣១២អគារ បើគិតជាចំនួនអគារគិតជាមធ្យមមានប្រមាណ ៩៧ ភាគរយធៀបនឹងចំនួនគ្រួសារសរុប ។

**តារាង ៨. ចំនួនគ្រួសារ និង អគារ ខេត្តកំពត កែប និង កម្ពុជា**

| ឆ្នាំ | ចំនួនគ្រួសារ | | | ចំនួនអគារ | | |
|---|---|---|---|---|---|---|
| | កំពត | កែប | កម្ពុជា | កំពត | កែប | កម្ពុជា |
| 1998 | 104,998 | 5,369 | 2,162,086 | 104,993 | 5,369 | 2,188,663 |
| 2008 | 130,084 | 7,236 | 2,817,637 | 127,118 | 6,904 | 2,841,897 |
| 2019 | 143,402 | 9,605 | 3,553,021 | 141,819 | 9,312 | 3,593,943 |

**សំគាល់÷ (1) ចំនួនអគារត្រូវបានរាប់បញ្ចូលគ្រប់ប្រភេទនៃគ្រួសារ (គ្រួសារធម្មតា និងគ្រួសារស្ថាប័ន)**

**(2) ចំនួនគ្រួសារគ្រួសារធម្មតា**

**ក្រាហ្វិក ២២. ចំនួនគ្រួសារ និងអគារ**



## គ. លំនៅដ្ឋាន

តារាង៩. បង្ហាញអំពីចំនួនលំនៅដ្ឋានតាមប្រភេទនៃលំនៅដ្ឋាននៅឆ្នាំ២០២១ ផ្អែកតាមទិន្នន័យមូលដ្ឋាន។ ស្ទូចនាករនេះ ក៏ឆ្លុះបញ្ចាំងអំពីជីវភាពរស់នៅរបស់ប្រជាជននៅក្នុងប្រទេសកម្ពុជា ខេត្តកំពត និងខេត្តកែប។ តារាងខាងក្រោមបង្ហាញថា លំនៅដ្ឋានក្នុងប្រទេសកម្ពុជាមានចំនួនសរុប ៣,៥ លានលំនៅដ្ឋាន ក្នុងចំនួនគ្រួសារ ៣,៧លាននាក់។ លំនៅដ្ឋានដែលចំនួនច្រើនជាងគេ គឺចំនួនលំនៅដ្ឋានដំបូលប្រក់ស័ង្កសីហ្វីប្រូស៊ីម៉ង់មានចំនួន ១,៨ លាន ចំនួនលំនៅដ្ឋានដំបូលប្រក់ក្បឿងមានចំនួន ១,១ លាន ឈរលំដាប់លេខ ២ និងតិចជាងគេគឺ ចំនួនលំនៅដ្ឋានភូមិគ្រឹះ មានចំនួនជាង ១៧ ពាន់លំនៅដ្ឋាន។ ខេត្តកំពតមានចំនួនលំនៅដ្ឋានសរុបជាង ១៥៥ពាន់លំនៅដ្ឋាន ហើយចំនួនលំនៅដ្ឋាន ដំបូលប្រក់ស័ង្កសីហ្វីប្រូស៊ីម៉ង់មានចំនួនជាង៨៥ពាន់លំនៅដ្ឋាន ខណៈដែលចំនួនលំនៅដ្ឋានប្រក់ក្បឿងមានចំនួនជាង ៤៧ ពាន់លំនៅដ្ឋាន លំនៅដ្ឋានថ្មមិនមែនបេតុងមានចំនួនជាង ១៣ពាន់ខ្នង និងភូមិគ្រឹះមានចំនួនជាង២ពាន់ភូមិគ្រឹ។ ខេត្តកែបមានលំនៅដ្ឋានសរុបជាង៩ពាន់លំនៅដ្ឋាន ក្នុងនោះផ្ទះដំបូលប្រក់ស័ង្កសីហ្វីប្រូស៊ីម៉ង់មានចំនួនជាង៥ពាន់ខ្នង ផ្ទះថ្មមិនមែនបេតុង ជិត២ពាន់ខ្នង ផ្ទះដំបូលក្បឿងមានចំនួនជាង ១ពាន់ខ្នង ចំនួនផ្ទះដំបូលប្រក់ស័ង្កសីតិចជាង២០សន្លឹកមានចំនួនជាង២០០ខ្នង ប្រហាក់ប្រហែលនឹងផ្ទះល្វែងផងដែរ ខណៈដែលផ្ទះជាភូមិគ្រឹះមានចំនួន២០។

**តារាង ៩. ចំនួនលំនៅដ្ឋានតាមប្រភេទ**

| ប្រភេទលំនៅដ្ឋាន | កំពត | កែប | កម្ពុជា |
|---|---|---|---|
| ចំនួនផ្ទះដំបូលប្រក់ស្លឹកស្បូវ | 2,632 | 15 | 50,268 |
| ចំនួនផ្ទះដំបូលប្រក់ស័ង្កសីហ្វីប្រូស៊ីម៉ង់ | 85,082 | 5,637 | 1,759,171 |
| ចំនួនផ្ទះដំបូលប្រក់ស័ង្កសីតិចជាង២០សន្លឹក | 4,049 | 231 | 140,856 |
| ចំនួនផ្ទះដំបូលប្រក់ក្បឿង | 47,495 | 1,082 | 1,094,012 |
| ចំនួនផ្ទះថ្មមិនមែនបេតុង | 13,612 | 1,843 | 239,357 |
| ចំនួនផ្ទះថ្មល្វែង | 2,659 | 239 | 204,637 |
| ចំនួនផ្ទះភូមិគ្រឹះ (វីឡា) | 148 | 20 | 17,592 |
| **សរុប** | **155,677** | **9,067** | **3,505,893** |

ប្រភព: ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០២១

ក្រាហ្វិក ២៣. បង្ហាញអំពីចំនួនលំនៅដ្ឋាន និងចំនួនគ្រួសារ ឆ្នាំ២០២១។ ផ្អែកតាមទិន្នន័យមូលដ្ឋានឆ្នាំ២០២១ បានង្ហាញថា ចំនួនគ្រួសារសរុបនៅទូទាំងប្រទេសមានចំនួន ៣.៧លានគ្រួសារ និងចំនួនលំនៅដ្ឋានមានចំនួន ៣.៥លាន លំនៅដ្ឋាន។ បើប្រៀបធៀបចំនួនលំនៅដ្ឋាន និងចំនួនគ្រួសារ គឺមានចំនួន ៩៥% សម្រាប់ទូទាំងប្រទេស ខណៈដែលខេត្តកំពត ចំនួនលំនៅដ្ឋានមានចំនួនជាង១០០% លើសចំនួនគ្រួសារបន្តិចដោយសារលំនៅដ្ឋានមួយចំនួនទើបសាងសង់តែមិនទាន់មានគ្រួសាររស់នៅ និងខេត្តកែបមានចំនួនលំនៅដ្ឋានប្រហែល៩២% បើប្រៀបធៀបជាមួយនឹងចំនួនគ្រួសារសរុប ផ្អែកលើទិន្នន័យមូលដ្ឋានឆ្នាំ ២០២១។

**ក្រាហ្វិក ២៣. ចំនួនលំនៅដ្ឋាន និងចំនួនគ្រួសារសរុប ខេត្តកំពត កែប និងកម្ពុជា**




ប្រភព: ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០២១

ផ្អែកតាមក្រាហ្វិក ២៤. បានបង្ហាញថាភាគរយនៃប្រភេទលំនៅដ្ឋានផ្ទះប្រក់សង្កសី ហ្វីប្រូស៊ីម៉ង់ត៍មានភាគរយខ្ពស់ជាង៥០% សម្រាប់ខេត្តទាំង២ និងទូទាំងប្រទេស ខណៈដែលផ្ទះដំបូលប្រក់ស្លឹកស្បូវមានចំនិន្ទនទាបជាង២%ទាំងទូទាំងប្រទេស និងខេត្តទាំង២។ ទិន្នន័យនេះ បានឆ្លុះបញ្ចាំងពីកម្រិតជីវភាពរស់នៅរបស់ប្រជាជននៅក្នុងកម្រិតមធ្យមនៅឡើយ។

## ក្រាហ្វិក ២៤. ភាគរយតាមប្រភេទលំនៅដ្ឋានខេត្តកំពត កែប និងកម្ពុជា




ប្រភព: ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០២១

## ២.១.៣ បរិស្ថាន ទឹកស្អាត និង បង្គន់អនាម័យ



## ឝ. បរិស្ថាន

ដែលហៅថា បរិស្ថានគឺជាអ្វីៗដែលនៅជុំវិញខ្លួនយើង ដែលយើងមានទំនាក់ទនងដោយផ្ទាល់ ឬដោយប្រយោលជាមួយវា ហើយជីវិតយើងគ្រប់គ្នាទាំងអស់សុទ្ធតែត្រូវការបរិស្ថាន ដោយមិនអាចខ្វះបាន។ បរិស្ថានត្រូវបានបែងចែកជាបីប្រភេទគឺ បរិស្ថានធម្មជាតិ បរិស្ថានសង្គមវប្បធម៌ និងបរិស្ថានមនុស្ស[2]។

**១. បរិស្ថានធម្មជាតិ** (មានជីវិត និងឥតជីវិត) គឺជាអ្វីៗដែលកើតមានឡើងដោយឯកឯង ក្រៅពីសកម្មភាពពលកម្ម ផលិតកម្មរបស់មនុស្សគឺវាកើតឡើងដោយធម្មជាតិខ្លួនឯងផ្ទាល់ ។ ម៉្យាងទៀតគឺរាល់សរីរាង្គដែលកើតឡើងដោយភាវៈធម្មជាតិដែលផ្សំបង្កើតឲ្យមានឡើង តួយ៉ាងធម្មជាតិគ្មានជីវិតមានដូចជា ទឹក ដី ភ្លើង ខ្យល់ ជាដើម។

**២. បរិស្ថានសង្គមវប្បធម៌** (មានជីវិត និងឥតជីវិត) គឺអ្វីៗដេលកើតមានជារូបរាងឡើងដោយផ្ទាល់ដៃ ពលកម្ម ផលិតកម្មប្រកបដោយការប៉ិនប្រសប់ និងការច្នៃប្រឌិតរបស់មនុស្ស ដើម្បីបម្រើសំណូមពរ និងតម្រូវការក្នុងជីវភាពរស់នៅរបស់មនុស្ស ។ ដោយសមិទ្ធផលនៃបរិស្ថានសង្គមវប្បធម៌នេះបានញ៉ាំងឲ្យចាកផុតពីភាពចំណុះធម្មជាតិ និងដកខ្លួនឲ្យផុតពីស្ថានភាពជាសត្វ។ ប៉ុន្តែរាល់សមិទ្ធផលទាំងនេះ មនុស្សបានច្នៃបង្កើតឡើងដោយធ្វើការកែច្នៃធម្មជាតិ បើគ្មានបរិស្ថានធម្មជាតិគឺ មិនអាចមានបរិស្ថានសង្គមវប្បធម៌បានឡើយ។ តួយ៉ាងបរិស្ថានសង្គមវប្បធម៌មានជីវិតដូចជា អគារផ្សេងៗ ផ្លូវថ្នល់ស្ពាន ក្រុង ភូមិ ស្រុក ប្រឡាយទឹកឧបករណ៍ផលិតកម្មជាដើម។ ចំណែកឯបរិស្ថានសង្គមវប្បធម៌ឥតជីវិតគឺ សកម្មភាពសង្គម ស្ថាប័ន ការគ្រប់គ្រងដឹកនាំសង្គម នយោបាយ សេដ្ឋកិច្ច ការអប់រំ សាសនា ប្រវត្តិសាស្ត្រ ការកម្សាន្តជាដើម។

**៣. បរិស្ថានមនុស្ស** (មានជីវិត និងឥតជីវិត) គឺជាមនុស្សទូទៅ ដែលរស់នៅលើភពផែនដីទាំងអស់ ។ បរិស្ថានមនុស្សមានជីវិត : មនុស្សដែលកំពុងតែរស់រានមានជីវិតនៅសព្វថ្ងៃ គឺស្ថិតនៅក្នុងចំណោមភាវៈមានជីវិតទាំងអស់។ បរិស្ថានមនុស្សឥតជីវិតៈ គឺមនុស្សដែលបាត់បង់ជីវិតទៅហើយពោលគឺបុព្វបុរសជំនាន់ដើម និងមនុស្សជំនាន់ក្រោយ ដែលពុំទាន់មនាកំណើតគឺស្ថិតនៅក្នុងភាវៈឥតជីវិត។

មនុស្សគ្រប់រូបយើងត្រូវរួមចំណែកដល់ការកសាង និងការពារបរិស្ថានដើម្បីឲ្យមានការអភិវឌ្ឍ ពីព្រោះបរិស្ថានជាភាវៈសម្រាប់ទ្រទ្រង់ភាវៈគ្មានជីវិត និងមានជីវិតហើយជាប្រភពធនធានធម្មជាតិ ដែលជាប្រភពនៃជីវិតព្រមទាំងវត្ថុធាតុដើម សម្រាប់ធ្វើការកែច្នៃបង្កើតភោគទ្រព្យនានាសម្រាប់បម្រើ

[2] ចំណេះដឹងទូទៅ, *បរិស្ថាន ការអភិវឌ្ឍ* [website],27 September 2018. https://www.khsearch.com/qna/8284. (Accessed 21 August 2023).

តម្រូវការរបស់មនុស្ស។ កន្លងមក បើមនុស្សគ្រាន់តែទាញផលពីធម្មជាតិ ដើម្បីបម្រើនូវតម្រូវការ ដែលចាំបាច់នៃជីវិតប្រចាំថ្ងៃរបស់ខ្លួន។ ដូច្នេះ ធនធានធម្មជាតិក៏ដូចជាបរិស្ថានធម្មជាតិ គឺមិនទទួលរងនូវការវិនាសខូចខាតបាត់បង់តុល្យភាព ឬជះឥទ្ធិពលអាក្រក់ដល់ប្រព័ន្ធអេកូឡូស៊ីនៃភពផែនដីនោះឡើយ។ តែចំពោះមុខ ទោះបីបរិស្ថានធម្មជាតិ ឬភពផែនដីអាចបន្តពូជមនុស្សឲ្យរស់នៅបាន តែបរិស្ថានសព្វថ្ងៃមានការប្រែប្រួលគួរឲ្យព្រួយបារម្ភដូចជា ការកើនឡើងនៃកម្តៅព្រះអាទិត្យ គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត រដូវមិនទៀងទាត់ បណ្តាលឲ្យមានគ្រោះទុរ្ភិក្ស ហើយបញ្ជាក់ថាបរិស្ថាននៃភពផែនដីទទួលរងនូវការខូចខាតដោយសារសកម្មភាពមនុស្ស ។ ដូចនេះយើងត្រូវតែយល់កិច្ចកសាង និងការពារបរិស្ថានជាភារកិច្ចរបស់យើងទាំងអស់គ្នា និងមនុស្សជាតិនៃសកលលោកទាំងមូល ជួយការពារគុណភាពបរិស្ថានស្រឡាញ់ខ្លួន ស្រឡាញ់ជីវិត ហើយបានរៀបចំអនាគតល្អសម្រាប់កូនចៅជំនាន់ក្រោយព្រមទាំងបានស្រឡាញ់មនុស្សជាតិទាំងមូលលើភពផែនដី ។

កត្តាមួយក្នុងចំណោមកត្តាផ្សេងទៀត ដែលបណ្តាលឲ្យមានប៉ះពាល់ដល់បរិស្ថានធ្ងន់ធ្ងរនោះគឺកំណើនប្រជាជន។ នៅក្នុងពិភពលោកយើងនេះ តែងតែមានកំណើនប្រជាជនដូចគ្នា មិនថាប្រទេសជឿនលឿនឬកំពុងអភិវឌ្ឍន៍ឡើយ គ្រាន់តែប្រទេសជឿនលឿនមានកំណើនប្រជាជនទាបជាងប្រទេសកំពុងអភិវឌ្ឍន៍តែប៉ុណ្ណោះ ។ ជាទូទៅ ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ដូចជា នៅទ្វីបអាព្រិចនិងអាស៊ីប្រជាជននៅតែកើនឡើងជានិច្ច ។ កាលណាប្រជាជននៅលើពិភពលោកចេះតែកើនឡើងៗ តម្រូវការអាហារ ទឹក ជម្រក សំលៀកបំពាក់ សេវាកម្មផ្សេងៗ និងការប្រើប្រាស់ធនធានរបស់ផែនដីក៏កាន់តែកើនឡើងដែរ។

## ក១. គ្រួសារដែលពាក់ព័ន្ធនឹងបរិស្ថាន និងសំណល់

### ក១.១ គ្រួសារដែលពាក់ព័ន្ធនឹងបរិស្ថាន

ផ្អែកលើទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានីខេត្តឆ្នាំ២០២១ បានបង្ហាញថា ចំនួនគ្រួសារនៅទូទាំងប្រទេសដែលរស់នៅក្នុងតំបន់ការពារឬអភិរក្សមានចំនួន ៥៤.៧៤១ គ្រួសារ ស្មើនឹង ១,៤ ភាគរយ ធៀបនឹងចំនួនគ្រួសារសរុប ខណៈដែលខេត្តកំពតមានចំនួនតែ ៤ គ្រួសារ ស្មើនឹង ០,០ ភាគរយ និងខេត្តកែបមានចំនួន ០ គ្រួសារ ស្មើនឹង ០,០ភាគរយ ធៀបនឹងចំនួនគ្រួសារសរុបនៅក្នុងខេត្តនីមួយៗ។ ចំនួនគ្រួសារដែលមានសេវាប្រមូលសំរាមតាមផ្ទះ នៅទូទាំងប្រទេសមានចំនួន ៥០៥.៣២៥ គ្រួសារ ស្មើនឹង ១៣,១ភាគរយ ធៀបទៅនឹងគ្រួសារសរុប ហើយខេត្តកំពតមានចំនួនគ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះមានចំនួន ៦.៥៦៩ គ្រួសារ ស្មើនឹង ៤,១ភាគរយ និងខេត្តកែបមានចំនួន ៧៨៩ គ្រួសារ ស្មើនឹង ៨,០ភាគរយ ធៀបទៅនឹងចំនួនគ្រួសារសរុបរបស់ខេត្តនីមួយៗ។ ចំនួនគ្រួសារ ដែលទទួលរងផលប៉ះពាល់ពីការបំពុលបរិស្ថាននៅទូទាំងប្រទេសមានចំនួន ៤១.៦៤៩គ្រួសារ ស្មើនឹង១,១ ភាគរយ ធៀបនឹងគ្រួសារសរុប ខណៈដែលខេត្តកំពតមានចំនួន៨៤៧ ស្មើនឹង ០,១ភាគរយ និងខេត្តកែបមានចំនួន៣២ គ្រួសារ ស្មើនឹង ០,១ភាគរយ ធៀបនឹងចំនួនគ្រួសារសរុបក្នុងខេត្តនីមួយៗ។

**តារាង ១០. ចំនួនគ្រួសារដែលពាក់ព័ន្ធនឹងបរិស្ថានឆ្នាំ២០២១ ខេត្តកំពត និងខេត្តកែប**

| អធិប្បាយ | កំពត | កែប | កម្ពុជា |
|---|---|---|---|
| គ្រួសារដែលរស់នៅក្នុងតំបន់ការពារឬអភិរក្ស | 4 | 0 | 54,741 |
| គ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះ | 6,569 | 789 | 505,325 |
| គ្រួសារដែលទទួលរងផលប៉ះពាល់ពីការបំពុលបរិស្ថាន | 847 | 32 | 41,649 |
| **ចំនួនគ្រួសារសរុប** | **161,298** | **9,898** | **3,816,272** |

ប្រភព: ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០២១

នៅក្នុងក្រាហ្វិក ២៥. បង្ហាញថា គ្រួសារដែលមានសេវាប្រមូលសំរាមតាមផ្ទះមានតែ ១៣,១ ភាគរយប៉ុណ្ណោះដែលទទួលបានសេវានេះ ហើយចំនួនគ្រួសារចំនួន ៨៦,៩ ភាគរយទៀតពុំទាន់បានទទួលសេវាប្រមូលសំរាម ។ នៅក្នុងខេត្តកំពត ចំនួនគ្រួសារដែលទទួលបានសេវាប្រមូលសំរាមមានចំនួន ៤,១ ភាគរយ តិចជាងទូទាំងប្រទេស ដែលមានចំនួន ៩,០% និងខេត្តកែបមានចំនួនគ្រួសារដែលបានទទួលសេវាសំរាមមានចំនួន ៨,០ ភាគរយតិចជាងទូទាំងប្រទេស ៥,១ភាគរយ។

**ក្រាហ្វិក ២៥. ភាគរយគ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះឆ្នាំ២០២១**




ប្រភព: *ទិន្នន័យមូលដ្ឋាន (CDB)* មន្ទីរផែនការរាជធានី ខេត្តឆ្នាំ២០២១

## ក១.២. សំណល់

ប្រទេសកម្ពុជាបានធ្វើការអភិវឌ្ឍន៍លើគ្រប់វិស័យ ដែលធ្វើឱ្យមានកំណើន GDP ក្នុងប្រជាជនម្នាក់បានកើនឡើងពី ២៥៥ ដុល្លារអាមេរិក ទៅ ១.៦៤៨ ដុល្លារអាមេរិក ពីឆ្នាំ១៩៩៨ ទៅ ២០២១។ ទន្ទឹមនឹងកំណើនសេដ្ឋកិច្ចនេះ ចំនួនប្រជាជនក៏មានកំណើនផងដែរ គឺបានកើនឡើងពីចំនួន ៥,៧លាននាក់ នៅឆ្នាំ១៩៦២ ហើយបានកើនឡើងនៅឆ្នាំ១៩៩៨ មានចំនួន ១១,៤លាននាក់ បន្តកើនឡើងនៅឆ្នាំ២០០៨ មានចំនួន១៣,៤លាននាក់ និងនៅឆ្នាំ២០១៩ មានចំនួន ១៥,៣លាននាក់ ហើយបានព្យាការណ៍ឆ្នាំ២០៣៥ អាចកើនឡើងដល់ ១៩,៨ លាននាក់ ដោយផ្អែកលើលទ្ធផលនៃការធ្វើជំរឿនប្រជាជនឆ្នាំ១៩៩២ ១៩៩៨ ២០០៨ ២០១៩ និងការធ្វើចំណោលឆ្នាំ២០២០ (វិទ្យាស្ថានជាតិស្ថិតិ)។ ការកើនឡើងចំនួនប្រជាជននេះ បានធ្វើឱ្យមានការប្រើប្រាស់វត្ថុធាតុដើម និងធនធានធម្មជាតិមានការកើនឡើងផងដែរ ហើយវាបានធ្វើឱ្យមានការកើនឡើងជាគំហុកនៃការបង្កើតសំណល់ រួមមានទាំងសំណល់រឹង និងសំណល់រាវ ដែលទាមទាឱ្យមានការគ្រប់គ្រងឱ្យបានល្អប្រសើរ។

### ក១.២.១ សំណល់រាវ

សំណល់រាវ -ទឹកកខ្វក់ ភាគច្រើនបានបញ្ជូនតាមរយៈបំពង់លូទៅកាន់ស្ថានីយប្រព្រឹត្តិកម្មដោយក្នុងនោះស្ថានីយ៍បូមទឹកចែកចាយសំណល់រាវ-ទឹកកខ្វក់ដែលបានប្រព្រឹត្តិកម្មរួច បានបង្ហូរទៅកាន់ស្រះទៅកាន់ស្រះដាក់ទឹកឱ្យរង។ សំណល់រាវ -ទឹកកខ្វក់ក្នុងបរិមាណគួរឱ្យកត់សម្គាល់នៅតំបន់ជនបទនៃប្រទេសកម្ពុជា ពុំត្រូវបានរាំងខ្ទប់ឱ្យស្ថិតក្នុងប្រព័ន្ធបិទជិតនោះទេ ប៉ុន្តែផ្ទុយទៅវិញទឹកទាំងនោះត្រូវបានបញ្ចេញដោយផ្ទាល់ទៅក្នុងបរិស្ថាន ដោយសារពុំទាន់មានប្រព័ន្ធប្រត្តិកម្មសំណល់រាវ-ទឹកកខ្វក់នៅឡើយ។ស្ថានីយប្រព្រឹត្តិកម្មសំណល់រាវ-ទឹកកខ្វក់មាននៅក្នុងខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តកែប និងខេត្តបាត់ដំបង។ តែទោះយ៉ាងណាក្តី ទីក្រុងកំពុងលូតលាស់នេះបន្តជួបប្រទះបញ្ហាប្រឈមដោយសារសមត្ថភាពរបស់ស្ថានីយទាំងនេះពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ ដើម្បីឆ្លើយតបតាមសេចក្តីត្រូវការនៅឡើយ។

ក្រាហ្វិក ២៦. បង្ហាញអំពីសមត្ថភាពប្រព្រឹត្តិកម្មសំណល់រាវ-ទឹកកខ្វក់ នៅក្នុងខេត្តព្រះសីហនុ ខេត្តសៀមរាប ខេត្តបាត់ដំបង និងខេត្តកែប។ ខេត្តព្រះសីហនុបានកសាងអាងប្រព្រឹត្តិកម្មទឹកកខ្វក់តាំងពីឆ្នាំ២០០៨ ដែលមានសមត្ថភាពសរុបមានចំនួន ៦.៩០០ម³/ថ្ងៃ ហើយបានកើនឡើងសមត្ថភាពប្រព្រឹត្តិកម្មដល់ ២០.០០០ម³/ថ្ងៃ នៅឆ្នាំ២០១៨ ដោយសារមានអនុស្ថានីយចំនួន ៥ កន្លែងបន្ថែមទៀត។ ខេត្តសៀមរាបមានសមត្ថភាពប្រព្រឹត្តិកម្មដំបូងចំនួន ៣.០០០ ម³/ថ្ងៃ បានកើនឡើងដល់ ៨.០០០ ម³/ថ្ងៃ នៅឆ្នាំ២០១៤។ ខេត្តបាត់ដំបងបានកសាងអាងប្រព្រឹត្តិកម្មទឹកកខ្វក់នៅក្នុងឆ្នាំ ១៩៩៤ ដែលមានអាចមានសមត្ថភាពប្រព្រឹត្តិកម្មចំនួន ១.០០០ម³/ថ្ងៃ ប៉ុន្តែបច្ចុប្បន្ននេះបានធ្លាក់ចុះមកត្រឹម ៤៥០ម³/ថ្ងៃ ដោយសារតែការថមថយចុះរបស់ប្រព័ន្ធ។

### ក្រាហ្វិក ២៦. សមត្ថភាពប្រព្រឹត្តិកម្មសំណល់រាវ-ទឹកកខ្វក់




ប្រភព៖ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០២១។

### ក១.២.២ សំណល់រឹង

នៅក្នុងក្រាហ្វិក ២៧ បង្ហាញពីបរិមាណសំណល់រឹងទីប្រជុំជន ដែលចាក់នៅទីលានប្រចាំឆ្នាំពី ២០០៤ ដល់ឆ្នាំ២០១៧(ក្រសួងបរិស្ថាន ២០១៧ច) ។ ជាមួយនឹងកំណើនសន្សឹមៗចាប់ពី ៣១៧.៥៥០ តោន នៅឆ្នាំ ២០០៤ រហូតដល់ប្រមាណជាង ៦៣៥.០០០ តោន ក្នុងឆ្នាំ ២០១១ និងមានសន្ទុះខ្លាំងនៅឆ្នាំ បន្ទាប់គឺប្រមាណជាង ៩៣០.០០០តោន ។ ទិន្នន័យឆ្នាំ២០១៧ បង្ហាញថា សំណល់រឹងដែលបានចាក់នៅទីលានសរុបមានប្រមាណ ១.៤៥៤.៦៥៣ តោន ធៀបនឹងឆ្នាំ២០១៦ គឺកើនឡើង ១៨៨.០៣៣ តោន ស្មើនឹង ១៤,៨ ភាគរយ និងមានកំណើន ៤៦,៩ភាគរយ ធៀបនឹងឆ្នាំ២០១៣។

**ក្រាហ្វិក ២៧. បរិមាណសំរាម សំណល់រឹងទីប្រជុំជន ដែលបានចាក់នៅទីលានប្រចាំឆ្នាំនៅទូទាំងប្រទេស**




ប្រភព៖ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៣* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០១៩។

ក្រាហ្វិក ២៨ បង្ហាញអំពីបរិមាណសំណល់រឹងនៅរាជធានីភ្នំពេញ ដែលបានប្រមូលប្រចាំឆ្នាំគិតជាតោន។ បរិមាណសំណល់រឹង គឺបានបង្ហាញអំពីការកើនឡើងគួរឲ្យកត់សំគាល់ដែលមានចំនួន ២៥០.០០០ តោន/ឆ្នាំ (ឆ្នាំ២០០៤) បានកើនដល់ ៩៥០.០០០ តោន/ឆ្នាំ (២០១៨)។ ជាទូទៅសំណល់សរីរាង្គមានចំនួនច្រើនជាង ៥០% ខណៈដែលសំណល់ផ្លាស្ទិកមានប្រមាណ ២១% ក្រដាសមានប្រមាណ១០% និងក្រៅពីនោះជាប្រភេទសំណល់រឹងផ្សេងៗ ដូចបង្ហាញជូននៅក្នុងក្រាហ្វិក២៩ ផ្នែកខាងក្រោម។

**ក្រាហ្វិក ២៨. បរិមាណសំណល់រឹងនៅរាជធានីភ្នំពេញ (តោន/ឆ្នាំ)**



## ក្រាហ្វិក ២៩. ភាគរយបរិមាណសំណល់រឹងនៅរាជធានីភ្នំពេញឆ្នាំ២០១៥




ប្រភព÷ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០២១។

នៅក្នុងក្រាហ្វិក ៣០ និងតារាង ១១ បង្ហាញអំពីបរិមាណសំណល់រឹងប៉ាន់ប្រមាណនៅឆ្នាំ ២០១៥ នៅទូទាំង ប្រទេសមានចំនួន ៤.០៩០.២០៩ តោន/ឆ្នាំ ដែលក្នុងនោះបរិមាណសំណល់រឹងដែលបានប្រមូលមានចំនួន ២.៥៧១.២៣៥តោន/ឆ្នាំ ស្មើនឹង ៦៣ ភាគរយ ការបោះសំណល់រឹងចោលដោយខុសច្បាប់មានចំនួន ១.១៩៤.៤៥៦ តោន/ឆ្នាំ ស្មើនឹង ២៩ ភាគរយ និង បរិមាណសំណល់ដែលត្រូវកែច្នៃឡើងវិញមានចំនួន ៣២៤.៥១២តោន/ឆ្នាំ ស្មើនឹង ៨ភាគរយ។ តំបន់ឆ្នេរសមុទ្រមានសំរាមប៉ាន់ប្រមាណ ៣៩២.២៩៩ តោន/ឆ្នាំ ដែលក្នុងនោះបរិមាណសំណល់រឹងដែលបានប្រមូលមានចំនួន ២.៥៧១.២៣៥តោន/ឆ្នាំ ស្មើនឹង ៧៩ ភាគរយ ការបោះសំណល់រឹងចោលដោយខុសច្បាប់មានចំនួន ១៩៥.៦៤៤ តោន/ឆ្នាំ ស្មើនឹង ១៥ ភាគរយ និង បរិមាណសំណល់ដែលត្រូវកែច្នៃឡើងវិញមានចំនួន ៨៣.០០៨តោន/ឆ្នាំ ស្មើនឹង ៧ភាគរយ។ ភាគរយនៃការបោះចោលសំរាមនៅក្នុងខេត្តកំពតមានភាគរយខ្ពស់ជាងទូទាំងប្រទេស និងតំបន់ឆ្នេរសមុទ្រ ខណៈខេត្តព្រះសីហនុមានចំនួនតិចជាងគេ។

## ក្រាហ្វិក ៣០. បរិមាណសំណល់រឹងទីក្រុងឆ្នាំ២០១៥




ប្រភព÷ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០២១។

## តារាង ១១. បរិមាណការប្រមូលសំណល់រឹងទីក្រុង ការចោលសំរាមខុសច្បាប់ និងការកែច្នៃឡើងវិញ ឆ្នាំ ២០១៥

| ខេត្ត | បរិមាណសំណល់ ប៉ាន់ស្មាន | បរិមាណសំណល់ ដែលបានប្រមូល | ការបោះសំណល់រឹង ចោលដោយ ខុសច្បាប់ | បរិមាណសំណល់ ដែលបានកែច្នៃ ឡើងវិញ |
|---|---|---|---|---|
| **កម្ពុជា** | **4,090,209** | **2,571,235** | **1,194,456** | **324,512** |
| **តំបន់ឆ្នេរ** | **392,299** | **195,644** | **113,646** | **83,008** |
| កំពត | 304,410 | 120,450 | 105,120 | 78,840 |
| កែប | 13,505 | 9,125 | 2,555 | 1,825 |
| ព្រះសីហនុ | 46,063 | 43,800 | 1,825 | 438 |
| កោះកុង | 28,321 | 22,269 | 4,146 | 1,905 |

ប្រភព÷ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០២១។

ផ្អែកតាមរបាយការណ៍ស្ថានភាពបរិស្ថានលើកទី៣ ឆ្នាំ២០១៩ បាន បង្ហាញថា ការផ្តល់សេវាប្រមូលដឹកជញ្ជូនសំរាម សំណល់រឹងនៅទីប្រជុំជន ក្រុង ស្រុក ភាគច្រើនអនុវត្តដោយអ្នកគ្រប់គ្រងផ្សារ ឬ ភាស៊ីផ្សារដែលមានរហូតដល់ ៥៣ ភាគរយ ហើយការផ្តល់សេវានេះដោយក្រុមហ៊ុនឯកជននៅទីប្រជុំជន ក្រុងមានចំនួនតែ ២០ ភាគរយ ប៉ុណ្ណោះ ។ មូលហេតុមកពីនៅតាមទីប្រជុំជនស្រុក ការចូលរួមបង់ថ្លៃសេវាកម្មដឹកជញ្ជូនសំរាម សំណល់រឹងមានតែអាជីវករលក់ដូរតាមតូបក្នុងផ្សារ និងហាងទំនិញ ឬ ផ្ទះប្រជាពលរដ្ឋជុំវិញផ្សារតែប៉ុណ្ណោះ ហើយដែលក្រុមហ៊ុនពិបាកនឹងទទួលយក (ទំហំការងារមិនសមាមាត្រនឹងចំណាយរបស់ក្រុមហ៊ុន) ហើយយោងតាមក្រាហ្វិក ៣១ បង្ហាញថា ២៤ភាគរយ ទៀតពុំទទួលបានសេវាប្រមូលសំរាម សំណល់រឹង ទីប្រជុំជននៅក្នុងក្រុង សំណល់រឹងទូទាំងប្រទេស។

**ក្រាហ្វិក ៣១. ភាគរយការផ្តល់សេវា ដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន នៅក្រុង ស្រុក ទាំង១៨៥ទូទាំងប្រទេស ឆ្នាំ២០១៧**




ប្រភព៖ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០១៩។

## ក២. តំបន់ការពារ

តំបន់ការពារនៅក្នុងប្រទេសកម្ពុជាចែកជា៤ផ្នែកធំៗគឺ ១) ឧទ្យានជាតិ(National Park) មានផ្ទៃដីសរុប ៧៤២,៣ ពាន់ហិកតាស្មើនឹង ១៣,៨% ២) តំបន់ការពារសត្វព្រៃ (Wildlife Sanctuary) មានផ្ទៃដីចំនួន៤.១៣៧,៦ ពាន់ហិកតា ស្មើនឹង ៧៦,៩% ៣) តំបន់ប្រាសាទ (Protected Land Scape) មានចំនួន ៩៧ ពាន់ហិកតា ស្មើនឹង ១,៨% និងតំបន់គ្រប់គ្រងប្រើប្រាស់ច្រើនយ៉ាង (Multiple Use Management) មានចំនួន ៤០៣,៩ ពាន់ហិកតា ស្មើនឹង ៧,៥%។

**ក្រាហ្វិក ៣២. តំបន់ការពារ**




ប្រភព÷ ក្រសួងបរិស្ថាន

*សំគាល់: សៀវភៅកម្រងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ ២០១៧*វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ បោះពុម្ពខែមករា ឆ្នាំ ២០១៨។

### ក២.១. តំបន់ការពារធម្មជាតិ និងព្រៃការពារ

#### ក២.១.១ តំបន់ការពារធម្មជាតិ

តំបន់ការពារធនធានធម្មជាតិ គឺជាដែនដីសម្បត្តិសាធារណៈរបស់រដ្ឋ រួមមានដែនដីគោក ឬដែនទឹក រួមទាំងឆ្នេរសមុទ្រ និងសមុទ្រ ស្ថិតនៅក្នុងតំបន់ដែលទទួលស្គាល់ដោយបញ្ញត្តិនៃច្បាប់ ឬតំបន់ដែលបង្កើតថ្មីក្នុងដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ដែលធានាបាននូវការការពារប្រភេទសត្វព្រៃ និងរុក្ខជាតិសំខាន់ៗ ក៏ដូចជាសហគមន៍ធម្មជាតិ។ រហូតមកដល់ឆ្នាំ២០២១នេះ កម្ពុជាមានតំបន់ការពារធនធានធម្មជាតិចំនួន ៧៣ ដែលមានផ្ទៃដីសរុប ៧,២៩៧,៣១៤ ហិកតា ស្មើនឹង ៤១% នៃផ្ទៃដី

ប្រទេសកម្ពុជាទាំងមូល។ តំបន់ការពារធនធានធម្មជាតិចំនួន៧៣នេះ គឺស្ថិតនៅក្នុងប្រភេទតំបន់ការពារធំៗចំនួន ៨ រួមមាន៖

**ទី១៖ តំបន់ឧទ្យានជាតិ៖** តំបន់ឧទ្យានជាតិនេះមានចំនួន ១១ តំបន់ផ្សេងៗគ្នា និងមានផ្ទៃដីសរុប ១,៧១៧,៦១៤ ហិកតា រួមមាន ឧទ្យានជាតិកែប ឧទ្យានជាតិព្រះមុនីវង្ស «**បូកគោ** » ឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ «គីរីរម្យ» ឧទ្យានជាតិសីហនុ-រាម ឧទ្យានជាតិបុទុមសាគរ ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ឧទ្យានជាតីវីរជ័យ ឧទ្យានជាតិវើនសៃ-សៀមប៉ាង ឧទ្យានជាតិអូរយ៉ាដាវ ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល និងឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង។ តំបន់ឧទ្យានជាតិទាំងនេះ សម្បូរទៅដោយសត្វព្រៃកម្រជាច្រើនប្រភេទ និងសម្បត្តិទៅដោយព្រៃស្រោង ព្រៃរបោះ និងជាតំបន់ទាក់ទាញភ្ញៀវទេសចរឱ្យចូលទស្សនាបានយ៉ាងច្រើនផងដែរ។

**ទី២៖ តំបន់ដែនជម្រកសត្វព្រៃ៖** តំបន់ដែនជម្រកសត្វព្រៃនេះត្រូវបែងចែកជា ១៩ តំបន់ផ្សេងៗគ្នា និងមានផ្ទៃដីសរុប ៣,៤៣៣,៣៣៦ ហិកតា រួមមាន ដែនជម្រកសត្វព្រៃឱរ៉ាល់ ដែនជម្រកសត្វព្រៃពាមក្រសោប ដែនជម្រកសត្វព្រៃភ្នំសំកុស ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ដែនជម្រកសត្វព្រៃបឹងពែរ ដែនជម្រកសត្វព្រៃលំផាត់ ដែនជម្រកសត្វព្រៃភ្នំព្រេច ដែនជម្រកសត្វព្រៃភ្នំណាមលៀរ ដែនជម្រកសត្វព្រៃព្រៃឡង់ ដែនជម្រកសត្វព្រៃព្រះរកា ដែនជម្រកសត្វព្រៃឆែប ដែនជម្រកសត្វព្រៃតាតៃ ដែនជម្រកសត្វព្រៃកែវសីមា ដែនជម្រកសត្វព្រៃស្រែពក ដែនជម្រកសត្វព្រៃភ្នំត្នោត-ភ្នំពក ដែនជម្រកសត្វព្រៃសង្ឃរុក្ខវ័ន្ត ដែនជម្រកសត្វព្រៃព្រែកប្រសព្វ ដែនជម្រកសត្វព្រៃសំបូរ និងដែនជម្រកសត្វព្រៃសៀមប៉ាង។ តំបន់ដែនជម្រកសត្វព្រៃទាំងនេះសម្បូរទៅដោយប្រភេទសត្វព្រៃជិតផុតពូជ សត្វព្រៃកម្រ សត្វព្រៃរងការគំរាមកំហែង ពពួកមច្ឆាជាតិជិតផុតពូជ និងកម្រ ព្រមទាំងជាជម្រកសត្វព្រៃ និងជីវចម្រុះជាច្រើនប្រភេទ ពិសេសសម្បូរទៅដោយធនធានធម្មជាតិ ព្រៃស្រោង និងព្រៃរបោះជាដើម។

**ទី៣៖ តំបន់ទេសភាព៖** តំបន់ទេសភាពនេះត្រូវបែងចែកជា ១៣ តំបន់ផ្សេងៗគ្នា និងមានផ្ទៃដីសរុប ១៥៣,៦០៤ ហិកតា រួមមាន តំបន់រមណីយដ្ឋានអង្គរ តំបន់បន្ទាយឆ្មារ តំបន់ព្រះវិហារ តំបន់អង្គ្លង់ព្រីង តំបន់ទំនាបខាងជើងទន្លេសាប តំបន់បឹងព្រែកល្ពៅ តំបន់អាងត្រពាំងថ្ម តំបន់ប្រាសាទបាកាន «ព្រះខ័នកំពង់ស្វាយ» តំបន់រនាមដូនសំ តំបន់សំបូរព្រៃគុក តំបន់បឹងលំកុដ តំបន់ភ្នំក្រាំងដីមាស និងតំបន់បឹងយ៉ាកអោម-យ៉ាកការ៉ា។ សម្រាប់តំបន់ទេសភាពនេះ គឺសម្បូរទៅដោយប្រាង្គប្រាសាទបុរាណ សម្បត្តិបេតិកភណ្ឌវប្បធម៌ ព្រៃឈើ និងធនធានធម្មជាតិជាច្រើនទៀត។

**ទី៤៖ តំបន់ប្រើប្រាស់ច្រើនយ៉ាង៖** តំបន់ប្រើប្រាស់ច្រើនយ៉ាងត្រូវបែងចែកជា ៨ តំបន់ផ្សេងៗគ្នា និងមានផ្ទៃដីសរុប ៤១៥,៧៩៦ ហិកតា រួមមាន តំបន់ដងព្រែក តំបន់សំឡូត តំបន់ទន្លេសាប តំបន់ពញាក្រែក តំបន់ព្រែកទឹកសាបក្បាលឆាយ តំបន់ភ្នំនាងកង្រី-ភ្នំទូកមាស តំបន់សសរស្តម្ភសត្វគោ និងតំបន់បឹងយក្ខឡោម។

**ទី៥៖ តំបន់រ៉ាមសារ៖** តំបន់រ៉ាមសារត្រូវបែងចែកជា ៥ តំបន់ និងមានផ្ទៃសរុប ៦០,៩៩៥ ហិកតា រួមមាន តំបន់ស្ទឹងត្រែង តំបន់កោះកាពិ បឹងទន្លេឆ្មារ តំបន់ព្រែកទាល់ និងតំបន់ស្ទឹងសែន។

**ទី៦÷ តំបន់ស្នូលនៃបេតិកភណ្ឌជីវមណ្ឌល÷**តំបន់ស្នូលនៃបថនីយជីវមណ្ឌលនេះត្រូវបែងចែកជា ៣ តំបន់ផ្សេងៗគ្នា និងមានផ្ទៃសរុប ៤២,២៥៧ ហិកតា រួមមាន តំបន់ព្រែកទាល់ តំបន់ស្ទឹងសែន និងតំបន់បឹងទន្លេឆ្មារ។

**ទី៧÷ តំបន់បេតិកភណ្ឌធម្មជាតិ÷** តំបន់បេតិកភណ្ឌធម្មជាតិនេះត្រូវបែងចែកជា ១១ តំបន់ផ្សេងៗគ្នា និងមានផ្ទៃដីសរុប ៣៣,៩៥១ ហិកតា រួមមាន តំបន់ភ្នំត្បែង តំបន់ភ្នំយ៉ាត តំបន់ភ្នំប្រាំពីរ តំបន់ជញ្ជាំងតំបន់គីរីយង់ តំបន់ភ្នំទាក់ទ្រាំង តំបន់ភ្នំព្រះនេត្រព្រះ តំបន់ភ្នំព្រះ-ភ្នំវែង តំបន់ភ្នំយាយសំ តំបន់ភ្នំបាក់ និងតំបន់ភ្នំស្វាយ។

**ទី៨÷ តំបន់ឧទ្យានសមុទ្រ÷** តំបន់ឧទ្យានសមុទ្រនេះមានផ្ទៃដីសរុប ៥២,៤៤៨ ហិកតា គឺតំបន់សមុទ្រកោះរ៉ុង។ ក្រៅពីនេះ ក៏នៅមានតំបន់អភិរក្សទឹកសាបបឹងព្រែកទប់ ដែលមានផ្ទៃដីសរុប ១,៦៣០ ហិកតា និងរបៀងអភិរក្សជីវចម្រុះ ដែលមានផ្ទៃដីសរុប ១៤២,៧៩៤០ ហិកតា។ ការបង្កើតឱ្យមានតំបន់ការពារទាំងអស់នេះ របស់រាជរដ្ឋាភិបាល គឺក្នុងគោលបំណងកែប្រែតំបន់នានាឱ្យក្លាយទៅជាតំបន់បេតិកភណ្ឌធម្មជាតិភ្នំ លើកស្ទួយតម្លៃទៅលើប្រវត្តិសាស្ត្រ វប្បធម៌ ការអភិរក្ស ជីវចម្រុះ លើកស្ទួយជីវភាពប្រជាពលរដ្ឋ និងវិស័យទេសចរណ៍នៅតំបន់ទាំងនោះ។

**តារាង ១២ ចំនួនផ្ទៃដីតំបន់ការពារធម្មជាតិ**

| លរ | ប្រភេទតំបន់ការពារធម្មជាតិ | ផ្ទៃដីគិតជាហិកតា |
|---|---|---|
| 1 | តំបន់ឧទ្យានជាតិ | 1,717,614 |
| 2 | តំបន់ដែនជម្រកសត្វព្រៃ | 3,433,336 |
| 3 | តំបន់ទេសភាព | 153,604 |
| 4 | តំបន់ប្រើប្រាស់ច្រើនយ៉ាង | 415,796 |
| 5 | តំបន់រ៉ាមសា | 60,994 |
| 6 | តំបន់ស្នូលនៃបថនីយជីវមណ្ឌល | 42,257 |
| 7 | តំបន់បេតិកភណ្ឌធម្មជាតិ | 33,951 |
| 8 | តំបន់ឧទ្យានសមុទ្រ | 52,448 |
| | **សរុប** | **5,910,000** |

សំគាល់÷ផ្ទៃដីតំបន់ឧទ្យានសមុទ្រខាងលើមិនបានរាប់បញ្ចូលផ្ទៃដីតំបន់អភិរក្សទឹកសាបបឹងព្រែកទប់ដែលមានផ្ទៃដី ១.៦៣០ហិកតា និងរបៀងអភិរក្សជីវចម្រុះ ដែលមានផ្ទៃដីសរុប ១.៤២៧.៩៤០ ហិកតា ទេ។

ប្រភព÷ ក្រសួងបរិស្ថាន *តំបន់ការពារធម្មជាតិ*[website], 15 March 2021. https:// www.moe.gov.kh/index/29971. (Accessed 23 August 2023).

**ក្រាហ្វិក ៣៣. ភាគរយតាមប្រភេទតំបន់ការពារធម្មជាតិ**




### ក២.១.២ តំបន់ព្រៃការពារ

នៅក្នុងប្រទេសកម្ពុជាមានព្រៃ ៥ ប្រភេទធំៗ ព្រៃជ្រុះស្លឹករួមទាំងព្រៃល្បោះ(១៨,៥%) ព្រៃស្រោង (១៥,៨%) ព្រៃពាក់កណ្ដាលស្រោង (៥,៩%) ព្រៃលិចទឹក (២,៦%) និងព្រៃផ្សេងៗ (៥%) ដែលរាប់បញ្ចូលព្រៃដុះឡើងវិញ និងព្រៃលួតលាស់ឡើងវិញ ព្រៃកោងកាង កៅស៊ូ ចម្ការឈើ ចម្ការដូងប្រេង និងឬស្សី ខណៈដែល តំបន់មិនមានព្រៃមានប្រមាណ ៥២%។ នៅចន្លោះឆ្នាំ២០០៦ ដល់ ២០១៨ ប្រទេសកម្ពុជាបាត់បង់ព្រៃឈើចំនួន ២,៧ លានហិកតា នៅក្នុងគ្រប់តំបន់អេកូឡូស៊ីទាំងអស់។ តំបន់មេគង្គខាងកើត និងតំបន់ទំនាបកណ្ដាលបាត់បង់ព្រៃឈើក្នុងផ្ទៃដីធំជាងគេបំផុតចំនួន ៧៦០ ០០០ ហិកតា នៅក្នុងមួយតំបន់ ចំណែកឯគម្របព្រៃឈើក្នុងតំបន់ប្រជុំភ្នំក្រវាញ ហាក់បីនៅមានចំនួនថេរ (ក្រសួងបរិស្ថាន ឆ្នាំ២០១៨)។

### ក្រាហ្វិក ៣៤. ប្រភេទព្រៃឈើ




ប្រភព÷ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ២០២១។

## ក២.១.៣ គម្របព្រៃឈើ

ប្រទេសកម្ពុជា គឺជាប្រទេសមួយ ដែលរក្សាបានគម្របព្រៃឈើមានចំនួនខ្ពស់ជាងគេបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍យើងនេះ ។ តែទោះបីយ៉ាងណាក៏ដោយ និន្នាការនៃការប្រែប្រួលគម្របព្រៃឈើពីឆ្នាំ ១៩៦៥ មានចំនួនប្រហែល ៧៣% បានថយចុះមកត្រឹម ៤៧% នៅឆ្នាំ២០១៨ ។

### ក្រាហ្វិក ៣៥. ការប្រែប្រួលគម្របព្រៃឈើ




សំគាល់÷ ព្រៃឈើទូទាំងប្រទេសរួមបញ្ចូលចម្ការកៅស៊ូ និងចម្ការដូងប្រេង។

ប្រភព÷ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០២១។

## ក២.១.៤ តំបន់វាលភក់ និងលក្ខណៈពិសេស

តំបន់វាលភក់មាននៅតាមដងទន្លេដូចជាទន្លេមេគង្គ ទន្លេស្រែពក ទន្លេសេកុង និងតំបន់ដែលមានបឹងធំៗ ជាដើម ដែលមានចំនួន ១៧ គឺ បឹងព្រីង ប្រព័ន្ធទន្លេក្រចេះ ប្រព័ន្ធទន្លេស្រែពក ប្រព័ន្ធទន្លេសេសាន ព្រៃលិចទឹក ទន្លេមេគង្គស្ទឹងត្រែង ប្រព័ន្ធទន្លេមេគង្គពាមជីលាំង បឹងប្រាសាទទុយោ បឹងវាលសំណប់ បឹងប្រាំង បឹងចាំងរុង ប្រព័ន្ធសុងសែនខាងលើ ភូមិមុតពាម បឹងវាលដំរី ស្ទឹងសែនទាប បឹងឆ្មា និង បឹងវាលពក ។

**ក្រាហ្វិក ៣៦. តំបន់វាលភក់ គិតជាហិកតា**




ប្រភព÷ ក្រសួងបរិស្ថាន

*សំគាល់: សៀវភៅកម្រងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ ២០១៧* វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ បោះពុម្ពខែមករា ឆ្នាំ ២០១៨។

## ខ. ទឹកស្អាត និងទឹកកខ្វក់






ទឹកបានដើរតួនាទីយ៉ាងសំខាន់ជាគ្រឹះសម្រាប់ការអភិវឌ្ឍនានានៃប្រទេសមួយ។ ប្រទេសកម្ពុជាពិតជាមានចំណងជាក់លាក់ខ្លាំងទៅនឹងអ្វីដែលត្រូវបានហៅ មាសខៀវ ដូចដែលវាត្រូវបានគេចាត់ទុកថា ជាប្រទេសមួយ ដែលអំណោយទានដ៏ពិសិដ្ឋ ជាពិសេសធនធានទឹក។ ភ្នំគូលែននៃអតីតចក្រភពខ្មែរមានភាពល្បីល្បាញដោយសារទឹកដ៏ពិសិដ្ឋ ហើយរាជធានីអង្គរវត្ត ក៏បានបង្ហាញពីប្រព័ន្ធធារាសាស្ត្រដ៏ទំនើបបំផុតនៃសម័យនោះផងដែរ។ ប្រជាជនកម្ពុជា ពឹងផ្អែកយ៉ាងខ្លាំងទៅលើទឹកសាបជាជាងតំបន់ឆ្នេរសមុទ្រ ជាពិសេសជលផលទឹកសាប សម្រាប់ទ្រទ្រង់ដល់ជីវភាពរស់នៅ និងសម្រាប់ជាប្រភពប្រូតេអ៊ីនចម្បងរបស់ពួកគេ។ ប្រទេសកម្ពុជាទទួលរងនូវអាកាសធាតុត្រូពិច ដែលនាំឱ្យមានការឆ្លាស់គ្នានៃរដូវខ្វះទឹក និងរដូវទឹកច្រើនហួស។ ប្រភពទឹកសាបសំខាន់ៗរបស់ប្រទេសកម្ពុជាមានដូចជាទន្លេមេគង្គ ទន្លេស្រែពក ទន្លេសេកុង ទន្លេសាប ទន្លេបាសាក់ ស្ទឹង ព្រែក ទឹកបឹង ទឹកត្រពាំង ទឹកចេញពីក្រោមដី និងទឹកភ្លៀងជាដើម។ ទន្លេមេគង្គ និងទន្លេសាបមានសារៈសំខាន់សម្រាប់ប្រព័ន្ធជលសាស្ត្រកម្ពុជា ហើយវាជាប្រភពដ៏សំខាន់សម្រាប់ការផ្គត់ផ្គង់ប្រូតេអ៊ីននៅកម្ពុជា ។ ទោះបីជាយ៉ាងណាក៏ដោយ វាត្រូវបានផ្លាស់ប្តូរ ខណៈពេលដែលចំនួនប្រជាជនកំពុងតែកើនឡើង ហើយតម្រូវការទឹកកំពុងកើនឡើងជាមួយនឹងកង្វះការការពារ ដែលប្រកបដោយប្រសិទ្ធភាព។ កំណើនសេដ្ឋកិច្ចបាននាំឱ្យមានតម្រូវការទឹកខ្លាំងសម្រាប់វិស័យឧស្សាហកម្ម និងកសិកម្ម ដែលធ្វើឱ្យមានការប្រកួតប្រជែងរវាងវិស័យទាំងនេះជាមួយនឹងវិស័យផ្សេងទៀត ហើយវាកំពុងតែធ្វើឱ្យមានការប៉ះពាល់ទាំងបរិមាណ និងគុណភាពទឹក។

គោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាពទី ៦ មានចំណុចដៅចំនួន ៨ និងសូចនាករចំនួន ១១ ដែលនឹងត្រូវប្រើ ដើម្បីជម្រុញសកម្មភាពឆ្ពោះទៅរកការទទួលបានជាសកលនូវការគ្រប់គ្រងទឹកស្អាត និង អនាម័យដោយសុវត្ថិភាព និងការគ្រប់គ្រងធនធានទឹកសមស្រប។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៦ ទទួលស្គាល់ការគ្រប់គ្រងទឹកប្រកបដោយចីរភាព សំដៅលើការផ្គត់ផ្គង់ទឹកស្អាត (ចំណុចដៅ ៦.១) និង អនាម័យ (ចំណុចដៅ ៦.២) ដែលជាសិទ្ធិមនុស្សជាមូលដ្ឋាន។ គោលដៅនេះ ក៏ផ្តោតលើបញ្ហាដូចជា គុណភាពទឹក និងការគ្រប់គ្រងសំណល់រាវ (ចំណុចដៅ ៦.៣) កង្វះខាតទឹក និងការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាព (ចំណុចដៅ ៦.៤) ការគ្រប់គ្រងធនធានទឹក (ចំណុចដៅ ៦.៥) និងការការពារ និងការស្តារប្រព័ន្ធអេកូឡូស៊ីទាក់ទងនឹងទឹក (ចំណុចដៅ ៦.៦)។

## ២១.ទឹកស្អាត

### ២១.១ ទីតាំងប្រភពទឹក

ក្រាហ្វិក ៣៧ បានបង្ហាញថាភាគរយគ្រួសារដែលមានទីតាំងប្រភពទឹកសម្រាប់ទទួលទាននៅក្នុងបរិវេណលំនៅដ្ឋានសម្រាប់នៅទូទាំងប្រទេសនៅឆ្នាំ ២០០៨ មានចំនួនគ្រួសារ ៣៦ ភាគរយ និងបានកើនដល់ ៦៤ភាគរយ នៅឆ្នាំ ២០១៩ ហើយខេត្តកំពតនៅឆ្នាំ ២០០៨ មានចំនួនគ្រួសារ ២២ ភាគរយ បានកើនដល់ ៥១ភាគរយ នៅឆ្នាំ ២០១៩ និង ខេត្តកែបនៅឆ្នាំ ២០០៨ មានចំនួនគ្រួសារ ១៥ភាគរយ បានកើនដល់ ៣៦ភាគរយ នៅឆ្នាំ ២០១៩។ ចំពោះភាគរយទីតាំងប្រភពទឹកដែលមានចម្ងាយទៅយកទឹកតិចជាង៣០នាទី នៅទូទាំងប្រទេសនៅឆ្នាំ២០០៨ មានចំនួន ៣២ភាគរយ បានធ្លាក់ចុះមក ២៤ភាគរយនៅឆ្នាំ ២០១៩ ខណៈដែលខេត្តកំពតនៅឆ្នាំ២០០៨ មាន៣២ភាគរយ បានកើនឡើង ៣៦ភាគរយនៅឆ្នាំ ២០១៩ និងខេត្តកែបមានចំនួន ៣១ភាគរយ បានកើនឡើងដល់៥៤ភាគរយនៅឆ្នាំ ២០១៩។ លទ្ធផលជារួមទាំងកម្ពុជា ខេត្តកំពត និងខេត្តកែបភាគរយចម្ងាយនៃទីតាំងពីប្រភពទឹកដែលចំណាយពេលច្រើនជាង ៣០នាទី មានការធ្លាក់ចុះពីឆ្នាំ ២០០៨ ទៅឆ្នាំ ២០១៩ នៅសល់ប្រហែល ១១ភាគរយប៉ុណ្ណោះ។

**ក្រាហ្វិក ៣៧. ភាគរយគ្រួសារ តាមទីតាំងប្រភពទឹកទទួលទាន ឆ្នាំ២០១៩**




សំគាល់៖ ទិន្នន័យចម្ងាយច្រើនជាង៣០នាទី បានបូកបញ្ចូលទិន្នន័យមិនដឹងសម្រាប់ឆ្នាំ ២០១៩

ប្រភព៖ លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩

## ១១.២. ការប្រើប្រាស់ទឹកស្អាត

ក្រាហ្វិក ៣៨ បង្ហាញអំពីភាគរយគ្រួសារមានទឹកស្អាតប្រើប្រាស់។ នៅក្នុងប្រទេសកម្ពុជាភាគរយនៃគ្រួសារ ដែលមានទឹកស្អាតនៅឆ្នាំ១៩៩៨ មានចំនួន ២៩ ភាគរយ ហើយបានកើនឡើងរហូតដល់ ៧៣ ភាគរយនៅឆ្នាំ២០១៩ ផ្អែកតាមទិន្នន័យជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩ ។ នៅក្នុងរវាង១០ឆ្នាំ បើប្រៀបធៀបរវាងឆ្នាំ១៩៩៨ និង ២០០៨ ភាគរយនៃការប្រើប្រាស់ទឹកស្អាតបានកើនឡើងមានចំនួន ១៨ ភាគរយ និងពីឆ្នាំ២០០៨ ដល់ ២០១៩ កើនឡើង ២៦ ភាគរយ ។ ខេត្តកំពតភាគរយនៃគ្រួសារ ដែលមានទឹកស្អាតនៅឆ្នាំ១៩៩៨ មានចំនួន ១៣ភាគរយ បានកើនឡើងដល់ ៥៣ ភាគរយ នៅឆ្នាំ២០១៩ ខណៈដែលខេត្តកែប នៅឆ្នាំ១៩៩៨ មាន ១២ ភាគរយ បានកើនឡើងដល់ ៥៩ ភាគរយ នៅឆ្នាំ២០១៩។ នៅពេលអនាគត ការថែរក្សាប្រភពទឹកឲ្យបានគង់វង្សសម្រាប់ការផ្គត់ទឹកដល់មនុស្ស សត្វ និងការដាំដំណាំ កសិកម្មផ្សេងៗជាការចាំបាច់បំផុត។

**ក្រាហ្វិក ៣៨. ភាគរយគ្រួសារមានទឹកស្អាតប្រើប្រាស់**




*សំគាល់៖ ទឹកស្អាតសម្រាប់ទទួលទានរួមមានទឹកបំពង់បណ្តាញក្នុងលំនៅដ្ឋាន ទឹកបំពង់បណ្តាញក្នុងទីធ្លា/បរិវេណលំនៅដ្ឋាន ទឹកបំពង់សាធារណៈ អណ្តូងស្នប់/អណ្តូងខួង អណ្តូងជីកមានគម្របការពារ ទឹកភ្លៀង និងទឹកដប/ទឹកពិសារដប។*

ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨

- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩

## ១២.ទឹកកខ្វក់

ផ្អែកតាមរបាយការណ៍ស្ថានភាពបរិស្ថានលើកទី ៣ ឆ្នាំ២០១៩ បង្ហាញថា បរិមាណសំណល់រាវបញ្ចេញចោលនៅរាជធានីភ្នំពេញក្នុងឆ្នាំ២០១៣ មានប្រមាណ១០៨.១៩៨.៧២៥ ម$^{៣}$/ឆ្នាំ គឺមានការកើនឡើងប្រមាណ ១៧.៨៩៨.៥៧៤ ម$^{៣}$/ឆ្នាំ បើប្រៀបធៀបឆ្នាំ ២០១២។ មានន័យថា ឆ្នាំ២០១២ បរិមាណសំណល់រាវដែលបញ្ចេញចោលនៅរាជធានីភ្នំពេញ មាន ៩០.២៩៩.២៣៤ម$^{៣}$/ឆ្នាំ។ បរិមាណបញ្ចេញចោលនេះ មានការកើនឡើងជាប្រចាំពីមួយឆ្នាំទៅមួយឆ្នាំ ។ រូបភាព ៣៩ បង្ហាញពីបរិមាណទឹកកខ្វក់នៅរាជធានីភ្នំពេញ ដែលបានបញ្ចេញចោលនៅក្នុងចន្លោះឆ្នាំ ២០០៦ ដល់២០១៧។

**ក្រាហ្វិក ៣៩. បរិមាណទឹកកខ្វក់បញ្ចេញពីរាជធានីភ្នំពេញ ឆ្នាំ២០០៦ ដល់ ២០១៧**




ប្រភព÷ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៣* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០១៩។

## គ. បង្គន់អនាម័យ

ក្រាហ្វិក ៤០ បង្ហាញអំពីភាគរយចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់សម្រាប់ខេត្តកំពត កែប និងទូទាំងប្រទេស។ នៅក្នុងឆ្នាំ១៩៩៨ ភាគរយគ្រួសារមានបង្គន់អនាម័យប្រើប្រាស់មានចំនួន ១៣ ភាគរយ បានកើនឡើង ៣៤ ភាគរយ នៅឆ្នាំ២០០៨ និងនៅឆ្នាំ២០១៩ កើនឡើងដល់ ៨៤ ភាគរយ សម្រាប់ទូទាំងប្រទេស។ ខេត្តកែប ភាគរយគ្រួសារមានបង្គន់ប្រើប្រាស់មានចំនួន ៣,៣ ភាគរយ នៅឆ្នាំ ១៩៩៨ បានកើនឡើងដល់ ៧៥ភាគរយ នៅឆ្នាំ២០១៩ ខណៈដែលខេត្តកំពត ភាគរយគ្រួសារមានបង្គន់ប្រើប្រាស់នៅឆ្នាំ១៩៩៨ មានចំនួន ៨ ភាគរយ បានកើនឡើងដល់ ៨២ ភាគរយ នៅឆ្នាំ២០១៩ តិចជាងទូទាំងប្រទេស២ភាគរយ។

ក្រាហ្វិក ៤០. ភាគរយចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩

## ២.១.៤ ស្ថានភាពគ្រោះមហន្តរាយ



គ្រោះមហន្តរាយ គឺបានកើតឡើងស្ទើរគ្រប់ប្រទេសទាំងអស់ដែលរស់នៅលើពិភពលោក មិនថាប្រទេសអភិវឌ្ឍន៍ និងប្រទេសមិនទាន់អភិវឌ្ឍន៍ឡើយ។ គ្រោះមហន្តរាយទាំងអស់នោះបានកើតឡើងដោយធម្មជាតិ ជំងឺឆ្លង និងដោយសារសង្គ្រាម។ គ្រោះមហន្តរាយធម្មជាតិមានដូចជា រញ្ជួយដី បន្ទុះភ្នំភ្លើង បាក់ដី ភ្លើងឆេះព្រៃដោយគ្រោះរាំងស្ងួត រលកយក្សស៊ូណាមិ ព្យុះ ទឹកជំនន់។ គ្រោះមហន្តរាយបង្ករដោយសង្គ្រាមបានបន្សល់ទុកនូវគ្រាប់ អាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ បំផ្លាញលំនៅដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធ បង្ករឲ្យប្រជាជនស្លាប់ និងភ័យខ្លាចជាដើម។

## ក. គ្រោះមហន្តរាយធម្មជាតិ

### ក១. សកលលោក

គ្រោះមហន្តរាយធម្មជាតិមានដូចជា រញ្ជួយដី បន្ទុះភ្នំភ្លើង បាក់ដី ភ្លើងឆេះព្រៃដោយគ្រោះរាំងស្ងួត រលកយក្សស៊ូណាមិ ព្យុះ ទឹកជំនន់។ យោងតាមរបាយការណ៍វាយតម្លៃអំពីគ្រោះមហន្តរាយធម្មជាតិសកលឆ្នាំ ២០២១ បានបង្ហាញថាចំនួនករណីគ្រោះមហន្តរាយដែលបានកើតឡើងនៅលើពិភពលោកមានចំនួន ៣៦៧ ដង បានធ្វើឲ្យប៉ះពាល់ដល់ប្រជាជនចំនួន ១០៤.១៦៧.៦០០ នាក់ ប៉ះពាល់ដល់ការខាតបង់នៃសេដ្ឋកិច្ចមានចំនួន ២៥២.១៣៨កោដិដុល្លារ និងបាត់បង់ជីវិតមនុស្សមានចំនួន ១០.៤៩២នាក់។ ព័ត៌មានលំអិតមានបង្ហាញជូននៅក្នុងតារាង ១៣ និងក្រាហ្វិក ២.៤៥ នៅផ្នែកខាងក្រោម។

**តារាង ១៣. ចំនួនដែលបានកើតឡើង និងការបាត់បង់នៃគ្រោះមហន្តរាយធម្មជាតិឆ្នាំ២០២១**

| Type of Disaster | Frequency (time)/% | Deaths (persons)/% | Population affected (ten thousand)/% | Direct economic losses (USD 0.1 billion)/% |
|---|---|---|---|---|
| Flood | 206/56.13 | 4393/41.87 | 2919.81/28.03 | 746.07/29.59 |
| Storm | 82/22.34 | 1876/17.88 | 1761.45/16.91 | 1376.76/54.60 |
| Earthquake | 25/6.81 | 2742/26.13 | 109.13/1.05 | 113.06/4.48 |
| Wildfire | 19/5.18 | 128/1.22 | 71.77/0.69 | 92.54/3.67 |
| Drought | 13/3.54 | 0/0 | 5504.67/52.84 | 121.00/4.80 |
| Landslide | 11/3.00 | 224/2.13 | 0.56/0.01 | 2.50/0.10 |
| Volcanic eruption | 8/2.18 | 85/0.81 | 49.37/0.47 | 13.45/0.53 |
| Extreme temperature | 3/0.82 | 1044/9.95 | 0/0 | 56.00/2.22 |
| **Total** | **367/100** | **10492/100** | **10416.76/100** | **2521.38/100** |

ប្រភព÷ RELIEFWEB, *2021 Global Natural Disaster Assessment Report,* [website], 14 October 2022, https://reliefweb.int/report/world/2021-global-natural-disaster-assessment-report. (Accessed 7 December 2022).

ក្រាហ្វិក ៤១ បង្ហាញអំពីចំនួនដែលបានកើតឡើង និងការបាត់បង់នៃគ្រោះមហន្តរាយធម្មជាតិឆ្នាំ២០២១នៅលើពិភពលោក។ ភាគរយនៃគ្រោះមហន្តរាយទឹកជំនន់មានរហូតដល់ ៥៦%ក្នុងចំណោមគ្រោះមហន្តរាយ ៣៦៧ដង បង្កឱ្យមនុស្សស្លាប់មានរហូត ៤២% ក្នុងចំណោមអ្នកស្លាប់ដោយគ្រោះមហន្តរាយ ធ្វើឱ្យមានផលប៉ះពាល់ដល់សេដ្ឋកិច្ចមានភាគរយចំនួន ៣០% ក្នុងចំណោមនៃផលប៉ះពាល់សេដ្ឋកិច្ចទាំងមូល។ គ្រោះមហន្តរាយដោយសារគ្រោះរាំងស្ងួតមានចំនួន ប្រហែល៥% ប៉ុន្តែបានធ្វើឱ្យមានផលប៉ះពាល់រហូតដល់ ៥៣% និងប៉ះពាល់ដល់ការខាតបង់ផ្នែកសេដ្ឋកិច្ចប្រហែល ៥% ខណៈដែលគ្រោះមហន្តរាយដោយសារព្យុះមានចំនួន ២២% បង្កឱ្យមានអ្នកស្លាប់ប្រហែល១៨% និងបង្កឱ្យខាងបង់ផ្នែកសេដ្ឋកិច្ចរហូតដល់ ៥៥% ក្នុងចំណោមគ្រោះមហន្តរាយទាំងអស់។ គ្រោះមហន្តរាយរញ្ជួយដីបានកើតឡើងមានចំនួន ៧% ធ្វើឱ្យខាតបង់សេដ្ឋកិច្ចចំនួន ៤% តែបង្កឱ្យមានអ្នកស្លាប់រហូតដល់ ២៦% ខណៈដែលគ្រោះមហន្តរាយដោយអាកាសធាតុក្តៅ និងត្រជាក់ខ្លាំងបានកើតឡើងតិចជាង ១% ប៉ុន្តែបណ្តាលឱ្យអ្នកស្លាប់ប្រហែល១០% និងធ្វើឱ្យខូចខាតសេដ្ឋកិច្ចប្រហែល២% ក្នុងចំណោមផលប៉ះពាល់សេដ្ឋកិច្ចពិភពលោកទាំងមូល។

**ក្រាហ្វិក ៤១. ចំនួនដែលបានកើតឡើង និងការបាត់បង់នៃគ្រោះមហន្តរាយធម្មជាតិឆ្នាំ២០២១**




ប្រភព÷ RELIEFWEB, *2021 Global Natural Disaster Assessment Report,* [website], 14 October 2022, https://reliefweb.int/report/world/2021-global-natural-disaster-assessment-report. (Accessed 7 December 2022).

## ក២ គ្រោះមហន្តរាយនៅកម្ពុជា

គ្រោះមហន្តរាយធម្មជាតិដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា គឺគ្រោះទឹកជំនន់ ខ្យល់ព្យុះ រន្ទះបាញ់ គ្រោះរាំងស្ងួត ការបាក់ច្រាំងទន្លេស្ទឹង ការបាក់រលំអគារ ឬ សំណង់ អគ្គីភ័យ ការពុលស្រា និងជំងឺឆ្លងផ្សេងៗ ។ គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតជាគ្រោះមហន្តរាយដែលប៉ះពាល់ដល់ប្រជាជនច្រើនជាងគេនៅក្នុងប្រទេសកម្ពុជា ដែលជានិច្ចកាលគ្រោះថ្នាក់ទាំងនេះរមែងនាំឱ្យមានការចំណាយខ្ពស់ជាងគេផងដែរ។ នៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គោលដៅទី១៣ វិធានការចំពោះអាកាសធាតុមានគោលបំណងចាត់វិធានការជាបន្ទាន់ ក្នុងការប្រយុទ្ធប្រឆាំងទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដោយអភិវឌ្ឍសមត្ថភាពរបស់ប្រទេសនីមួយៗ ដើម្បីកាត់បន្ថយហានិភ័យអាកាសធាតុ និងការបន្សាំ។ គ្រោះមហន្តរាយមាននៅក្នុងចំណុចដៅ ៣.១ នៅក្នុងគោលដៅទី ១៣ នៃ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

នៅក្នុងរបាយការណ៍វិភាគនេះ គឺបង្ហាញអំពីគ្រោះមហន្តរាយ ៣ ចំណុចដែលបានកើតឡើងរួមមាន÷

១) គ្រោះមហន្តរាយធម្មជាតិ

២) គ្រោះមហន្តរាយដោយអគ្គីភ័យ

៣) គ្រោះមហន្តរាយដោយជំងឺឆ្លង

៤) គ្រោះមហន្តរាយដោយសារសង្គ្រាម។

ក្រាហ្វិក ៤២ បង្ហាញអំពីចំនួនជនរងគ្រោះដោយអគ្គីភ័យ ខ្យល់កន្ត្រាក់ និងរន្ទះបាញ់។ តាមរបាយការណ៍របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយរយៈពេល ៦ ខែ ឆ្នាំ២០២៣ បានបង្ហាញថា ចំនួនអ្នកស្លាប់សរុបមានចំនួន ៦៦ នាក់ ច្រើនជាងឆ្នាំ ២០២២ ដែលមានចំនួនអ្នកស្លាប់សរុប ៤៦ នាក់។ នៅក្នុងឆ្នាំ ២០២៣នេះដែរ ចំនួនអ្នកស្លាប់ដោយសាររន្ទះបាញ់នៅតែមានចំនួនខ្ពស់ដូចឆ្នាំ ២០២២ ដែរ និងចំនួនអ្នករបួសដោយសារខ្យល់កន្ត្រាក់មានចំនួនខ្ពស់ខ្លាំងជាងឆ្នាំ ២០២២។

### ក្រាហ្វិក ៤២. ចំនួនជនរងគ្រោះដោយអគ្គិភ័យ ខ្យល់កន្ត្រាក់ និង រន្ទះបាញ់




ប្រភព÷ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម) ឆ្នាំ២០២២ និងឆ្នាំ ២០២៣

*សំគាល់: គិតត្រឹមរយៈពេល ៦ខែ ឆ្នាំ២០២២ និងឆ្នាំ ២០២៣។*

## ក២.១. គ្រោះមហន្តរាយធម្មជាតិ

គ្រោះមហន្តរាយធម្មជាតិ សំដៅលើគ្រោះថ្នាក់ធម្មជាតិ ដែលបានកើតឡើង ដូចជា ខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ រន្ទះបាញ់ គ្រោះទឹកជំនន់ និង គ្រោះរាំងស្ងួត ជាដើម។

### *១. ខ្យល់ព្យុះ/ខ្យល់កន្ត្រាក់*

តាមរបាយការណ៍រយៈពេល ៦ខែ ឆ្នាំ២០២៣ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានបង្ហាញថាព្យុះក្នុងតំបន់ចំនួន ៣ បានកើតឡើងនៅឆមាសទី១ ឆ្នាំ ២០២៣ ហើយក្នុងនោះឥទ្ធិពលបន្ទាប់នៃព្យុះទី១ បានធ្វើឲ្យខ្យល់មូសុងនិរតីបង្កើនឥទ្ធិពល និងការចូលមកដល់នៃរដូវវស្សាក្នុងសប្តាហ៍ទី២នៃខែឧសភា ឆ្នាំ ២០២៣។ អាកាសធាតុមានការប្រែប្រួលខ្លាំង បន្ទាប់ពីមានភ្លៀងកក់ខែធ្លាក់មកក្នុងខែមីនាលាយឡំជាមួយបាតុភូត ផ្គរ រន្ទះ និងខ្យល់បក់បោកខ្លាំងបង្កឲ្យមានការខាតបង់ និងបាត់បង់ច្រើនក្នុងខែមេសា និងឧសភា មានបរិមាណច្រើនជាងរាល់ឆ្នាំ។

## តារាង ១៤. ចំនួនការខូចខាតដោយខ្យល់កន្ត្រាក់ គិតឆមាសទី១ ឆ្នាំ២០២៣

| ការខូចខាតនិងបាត់បង់ | កែប | កំពត | កម្ពុជា |
|---|---|---|---|
| ចំនួនស្រុក/ ខណ្ឌ | 1 | 7 | 150 |
| លើក | 1 | 7 | 204 |
| ផ្ទះរលំ | 9 | 37 | 1734 |
| ផ្ទះរបើក | 33 | 543 | 10754 |
| សាលារៀន( ខ្នង) | 0 | 1 | 78 |
| តូប/ ផ្សារ | 0 | 0 | 76 |
| អគាររដ្ឋបាល ( កន្លែង) | 0 | 0 | 26 |
| មនុស្សស្លាប់ | 0 | 1 | 6 |
| មនុស្សរបួស | 0 | 21 | 120 |

## ក្រាហ្វិក ៤៣. ចំនួនការខូចខាតដោយខ្យល់កន្ត្រាក់ គិតត្រឹមឆមាសទី១ ឆ្នាំ២០២៣




ប្រភព÷ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម) ឆ្នាំ២០២៣

*សំគាល់: គិតត្រឹមរយៈពេល ៦ខែ ឆ្នាំ២០២៣។*

តារាង ១៥ បង្ហាញអំពីចំនួនគ្រួសារ និងចំនួនជនរងគ្រោះដោយសារខ្យល់ព្យុះ ផ្អែកតាមទិន្នន័យមូលដ្ឋានរបស់មន្ទីរផែនការរាជធានីខេត្តឆ្នាំ ២០២១។ ចំនួនគ្រួសារដែលរងគ្រោះដោយសារខ្យល់ព្យុះនៅកម្ពុជាឆ្នាំ២០២១ មានប្រហែល ៥.១៤៥ គ្រួសារ និង ជនរងគ្រោះមានចំនួនប្រហែល ១៨.៧៣៦ នាក់ និងអ្នកស្លាប់មានចំនួន ២៥ នាក់ ខណៈដែលនៅក្នុងខេត្តកំពតអ្នករងគ្រោះដោយសារខ្យល់ព្យុះមានគ្រួសារចំនួន ៤៩ គ្រួសារ ចំនួនជនរងគ្រោះមានចំនួន ១៦២នាក់ និងអ្នកស្លាប់មានចំនួន០១នាក់។ ខេត្តកែបគ្រួសារដែលរងគ្រោះ ដោយសារខ្យល់ព្យុះ មានគ្រួសារចំនួន២៤គ្រួសារ ជនរងគ្រោះចំនួន ១១០នាក់ និងពុំមានអ្នកស្លាប់។

**តារាង ១៥. ចំនួនគ្រួសារ និងជនរងគ្រោះដោយខ្យល់ព្យុះ**

| អធិប្បាយ | កែប | កំពត | កម្ពុជា |
|---|---|---|---|
| ចំនួនគ្រួសារទទួលការប៉ះពាល់ធ្ងន់ធ្ងរពីខ្យល់ព្យុះ | 24 | 49 | 5,145 |
| ចំនួនមនុស្សទទួលការប៉ះពាល់ធ្ងន់ធ្ងរពីខ្យល់ព្យុះ | 110 | 162 | 18,736 |
| ចំនួនអ្នកស្លាប់បណ្តាលមកពីខ្យល់ព្យុះ | 0 | 1 | 25 |

ប្រភព÷ ទិន្នន័យមន្ទីរផែនការខេត្តឆ្នាំ ២០២១

### *២. រន្ទះបាញ់*

តារាង ១៦ បង្ហាញចំនួនការខូចខាតដោយរន្ទះបាញ់ គិតត្រឹម ៦ខែ ឆ្នាំ២០២៣ ។ តាមទិន្នន័យខាងក្រោមបង្ហាញថា ចំនួនរន្ទះបាញ់បានកើតឡើងទូទាំងប្រទេសចំនួន ៨២ លើក ខូចខាតផ្ទះ ៥ខ្នង មនុស្សស្លាប់ ៤៦នាក់ មនុស្សរបួស ៣៩នាក់ និង គោក្របីងាប់ ៧១ក្បាល នៅទូទាំងប្រទេស។ ខេត្តកំពតក់តឡើងចំនួន ២ លើក បានបណ្តាលឱ្យមនុស្សស្លាប់ ១ នាក់ និងងាប់គោក្របី ២ក្បាល។ នៅខេត្តកែបពុំមានរន្ទះបាញ់កើតឡើងទេ។ រូបភាព ៤៤ បង្ហាញអំពីក្រាហ្វិកនៃការខូចខាតដោយសាររន្ទះបាញ់។

**តារាង ១៦. ចំនួនការខូចខាតដោយរន្ទះបាញ់ គិតត្រឹម ៦ខែ ឆ្នាំ២០២៣**

| ការខូចខាត និងបាត់បង់ | កែប | កំពត | កម្ពុជា |
|---|---|---|---|
| លើក | 0 | 2 | 82 |
| ផ្ទះ | 0 | 0 | 5 |
| មនុស្សស្លាប់ | 0 | 1 | 46 |
| មនុស្សរបួស | 0 | 0 | 39 |
| គោក្របីងាប់ (ក្បាល) | 0 | 2 | 71 |

ក្រាហ្វិក ៤៤. ចំនួនការខូចខាតដោយរន្ទះបាញ់ គិតត្រឹម ៦ខែ ឆ្នាំ២០២២ និង ឆ្នាំ២០២៣




ប្រភព៖ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម) ឆ្នាំ២០២២ និង ២០២៣

*សំគាល់: គិតត្រឹមរយៈពេល ៦ខែ ឆ្នាំ២០២២ និង ២០២៣។*

### *៣. គ្រោះទឹកជំនន់*

ផ្អែកតាមរបាយការណ៍របស់គណៈកម្មាជាតិគ្រប់គ្រងគ្រោះមហន្តរាយគិត្រឹមរយៈពេល៦ ខែ ឆ្នាំ ២០២៣ បានបង្ហាញថា គ្រោះទឹកជំនន់ បានកើតឡើងដោយជំនន់ទឹកភ្លៀង។ ភ្លៀងខុសរដូវបានធ្លាក់រាយប៉ាយចាប់ពីថ្ងៃទី ៩ដល់១៣ ខែមករា ក្នុងបរិមាណច្រើន និងបានបង្កឲ្យប្រព័ន្ធធារាសាស្ត្រមួយចំនួនមានទឹកពេញព្រៀប និងត្រូវបើកបង្ហូរចេញតាមប្រឡាយ និងផ្លូវទឹកជាបន្តបន្ទាប់ ហើយបានធ្វើឲ្យភូមិសាស្ត្រផ្នែកខាងក្រោមទទួលរងការលិចលង់ប៉ះពាល់ដល់លំនៅដ្ឋាន និងផ្ទៃដីស្រូវប្រាំងមួយចំនួន។ ការរងគ្រោះកម្រិតមធ្យមនៅរាជធានី ខេត្ត ចំនួន ៥រួមមាន៖ ខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ និងរាជធានីភ្នំពេញ និងប៉ះពាល់កម្រិតស្រាលក្នុងខេត្តកំពត តាកែវ និងខេត្តព្រះសីហនុ។ ផលប៉ះពាល់ដល់ប្រជាជន លំនៅដ្ឋាន និងវិស័យកសិកម្មមានដូចខាងក្រោម÷

## តារាង ១៧. ចំនួនផលប៉ះពាល់ដោយគ្រោះទឹកជំនន់ គិតត្រឹម ៦ខែ ឆ្នាំ២០២៣

| ល.រ | ប្រភេទនៃផលប៉ះពាល់ | ចំនួន |
|---|---|---|
| **១** | **វិស័យសង្គម** | |
| (១) | ចំនួនគ្រួសារដែលរងផលប៉ះពាល់ | 6,643 |
| (២) | ចំនួនគ្រួសារដែលបានជម្លៀសទៅទីទួលសុវត្ថិភាព | 1,486 |
| (៣) | ចំនួនប្រជាជនដែលរងផលប៉ះពាល់ | 26,572 |
| (៤) | ចំនួនប្រជាជនដែលរងគ្រោះដល់ស្លាប់ | 1 |
| (៥) | ចំនួនលំនៅដ្ឋានដែលបានលិច | 567 |
| (៦) | ចំនួនលំនៅដ្ឋានដែលខូចខាតទាំងស្រុង | 12 |
| (៧) | ចំនួនលំនៅដ្ឋានបានរុះរើទាំងស្រុង | 71 |
| **២** | **វិស័យកសិកម្ម** | |
| (១) | លិចដំណាំស្រូវ (ហិកតា) | 6,247 |
| (២) | ខូចខាតដំណាំស្រូវ (ហិកតា) | 3,032 |
| (៣) | លិចដំណាំរួមផ្សំ (ហិកតា) | 617 |
| (៤) | ខូចខាតដំណាំរួមផ្សំ (ហិកតា) | 444 |

ប្រភព៖ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម) ឆ្នាំ២០២៣។
*សំគាល់: គិតត្រឹមរយៈពេល ៦ខែ ឆ្នាំ២០២៣ ។*

ក្រាហ្វិក ៤៥. បង្ហាញអំពីការខូចខាតដំណាំស្រូវ និងដំណាំរួមផ្សំ ដោយសារគ្រោះទឹកជំនន់ គិតត្រឹម ៦ខែ ឆ្នាំ២០២២ និងឆ្នាំ ២០២៣។ ស្ថានភាពនៃផលប៉ះពាល់ដំណាំស្រូវឆ្នាំ ២០២២ មានចំនួន ១៣.៧៥១ ហិកតា និងឆ្នាំ ២០២៣ មានការថយចុះជាងពាក់កណ្តាលនៃឆ្នាំ ២០២២ ហើយដំណាំស្រូវដែលខូចខាតមានចំនួនតិចជាង៣ដងជាងឆ្នាំ ២០២២ ប៉ុន្តែការខូចខាតដំណាំរួមផ្សំមានចំនួនច្រើនជាងឆ្នាំ ២០២២ ច្រើនជាង២០ដង។ ទិន្នន័យលំអិតមាននៅក្នុងរូបភាព ២.៦០ ខាងក្រោម។

**ក្រាហ្វិក ៤៥. ចំនួនការខូចខាតដំណាំកសិកម្មដោយសារទឹកជំនន់ គិតត្រឹម៦ខែ ឆ្នាំ២០២២ និងឆ្នាំ ២០២៣**




ប្រភព៖ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម) ឆ្នាំ ២០២២ និង២០២៣
*សំគាល់: គិតត្រឹមរយៈពេល ៦ខែ ឆ្នាំ ២០២២ និង២០២៣។*

តារាង ១៨. ចំនួនការខូចខាតដោយសារទឹកជំនន់ ឆ្នាំ២០២១ បានបង្ហាញថា ចំនួនគ្រួសារទទួលការប៉ះពាល់ធ្ងន់ធ្ងរពីទឹកជំនន់នៅទូទាំងប្រទេសមានចំនួន ៦៣.៩៣៧ គ្រួសារ ក្នុងនោះខេត្តកំពតមានចំនួន ១៨០ គ្រួសារ និង ខេត្តកែបមិនមានគ្រួសាររងគ្រោះទេ។ ចំនួនមនុស្សទទួលការប៉ះពាល់ធ្ងន់ធ្ងរពីទឹកជំនន់នៅទូទាំងប្រទេសមានចំនួន ២២៨.២២១ នាក់ ខេត្តកំពតមានចំនួន ៦៨៤នាក់ និងខេត្តកែបមានចំនួន ០ នាក់ ខណៈដែលអ្នកស្លាប់មានចំនួន ១៦៨ នាក់នៅទូទាំងប្រទេស ខេត្តកំពតមានស្លាប់ចំនួន ៥នាក់ និងខេត្តកែបស្លាប់ចំនួន ០នាក់។ ចំនួនផ្ទៃដីស្រែដែលខូចខាតមកពីទឹកជំនន់នៅទូទាំងប្រទេសមានចំនួន ១៥៤.៧៩៣ ហិកតា ក្នុងនោះខេត្តកំពតមានចំនួន ៨៥២ ហិកតា និងខេត្តកែបមានចំនួន ០ ហិកតា។ ចំពោះស្ពានមានការខូចខាតទូទាំងប្រទេសចំនួន ៣.៧២៣ ក្នុងខេត្តកំពតមានចំនួន ១៥ និងខេត្តកែបមានចំនួន ០ និងខូចខាតផ្លូវចំនួនប្រហែល ១,៧ លានម៉ែត្រ សម្រាប់ទូទាំងប្រទេស ក្នុងនោះខេត្តកំពតមានចំនួនប្រហែល២៩ ពាន់ម៉ែត្រ និងខេត្តកែបមានចំនួន ៦២៧ម៉ែត្រ។

តារាង ១៨. ចំនួនការខូចខាតដោយសារទឹកជំនន់ ឆ្នាំ២០២១

| អធិប្បាយ | កែប | កំពត | កម្ពុជា |
|---|---|---|---|
| ចំនួនគ្រួសារទទួលការប៉ះពាល់ធ្ងន់ធ្ងរពីទឹកជំនន់ | 0 | 180 | 63,937 |
| ចំនួនមនុស្សទទួលការប៉ះពាល់ធ្ងន់ធ្ងរពីទឹកជំនន់ | 0 | 684 | 228,221 |
| ចំនួនអ្នកស្លាប់បណ្តាលមកពីគ្រោះទឹកជំនន់ | 0 | 5 | 168 |
| ចំនួនផ្ទៃដីស្រែដែលខូចខាតមកពីទឹកជំនន់(ហ.ត) | 0 | 852 | 154,793 |
| ប្រវែងផ្លូវដែលខូចខាតមកពីទឹកជំនន់ (ម៉ែត្រ) | 627 | 28,655 | 1,686,667 |
| ចំនួនស្ពានដែលខូចខាតមកពីទឹកជំនន់ | 0 | 15 | 3,723 |

ប្រភព÷ ទិន្នន័យមន្ទីរផែនការខេត្តឆ្នាំ២០២១

## *៤. គ្រោះរាំងស្ងួត*

ស្ថានភាពនៃភាពរាំងស្ងួតអាចបណ្តាលឲ្យមានកង្វះខាតទឹកសម្រាប់ប្រើប្រាស់។ តាមរបាយការណ៍របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម) ឆ្នាំ ២០២៣បានបង្ហាញថា ជាទូទៅក្នុងរដូវប្រាំងតំបន់គ្មានប្រភពទឹកឬ មានភ្លៀងកក់ខែតិចតួចតែងតែមានការប្រឈមនឹងការខ្វះខាតទឹកសម្រាប់ប្រើប្រាស់ បន្ទាប់ពីប្រភពទឹកលើដី និងក្រោមដីត្រូវបានរីងស្ងួត ដែលតម្រូវឲ្យប្រជាជនត្រូវការដឹកជញ្ជូនទឹកពីតំបន់ឆ្ងាយ ឬ ធ្វើការបង្វែរចរន្តទឹកមកតំបន់ដែលខ្វះខាតទឹកសម្រាប់ឲ្យប្រជាពលរដ្ឋដែលខ្វះខាតទឹកប្រើប្រាស់។ នៅក្នុងខែមេសា ឆ្នាំនេះបណ្តាខណ្ឌនៅភាគខាងលិច និងភាគខាងជើងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ខេត្តកណ្តាលបានប្រឈមនឹងការខ្វះខាតទឹកប្រើប្រាស់មួយរយៈពេលខ្លី ហើយត្រូវបានឆ្លើយតបពីរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាជ្ញាធរមូលដ្ឋាន និងស្ថាប័នជំនាញពាក់ព័ន្ធធ្វើការដឹកជញ្ជូនទឹកមកផ្គត់ផ្គង់ការប្រើប្រាស់រហូតដល់ខែឧសភាទើបស្ថានភាពមានភាពប្រសើរ បន្ទាប់ពីរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានដាក់ឲ្យដំណើរការរោងចក្រផលិតទឹកស្អាតបាក់ខែងក្នុងជំហានទី១ មុនកាលកំណត់ ដើម្បីដោះស្រាយបញ្ហាប្រឈមនិងការខ្វះខាតទឹកប្រើប្រាស់របស់ប្រជាពលរដ្ឋនៅតំបន់ជាយរាជធានីភ្នំពេញ។

នៅក្នុងស្ថានភាពដែលអាកាសធាតុក្តៅស្ងួត និងមានភ្លៀងកក់ខែតិចតួចបានធ្វើឲ្យដំណាំស្រូវចុងរដូវ និងស្រូវប្រាំងនៅតាមបណ្តាខេត្តមួយចំនួនមានការខ្វះខាតទឹក និងត្រូវបានមន្ទីរជំនាញ និងអាជ្ញាធរមូលដ្ឋានធ្វើការបើកបញ្ចេញទឹកពីអាងស្តុកទឹកធំៗដែលបានសន្សំទុកពីចុងឆ្នាំកន្លងមក និងបញ្ជូនម៉ាស៊ីនបូមទឹកធ្វើការបូមសង្គ្រោះជាបន្តបន្ទាប់ និងបានណែនាំអប់រំប្រជាកសិករឲ្យយល់ដឹងពីស្ថានភាពអាកាសធាតុ និងស្ថានភាពទឹកដែលមាន ហើយបានហាមមិនឲ្យប្រជាជនធ្វើស្រែប្រាំងលើកទី២ទេ។

- ការអន្តរាគមន៍បើកបញ្ចេញទឹក និងបូមទឹកសង្គ្រោះនៅមូលដ្ឋានខេត្តចំនួន ៨ រួមមាន÷ ខេត្តបន្ទាយមានជ័យ កំពង់ធំ ពោធិ៍សាត់ ត្បូងឃ្មុំ កណ្តាល ព្រៃវែង និងខេត្តស្វាយរៀង។

- ការសង្គ្រោះស្រូវប្រាំងចំនួន ៤៦.០៨៧ហិកតា និងស្រូវវស្សាដើមរដូវ ៤៤០ហិកតា។

- ស្រូវប្រាំងឆ្នាំ ២០២២-២០២៣ អនុវត្តបានចំនួន ៦៨២.៨៤៧ហិកតា កើនលើសឆ្នាំមុនចំនួន ៤២.៩៧៦ហិកតា។

ក្រាហ្វិក ៤៦ បង្ហាញអំពីចំនួនគ្រួសារ និងផ្ទៃដីដែលរងផលប៉ះពាល់ដោយសារគ្រោះរាំងស្ងួតឆ្នាំ ២០២១។ ចំនួនគ្រួសារដែលរងផលប៉ះពាល់ដោយសារគ្រោះរាំងស្ងួតមានចំនួន ៨០.៨១៦ គ្រួសារ និងចំនួនផ្ទៃដីចំនួន ៩៦.៨៣១ ហិកតា ឆ្នាំ២០២១ នៅទូទាំងប្រទេស។

**ក្រាហ្វិក ៤៦. ចំនួនគ្រួសារ និងផ្ទៃដីដែលរងផលប៉ះពាល់ដោយសារគ្រោះរាំងស្ងួតទូទាំងប្រទេស ឆ្នាំ២០២១**




ប្រភព÷ ទិន្នន័យមន្ទីរផែនការខេត្តឆ្នាំ២០២១

### ៥. បាក់ច្រាំងទន្លេ/ស្ទឹង/ព្រែក

យោងតាមរបាយការណ៍របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ឆ្នាំ២០២៣ គិតត្រឹមរយៈពេល ៦ខែ បានបង្ហាញថា ការបាក់ច្រាំងទន្លេ ស្ទឹង ឬ ព្រែក បានកើតឡើងចំនួន ១៤ ករណីនៅរាជធានីភ្នំពេញ ខេត្តចំនួន ៤ ក្នុងនោះមាន÷ ខេត្តព្រៃវែង កណ្តាល ពោធិ៍សាត់ និង រាជធានីភ្នំពេញ។ ការខូចខាត និងការបាត់បង់ដោយសារការបាក់ច្រាំងទន្លេ ស្ទឹងមានដូចខាងក្រោម÷

- ផ្ទះខូចខាត និងបាក់ស្រុតចូលក្នុងទឹក ៣១ខ្នង ផ្ទះរំកិល និងរុះរើចេញ ១៦៧ ខ្នង
- បាក់ស្រុតដីច្រាំងទន្លេ ស្ទឹង ព្រែក មានប្រវែង ១,២៩០ម៉ែត្រ។

## ខ. អគ្គីភ័យ

តារាង ១៩ បង្ហាញអំពីការខូចខាតដោយគ្រោះអគ្គីភ័យគិតត្រឹម ៦ខែ ឆ្នាំ២០២៣។ អគ្គីភ័យនៅឆ្នាំ ២០២៣ គិតត្រឹម រយៈពេល៦ខែ បានកើតឡើង៣៣៧ លើក ក្នុងស្រុកចំនួន ១៤៥ នៅទូទាំងប្រទេស បានបង្ករឲ្យឆេះផ្ទះចំនួន ៣៧២ខ្នង តូបផ្សារចំនួន ៥៩ ឃ្លាំងស្តុកទំនិញចំនួន ៨ សាលារៀនចំនួន១ខ្នង រោងចក្រចំនួន ៦កន្លែង អគាររដ្ឋបាលមានចំនួន ៦កន្លែង ចម្ការព្រៃចំនួន ១៧កន្លែង បង្កឲ្យមនុស្សស្លាប់ ចំនួន ១៤នាក់ និងរងរបួសចំនួន ២៧នាក់។ ខេត្តកំពតបានកើតឡើងចំនួន១៦លើក ក្នុងស្រុកចំនួន៦ ឆេះផ្ទះចំនួន១៧ខ្នង ប៉ុន្តែមិនបង្កឲ្យមនុស្សស្លាប់ និងរបួសទេ ខណៈដែលខេត្តកែបបានកើតឡើងចំនួន ១លើក ក្នុងស្រុក/ក្រុងចំនួន១ ហើយមិនបង្កឲ្យខូចខាត ឬ មនុស្សស្លាប់នោះទេ។

**តារាង ១៩. ការខូចខាតដោយគ្រោះអគ្គីភ័យគិតត្រឹម ៦ខែ ឆ្នាំ២០២៣**

| ការខូចខាត និងបាត់បង់ | កំពត | កែប | កម្ពុជា |
|---|---|---|---|
| ចំនួនស្រុក/ខណ្ឌ | 6 | 1 | 145 |
| លើក | 16 | 1 | 337 |
| ផ្ទះ (ខ្នង) | 17 | 0 | 372 |
| តូប/ផ្សារ | 0 | 0 | 59 |
| ឃ្លាំងទំនិញ | 0 | 0 | 8 |
| សាលារៀន (ខ្នង) | 0 | 0 | 1 |
| រោងចក្រ/សិប្បកម្ម(កន្លែង) | 0 | 0 | 6 |

| ការខូចខាត និងបាត់បង់ | កំពត | កែប | កម្ពុជា |
|---|---|---|---|
| អគាររដ្ឋបាល (កន្លែង) | 0 | 0 | 6 |
| ចម្ការ/ព្រៃ (កន្លែង) | 0 | 0 | 17 |
| មនុស្សស្លាប់ | 0 | 0 | 14 |
| មនុស្សរបួស | 0 | 0 | 27 |

ប្រភព÷ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម) ឆ្នាំ២០២៣

*សំគាល់: គិតត្រឹមរយៈពេល ៦ខែ ឆ្នាំ២០២៣។*

## ក្រាហ្វិក ៤៧. ចំនួនអគ្គីភ័យដែលកើតឡើង (ឆេះផ្ទះ ឆេះផ្សារ) ឆ្នាំ២០២១




ប្រភព÷ ទិន្នន័យមន្ទីរផែនការខេត្ត ឆ្នាំ២០២១

### គ. ជំងឺឆ្លង

នៅលើពិភពលោកយើងនេះ មានជំងឺឆ្លងជាច្រើនបានឆ្លងមកលើមនុស្ស។ ជំងឺឆ្លងទាំងនោះ រួមមានដូចជាជំងឺកូវីដ១៩ ជំងឺផ្តាសាយបក្សី និងជំងឺឆ្លងអេប៊ូឡា ជាដើម ប៉ុន្តែជំងឺឆ្លងដែលប្រជាជនលើពិភពលោកកំពុងចាប់អារម្មណ៍នោះគឺជំងឺឆ្លងកូវីដ១៩។

### គ១. ស្ថានភាពជំងឺកូវីដ១៩ទូទាំងពិភពលោក

ក្រាហ្វិក ៤៨ បង្ហាញអំពីស្ថានភាពជំងឺកូវីដ១៩ តាមរយៈគេហទំព័ររបស់អង្គការសុខភាពពិភពលោក (WHO) ។ តាមទិន្នន័យបង្ហាញថាចំនួនអ្នកឆ្លងជំងឺកូវីដ១៩ ប្រហែលចំនួន ៧៧១លាននាក់ ស្មើនឹង ៩,៦% នៃប្រជាជនពិភពលោកចំនួន ៨,១ ពាន់លាននាក់ និងបានស្លាប់បានកើនដល់ជិត ៧លាននាក់គិតត្រឹមថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០២៣។ វ៉ាក់សាំងដែលបានចាក់ទៅលើប្រជាជននៅលើពិភពលោកគិតជាចំនួនដូសមានចំនួនប្រហែល ១៣,៥ ពាន់លានដូស ក្នុងចំណោមប្រជាជនជិត ៨,១ ពាន់លាននាក់ ។

**ក្រាហ្វិក ៤៨. ស្ថានភាពជំងឺកូវីដ១៩ទូទាំងពិភពលោកគិតត្រឹមថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២៣**




ប្រភព÷ (1) World Health Organization (WHO), *WHO Coronavirus (COVID-19) Dashboard,* [website], 19 October 2023, https:// covid19.who.int/?mapFilter=vaccinations. (Accessed 19 October 2023).

(2) Worldometer, *Current World Population Clock: 8.1 Billion People (LIVE, 2023),* [website], 19 October 2023, www.worldometers.info/worldpopulation/#:~:text=World%20Population%20Clock %3A%208.1%20Billion, (LIVE%2C%202023)%20-%20Worldometer. (Accessed 19 October 2023).

ក្រាហ្វិក ៤៩. បង្ហាញអំពីស្ថានភាពនៃការចាក់វ៉ាក់សាំងជំងឺកូវីដ១៩ តាមរយៈគេហទំព័ររបស់អង្គការសុខភាពពិភពលោក (WHO)។ តាមទិន្នន័យបានបង្ហាញថា ក្នុងចំណោមប្រជាជន១០០នាក់ បានចាក់វ៉ាក់សាំង ១៧៣,៤១ដូស មានន័យថាមានប្រជាជនភាគច្រើនចាក់បាន២ដូស ខណៈដែលវ៉ាក់សាំងខ្លះតម្រូវឱ្យចាក់តែ ១ដូស។ ប្រជាជននៅលើពិភពលោកចំនួន ៦៦ នាក់បានចាក់វ៉ាក់សាំងពេញលេញតាមស៊េរីនៃវ៉ាក់សាំងដែលកំណត់ឱ្យចាក់ក្នុងប្រជាជន១០០នាក់ និងបានចាក់វ៉ាក់សាំងដូសជំរុញមានប្រជាជនប្រហែល ៣១,៧១នាក់ ក្នុងចំណោមប្រជាជន១០០នាក់ ។

**ក្រាហ្វិក ៤៩. ស្ថានភាពនៃចាក់វ៉ាក់សាំងជំងឺកូវីដ១៩ទូទាំងពិភពលោកគិតត្រឹមថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០២៣**




ប្រភព÷ World Health Organization (WHO), *WHO Coronavirus (COVID-19) Dashboard,* [website], 19 October 2023, https:// covid19.who.int/?mapFilter=vaccinations. (Accessed 19 October 2023).

## គ២. ស្ថានភាពជំងឺឆ្លងនៅកម្ពុជា

យោងតាមរបាយការណ៍ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងឆ្នាំ២០២៣ គិតត្រឹមរយៈពេល៦ខែ បានបង្ហាញថាជំងឺឆ្លង ដែលបានកើតឡើងរួមមាន÷ ជំងឺផ្តាសាយបក្សី ជំងឺគ្រុនឈាម និងជំងឺកូវីដ១៩។

### គ២.១ ជំងឺផ្តាសាយបក្សី

- ជំងឺផ្តាសាយបក្សី H5N1 ត្រូវបានរកឃើញ២ករណី នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ២០២៣ ដែលបណ្តាលឲ្យក្មេងស្រីម្នាក់អាយុ១១ឆ្នាំ រងគ្រោះស្លាប់ និងបុរសជាឪពុកបានឆ្លងជំងឺនេះ ដែលមានលំនៅដ្ឋានស្ថិតនៅភូមិរលាំង ឃុំរំលេច ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង។

- មនុស្សចំនួន ២៩នាក់ ដែលបានប៉ះពាល់នឹងមុខសញ្ញាត្រូវបានក្រុមឆ្លើយតបបន្ទាន់នៃក្រសួងសុខាភិបាលធ្វើតេស្តជាបន្តបន្ទាប់ក្នុងលទ្ធផលវិភាគអវិជ្ជមាន។

### គ២.២ ជំងឺគ្រុនឈាម

យោងតាមរបាយការណ៍ស្តីពី លទ្ធផលការងារគ្រប់គ្រងគ្រោះមហន្តរាយឆមាសទី១ ឆ្នាំ ២០២៣ និងទិសដៅឆមាសទី២ ឆ្នាំ ២០២៣ បានបង្ហាញថា នៅក្នុងឆ្នាំនេះ គឺជាវដ្តនៃជំងឺគ្រុនឈាម ក្រសួងសុខាភិបាល បានចេញសេចក្តីណែនាំជាបន្តបន្ទាប់ ដើម្បីឲ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងការធ្វើអនាម័យជុំវិញផ្ទះ និងកម្ចាត់មូសខ្លា ដែលជាភ្នាក់ងារចម្លងជំងឺគ្រុនឈាម ដែលកំពុងមានអត្រាកើនឡើង២ដងធៀបនឹងឆ្នាំកន្លងមក។ ការទទួលរងគ្រោះក្នុងរយៈពេល ២១ សប្តាហ៍ដើមឆ្នាំរួមមាន÷

- កើតមាន ៣.៤៣៩ករណី ក្នុងក្របខណ្ឌទូទាំងប្រទេស
- ស្ថានភាពរងគ្រោះ÷ ស្លាប់ ៥នាក់។

ក្នុងការត្រៀមបង្ការ និងការឆ្លើយតប ក្រសួងសុខាភិបាលបានចែកចាយដល់រាជធានីខេត្ត នូវថ្នាំអាប៊ែត ចំនួន២០០តោន ស្ព្រៃ៉ម៦០.០០០ប្លោក និងថ្នាំបាញ់មូសប្រមាណ ៥.០០០ លីត្រ និងរៀបចំអប់រំអំពីវិធានការការពារជំងឺគ្រុនឈាម និងធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធបណ្តាញសង្គម និងប្រព័ន្ធផ្សព្វផ្សាយរដ្ឋ និងឯកជន ដើម្បីបង្កើនការយល់ដឹងក្នុងសហគមន៍ សម្រាប់ការទប់ស្កាត់ការឆ្លងទ្រង់ទ្រាយធំនៃជំងឺគ្រុនឈាមក្នុងឆ្នាំ ២០២៣នេះ។

### គ២.៣ ជំងឺកូវីដ១៩

រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងសុខាភិបាល បានអំពាវនាវឲ្យប្រជាពលរដ្ឋអនុវត្តវិធានការ «៣ការពារ និង៣កុំ» ដោយប្រុងប្រយ័ត្ន ទោះបីជាអង្គការសុខភាពពិភពលោកប្រកាសជំងឺកូវីដ១៩ លែងជាភាពអាសន្នសុខភាពសាធារណៈក៏ដោយ ប៉ុន្តែការបំប្លែងខ្លួនជាបន្តបន្ទាប់នៃវីរុសកូវីដ១៩ ធ្វើឲ្យនៅតែមានការឆ្លងនៅបណ្តាប្រទេសមួយចំនួនរួមទាំងកម្ពុជាផង ដែលអាចមានលទ្ធភាពក្នុងការផ្ទុះឡើងជាថ្មីក្នុងសហគមន៍។

- ការឆ្លងថ្មីក្នុងឆមាសទី១ឆ្នាំ ២០២៣ មានចំនួន ៣០៦នាក់
- ការឆ្លងក្នុងសហគមន៍ ៣០០នាក់ ករណីនាំចូល៦នាក់ និងការព្យាបាលជាសះស្បើយ ៣៤១នាក់
- ការចាក់វ៉ាក់ការពារសរុបលើចំនួនប្រជាជន ១៥.២៩៨.០០៩ នាក់។

**ក្រាហ្វិក ៥០. ស្ថានភាពជំងឺកូវីដ១៩នៅកម្ពុជាគិតត្រឹមថ្ងៃទី ២០ ខែ១០ឆ្នាំ២០២៣**




ប្រភព÷ - World Health Organization (WHO), *WHO Coronavirus (COVID-19) Dashboard,* [website], 19 October 2023, https:// covid19.who.int/?mapFilter=vaccinations. (Accessed 19 October 2023).

- របាយការណ៍ស្ដីពី លទ្ធផលការងារគ្រប់គ្រងគ្រោះមហន្តរាយឆមាសទី១ ឆ្នាំ ២០២៣ និងទិសដៅឆមាសទី២ ឆ្នាំ ២០២៣
- ចំណោលប្រជាជនឆ្នាំ ២០២០ ផ្អែកតាមទិន្នន័យជំរឿនទូទៅប្រជាជនឆ្នាំ២០១៩។

ក្រាហ្វិក ៥១ បង្ហាញថាចំនួនប្រជាជនកម្ពុជា ១០០នាក់ដែលបានចាក់វ៉ាក់សាំង គឺបានប្រើប្រាស់វ៉ាក់សាំងអស់ចំនួន ២៨៤,៧២ដូស (២៨៥ដូស) មានន័យថា ប្រជាជនកម្ពុជាម្នាក់បានចាក់វ៉ាក់សាំងដូសទី៣ភាគច្រើន ខណៈដែលភាគច្រើនវ៉ាក់សាំងដែលបានប្រើប្រាស់នៅក្នុងប្រទេសកម្ពុជាចាក់បាន២ដូសទើបកំណត់ថាពេញលេញ។ ស្ថានភាពចាក់វ៉ាក់សាំងប្រជាជនពិភពលោកលើចំនួនប្រជាជន១០០

នាក់ ដែលបានចាក់វ៉ាក់សាំង គឺបានប្រើប្រាស់វ៉ាក់សាំងចំនួន ១៧៣,៤១ ដូស (១៧៣ដូស) មានន័យថាភាគច្រើនចាក់បានដូសទី២ ខណៈដែលភាគច្រើនវ៉ាក់សាំងតម្រូវឱ្យចាក់តែ១ដូស។ ប្រជាជនកម្ពុជាដែលបានចាក់វ៉ាក់សាំងពេញលេញមានចំនួន៨៨នាក់ និងបានចាក់ដូសជំរុញចំនួន ៦៤នាក់ ក្នុងចំណោមប្រជាជនដែលបានចាក់វ៉ាក់សាំង១០០ នាក់ ខណៈប្រជាជនពិភពលោកបានចាក់វ៉ាក់សាំងពេញលេញមានចំនួន ៦៦នាក់ និងចាក់ដូសជំរុញមានចំនួន ៣២នាក់ ក្នុងចំណោមប្រជាជនដែលបានចាក់វ៉ាក់សាំង ១០០ នាក់ ផ្អែកតាមគេហទំព័ររបស់អង្គការសុខភាពពិភពលោក គិតត្រឹមថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣។

**ក្រាហ្វិក ៥១. ស្ថានភាពចាក់វ៉ាក់សាំងជំងឺកូវីដ១៩នៅកម្ពុជា និងពិភពលោក គិតត្រឹមថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០២៣**




ប្រភព÷ - World Health Organization (WHO), *WHO Coronavirus (COVID-19) Dashboard,* [website], 19 October 2023, https:// covid19.who.int/?mapFilter=vaccinations. (Accessed 19 October 2023).

## ឃ. គ្រោះមហន្តរាយដោយសារសង្គ្រាម

### ឃ១. សកលលោក

សង្គ្រាមបានបង្កឲ្យមានគ្រោះមហន្តរាយយ៉ាងធំធេងដល់ជីវិតមនុស្ស និងបានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិជាច្រើន ព្រមទាំងបន្សល់ទុកនូវដីធ្លីដែលមានគ្រាប់មីន និងអាវុធផ្សេងៗទៀតសម្រាប់ការប្រើប្រាស់ដាំដំណាំ និងដីសម្រាប់ការសាងសង់លំនៅដ្ឋានរស់នៅ។ សង្គ្រាមធំៗ២បានកើតឡើង គឺសង្គ្រាមលោកលើកទី១ពីឆ្នាំ១៩១៤ ដល់ ឆ្នាំ១៩២១ និង សង្គ្រាមលោកលើកទី២ ពីឆ្នាំ១៩៣៩ ដល់ឆ្នាំ១៩៤៥។ ចំនួនទាហានដែលប្រយុទ្ធស្លាប់សរុបក្នុងសង្គ្រាមលោកលើកទី១ និងទី២ មានចំនួនសរុប២៤,៧លាននាក់ និងទាហានរងរបួសចំនួនសរុប៤៦,២លាននាក់ និងជនស៊ីវិលស្លាប់សរុបមានចំនួន៥១,៨ លាននាក់ ។ គ្រោះមហន្តរាយនេះមិនទាន់គិតអំពីការខូចខាតផ្សេងៗផង។

**ក្រាហ្វិក ៥២. ចំនួនអ្នកស្លាប់ និង របួសក្នុងសង្គ្រាមលោកលើកទី១ និងលើកទី២**




ប្រភព÷ 1) https://www.census.gov/history/pdf/reperes112018.pdf. *(Accessed 24 October 2023).*

2) https://www.nationalww2museum.org/students-teachers/student-resources/research-starters/research-starters-worldwide-deaths-world-war. *(Accessed 24 October 2023).*

*សំគាល់÷ *Worldwide casualty estimates vary widely in several sources. The number of civilian deaths in China alone might well be more than 50,000,000.*

## ឃ១.១ សង្គ្រាមលោកលើកទី១ ពីឆ្នាំ១៩១៤ ដល់ ឆ្នាំ១៩២១

សង្គ្រាមលោកលើកទី១បានចាប់ផ្តើមពីឆ្នាំ១៩១៤ និងបានបញ្ចប់នៅឆ្នាំ ១៩២១។ ចំនួនទាហាន និងជនស៊ីវិលដែលស្លាប់នៅក្នុងសង្គរាមលោកលើកទី១មានប្រហែល៤០លាននាក់ ក្នុងនោះ២០លាននាក់ ស្លាប់ និង ២១លាននាក់រងរបួស។ ចំនួនអ្នកស្លាប់សរុបត្រូវបានរាប់បញ្ចូលបុគ្គលិកទាហាន ៩លាននាក់ និងជនស៊ីវិលប្រហែល១០លាននាក់ផងដែរ។ ក្រុម Allies ឬ The Entente Powers គឺជាទាហានអន្តរជាតិដែលដឹកនាំដោយបារាំង ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក រុស្ស៊ី អ៊ីតាលី និងជប៉ុន បាត់បង់កងទ័ពប្រហែល ៥,៧លាននាក់ ខណៈដែលក្រុម The Central Power (Central Empire) ដែលមានប្រទេសអាល្លឺម៉ង់ អូទ្រីស-ហុងហ្គារី ចក្រភពអូត្តូម៉ង់ និងប៊ុលហ្គារីដែលគេស្គាល់ថាជាក្រុម Quadruple Alliance។ ចំណាត់ថ្នាក់នៃស្ថិតិអ្នកស្លាប់បានប៉ាន់ប្រមាណសម្រាប់សង្គ្រាមលោកលើកទី១ គឺជាទាហានដែលបានចុះបញ្ជីរួមបញ្ចូលការប្រយុទ្ធព្រមទាំងស្លាប់ដោយសារគ្រោះថ្នាក់ ជំងឺ និងស្លាប់នៅក្នុងគុកនៃសង្គ្រាម។ ការស្លាប់ភាគច្រើនគឺអត់អាហារ និងជំងឺ។ ជនស៊ីវិលស្លាប់ដោយសារផ្តាសាយនៅអេស្ប៉ាញមិនរាប់បញ្ចូលទេ តែជនស៊ីវិលស្លាប់ដោយការសម្លាប់រង្គាលនៅប្រទេសអាមេនីត្រូវបានរាប់បញ្ចូល[3]។ គ្រោះមហន្តរាយនេះ មិនទាន់គិតអំពីការខូចខាតសម្ភារៈ ផ្ទះសម្បែង និងផ្ទៃដីកសិកម្មដែលបន្សល់ទុកនូវអាវុធជាតិផ្ទុះផ្សេងៗទៀត។

**តារាង ២០. ចំនួនប្រជាជន និង ចំនួនអ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១**

| No. | Country Name | Population (Millions) | Military deaths | Civilian deaths | Total deaths | Deaths as % of population | Military wounded |
|---|---|---|---|---|---|---|---|
| 1 | Australia | 4.5 | 61,928 | | 61,928 | 1.38 | 152,171 |
| 2 | Canada | 7.2 | 64,944 | 2,000 | 66,944 | 0.92 | 149,732 |
| 3 | India Empire | 315.1 | 74,187 | | 74,187 | 0.02 | 69,214 |
| 4 | New Zealand | 1.1 | 18,050 | | 18,050 | 1.64 | 41,317 |
| 5 | New Found land | 0.2 | 1,204 | | 1,204 | 0.60 | 2,314 |
| 6 | South Africa | 6.0 | 9,463 | | 9,463 | 0.16 | 12,029 |
| 7 | United Kingdom | 45.4 | 885,138 | 109,000 | 994,138 | 2.19 | 1,663,435 |
| | Sub-total for British Imperial Forces | - | 1,114,914 | 111,000 | 1,225,914 | - | 2,090,212 |
| 8 | Belgium | 7.4 | 58,637 | 62,000 | 120,637 | 1.63 | 44,686 |
| 9 | France | 39.6 | 1,397,800 | 300,000 | 1,697,800 | 4.29 | 4,266,000 |
| 10 | Greece | 4.8 | 26,000 | 150,000 | 176,000 | 3.67 | 21,000 |
| 11 | Italy | 35.6 | 651,000 | 589,000 | 1,240,000 | 3.48 | 953,886 |

[3] REPERES, *World War I Casualty*, [website], 2011, https://www.census.gov/history/pdf/reperes112018.pdf. (Accessed 24 October 2023).

| No. | Country Name | Population (Millions) | Military deaths | Civilian deaths | Total deaths | Deaths as % of population | Military wounded |
|---|---|---|---|---|---|---|---|
| 12 | Empire of Japan | 53.6 | 415 | - | 415 | - | 907 |
| 13 | Luxembourg | 0.3 | | - | - | - | |
| 14 | Montenegro | 0.5 | 3,000 | - | 3,000 | 0.60 | 10,000 |
| 15 | Portugal | 6.0 | 7,222 | 82,000 | 89,222 | 1.49 | 13,751 |
| 16 | Romania | 7.5 | 250,000 | 430,000 | 680,000 | 9.07 | 120,000 |
| 17 | Russian Empire | 175.1 | 1,811,000 | 1,500,000 | 3,311,000 | 1.89 | 4,950,000 |
| 18 | Serbia | 4.5 | 275,000 | 450,000 | 725,000 | 16.11 | 133,148 |
| 19 | United States | 92.0 | 116,708 | 757 | 117,465 | 0.13 | 205,690 |
| | Total (Entente Powers) | 806.4 | 5,711,696 | 3,674,757 | 9,386,453 | 1.19 | 12,809,280 |
| 1 | Austria-Hungary | 51.4 | 1,100,000 | 467,000 | 1,567,000 | 3.05 | 3,620,000 |
| 2 | Bulgaria | 5.5 | 87,500 | 100,000 | 187,500 | 3.41 | 152,390 |
| 3 | German Empire | 64.9 | 2,050,897 | 426,000 | 2,476,897 | 3.82 | 4,247,143 |
| 4 | Ottoman Empire | 21.3 | 771,844 | 2,150,000 | 2,921,844 | 13.72 | 400,000 |
| | Total (Central Powers) | 143.1 | 4,010,241 | 3,143,000 | 7,153,241 | 5.00 | 8,419,533 |
| 1 | Denmark | 2.7 | | 722 | 722 | 0.03 | |
| 2 | Norway | 2.4 | | 1,892 | 1,892 | 0.08 | |
| 3 | Sweden | 5.6 | | 877 | 877 | 0.02 | |
| | Neutral nations | 10.7 | - | 3,491 | 3,491 | | |
| | Grand total | 960.2 | 9,721,937 | 6,821,248 | 16,543,185 | 1.75 | 21,228,813 |

ក្រាហ្វិក ៥៣ បង្ហាញអំពីចំនួនប្រជាជនតាមប្រទេស ដែលមានការទាក់ទងការស្លាប់ទាហាន ជនស៊ីវិល និង រងរបួសអំឡុងពេលសង្គ្រាមលោកលើកទី១។ ក្រុមប្រទេសដែលស្ថិតក្នុងចំណាត់ថ្នាក់ Ententes Powers ដែលមានចំនួនប្រជាជនច្រើនជាងគេគឺចក្រភពឥណ្ឌាមានប្រជាជនជាង៣០០ លាននាក់ ហើយប្រទេសដែលមានចំនួនប្រជាជនតិចជាងគេ គឺប្រទេស New Found land មានចំនួនប្រជាជនប្រហែល ២០ម៉ឺននាក់។ នៅក្នុងក្រុមប្រទេស Central Powers ចក្រភពអាល្លឺម៉ង់មានចំនួនប្រជាជនប្រហែល ៦៥លាននាក់ និងប្រទេសដែលមានប្រជាជនតិចជាងគេគឺប្រទេសប៊ុលហ្គារី មានប្រជាជនប្រហែល ៥,៥លាននាក់។ ចំពោះក្រុមប្រទេស **Neutral nations** ប្រទេស Norway មានចំនួនប្រជាជនតិចជាងគេប្រហែល ២,៤លាននាក់ និងច្រើនជាងគេប្រទេសស៊ុយអែតមានចំនួនប្រជាជនប្រហែល ៥,៦លាននាក់។

**ក្រាហ្វិក ៥៣. ចំនួនប្រជាជនសរុបក្នុងអំឡុងពេល WWI**




ក្រាហ្វិក ៥៤ បង្ហាញថាចំនួនអ្នកស្លាប់ក្នុងនោះមានទាហាននិងជនស៊ីវិលស្លាប់ និង ទាហានដែលរងរបួសច្រើនជាងគេគឺចក្រភពរុស្ស៊ី។ ចក្រភពរុស្ស៊ីមានអ្នកស្លាប់ (ទាហាននិងជនស៊ីវិល) មានចំនួនប្រហែល ៣,៣លាននាក់ និងទាហានរងរបួសមានចំនួនប្រហែល ៤,៩ លាននាក់ និងចក្រភពជប៉ុនមានមានអ្នកស្លាប់ ៤១៥នាក់ និងទាហានរងរបួសមានចំនួន ៩០៧នាក់តិចជាងគេ ខណៈដែលប្រទេស Luxembourg ពុំមានអ្នកស្លាប់ និងរងរបួស សម្រាប់ក្រុមប្រទេស Ententes Powers។ ចំពោះក្រុមប្រទេស Central Powers ចក្រភព Ottoman មានអ្នកស្លាប់២,៩លាននាក់ និង ទាហានរងរបួសប្រហែល៤០ម៉ឺន ខណៈដែលចក្រភពអាល្លឺម៉ង់ មានអ្នកស្លាប់ប្រហែល២,៥លាននាក់ និងទាហានរងរបួស ៤,២លាននាក់។ ចំពោះក្រុមប្រទេស Neutral nations មានប្រជាជនស៊ីវិលស្លាប់ចំនួន ៣៤៩១នាក់។

ក្រាហ្វិក ៥៤. ចំនួនអ្នកស្លាប់ និងទាហានរងរបួសសរុបក្នុងអំឡុងពេល WWI




សំគាល់÷ 1) ក្រុមប្រទេស Entente Powers (Australia, Canada, India Empire, New Zealand, New Found Land, South Africa, United Kingdom, Belgium, France, Greece, Italy, Empire of Japan, Luxembourg, Montenegro, Portugal, Romania, Russian Empire, Serbia and United States.

2) ក្រុមប្រទេស Central Powers (Austria-Hungary, Bulgaria, German Empire, and Ottoman Empire).

3) ក្រុមប្រទេស Neutral nations (Denmark, Norway, and Sweden).

4) Total deaths (Military death and Civilians deaths).

ក្រាហ្វិក ៥៥. ភាគរយចំនួនអ្នកស្លាប់តាមចំណាត់ថ្នាក់ក្នុង WWI (1914-1921)




ក្រាហ្វិក ៥៦. ភាគរយចំនួនទាហានសម្រាប់ក្រុម Entente Powers ក្នុង WWI



ក្រាហ្វិក ៥៧. ភាគរយចំនួនទាហានសម្រាប់ក្រុម Central Powers ក្នុង WWI




## ឃ១.២ សង្គ្រាមលោកលើកទី២ ពីឆ្នាំ១៩៣៩ ដល់ ឆ្នាំ១៩៤៥

សង្គ្រាមលោកលើកទី២គឺជាជម្លោះសកលដែលបានចាប់ផ្តើមពីឆ្នាំ ១៩៣៩ ដល់ឆ្នាំ ១៩៤៥។ ប្រទេសធំៗនៅលើពិភពលោករួមបញ្ចូលទាំងប្រទេស ដែលមានអំណាចធំៗ បានប្រយុទ្ធគ្នាដែលមានទាហានជាសម្ព័ន្ធភាពនឹងគ្នាបានបែងចែកជាពីរក្រុមធំៗគឺ ក្រុមប្រទេស Allies និងក្រុមប្រទេស Axis។ ក្រុមប្រទេស Allies មានប្រទេសធំៗចំនួន៤គឺ ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក សហភាពសូវៀត និង ប្រទេសចិន។ ក្រុមប្រទេស Axis មាន Nazi Germany, Empire of Japan, និង Kingdom of Italy។

តារាង ២១. បង្ហាញអំពីចំនួនទាហានស្លាប់ ជនស៊ីវិលស្លាប់ និង ទាហានរងរបួសនៅក្នុងអំឡុងពេលសង្គ្រាមលោកលើកទី២ ពីឆ្នាំ១៩៣៩ ដល់ ឆ្នាំ១៩៤៥។ ចំនួនអ្នកស្លាប់ច្រើនជាងគេ គឺសហភាពសូវៀតមានចំនួនប្រហែល ២៤លាននាក់ ក្នុងនោះមានទាហានស្លាប់ប្រហែល ១០លាននាក់ ក្រៅពីនោះជាជនស៊ីវិល។ ប្រទេសចិនមានចំនួនអ្នកស្លាប់ប្រហែល២០លាននាក់ ក្នុងនោះមានទាហានស្លាប់ពី៣ទៅ ៤លាននាក់ ប្រទេសអាល្លឺម៉ង់មានអ្នកស្លាប់ចំនួនចន្លោះពី ៦ ដល់៨លាននាក់ ក្នុងនោះមានទាហានស្លាប់ប្រហែល ៥,៥លាននាក់ ប្រទេសជប៉ុន មានអ្នកស្លាប់ប្រហែល៣លាននាក់ ក្នុងនោះមានទាហានចំនួន ២,១លាននាក់ និងប្រទេសប៉ូឡូញមានអ្នកស្លាប់ចំនួន ៥,៦លាននាក់ ក្នុងនោះទាហានស្លាប់ប្រហែល ២៤ម៉ឺននាក់។

## តារាង ២១. ចំនួនអ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី២

| Country | Military Deaths | Total Civilian and Military Deaths |
|---|---|---|
| Albania | 30,000 | 30,200 |
| Australia | 39,800 | 40,500 |
| Austria | 261,000 | 384,700 |
| Belgium | 12,100 | 86,100 |
| Brazil | 1,000 | 2,000 |
| Bulgaria | 22,000 | 25,000 |
| Canada | 45,400 | 45,400 |
| China | 3-4,000,000 | 20,000,000 |
| Czechoslovakia | 25,000 | 345,000 |
| Denmark | 2,100 | 3,200 |
| Dutch East Indies | -- | 3-4,000,000 |
| Estonia | -- | 51,000 |
| Ethiopia | 5,000 | 100,000 |
| Finland | 95,000 | 97,000 |
| France | 217,600 | 567,600 |
| French Indochina | -- | 1-1,500,000 |
| Germany | 5,533,000 | 6,600,000-8,800,000 |
| Greece | 20,000-35,000 | 300,000-800,000 |
| Hungary | 300,000 | 580,000 |
| India | 87,000 | 1,500,000-2,500,000 |
| Italy | 301,400 | 457,000 |
| Japan | 2,120,000 | 2,600,000-3,100,000 |
| Korea | -- | 378,000-473,000 |
| Latvia | -- | 227,000 |
| Lithuania | -- | 353,000 |
| Luxembourg | -- | 2,000 |
| Malaya | -- | 100,000 |
| Netherlands | 17,000 | 301,000 |
| New Zealand | 11,900 | 11,900 |
| Norway | 3,000 | 9,500 |
| Papua New Guinea | -- | 15,000 |
| Philippines | 57,000 | 500,000-1,000,000 |
| Poland | 240,000 | 5,600,000 |
| Romania | 300,000 | 833,000 |
| Singapore | -- | 50,000 |
| South Africa | 11,900 | 11,900 |
| Soviet Union | 8,800,000-10,700,000 | 24,000,000 |
| United Kingdom | 383,600 | 450,700 |
| United States | 416,800 | 418,500 |
| Yugoslavia | 446,000 | 1,000,00 |

## ក្រាហ្វិក ៥៨. ចំនួនអ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី២




ប្រភព÷ 1) https://www.census.gov/history/pdf/reperes112018.pdf. *(Accessed 24 October 2023).*

2) https://www.nationalww2museum.org/students-teachers/student-resources/research-starters/research-starters-worldwide-deaths-world-war. *(Accessed 24 October 2023).*

*សំគាល់÷ *Worldwide casualty estimates vary widely in several sources. The number of civilian deaths in China alone might well be more than 50,000,000*

### ឃ២. កម្ពុជា

ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមជាច្រើន នៅក្នុងដំណាក់កាលនៃសម័យកាលនីមួយៗ ជាពិសេស ជាមួយនឹងប្រទេសជិតខាង។ បន្ទាប់មានបញ្ចប់ជម្លោះជាមួយនឹងប្រទេស កម្ពុជាមានសង្គ្រាមផ្ទៃក្នុងរវាងខ្មែរ និងខ្មែរ។ សង្គ្រាមនេះបានធ្លាក់ចូលក្នុងគ្រោះមហន្តរាយយ៉ាងធំធេង ដូចជាការបាត់បង់ជីវិតមនុស្ស និងបន្សល់ទុកគ្រាប់មីនជាច្រើននៅក្នុងប្រទេសកម្ពុជា។

ក្រោយថ្ងៃរំដោះ៧មករាឆ្នាំ១៩៧៩ ប្រទេសកម្ពុជាបានរួចផុតពីរបបប្រល័យពូជសាសន៍ប្រជាជាតិខ្មែរទាំងមូលបានរស់ឡើងវិញ ហើយក្រសួងស្ថាប័នរដ្ឋត្រូវបានបង្កើតឡើងវិញ។ ពេលនោះ ក្រសួងផែនការ មិនទាន់បានបង្កើតនៅឡើយ តែការងារផែនការបានបញ្ចូលនៅក្នុងក្រសួងសេដ្ឋកិច្ច និងជីវភាព។ នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ១៩៨១ ការបោះក្រដាសប្រាក់រៀល និងចរាចរប្រាក់រៀលត្រូវបានដាក់ឱ្យប្រើ

ប្រាស់ឡើងវិញ បន្ទាប់ពីត្រូវបានលុបចោលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) ក្រសួងសេដ្ឋកិច្ច និងជីវភាពត្រូវបានបែកជា÷ ក្រសួងផែនការ ក្រសួងហិរញ្ញវត្ថុ និង ក្រសួងផ្សេងៗទៀត។ ចាប់ពីពេលនោះមក ក្រសួងផែនការមានតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំផែនការ និងលើកទិសដៅអនុវត្តដល់គ្រប់បណ្តាក្រសួងទាំងអស់សម្រាប់គ្រប់គ្រង និងអភិវឌ្ឍសេដ្ឋកិច្ចជាតិតាមបែបសេដ្ឋកិច្ចផែនការ។ នៅក្នុងដំណាក់កាលនោះ ប្រទេសកម្ពុជាពុំទាន់បានទទួលសន្តិភាពទាំងស្រុងនៅឡើយទេ តែក្រោមការដឹកនាំប្រកបដោយភាពវៃឆ្លាត និងគតិបណ្ឌិត **សម្តេចនាយករដ្ឋមន្ត្រី** បានដាក់ចេញនូវគោលនយោបាយបង្រួបបង្រួមជាតិ ដែលបានឈានដល់ការជួបសន្ទនា ឬ ហៅកាត់ថាការចរចា **សីហនុ ហ៊ុនសែន** នៅហ្វែរអង់តាជីន័រ នៅប្រទេសបារាំងថ្ងៃទី ២ ខែធ្នូ ឆ្នាំ ១៩៨៧ រហូតដល់ការបង្កើតបានកិច្ចព្រមព្រៀងក្រុងប៉ារីសថ្ងៃទី ២៣ ខែ តុលា ឆ្នាំ១៩៩១ ។ អនុវត្តកិច្ចព្រមព្រៀងនេះ ការបោះឆ្នោតនៅឆ្នាំ ១៩៩៣ ដែលបានរៀបចំឡើងដោយអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិ (UNTAC) នៅកម្ពុជាត្រូវបានធ្វើឡើង របបរាជានិយមត្រូវបានបង្កើតជាថ្មី។ ប៉ុន្តែសង្គ្រាមនៅតែអូសបន្លាយ ដោយកើតមានឡើងនៅតាមតំបន់មួយចំនួនរហូតដល់ចុងឆ្នាំ១៩៩៨ ទើបសង្គ្រាមត្រូវបានបញ្ចប់ទាំងស្រុងតាមរយៈគោលនយោបាយ « **ឈ្នះឈ្នះ** » ដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។ បើទោះបីសង្គ្រាមបានបញ្ចប់មែន តែគ្រាប់មីន និងអាវុធជាតិផ្ទុះបានកប់នៅក្នុងដី។ ដូច្នេះនៅក្នុងគោលដៅអភិវឌ្ឍន៍សហវត្សរ៍សកលមាន ៨គោលដៅ តែសម្រាប់ប្រទេសកម្ពុជាបានបន្ថែមតែ១គោលដៅទៀតគឺការដោះមីន និងអាវុធជាតិផ្ទុះ សរុបទាំងអស់ ៩គោលដៅ។

**ក្រាហ្វិក ៩៩. ចំនួនគ្រាប់មីន និងអាវុធជាតិផ្ទុះដែលបានកម្ទេច (១៩៩២-២០២៣)**



## ក្រាហ្វិក ៦០. ចំនួនជនរងគ្រោះដោយគ្រាប់មីន និង ដោយសារគ្រាប់ (១៩៩២-២០២៣)




## ក្រាហ្វិក ៦១. ប្រភេទជនរងគ្រោះដោយគ្រាប់មីន និង ដោយសារគ្រាប់ (១៩៩២ -២០២៣)




ប្រភព÷ អាជ្ញាធរមីនកម្ពុជា

## ក្រាហ្វិក ៦២. ចំនួនជនរងគ្រោះដោយគ្រាប់មីន និង ដោយសារគ្រាប់ ពីឆ្នាំ១៩៩២ -២០២៣ តាមរាជធានី ខេត្ត




ប្រភព÷ អាជ្ញាធរមីនកម្ពុជា

## ២.១.៥ ការប្រែប្រួលអាកាសធាតុ












នៅគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ បានកំណត់គោលដៅចំនួន ១៧ ដែលក្នុងនោះ នៅក្នុងគោលដៅទី ១៣ គឺ វិធានការលើការប្រែប្រួលអាកាសធាតុ (Climate Action) ។ នៅក្នុងគោលដៅទី ១៣ នេះ មានចំណុចដៅចំនួន ៥ គឺ ១៣.១, ១៣.២, ១៣.៣, ១៣.A និង ១៣.B ។

ការប្រែប្រួលអាកាសធាតុ គឺជាដំណើរការប្រែប្រួលបន្តិចម្តងៗនៃអាកាសធាតុ ក្នុងរយៈពេលវែង ក្នុងនោះរួមមាន សីតុណ្ហភាព និង ស្ថានភាពទឹកភ្លៀង របបខ្យល់ ឬ គម្របទឹកកក ជាដើម។ ការប្រែប្រួលនេះ កើតឡើងដោយសារ កត្តាធម្មជាតិ និងសកម្មភាពមនុស្សផងដែរ។ មូលហេតុ នៃការប្រែប្រួលអាកាសធាតុ អាចកើតឡើងដោយធម្មជាតិ ឬដោយសារសកម្មភាពមនុស្សរួមមាន÷

- សកម្មភាពមនុស្ស ដូចជាការដុតប្រេងឥន្ធនៈហ្វូស៊ីល ការកាប់បំផ្លាញព្រៃឈើ កសិកម្ម ។ល។ បានបញ្ចេញឧស្ម័នផ្ទះកញ្ចក់យ៉ាងច្រើន ទៅក្នុងបរិយាកាសផែនដី
- កំណើនកំហាប់ឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាសរាំងស្កាត់កំដៅដែលផ្លាតចេញពីផ្ទៃផែនដី ឱ្យនៅក្នុងបរិយាកាសកាន់តែច្រើន ដែលជាមូលហេតុនៃកំណើនកំដៅសកល
- បាតុភូត “ផលផ្ទះកញ្ចក់” សំដៅលើកំណើនសីតុណ្ហភាពបរិយាកាស ដោយសារកំដៅដែលចាំងផ្លាតពីផ្ទៃផែនដី ហើយត្រូវរាំងស្កាត់មិនឱ្យភាយចេញទៅ ក្នុងលំហអវកាសបាន
- ឧស្ម័នផ្ទះកញ្ចក់(GHGs) សំខាន់ៗ នៅក្នុងបរិយាកាសរួមមាន ÷ ចំហាយទឹក(water vapor), ឧស្ម័នកាបូនិច CO2, មេតាន CH4, ឌីអាសូតម៉ូណូអុកស៊ីត N2O, អ៊ីដ្រូហ្លុយអរ៉ូកាបូន HFCs, ពែរហ្លុយអរ៉ូកាបូន PFCs, ស៊ុលភួអិចសាភ្លួរ SF6 ។

ការប្រែប្រួលអាកាសធាតុបានធ្វើឱ្យមានគ្រោះធម្មជាតិផ្សេងៗដូចជាខ្យល់ព្យុះ គ្រោះទឹកជំនន់ និងភាពរាំងស្ងួតជាដើម។ គ្រោះធម្មជាតិទាំងនេះ បានធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅខ្លាំងចំពោះប្រជាជននៅតាមជនបទជាពិសេសប៉ះពាល់ដល់ការធ្វើកសិកម្ម។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ក្នុងឆ្នាំ១៩៩៥ ។

ប្រទេសកម្ពុជាមានផ្ទៃដី ១៨១.០៣៥ គីឡូម៉ែត្រក្រឡា ស្ថិតនៅភាគនិរតីនៃឧបទ្វីបអាស៊ីបូព៌ា ហើយផ្ទៃដីប្រមាណ ២០ ភាគរយត្រូវបានប្រើប្រាស់សម្រាប់ដំណាំកសិកម្ម ។ ប្រទេសកម្ពុជាស្ថិតនៅក្នុងតំបន់ត្រូពិកទាំងស្រុង និងស្ថិតនៅចំណុចខាងត្បូងច្រើនជាង ១០ អង្សានៅលើអេក្វាទ័រ។ សីតុណ្ហភាពអតិបរមាខ្ពស់ជាង ៣៣ អង្សាសេ ជាទូទៅចាប់ផ្តើមរដូវវស្សានៅខែមីនា និងខែមេសា ហើយអាចកើនឡើងដល់ ៣៨ អង្សាសេ។ សីតុណ្ហភាពអប្បបរមាធ្លាក់នៅក្រោម ១០ អង្សាសេ ។ នៅ ខែមករាជាខែត្រជាក់បំផុត និង ខែមេសាជាខែដែលក្តៅបំផុត។ បរិមាណទឹកភ្លៀងប្រចាំឆ្នាំគឺរវាង ១៤២ និង ២០០ សង់ទីម៉ែត្រ ។ ភ្លៀងធ្លាក់ពីខែ មេសាដល់ខែកញ្ញាក្នុងតំបន់ដីទំនាបបឹងទន្លេសាប មេគង្គ ជាមធ្យមប្រចាំឆ្នាំពី ១១០ ទៅ ១៩០ សង់ទីម៉ែត្រ ប៉ុន្តែបរិមាណនេះប្រែប្រួលដែលគួរឱ្យកត់សំគាល់ពីមួយឆ្នាំទៅមួយឆ្នាំ ។ តែទោះបីយ៉ាងណាក៏ដោយ តំបន់ទឹកភ្លៀងដ៏ធំបំផុតនេះភាគច្រើនហូរទៅសមុទ្រ ហើយមានបរិមាណតិចតួចប៉ុណ្ណោះ ដែលហូរតាមស្ទឹងទន្លេចូលក្នុងបឹងទន្លេសាប។ សំណើមនៅប្រទេសកម្ពុជា គឺ

ខ្ពស់នៅពេលយប់ពេញមួយឆ្នាំ និងនៅពេលរដូវប្រាំងសំណើមមធ្យមប្រមាណ ៥០ ភាគរយ ឬ ទាបជាងបន្តិច ប៉ុន្តែវាអាចមានប្រមាណ ៦០ ភាគរយ នៅរដូវវស្សា។

### ក. ការយល់ដឹងពីការប្រែប្រួលអាកាសធាតុ

យោងតាមរបាយការណ៍របស់ក្រសួងបរិស្ថាន ដែលបានសិក្សាអំពីឥរិយាបថនៃការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងអាកាសធាតុសកលតាមរយៈការសម្ភាសន៍ពីប្រជាជន សិស្ស និសិត្ស និងកម្មករជាដើម។ តាមលទ្ធផលបានបង្ហាញថា ភាគរយអ្នកដែលបានយល់ដឹងពីការប្រែប្រួលអាកាសធាតុមានចំនួន ៧២% ក្នុងនោះអ្នកយល់ដឹងអំពីអត្ថន័យការប្រែប្រួលមានចំនួន ៣៣% និងមិនយល់ដឹងអំពីអត្ថន័យការប្រែប្រួលមានចំនួន ៣៩% និងមិនដែលដឹងអំពីការប្រែប្រួលមានចំនួន ២៨%។ ចំពោះការយល់ដឹងអំពីអាកាសធាតុសកលមានចំនួន ៧១% ក្នុងនោះ៣១% យល់ដឹងពីអត្ថន័យនៃអាកាសធាតុសកល និងដឹងតែមិនយល់ពីអត្ថន័យមានចំនួន៤០% និងមិនដឹងចំនួន ២៩%។ ក្រាហ្វិក ៦៣ បង្ហាញអំពីការយល់ដឹងអំពីអត្ថន័យការប្រែប្រួលអាកាសធាតុ និង អាកាសធាតុសកល។

**ក្រាហ្វិក ៦៣. ការយល់ដឹងអំពីអត្ថន័យការប្រែប្រួលអាកាសធាតុ និង អាកាសធាតុសកលនៅកម្ពុជា**




ប្រភព÷ Ministry of Environment, *A Third Study Understanding Public Perception of Climate Change in Cambodia, Knowledge, Attitude, and Practice (KAP3),* Ministry of Environment, 2020.

ក្រាហ្វិក ៦៤ អំពីការយល់ដឹងអំពីស្ថានភាពអាកាសធាតុតាមប្រភេទ និងតាមតំបន់នៅកម្ពុជា។ តាមទិន្នន័យខាងក្រោមដែលបានមកពីការសម្ភាសន៍នៅតាមតំបន់ផ្សេងៗពីគ្នា ហើយបានឆ្លើយថាការប្រែប្រួលអាកាសអាចឲ្យមានភ្លៀងធ្លាក់ មានសីតុណ្ហភាពប្រែប្រួល ទឹកជំនន់ គ្រោះរាំងស្ងួត និងបណ្តាលឲ្យមានខ្យល់ព្យុះ ។ ទិន្នន័យលំអិតមានបង្ហាញក្នុងក្រាហ្វិកខាងក្រោម។

**ក្រាហ្វិក ៦៤. ការយល់ដឹងអំពីស្ថានភាពអាកាសធាតុតាមប្រភេទ និងតាមតំបន់នៅកម្ពុជា**




ប្រភព÷ Ministry of Environment, *A Third Study Understanding Public Perception of Climate Change in Cambodia, Knowledge, Attitude, and Practice (KAP3),* Ministry of Environment, 2020.

## ខ. កត្តាចម្បងនៃការប្រែប្រួលអាកាសធាតុ

ក្រាហ្វិក ៦៥ បង្ហាញអំពីកត្តាដែលនាំឲ្យមានការប្រែប្រួលអាកាសធាតុ តាមរយៈការសម្ភាសន៍ប្រជាជនកម្ពុជា។ តាមទិន្នន័យបានបង្ហាញថា មូលហេតុដែលនាំឲ្យមានការប្រែប្រួលអាកាសធាតុដែលបណ្តាលមកពីការកាប់បំផ្លាញព្រៃឈើមានចំនួន៧៦% អត្រាភាគរយខ្ពស់ជាងគេលំដាប់ទី១ បន្ទាប់មកសកម្មភាពមនុស្សលំដាប់ទី២មានចំនួន ៥៣% កត្តាធម្មជាតិ៥២% ការបំផ្លាញស្រទាប់អូហ្សូន ៥០% កំណើនប្រជាជន ៤៩% បំលាស់ទីទៅទីក្រុង៣៤% និងពិធីសាសនាដូចជាដុតក្រដាស បណ្តែតសពក្នុងទន្លេ ជាដើមមានចំនួន ៣២% តាមលំដាប់រៀង។

### ក្រាហ្វិក ៦៥. កត្តាចម្បងដែលនាំឱ្យមានការប្រែប្រួលអាកាសធាតុនៅកម្ពុជា




ប្រភព÷ Ministry of Environment, *A Third Study Understanding Public Perception of Climate Change in Cambodia, Knowledge, Attitude, and Practice (KAP3),* Ministry of Environment, 2020.

## គ. ការបំភាយឧស្ម័នផ្ទះកញ្ចក់តាមវិស័យ

យោងតាមរបាយការណ៍ស្ថានភាពបរិស្ថានលើកទី៤ របស់ក្រសួងបរិស្ថានបានបង្ហាញថា ការបំភាយឧស្ម័នផ្ទះកញ្ចក់ដោយការប្រែប្រួលដី និងព្រៃឈើមានចំនួនច្រើនជាងគេ។ នៅឆ្នាំ១៩៩៤ មានចំនួនប្រហែល ៨១,១% ហើយព្យាករណ៍ថា ឆ្នាំ២០២០ មានការថយចុះមកត្រឹម៦៣%។ វិស័យកសិកម្មគឺមានការបំភាយផ្ទះកញ្ចក់លំដាប់ទី២ គឺនៅឆ្នាំ១៩៩៤ មានចំនួន១៥,៥% ហើយបានកើនឡើងនៅឆ្នាំ២០២០ មានចំនួន ២៧,៥%។ វិស័យថាមពលនិង ឧស្សាហកម្ម មានចំនួន ២,៩% នៅឆ្នាំ១៩៩៤ នឹងអាចកើនឡើងដល់ ៩,០% នៅឆ្នាំ២០២០។

## ក្រាហ្វិក ៦៦. ការបំភាយឧស្ម័នផ្ទះកញ្ចក់តាមវិស័យ




ប្រភព៖ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០២១។

សំគាល់៖ ទិន្នន័យឆ្នាំ ២០១០ និងឆ្នាំ ២០២០ គឺជាទិន្នន័យធ្វើចំណោលផ្អែកលើទិន្នន័យឆ្នាំ ២០០២។

## ឃ. ស្ថានភាពទឹកភ្លៀង

ក្រាហ្វិក ៦៧ បង្ហាញអំពីកម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំតាមស្ថានីយ គិតជាមីលីម៉ែត្រ សម្រាប់ទូទាំងប្រទេសកម្ពុជា ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តកំពត និងខេត្តកែប ពីឆ្នាំ២០១១ដល់ ២០២២។ តាមលទ្ធផលបានបង្ហាញថា កម្ពស់ទឹកភ្លៀងនៅប្រទេសកម្ពុជាមានកម្ពស់ខ្ពស់ជាង ២.០០០ មីលីម៉ែត្រ ពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០២២ ខណៈដែលពីឆ្នាំ ២០១១ ដល់២០២០ ស្ថិតនៅចន្លោះពី ១.៣៥៤ មីលីម៉ែត្រ ទៅ ១.៩៣៦ មីលីម៉ែត្រ ហើយនិន្នាការពីឆ្នាំ២០១៩ ទៅ២០២០ មានការកើនឡើងតិចតួច។ ជាទូទៅ ស្ថានភាពទឹកភ្លៀងនៅតំបន់ឆ្នេរសមុទ្រនៅឆ្នាំ២០២២ មានការកើនឡើងខ្ពស់ជាងឆ្នាំ ២០២១ ក្នុងខេត្តកំពត និងកែប តែកោះកុង និងខេត្តព្រះសីហនុមាននិន្នាការធ្លាក់ចុះតិចតួច។

ក្រាហ្វិក ៦៧. កម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំ តាមស្ថានីយគិតជាមីលីម៉ែត្រ




ប្រភព: នាយកដ្ឋានឧត្តុនិយម ក្រសួងធនធានទឹក និង ឧត្តុនិយម

ក្រាហ្វិក ៦៨. បង្ហាញអំពីចំនួនថ្ងៃដែលមានភ្លៀងក្នុងមួយឆ្នាំគិតជាមធ្យម តាមស្ថានីយសម្រាប់ទូទាំងប្រទេស ខេត្តកោះកុង ព្រះសីហនុ កែប និងខេត្តកំពត។ តាមនិន្នាការបានបង្ហាញថា ចំនួនថ្ងៃមានភ្លៀងធ្លាក់គឺច្រើនជាង១០០ ថ្ងៃក្នុងមួយឆ្នាំពីចន្លោះ ១១២ថ្ងៃ ទៅ ១៤៧ថ្ងៃ ពីឆ្នាំ ២០១០ ដល់២០១៨ ហើយនិន្នាការពីឆ្នាំ ២០១៤ ទៅ ២០១៥ មានការថយចុះតិចតួច។ ខេត្តកោះកុង ចំនួនថ្ងៃដែលមានភ្លៀងធ្លាក់ពីចន្លោះ ១៥២ថ្ងៃ ទៅ ១៩៣ថ្ងៃ ពីឆ្នាំ ២០១០ ដល់២០១៨។ ខេត្តព្រះសីហនុ ចំនួនថ្ងៃដែលមានភ្លៀងធ្លាក់ពីចន្លោះ ១៧១ថ្ងៃ ទៅ ១៩៩ថ្ងៃ ពីឆ្នាំ២០១០ ដល់២០១៨ ។ ខេត្តកំពតកែប ចំនួនថ្ងៃដែលមានភ្លៀងធ្លាក់ពីចន្លោះ ១២៣ថ្ងៃ ដល់ ១៨៤ថ្ងៃ។ និន្នាការជារួមចំនួនថ្ងៃនៃស្ថានភាពទឹកភ្លៀងទូទាំងប្រទេសធ្លាក់ចុះបន្តិចពីឆ្នាំ២០២១ទៅឆ្នាំ២០២២ ខណៈដែលតំបន់ឆ្នេរសមុទ្រមានការកើនឡើងពី១៧៧ ដល់១៩៣ថ្ងៃនៅខេត្តកោះកុង ខេត្តកំពតកែបពី ១៦២ ដល់១៨២ថ្ងៃ និងខេត្តព្រះសីហនុពី ១៨១ ដល់ ១៨៩ ថ្ងៃ ពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០២២ ដដែលនេះ។

## ក្រាហ្វិក ៦៨. ចំនួនថ្ងៃមានភ្លៀងក្នុងឆ្នាំគិតជាមធ្យមតាមស្ថានីយ




ប្រភព: នាយកដ្ឋានឧតុនិយម ក្រសួងធនធានទឹក និង ឧតុនិយម

## ខ. សីតុណ្ហភាព

ក្រាហ្វិក ៦៩ បង្ហាញអំពី សីតុណ្ហភាពអប្បបរមានៅទូទាំងប្រទេស ខេត្តព្រះសីហនុ កោះកុង កំពត និងខេត្តកែប។ និន្នាការសីតុណ្ហភាពអប្បបរមានៅទូទាំងប្រទេសស្ថិតនៅចន្លោះពី ១៥,៥អង្សាសេ (°C) ទៅ ២១,៩ អង្សាសេ (°C) ពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០២៣។ នៅឆ្នាំ ២០២៣ នេះ កម្រិតសីតុណ្ហភាពអប្បបរមានៅទូទាំងប្រទេសបានកើនបន្តិចពី ១៧,៣អង្សាសេ (°C) នៅឆ្នាំ២០២២ ដល់ ១៨,៤ អង្សាសេ (°C) នៅឆ្នាំ២០២៣ ខណៈដែលខេត្តពាដែលនៅជាប់ឆ្នេរសមុទ្រក៏មាននិន្នាការដូចគ្នានេះដែរ លើកលែងតែខេត្តកោះកុងពុំមានប្រប្រួល។

### ក្រាហ្វិក ៦៩. សីតុណ្ហភាពអប្បបរមា គិតជាអង្សាសេ




ប្រភព: នាយកដ្ឋានឧត្តុនិយម ក្រសួងធនធានទឹក និង ឧត្តុនិយម

ក្រាហ្វិក ៧០. បង្ហាញអំពី សីតុណ្ហភាពអតិបរមានៅទូទាំងប្រទេស ខេត្តកោះកុង ព្រះសីហនុ កំពត និងខេត្តកែប។ និន្នាការសីតុណ្ហភាពអតិបរមានៅទូទាំងប្រទេស និងខេត្ត៤ដែលស្ថិតនៅក្នុងតំបន់ឆ្នេរសមុទ្រមាននិន្នាការកើនឡើងដូចគ្នា។ ចំពោះនិន្នាការសីតុណ្ហភាពអតិបរមានៅទូទាំងប្រទេសបានកើនពី ៣៦,៤អង្សាសេ (°C) ទៅ ៣៨,៤អង្សាសេ (°C) ពីឆ្នាំ២០២២ ទៅឆ្នាំ២០២៣ ខណៈដែលខេត្តទាំង៤ស្ថិតនៅក្នុងតំបន់ឆ្នេរសមុទ្រមាននិន្នាការសីតុណ្ហភាពអតិបរមាបានកើនពី៣៤អង្សាសេ (°C) ទៅ ៣៦អង្សាសេ (°C) ពីឆ្នាំ២០២២ ទៅឆ្នាំ២០២៣។

## ក្រាហ្វិក ៧០. សីតុណ្ហភាព អតិបរមា គិតជាអង្សាសេ




ប្រភព: នាយកដ្ឋានឧតុនិយម ក្រសួងធនធានទឹក និង ឧតុនិយម

### ច. កម្ពស់ទឹក

នៅក្នុងក្រាហ្វិក ៧១ បង្ហាញអំពីស្ថានភាពទូទៅនៃកម្ពស់ទឹកនៅទន្លេមេគង្គ គិតជាម៉ែត្រពីឆ្នាំ ២០១១ ដល់ ២០២០ តាមស្ថានីយដែលរួមមាន ស្ទឹងត្រែង ក្រចេះ កំពង់ចាម និង បាសាក់។ និន្នាការនៃកម្ពស់ទឹកទន្លេមេគង្គអតិបរមានៅក្នុងឆ្នាំ២០១១ ដល់ ២០២២ មានការប្រែប្រួលឡើងចុះ។ កម្ពស់ទឹកអតិបរមានៅឆ្នាំ ២០២២ មានកម្ពស់១៣,៤ម៉ែត្រ ទាបជាងឆ្នាំ ២០១១ប្រហែល២ម៉ែត្រ ខណៈដែលឆ្នាំ២០២១ កម្ពស់ទឹកអតិបរមាមានកម្ពស់តែ ១១,៦ ម៉ែត្រ ទាបជាងឆ្នាំ ២០២២។ និន្នាការនៃកម្ពស់ទឹកទន្លេមេគង្គអប្បបរមានៅក្នុងឆ្នាំ ២០២២ មានកម្ពស់ ៣,៥ ម៉ែត្រ គឺកើនឡើងកម្ពស់ ១ម៉ែត្រ បើប្រៀបធៀប ឆ្នាំ ២០១១ ដែលមានកម្ពស់ ២,៥ម៉ែត្រ។ កម្ពស់ទឹកអប្បបរមា មានកម្ពស់ខ្ពស់ខ្លាំងនៅក្នុងឆ្នាំ ២០១៨ មានកម្ពស់ ៣,៧ ម៉ែត្រ និង ២០១៩ មានកម្ពស់ ៣,៦ម៉ែត្រ ។

### ក្រាហ្វិក ៧១. ស្ថានភាពកម្ពស់ទឹកនៅទន្លេមេគង្គពីឆ្នាំ ២០១១ ដល់២០២២ គិតជាម៉ែត្រ




ប្រភព៖ នាយកដ្ឋានឧត្តុនិយម ក្រសួងធនធានទឹក និង ឧត្តុនិយម

សំគាល់៖ គិតតែស្ថានីយ៍៤គឺ (១) ស្ទឹងត្រែង (២) ក្រចេះ (៣) កំពង់ចាម និង (៤) ចតុមុខ (បាសាក់)។

នៅក្នុងក្រាហ្វិក ៧២ បង្ហាញអំពីស្ថានភាពទូទៅនៃកម្ពស់ទឹកនៅទន្លេមេគង្គគិតជាម៉ែត្រពីឆ្នាំ១៩៩០ ដល់ ២០២២ តាមស្ថានីយដែលរួមមាន ស្ទឹងត្រែង ក្រចេះ កំពង់ចាម និង បាសាក់។ និន្នានៃកម្ពស់ទឹកទន្លេមេគង្គផ្អែកតាមស្ថានីយខាងលើ មានការប្រប្រួល ប៉ុន្តែជារួមកម្ពស់ទឹកមានការថយចុះមកត្រឹម ១៤ម៉ែត្រ ក្នុងឆ្នាំ ២០២២ នេះ បើទោះបីក្នុងឆ្នាំ២០២២ កម្ពស់ទឹកខ្ពស់ជាងឆ្នាំ ២០២១ ក៏ដោយ។

**ក្រាហ្វិក ៧២. ស្ថានភាពកម្ពស់ទឹកអតិបរមានៅទន្លេមេគង្គពីឆ្នាំ ១៩៩២ ដល់ ២០២២ គិតជាម៉ែត្រ**




ប្រភព÷ នាយកដ្ឋានឧត្តុនិយម ក្រសួងធនធានទឹក និង ឧត្តុនិយម

សំគាល់÷ គិតតែស្ថានីយ៤គឺ (១) ស្ទឹងត្រែង (២) ក្រចេះ (៣) កំពង់ចាម និង (៤) ចតុមុខ (បាសាក់)។

នៅក្នុងក្រាហ្វិក ៧៣. បង្ហាញអំពីស្ថានភាពទូទៅនៃកម្ពស់ទឹកនៅទន្លេមេគង្គ គិតជាម៉ែត្រពីឆ្នាំ ១៩៩០ ដល់ ២០២២ តាមស្ថានីយដែលរួមមាន ស្ទឹងត្រែង ក្រចេះ កំពង់ចាម និង បាសាក់។ និន្នាការជារួម កម្ពស់ទឹកអប្បបរមាមានការប្រប្រួល តែនៅឆ្នាំ ២០២២ មានកម្ពស់អប្បបរមា៣,៥ម៉ែត្រ ខ្ពស់ជាងឆ្នាំ ២០២០ និង ឆ្នាំ២០២១ តែទាបជាងឆ្នាំ២០១៧ ដល់ ឆ្នាំ២០១៩។

## ក្រាហ្វិក ៧៣. ស្ថានភាពកម្ពស់ទឹកអប្បបរមានៅទន្លេមេគង្គពីឆ្នាំ២០១១ ដល់ ឆ្នាំ២០២២គិតជាម៉ែត្រ




ប្រភព÷ នាយកដ្ឋានឧតុនិយម ក្រសួងធនធានទឹក និង ឧតុនិយម

សំគាល់÷ គិតតែស្ថានីយ៤គឺ (១) ស្ទឹងត្រែង (២) ក្រចេះ (៣) កំពង់ចាម និង (៤) ចតុមុខ (បាសាក់)។

នៅក្នុង តារាង ២២ និង ក្រាហ្វិក ៧៤. បង្ហាញអំពីស្ថានភាពទូទៅនៃកម្ពស់ទឹកអប្បបរមា គិតជាម៉ែត្រពីឆ្នាំ២០១១ ដល់ឆ្នាំ២០២២ តាមស្ថានីយ៍ចំនួន៧ ដែលរួមមាន÷ ស្ទឹងត្រែង ក្រចេះ កំពង់ចាម បាសាក់ (ចតុមុខ) អ្នកលឿង កោះខែល និងព្រែកក្តាម។ កម្ពស់ទឹកគិតជាមធ្យមទាំង១២ឆ្នាំ និង៧ ស្ថានីយ៍មានកម្ពស់ ២.៥ម៉ែត្រ។ កម្ពស់ទឹកអប្បបរមាដែលខ្ពស់បំផុតទាំង១២ឆ្នាំ និង ៧ស្ថានីយ៍គឺ ៦,៨ម៉ែត្រ និងទាបបំផុត គឺ ១ម៉ែត្រ។

## តារាង ២២. កម្ពស់ទឹកអប្បបរមាប្រចាំឆ្នាំតាមស្ថានីយពិឆ្នាំ ២០១១ ដល់ឆ្នាំ ២០២២ គិតជាម៉ែត្រ

| ស្ថានីយ | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | Average 12 years |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ស្ទឹងត្រែង | 2.3 | 2.5 | 2.4 | 2.7 | 2.5 | 2.27 | 2.64 | 2.67 | 2.54 | 2.27 | 2.5 | 2.56 | 2.5 |
| ក្រចេះ | 6.5 | 7 | 6.8 | 7.3 | 6.9 | 6.42 | 7.2 | 7.34 | 7.19 | 5.59 | 6.86 | 7 | 6.8 |
| កំពង់ចាម | 2.4 | 2.9 | 2.9 | 3.2 | 2.6 | 2.25 | 2.83 | 2.81 | 2.94 | 2.25 | 2.26 | 2.5 | 2.7 |
| បាសាក់ | 1.9 | 2.1 | 2.1 | 2.2 | 1.6 | 1.59 | 1.85 | 1.99 | 1.77 | 1.44 | 1.73 | 1.84 | 1.8 |
| អ្នកលឿង | 1.3 | 1.3 | 1.4 | 1.5 | 1 | 0.96 | 1.33 | 1.25 | 1.18 | 1.1 | 1.18 | 1.22 | 1.2 |
| កោះខែល | 1.8 | 1.9 | 2 | 2.3 | 1.7 | 1.23 | 1.78 | 1.77 | 1.03 | 1.43 | 1.65 | 1.7 | 1.7 |
| ព្រែកក្តាម | 1.0 | 1.2 | 1.2 | 2.2 | 1 | 0.8 | 1.05 | 1.03 | 1.03 | 0.76 | 0.62 | 1.05 | 1.1 |
| **ជាមធ្យមទាំង 7 ស្ថានីយ** | **2.5** | **2.7** | **2.7** | **3.1** | **2.5** | **2.2** | **2.7** | **2.7** | **2.5** | **2.1** | **2.4** | **2.6** | **2.5** |
| **អតិបរិមាទាំង 7 ស្ថានីយ** | **6.5** | **7** | **6.8** | **7.3** | **6.9** | **6.42** | **7.2** | **7.34** | **7.19** | **5.59** | **6.86** | **7.00** | **6.8** |
| **អប្បរមាទាំង 7 ស្ថានីយ** | **1.0** | **1.2** | **1.2** | **1.5** | **1.0** | **0.8** | **1.1** | **1.0** | **1.0** | **0.8** | **0.6** | **1.1** | **1.0** |

## ក្រាហ្វិក ៧៤. កម្ពស់ទឹកអប្បបរមាប្រចាំឆ្នាំតាមស្ថានីយពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០២២ គិតជាម៉ែត្រ




ប្រភព៖ នាយកដ្ឋានឧត្តុនិយម ក្រសួងធនធានទឹក និង ឧត្តុនិយម

តារាង ២៣ បង្ហាញអំពីស្ថានភាពនៃកម្ពស់ទឹកអតិបរមាប្រចាំឆ្នាំ តាមស្ថានីយ៍ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២២។ កម្ពស់ទឹកអតិបរមាគិតជាមធ្យមទាំង៧ស្ថានីយ៍ និង៧ឆ្នាំ មានកម្ពស់ជាមធ្យម ១០,៧ម៉ែត្រ កម្ពស់ខ្ពស់មបំផុត ២០,៦ម៉ែត្រ និងទាបបំផុត ៦,៤ម៉ែត្រ។

**តារាង ២៣. កម្ពស់ទឹកអតិបរមាប្រចាំឆ្នាំតាមស្ថានីយ៍ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២២ គិតជាម៉ែត្រ**

| Stations | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | Average 7 years |
|---|---|---|---|---|---|---|---|---|
| ស្ទឹងត្រែង | 9.6 | 10.7 | 11.0 | 12.0 | 8.8 | 8.3 | 9.9 | 10.0 |
| ក្រចេះ | 20.0 | 21.3 | 22.3 | 22.7 | 19.1 | 18.5 | 20.5 | 20.6 |
| កំពង់ចាម | 13.3 | 14.6 | 15.6 | 15.8 | 12.5 | 11.9 | 13.8 | 13.9 |
| បាសាក់ | 8.1 | 8.9 | 10.0 | 9.5 | 7.7 | 7.6 | 9.2 | 8.7 |
| អ្នកលឿង | 5.9 | 6.4 | 7.5 | 7.0 | 5.7 | 5.5 | 6.7 | 6.4 |
| កោះខែល | 6.9 | 7.5 | 7.8 | 7.7 | 6.9 | 6.7 | 7.7 | 7.3 |
| ព្រែកក្ដាម | 7.1 | 7.8 | 9.1 | 8.0 | 6.6 | 6.6 | 8.5 | 7.7 |
| **ជាមធ្យមទាំង 7 ស្ថានីយ** | **10.1** | **11.0** | **11.9** | **11.8** | **9.6** | **9.3** | **10.9** | **10.7** |
| **អតិបរិមាទាំង 7 ស្ថានីយ** | **20.0** | **21.3** | **22.3** | **22.7** | **19.1** | **18.5** | **20.5** | **20.6** |
| **អប្បរមាទាំង 7 ស្ថានីយ** | **5.9** | **6.4** | **7.5** | **7.0** | **5.7** | **5.5** | **6.7** | **6.4** |

**ក្រាហ្វិក ៧៥. កម្ពស់ទឹកអតិបរមាប្រចាំឆ្នាំតាមស្ថានីយ៍ពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០២២ គិតជាម៉ែត្រ**




ប្រភព÷ នាយកដ្ឋានឧតុនិយម ក្រសួងធនធានទឹក និង ឧតុនិយម

## ឆ. ផលប៉ះពាល់វិស័យសេដ្ឋកិច្ច

ការប្រែប្រួលអាកាសធាតុបានបណ្តាលឲ្យមានគ្រោះមហន្តរាយកើតឡើងនៅលើពិភពលោកដូចជា រលកយក្សស៊ូណាមី ទឹកជំនន់ គ្រោះរាំងស្ងួត និងខ្យល់ព្យុះ ហើយធ្វើឲ្យប៉ះពាល់ដល់វិស័យសេដ្ឋកិច្ចជាតិនៃប្រទេសដែលបានទទួលរងគ្រោះដោយសារគ្រោះមហន្តរាយ។ ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាបានធ្វើការវាយតម្លៃអំពីផលប៉ះពាល់អំពីការខូចខាត និងការបាត់បង់ដោយសារឥទ្ធិពលនៃព្យុះកេតសាណា (Ketsana) ។ ការវាយតម្លៃត្រូវបានធ្វើឡើងនៅឆ្នាំ ២០១០ ទៅលើខេត្តចំនួន១៤ ក្នុងចំណោមខេត្តទាំង២៤ របស់ប្រទេសកម្ពុជា។ ការសិក្សាបានប៉ាន់ប្រមាណ ខ្យល់ព្យុះបានបំផ្លាញមុខរបរការចិញ្ចឹមជីវិត និ ផ្ទះសម្បែង របស់ប្រជាជនកម្ពុជាចំនួន ១,៤% នៃចំនួនប្រជាជនសរុប។

តារាង ២.១៨បង្ហាញអំពីការខាតបង់ផ្នែកសេដ្ឋកិច្ចបែងចែកតាមវិស័យឆ្នាំ២០០៩។ តាមទិន្នន័យបានបង្ហាញថាសរុបនៃការខូចខាត និងការបាត់បង់មានទំហំទឹកប្រាក់សរុបចំនួន ១៣១.៩៩៦.៤១៥ ដុល្លារសហរដ្ឋអាមេរិក ក្នុងនោះផលប៉ះពាល់ខ្លាំងលើវិស័យផលិតកម្មមានទំហំទឹកប្រាក់រហូតដល់ ៦០.០៥៩.២៨៦ ដុល្លារសហរដ្ឋអាមេរិក វិស័យសង្គមកិច្ចមានទំហំទឹកប្រាក់ ៤២.៨៨២.៣៧៦ ដុល្លារសហរដ្ឋអាមេរិក វិស័យហេដ្ឋារចនាសម្ព័ន្ធមានទំហំទឹកប្រាក់សរុប ២៨.៧៤៧.៦២៨ ដុល្លារសហរដ្ឋអាមេរិក និង អន្តរវិស័យមានចំនួន ៣០៨.១២៥ ដុល្លារសហរដ្ឋអាមេរិក។

ក្រាហ្វិក ៧៦ បង្ហាញអំពីភាគរយនៃការខាតបង់ផ្នែកសេដ្ឋកិច្ច បែងចែកតាមវិស័យឆ្នាំ២០០៩។ វិស័យដែលទទួលរងការខូចខាតធំជាងគេ គឺវិស័យផលិតកម្មមានចំនួន ៤៥,៥% វិស័យសង្គមកិច្ចមានចំនួន៣២,៥% វិស័យហេដ្ឋារចនាសម្ពន្ធ័មានចំនួន ២១,២% និងអន្តរវិស័យមានចំនួន ០,២%។

## តារាង ២៤. ការខាតបង់ផ្នែកសេដ្ឋកិច្ចបែងចែកតាមវិស័យ ឆ្នាំ២០០៩

| វិស័យនិងអនុវិស័យ | ផលប៉ះពាល់ដោយគ្រោះមហន្តរាយគិតជាដុល្លារ (US$) | | |
|---|---|---|---|
| | ការខូចខាត | ការបាត់បង់ | សរុប |
| **វិស័យហេដ្ឋារចនាសម្ព័ន្ធ** | **17,259,051** | **11,487,577** | **28,746,628** |
| ផ្លូវ | 14,388,832 | 11,076,698 | 25,465,530 |
| ការផ្គត់ផ្គង់ទឹកនិងអនាម័យ | 64,339 | 392,689 | 457,028 |
| ការគ្រប់គ្រងទឹកនិងប្រព័ន្ធស្រោចស្រព | 2,779,000 | 13,000 | 2,792,000 |
| ថាមពល | 26,880 | 5,190 | 320,170 |
| **វិស័យសង្គមកិច្ច** | **39,548,563** | **3,333,813** | **42,882,376** |
| ផ្ទះនិងទីជម្រក | 15,281,952 | 3,294,398 | 18,576,350 |
| សុខាភិបាល | 57,072 | 39,415 | 96,487 |
| អប់រំ | 24,209,539 | - | 24,209,539 |
| **វិស័យផលិតកម្ម** | **1,051,124** | **59,008,162** | **60,059,286** |
| កសិកម្មចិញ្ចឹមសត្វនិងនេសាទ | 91,270 | 56,420,846 | 56,512,116 |
| ឧស្សាហកម្មនិងនេសាទ | 959,854 | 2,587,316 | 3,547,170 |
| **អន្តរវិស័យ** | **205,358** | **102,767** | **308,125** |
| បរិស្ថាន | 31,073 | 98,367 | 129,440 |
| គ្រប់គ្រងសាធារណៈ | 174,285 | 4,400 | 178,685 |
| **សរុប** | **58,064,096** | **73,932,319** | **131,996,415** |

ប្រភព៖ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ២០២១។

## ក្រាហ្វិក ៧៦. ភាគរយនៃការខាតបង់ផ្នែកសេដ្ឋកិច្ចបែងចែកតាមវិស័យ ឆ្នាំ២០០៩




ប្រភព៖ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០២១។

## ២.២ ស្ថានភាពទូទៅផ្អែកលើទិន្នន័យពីផ្កាយរណប

យោងតាមការចែករំលែកទិន្នន័យពីអង្គការ NASA របស់សហរដ្ឋអាមេរិកតាមរយៈផ្កាយរណប Sentinel 2 បានផ្តល់ទិន្នន័យទាក់ទងផ្ទៃដីគ្របដណ្តប់តាមប្រទេសនីមួយៗ។ ប្រទេសកម្ពុជាយើងគឺត្រូវបានផ្តលទិន្នន័យតាមរយៈផ្កាយរណប Sentinel 2 ពីឆ្នាំ ២០១៧ ដល់ ២០២២ ហើយសម្រាប់ឆ្នាំ ២០២៣ អាចមានទិន្នន័យនៅក្នុងដើមឆ្នាំ ២០២៤ តាមការអះអាងរបស់មន្ត្រីដែលទាក់ទងការផ្តល់ទិន្នន័យខាងលើ។

### ២.២.១ ផ្ទៃដីគ្របដណ្តប់ (Land Cover)

នៅក្នុងផែនទី ៧ បង្ហាញអំពីស្ថានភាពផែនទីផ្ទៃដីដែលបានគ្របដណ្តប់ សម្រាប់ប្រទេសកម្ពុជា និងប្រទេសផ្សេងៗទៀតដែលមានព្រំប្រទល់ជាប់ប្រទេសកម្ពុជា ហើយក្នុងនោះក៏បានបង្ហាញអំពីពណ៌មានបៃតង ខៀវ ក្រហម លឿង និងពណ៌ប្រផេះដែលតំណាងដូចកំណត់សំគាល់ខាងក្រោម តាមរយៈផ្កាយរណប Sentinel 2 របស់អង្គការ NASA បានផ្តល់ឲ្យ។

**ផែនទី ៧. ផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជានិងប្រទេសផ្សេងៗទៀតឆ្នាំ ២០២២**



នៅក្នុងផែនទី ៨ បានបង្ហាញអំពីភាគរយនៃផ្ទៃដីរបស់ប្រទេសកម្ពុជានៅឆ្នាំ២០២២ តាមរយៈផ្កាយរណប Sentinel 2 របស់អង្គការ NASA។ រូបភាព ២.៨៣ បង្ហាញថាផ្ទៃដីគ្របដណ្តប់សម្រាប់ប្រទេសកម្ពុជាឆ្នាំ២០២២ បានគ្របដណ្តប់ដោយផ្ទៃទឹក (Water) មានប្រហែល ២០% គ្របដណ្តប់ដោយដើមឈើ (Tree) មានប្រហែល ៣៦% គ្របដណ្តប់ដោយទឹកជំនន់ (Flooded) 0,៨% គ្របដណ្តប់ដោយដាំដំណាំ (Crop) មានប្រហែល ២៨% គ្របដណ្តប់ដោយដីដែលបានសាងសង់សំណង់ផ្សេងៗ (Built) មានប្រហែល ៦% និងដីវាលឬ វាលស្មៅ (Rangeland) មានប្រហែល ៩%។

**ផែនទី ៨. ផ្ទៃដីគ្របដណ្តប់សម្រាប់ប្រទេសកម្ពុជាឆ្នាំ ២០២២**




## ក. ស្ថានភាពគ្របដំណប់លើផ្ទៃដីពីឆ្នាំ ២០១៧ ដល់ឆ្នាំ២០២២

អង្គការ NASA បានថត និងរក្សាទិន្នន័យទុកទិន្នន័យតាមរយៈផ្កាយរណប Sentinel 2 របស់ប្រទេសនីមួយៗ ជាច្រើនឆ្នាំ។ ចំពោះប្រទេសកម្ពុជា អង្គការ NASA បានថត និងរក្សាទិន្នន័យទុក

ទិន្នន័យចាប់ពីឆ្នាំ២០១៧ រហូតដល់ឆ្នាំ ២០២២ និងឆ្នាំ២០២៣ អាចមាននៅដើមឆ្នាំ២០២៤ខាងមុខ។ នេះប្រហែលជាការប្រមូលទិន្នន័យតាមផ្កាយរណបគឺចាប់ផ្តើមពីខែមករា ដល់ខែធ្នូ ទើបបូកសរុបរួមក្នុងមួយឆ្នាំតែម្តង។

### ក.១.១ ផែនទីផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាពីឆ្នាំ ២០១៧ ដល់ ២០២២

#### ១). ផែនទីផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាឆ្នាំ ២០១៧

**ផែនទី ៩. ផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាឆ្នាំ ២០១៧**



២). ផែនទីផ្ទៃដីគ្របដណ្ដប់ប្រទេសកម្ពុជាឆ្នាំ២០១៨

ផែនទី ១០. ផ្ទៃដីគ្របដណ្ដប់ប្រទេសកម្ពុជាឆ្នាំ២០១៨



៣). ផែនទីផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាឆ្នាំ២០១៩

ផែនទី ១១. ស្ថានភាពផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាឆ្នាំ២០១៩



### ៤). ផែនទីផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាឆ្នាំ២០២០

ផែនទី ១២. ស្ថានភាពផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាឆ្នាំ២០២០



### ៥). ផែនទីផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាឆ្នាំ២០២១

ផែនទី ១៣. ស្ថានភាពផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាឆ្នាំ២០២១



៦). ផែនទីផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជា ឆ្នាំ២០២២

ផែនទី ១៤. ស្ថានភាពផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជា និងផ្ទៃដីគ្របដណ្តប់ភាគខាងត្បូងប្រទេសវៀតណាមឆ្នាំ២០២២



## ២.២.២ ស្ថានភាពផ្ទៃដីគ្របដណ្តប់ពីឆ្នាំ ២០១៧ ដល់ ២០២៣ សម្រាប់ប្រទេសកម្ពុជា

ក្រាហ្វិក ៧៧ បានបង្ហាញថា ស្ថានភាពទឹកពីឆ្នាំ ២០១៧ ដល់ ឆ្នាំ ២០២២ មានភាគរយ២០% នៅដដែល ខណៈព្រៃឈើមានភាគរយ៣៩%នៅឆ្នាំ ២០១៧ ហើយថយចុះមកត្រឹម៣៦% នៅឆ្នាំ ២០២២នៃផ្ទៃដីទាំងអស់របស់ប្រទេសកម្ពុជា។ ចំពោះស្ថានភាពទឹកជំនន់នៅឆ្នាំ ២០១៧ មានចំនួន ១% ហើយបានថយចុះតិចតួចមានចំនួន ០,៨%នៅឆ្នាំ ២០២២ ប៉ុន្តែដីដែលបានដាំដំណាំបានកើនឡើងពី២៧%នៅឆ្នាំ ២០១៧ កើនបន្តិចដល់២៨%នៅឆ្នាំ២០២២ និង ផ្ទៃដីដែលបានសាងសង់មានចំនួន ៤%នៅឆ្នាំ ២០១៧ បានកើនដល់៦%នៅឆ្នាំ ២០២២។ ចំពោះស្ថានភាពផ្ទៃដីវាល ឬ វាលស្មៅមានចំនួន៩% នៅឆ្នាំ២០១៧ បានកើនខ្ពស់ដល់១៣%នៅឆ្នាំ ២០២០ ហើយបានថយមកត្រឹម៩%នៅឆ្នាំ២០២២ដូចឆ្នាំ២០១៧វិញ។

**ក្រាហ្វិក ៧៧. ភាគរយស្ថានភាពនៃផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាឆ្នាំ២០១៧ ដល់ឆ្នាំ ២០២២**



### ២.២.៣ ស្ថានភាពផ្ទៃដីគ្របដណ្តប់ប្រទេសផ្សេងៗឆ្នាំ ២០២២

#### ក. ប្រទេសវៀតណាមឆ្នាំ ២០២២

ផែនទី ១៥. ផ្ទៃដីគ្របដណ្តប់ប្រទេសវៀតណាមឆ្នាំ២០២២



## ខ. ប្រទេសឡាវឆ្នាំ២០២២

ផែនទី ១៦. ស្ថានភាពផ្ទៃដីគ្របដណ្តប់ប្រទេសឡាវឆ្នាំ២០២២



## គ. ប្រទេសថៃឆ្នាំ២០២២

ផែនទី ១៧. ស្ថានភាពផ្ទៃដីគ្របដណ្ដប់ប្រទេសឡាវឆ្នាំ២០២២



ក្រាហ្វិក ៧៨ បង្ហាញអំពីការប្រៀបធៀបរវាងប្រទេសកម្ពុជានិងប្រទេសដែលមានព្រំប្រទល់ជាប់នឹងប្រទេសកម្ពុជាលើផ្ទៃដីដែលគ្របដណ្តប់នៅឆ្នាំ២០២២។ តាមទិន្នន័យដែលទទួលបានពីផ្កាយរណបគឺ ផ្ទៃដីដែលគ្របដណ្តប់ដោយផ្ទៃទឹក គឺប្រទេសថៃមានផ្ទៃដីគ្របដណ្តប់ដោយផ្ទៃទឹកធំជាងគេមានចំនួន ២១% កម្ពុជាមានចំនួន២០% វៀតណាមមានចំនួន១៧% និងតិចជាងគេ គឺប្រទេសឡាវមានចំនួនប្រហែល១០%។ ផ្ទៃដីដែលគ្របដណ្តប់ព្រៃឈើ គឺប្រទេសវៀតណាមមានចំនួន ៤៤% ឡាវ ៤១% កម្ពុជាមានចំនួន៣៦% និងប្រទេសថៃមានចំនួន៣៥%។ ផ្ទៃដីដែលទទួលរងដោយគ្រោះដោយទឹកជំនន់ ប្រទេសកម្ពុជាមានផ្ទៃដីប្រហែល ០,៨% វៀតណាម ០,៥% ថៃ០,៥% និងប្រទេសឡាវ០,៤%។ ផ្ទៃដីដែលបានគ្របដណ្តប់ដោយការដាំដំណាំ គឺប្រទេសឡាវមានចំនួន២៩% កម្ពុជាមានចំនួន២៨% ថៃមានចំនួន២៧% និងប្រទេសវៀតណាមមានចំនួន២២%។ ផ្ទៃដីដែលគ្របដណ្តប់ដោយសំណង់ផ្សេងៗគឺប្រទេសឡាវមានចំនួន៧% កម្ពុជា៦% វៀតណាម៦% និងប្រទេសថៃ៥%។ ផ្ទៃដីដែលគ្របដណ្តប់ដោយទីវាលដែលមានរុក្ខជាតិដុះសម្រាប់សត្វគឺប្រទេសឡាវមានចំនួន១២% វៀតណាមមានចំនួន ១១% ថៃមានចំនួន១១% និងកម្ពុជាមានចំនួន៩%។ ភាគរយផ្ទៃដីដែលរៀបរាប់ខាងលើនេះ គឺធៀបទៅនឹងចំនួនផ្ទៃដីសរុបរបស់ប្រទេសនីមួយៗ។

**ក្រាហ្វិក ៧៨. ប្រៀបធៀបភាគរយស្ថានភាពនៃផ្ទៃដីគ្របដណ្តប់ជាមួយប្រទេសជិតខាងឆ្នាំ២០២២**



# ជំពូក ៣
# ការវិភាគលទ្ធផលផ្អែកលើទិន្នន័យទី១

## ៣.១ ព័ត៌មានទូទៅ

### ៣.១.១ គ្រួសារ

នៅក្នុងការចុះសម្ភាសន៍ស្រង់ទិន្នន័យជាក់ស្តែងនៅក្នុងខេត្តកេប និង ខេត្តកំពត សម្រាប់តំបន់ឆ្នេរសមុទ្រ ។ តារាងបញ្ជីសំណួរ ២ ត្រូវបានប្រើប្រាស់មានតារាងបញ្ជីសំណួរសម្រាប់សួរទៅមេភូមិនូវព័ត៌មាននៅក្នុងភូមិទាំងមូល និងតារាងបញ្ជីសំណួរសម្រាប់សួរមេគ្រួសារ។ តារាងទី១ គឺបានសួរមេភូមិចំនួន ១០ ភូមិក្នុងភូមិគោលដៅ និងតារាងទី២ គឺសម្ភាសន៍មេគ្រួសារផ្ទាល់ដែលមាន គ្រួសារចំនួន ៦០០ គ្រួសារ ក្នុងចំណោមគ្រួសារសរុប ៣.៤៦០ គ្រួសារ ត្រូវបានសម្ភាសន៍ដោយផ្អែកទៅលើចំនួនថវិកាដែលទទួលបាននៅមានកម្រិត។ តារាង ២៥ បញ្ជីភូមិ និងចំនួនគ្រួសារដែលត្រូវសម្ភាសន៍ ដូចខាងក្រោម។

**តារាង ២៥. បញ្ជីភូមិ និងចំនួនគ្រួសារដែលត្រូវសម្ភាសន៍**

| ល.រ | ខេត្ត | ស្រុក | ឃុំ | ភូមិ | ចំនួនគ្រួសារ | ចំនួនគ្រួសារត្រូវសម្ភាសន៍ |
|---|---|---|---|---|---|---|
| ១ | កែប | ដំណាក់ចង្អើរ | ពងទឹក | អរជ្ជុង | 348 | 60 |
| | | | | ព្រៃកតាកុយ | 289 | 60 |
| | | | | ភ្នំលាវ | 894 | 60 |
| | | | | រនេស | 303 | 60 |
| | | | | ចំការបី | 391 | 60 |
| ២ | កំពត | | ព្រៃឃ្មុំ | ព្រៃតុម្ព | 404 | 60 |
| | | | | បឹងតារោង | 252 | 60 |
| | | | ត្រពាំងធំ | ត្រពាំងជ្រៃ | 196 | 60 |
| | | | | ក្រាំង | 162 | 60 |
| | | | | ស្វាយធំ | 221 | 60 |
| **សរុប** | | | | | **3,460** | **600** |

ក្រាហ្វិក ៧៩ ភាគរយចំនួនមេភូមិដែលបានសម្ភាសន៍ទាំង១០ភូមិ។ ក្នុងចំណោមមេភូមិទាំង ១០ មានចំនួន ៩០% ដឹកនាំដោយមេភូមិជាបុរស និង ១០% ភាគរយដឹកនាំដោយស្ត្រី។

**ក្រាហ្វិក ៧៩. ភាគរយចំនួនមេភូមិដែលបានសម្ភាសន៍**




ក្រាហ្វិក ៨០ បង្ហាញអំពីភាគរយនៃមេគ្រួសារដែលបានសម្ភាន៍នៅក្នុងខេត្តកែប និងខេត្តកំពត ដែលមានចំនួនមេគ្រួសារសរុប ៦០០នាក់។ ក្នុងនោះមេគ្រួសារជាបុរសមានចំនួន៤៤៥នាក់ ស្មើនឹង ៧៤% និងចំនួនមេគ្រួសារជាស្ត្រីមានចំនួន១៥៥នាក់ ស្មើនឹង ២៦%។

### ក្រាហ្វិក ៨០. ភាគរយមេគ្រួសារដែលបានសម្ភាសន៍




តារាង ២៦ បង្ហាញអំពីចំនួនគ្រួសារតាមក្រុមអាយុ។ ក្នុងចំណោមមេគ្រួសារទាំងអស់ចំនួន ៦០០ នាក់ ក្នុងនោះមានបុរសជាមេគ្រួសារចំនួន ៤៤៥នាក់ (៧៦%) ហើយស្ត្រីជាមេគ្រួសារមានចំនួន ១៥៥ នាក់ (២៦%) ដែលបានចុះសម្ភាសន៍ផ្ទាល់នៅក្នុងភូមិគោលដៅ ។ តាមតួលេខ ចំនួនមេគ្រួសារក្រុមអាយុពី៤០ ដល់ ៥៩ ឆ្នាំ មានចំនួន ២៦៣នាក់(៤៤%) មេគ្រួសារស្ថិតក្នុងក្រុមអាយុ ១៥ ដល់ ៣៩ ឆ្នាំ មានចំនួន ១៩៣ នាក់ (៣២%) និង មេគ្រួសារស្ថិតក្នុងក្រុមអាយុ ៦០ឆ្នាំ ឡើងមានចំនួន ១៤៤នាក់ (២៤%) បើប្រៀបធៀបទៅនឹងចំនួនមេគ្រួសារសរុប។ ចំនួនភាគរយមេគ្រួសារក្នុងក្រុមអាយុពី ៤០ ដល់ ៥៩ នាក់មានចំនួនច្រើនជាងគេ បន្ទាប់មកអាយុចាប់ពី១៥ឆ្នាំដល់៣៩ឆ្នាំ និង មានចំនួនតិចជាងគេគឺ អាយុ៦០ឆ្នាំ ឡើង។ រូបភាព ៣.២ បង្ហាញអំពីភាគរយមេគ្រួសារតាមក្រុមអាយុនិងភេទ។

តារាង ២៦. ចំនួនមេគ្រួសារ បែងចែកតាមក្រុមអាយុ

| ក្រុមអាយុ | ភេទមេគ្រួសារ | | |
|---|---|---|---|
| | ប្រុស | ស្រី | ទាំងពីរភេទ |
| ១៥ ដល់ ៣៩ឆ្នាំ | 162 | 31 | 193 |
| ៤០ ដល់ ៥៩ឆ្នាំ | 193 | 70 | 263 |
| ៦០ឆ្នាំ ឡើង | 90 | 54 | 144 |
| **សរុប** | **419** | **181** | **600** |

ក្រាហ្វិក ៨១. បង្ហាញអំពីភាគរយមេគ្រួសារតាមក្រុមអាយុនិងភេទ



### ៣.១.២ ទំហំគ្រួសារ

ក្រាហ្វិក ៨២ បង្ហាញថា ចំនួនសមាជិកគ្រួសារជាមធ្យម ផ្អែកតាមលទ្ធផលចុងក្រោយ ជំរឿនទូទៅប្រជាជនឆ្នាំ១៩៩៨ ឆ្នាំ ២០០៨ និង ឆ្នាំ ២០១៩។ តាមទិន្នន័យបង្ហាញថា សមាជិកគ្រួសារជាមធ្យមនៅទូទាំងប្រទេសមានចំនួន ៥,៧នាក់ នៅឆ្នាំ១៩៩៨ បានធ្លាក់ចុះមក ៤,៧ នាក់នៅឆ្នាំ ២០០៨ និងបន្តធ្លាក់ចុះ៤,៣នាក់ នៅឆ្នាំ២០១៩។ នៅក្នុងខេត្តកំពតមានចំនួនសមាជិកជាមធ្យមក្នុងគ្រួសារចំនួន ៥,០នាក់ នៅឆ្នាំ១៩៩៨ បានធ្លាក់ចុះមកត្រឹម ៤,៥ និងបន្តធ្លាក់ចុះមកត្រឹម ៤,១ នៅឆ្នាំ២០១៩ ខណៈខេត្តកែបមានទំហំប្រជាជនជាមធ្យម៥,៣នាក់ ក្នុងឆ្នាំ១៩៩៨ បានធ្លាក់ចុះមកត្រឹម ៤,៩នាក់ នៅឆ្នាំ២០០៨ និង បន្តធ្លាក់ចុះមកត្រឹម ៤,៣ នៅឆ្នាំ២០១៩។

**ក្រាហ្វិក ៨២. បង្ហាញអំពីចំនួនសមាជិកគ្រួសារគិតជាមធ្យមឆ្នាំ១៩៩៨, ២០០៨ និង ឆ្នាំ២០១៩**




*ប្រភព៖ - ជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជាឆ្នាំ១៩៩៨*
*- ជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជាឆ្នាំ២០០៨*
*- ជំរឿនទូទៅនូវប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩។*

ក្រាហ្វិក ៨៣ បង្ហាញថា ចំនួនសមាជិកគ្រួសារជាមធ្យម ផ្អែកតាមការចុះសម្ភាសន៍ផ្ទាល់ជាមួយនឹងមេគ្រួសារ ៦០០ នាក់ ក្នុងនោះខេត្តកំពតមានចំនួនមេគ្រួសារ ៣០២នាក់ និង ខេត្តកែបមានចំនួនមេគ្រួសារ ២៩៨នាក់ ។ ជាលទ្ធផលបញ្ជាក់ថា ចំនួនសមាជិកគ្រួសារជាមធ្យមសរុបនៃខេត្តទាំង២ មានចំនួនសមាជិកគិតជាមធ្យម ៥,៥នាក់ ក្នុងមួយគ្រួសារ ខេត្តកំពតមានចំនួន ៤,៣ ទាបជាងសមាជិកគិតជាមធ្យមសរុបចំនួន ១,២ នាក់ និងខេត្តកែបមានចំនួនសមាជិកជាមធ្យម ៤,៥ ខ្ពស់ជាងខេត្តកំពត និងទាបជាងសមាជិកមធ្យមសរុបទាំងពីរខេត្ត ១,០នាក់។ ចំពោះខេត្តដែលបានចុះសម្ភាសន៍ផ្ទាល់មានចំនួនសមាជិកក្នុងគ្រួសារគិតជាមធ្យម គឺខ្ពស់ជាងចំនួនសមាជិកគិតជាមធ្យមនៅទូទាំងប្រទេសចំនួន ១,២ បើប្រៀបធៀបជាមួយនឹងចំនួនសមាជិកគិតជាមធ្យមទូទាំងប្រទេសឆ្នាំ២០១៩ ដែលបានពីលទ្ធផលនៃការធ្វើជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩។

**ក្រាហ្វិក ៨៣. បង្ហាញអំពីចំនួនសមាជិកគ្រួសារគិតជាមធ្យមឆ្នាំ២០២៣ (ការសម្ភាសន៍ជាក់ស្តែង)**



### ៣.១.៣ ចំណាកស្រុក

ទិន្នន័យនៅក្នុង តារាង ២៧ បង្ហាញថា ចំនួនប្រជាជន ៣៤ នាក់ ស្មើនឹង ៤,៩ ភាគរយ នៅក្នុងចំណោមប្រជាជន ២.៦៤៩នាក់ ដែលបានធ្វើចំណាកស្រុកទាំងក្នុង និងក្រៅប្រទេស។ នៅក្នុងចំណោមប្រជាជន ១៣០នាក់ ដែលបានធ្វើចំណាកស្រុកនោះ មានចំនួនប្រជាជន ១២៧នាក់បានធ្វើចំណាកស្រុកក្នុងប្រទេសស្មើនឹង ៩៧,៧ភាគរយ ធៀបជាមួយនឹងចំនួនប្រជាជនចំណាកស្រុកសរុប និងស្មើនឹង ២,៣ ភាគរយ បានធ្វើចំណាកស្រុកក្រៅប្រទេសធៀបនឹងចំនួនប្រជាជនចំណាកស្រុកសរុប។

**តារាង ២៧. ចំនួនសមាជិកអចិន្ត្រៃយ៍ និង សមាជិកចំណាកស្រុក**

| អធិប្បាយ | ប្រុស | ស្រី | សរុប |
|---|---|---|---|
| **សមាជិកអចិន្ត្រៃយ៍** | 1,289 | 1,360 | 2,649 |
| **សមាជិកចំណាកស្រុក** | 67 | 63 | 130 |
| សមាជិកចំណាកស្រុកក្នុងប្រទេស | 66 | 61 | 127 |
| សមាជិកចំណាកស្រុកក្រៅប្រទេស | 1 | 2 | 3 |

ក្រាហ្វិក ៨៤ បង្ហាញថា ភាគរយចំណាកស្រុកទាំងពីរភេទនៅក្នុងប្រទេសមានចំនួន ៩៧,៧% និង ក្រៅប្រទេសមានចំនួន ២,៣%។ ចំពោះសមាជិកចំណាកស្រុកក្នុងប្រទេសភេទប្រុសមានចំនួន ៩៨,៥ % ខណៈដែលការធ្វើចំណាកស្រុកទៅក្រៅប្រទេសមានតែ ១,៥ % ក្នុងចំណោមចំណាក់ស្រុកភេទប្រុសសរុប។ ចំណែកឯសមាជិកគ្រួសារភេទស្រី ដែលបានធ្វើចំណាកស្រុកនៅក្នុងប្រទេសមានចំនួន ៩៦,៨% និងចំណាកស្រុកក្រៅប្រទេស ៣,២% ក្នុងចំណោមចំណាកស្រុកភេទស្រី។

## ក្រាហ្វិក ៨៤. ភាគរយសមាជិកគ្រួសារធ្វើចំណាកស្រុកក្នុងនិងក្រៅប្រទេសបែងចែកតាមភេទ









## ក.ចំណាកស្រុកក្នុងប្រទេស

ការធ្វើចំណាកស្រុកសំដៅការផ្លាស់ប្តូរទីលំនៅដ្ឋានពីភូមិមួយទៅភូមិមួយទៀត បើទោះបីនៅក្នុងខេត្តតែមួយក៏ដោយ។ ទិន្នន័យក្នុងក្រាហ្វិក ៨៥ បានបង្ហាញអំពីសមាជិកគ្រួសារបានធ្វើចំណាកស្រុកពីខេត្តកែបនិងខេត្តកំពតទៅតាមរាជធានីខេត្តតាមភេទនៃសមាជិកចំណាកស្រុក។ តាមទិន្នន័យបង្ហាញថា ខេត្តព្រះសីហនុមានចំណាកស្រុកខ្ពស់ជាងគេមានចំនួន ៥៩នាក់ ប្រុស ២៩នាក និងស្រី ៣០នាក់ ស្ថិតក្នុងលំដាប់ទី១ និងរាជធានីភ្នំពេញមានចំណាកស្រុកសរុប៥២នាក់ ប្រុស ២៨នាក់ និងស្រី២៤នាក់ ស្ថិតក្នុងលំដាប់ទី២ ខេត្តកំពតនិងកោះកុងស្ថិតក្នុងលំដាប់ទី៣ ហើយខណៈចំណាកស្រុកទៅកាន់ខេត្តតាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង និងកំពង់ចាម មានចំនួនតិចជាងខេត្តដែលបានរៀបរាប់ខាងលើ។

**ក្រាហ្វិក ៨៥. ចំនួនសមាជិកគ្រួសារបានធ្វើចំណាកស្រុកទៅតាមរាជធានីខេត្ត និងតាមភេទ**



## ក១.មូលហេតុនៃចំណាកស្រុកក្នុងប្រទេស

ក្រាហ្វិក ៨៦ បង្ហាញអំពីមូលហេតុដែលសមាជិកនៅក្នុងគ្រួសារបានធ្វើចំណាកស្រុកទៅតាមរាជធានីខេត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ទិន្នន័យនេះបានបង្ហាញថាចំនួនសមាជិកបានធ្វើចំណាកស្រុកទាំងពីរភេទដោយសារតែការស្វែងរកការងារធ្វើមានចំនួនច្រើនជាងគេមានចំនួន ១០៣នាក់(៨១,១%) ប្តូរទីកន្លែងការងារមានចំនួន១៤នាក់(១១%) និងការសិក្សាមានចំនួន១០នាក់(៧,៩%%) ក្នុងចំណោមមូលហេតុនៃការចំណាកស្រុកក្នុងប្រទេស ។ សមាជិកភេទប្រុសដែលស្វែងរកការងារធ្វើមានចំនួន ៤៨នាក់ (៧២,៧%) ប្តូរទីកន្លែងការងារ ១១នាក់ (១៦,៧%) និងការសិក្សាមានចំនួន ៧នាក់ (១០,៦%) ខណៈដែលភេទស្រី ស្វែងរកការងារធ្វើមានចំនួន៥៥នាក់ (៩០,២%%) ប្តូរទីកន្លែងការងារនិងការសិក្សាមានចំនួនស្មើគ្នាមានចំនួន៣នាក់(៤,៩%)។ បើប្រៀបធៀបចំនួនចំណាកស្រុកតាមភេទនីមួយៗ។

**ក្រាហ្វិក ៨៦. ភាគរយសមាជិកចំណាកស្រុកក្នុងប្រទេសតាមមូលហេតុ**




## ខ.ចំណាកស្រុកក្រៅប្រទេស

ក្រាហ្វិក ៨៧ បង្ហាញថា ចំនួនសមាជិកដែលបានធ្វើចំណាកស្រុកទៅប្រទេសថៃមានចំនួន ១នាក់ (៣៣%) និងទៅប្រទេសកូរ៉េខាងត្បូងមានចំនួន២នាក់ (៦៧%) ក្នុងចំណោមចំនួនសមាជិកចំណាកស្រុកក្រៅប្រទេសសរុប៣នាក់ ។ ក្នុងចំណោមចំណាកស្រុកក្រៅប្រទេសភេទប្រុស១នាក់ បានធ្វើចំណាកស្រុកទៅប្រទេសកូរ៉េខាងត្បូង ខណៈដែលក្នុងចំណោមចំណាកស្រុកក្រៅប្រទេសភេទស្រី២នាក់ មានចំនួន ១នាក់ (៥០%) ទៅប្រទេសថៃ និង ១នាក់ (៥០%)ទៅប្រទេសកូរ៉េខាងត្បូង។

ក្រាហ្វិក ៨៧. ចំនួនសមាជិកចំណាកស្រុកក្រៅប្រទេសតាមប្រទេស




## ២១.មូលហេតុនៃចំណាកស្រុកទៅក្រៅប្រទេស

ក្រាហ្វិក ៨៨ បង្ហាញថាចំនួនសមាជិកបានធ្វើចំណាកស្រុកទៅក្រៅប្រទេស ដោយសារតែការស្វែងរកការងារធ្វើមានចំនួនសរុប ៣នាក់ ក្នុងនោះ១នាក់ទៅប្រទេសថៃ និង២នាក់ទៅប្រទេសកូរ៉េខាងត្បូង។

ក្រាហ្វិក ៨៨. មូលហេតុនៃការធ្វើចំណាកស្រុកទៅក្រៅប្រទេស



### ៣.១.៤ ការចូលរួមកម្លាំងពលកម្ម

#### ក. វិស័យសេដ្ឋកិច្ច

តារាង ២៨ បង្ហាញអំពីការចូលរួមកម្លាំងពលកម្មរបស់សមាជិកគ្រួសារទៅតាមវិស័យសេដ្ឋកិច្ច នៅខេត្តគោលដៅនីមួយៗ សរុបមានចំនួន ១,៤៣៨ នាក់ ស្មើនឹង ៥៤,៣% ក្នុងចំណោមប្រជាជនសរុប ២.៦៤៩នាក់ ។ ក្នុងនោះអ្នកធ្វើការទាំងពីរភេទនៅក្នុងកសិកម្មមានចំនួនមានចំនួន ៥៤៦នាក់ (៣៨%) អ្នកធ្វើការក្នុងវិស័យឧស្សាហកម្មមានចំនួន ១១៥នាក់ (៨%) និងអ្នកដែលធ្វើការក្នុងវិស័យសេវាកម្មមានចំនួន ៧៧៧នាក់ (៥៤%)។ ចំពោះបុរសដែលអ្នកធ្វើការកសិកម្មមានចំនួន ២៨៥នាក់ (៣៧,៥%) វិស័យឧស្សាហកម្មមានចំនួន ៥៩នាក់ (៧,៨%) និងវិស័យសេវាកម្មមានចំនួន ៤១៥នាក់ (៥៤,៧%) ខណៈដែលភេទស្ត្រីដែលធ្វើការក្នុងវិស័យកសិកម្មមានចំនួន ២៦១នាក់(៣៨,៥%) វិស័យឧស្សាកម្ម ៥៦នាក់(៨,២%) និងវិស័យសេវាកម្មមានចំនួន ៤១៥(៥៣,៣%)។

**តារាង២៨ ចំនួនសមាជិកធ្វើការតាមវិស័យសេដ្ឋកិច្ច**

| តាមវិស័យសេដ្ឋកិច្ច | ប្រុស | ស្រី | សរុប |
|---|---|---|---|
| កសិកម្ម | 285 | 261 | 546 |
| ឧស្សាហកម្ម | 59 | 56 | 115 |
| សេវាកម្ម | 415 | 362 | 777 |
| សរុប | 759 | 679 | 1,438 |

ក្រាហ្វិក ៨៩. ភាគរយការចូលរួមកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចទាំងពីរភេទ



ក្រាហ្វិក ៩០. ភាគរយការចូលរួមកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចទាំងភេទប្រុស




ក្រាហ្វិក ៩១. ភាគរយការចូលរួមកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចទាំងភេទស្រី



## ក. ផ្នែកការងារ

តារាង ២៩ បង្ហាញពីចំនួនសមាជិកគ្រួសារ ដែលបានចូលរួមកម្លាំងពលកម្មតាមផ្នែកការងារ។ ទិន្នន័យនេះ ឃើញថាសមាជិកភាគច្រើន បានចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យឯកជនមានចំនួន ១.២៦៥នាក់ ស្មើនឹង ៨៨% ក្នុងនោះផ្នែកឯកជនខ្មែរមានចំនួន ១,១២៩នាក់ ស្មើនឹង ៧៨,៥% និងផ្នែកឯកជនបរទេសមានចំនួន ១៣៦នាក់ ស្មើនឹង ៩,៥% ។ សមាជិកគ្រួសារដែលធ្វើការសម្រាប់គ្រួសារ និងផ្សេងៗមានចំនួន៨៤នាក់(៦,១%) ខណៈដែលសមាជិកធ្វើការក្នុងផ្នែករដ្ឋាភិបាលមានចំនួន៨៦នាក់ ស្មើនឹង ៦%។

**តារាង ២៩. ចំនួនសមាជិកគ្រួសារចូលរួមកម្លាំងពលកម្មតាមផ្នែកការងារ**

| ផ្នែកការងារ | ប្រុស | ស្រី | សរុប |
|---|---|---|---|
| រាជរដ្ឋាភិបាល | 62 | 24 | 86 |
| ផ្នែកឯកជនខ្មែរ | 610 | 519 | 1,129 |
| ផ្នែកឯកជនបរទេស | 53 | 83 | 136 |
| ផ្នែកគ្រួសារ | 29 | 52 | 81 |
| ផ្នែកមិនទទួលប្រាក់ចំណេញ | 3 | 1 | 4 |
| ផ្នែកស្ថានទូត អង្គការជាតិ និងអន្តរជាតិ | 2 | 0 | 2 |
| **សរុប** | **759** | **679** | **1,438** |

ក្រាហ្វិក ៩២. ភាគរយសមាជិកគ្រួសារធ្វើការតាមផ្នែកនៃការងារ



## ៣.២ បរិស្ថាន

បរិស្ថាន គឺជាអ្វីៗដែលនៅជុំវិញខ្លួនយើង ដែលយើងមានទំនាក់ទនងដោយផ្ទាល់ ឬ ទំនាក់ទំនងដោយប្រយោលជាមួយវាហើយជីវិតយើងគ្រប់គ្នាទាំងអស់សុទ្ធតែត្រូវការបរិស្ថាន ដោយមិនអាចខ្វះបាន។ បរិស្ថានចែកចេញជា៣ផ្នែកធំៗគឺ (១)បរិស្ថានធម្មជាតិ (២)បរិស្ថានសង្គមវប្បធម៌ និង (៣)បរិស្ថានមនុស្ស។ បរិស្ថានធម្មជាតិគឺរួមមានបរិស្ថានមានជីវិត និងបរិស្ថានឥតជីវិត។ បរិស្ថានមានជីវិតដូចជាសត្វ និងរុក្ខជាតិ រីឯបរិស្ថានឥតជីវិតដូចជាទឹក ដី ភ្លើង ខ្យល់ជាដើម។ បរិស្ថានមនុស្សគឺសំដៅដល់មនុស្សដែលរស់នៅលើផែនដីយើងនេះរួមទាំងអ្នក ដែលបានបាត់បង់ជីវិតទៅហើយ។ នៅក្នុងរបាយការណ៍នេះ បានបង្ហាញជូននូវផ្នែកផលប៉ះពាល់ទាក់ទងបរិស្ថានធម្មជាតិ និង បរិស្ថានមនុស្ស មិនបានលើកយកបរិស្ថានសង្គមវប្បធម៌មកបង្ហាញនោះទេ។ រូបក្រាហ្វិក ៩៣ បង្ហាញអំពីភាគរយនៃគ្រួសារយល់ថា មានផលប៉ះពាល់បរិស្ថានមានចំនួន៩៨,៨% ស្មើនឹងចំនួន៥៩៣គ្រួសារ ក្នុងចំណោម៦០០ គ្រួសារដែលបានសម្ភាសន៍។

ក្រាហ្វិក ៩៣. បង្ហាញអំពីភាគរយនៃគ្រួសារយល់ថាមានផលប៉ះពាល់បរិស្ថាន



### ៣.២.១ បង្គន់អនាម័យ

ក្រាហ្វិក ៩៤ បង្ហាញអំពីភាគរយគ្រួសារដែលប្រើប្រាស់បង្គន់អនាម័យប្រើប្រាស់ឆ្នាំ ២០២២ តាមរយៈការធ្វើសម្ភាសន៍ផ្ទាល់គឺមានគ្រួសារ ប្រហែល ៩២ ភាគរយមានបង្គន់អនាម័យប្រើប្រាស់ នៅសល់តែ ៨ភាគរយ ប៉ុណ្ណោះដែលគ្មានបង្គន់ប្រើប្រាស់ និងនៅឆ្នាំ ២០២៣ ភាគរយគ្រួសារដែលបានប្រើប្រាស់បង្គន់អនាម័យមានប្រហែល៩៤ភាគរយ និងភាគរយគ្រួសារដែលពុំមានបង្គន់អនម័យប្រើប្រាស់នៅសល់ចំនួន ៦% ទៀត។

**ក្រាហ្វិក ៩៤. ភាគរយគ្រួសារដែលប្រើប្រាស់បង្គន់អនាម័យ**



### ៣.២.២ សេវាប្រមូលសំរាម ទីតាំងទុកដាក់សំរាម និងផលប៉ះពាល់ពីការចាក់សំរាម

#### ក. សេវាប្រមូលសំរាម

ក្រាហ្វិក ៩៥ បង្ហាញអំពីចំនួនគ្រួសារមានសេវាប្រមូលសំរាម។ តាមទិន្នន័យនេះបង្ហាញថា ទិន្នន័យជារួមនៅក្នុងឆ្នាំ២០២៣ នៅតាមតំបន់គោលដៅដែលបានចុះសម្ភាសន៍គឺមានគ្រួសារ៩,៤% ទទួលបានសេវាប្រមូលសំរាម និងភាគរយគ្រួសារដែលមិនបាទទួសេវាសំរាមមានចំនួន៩០,៦% ខណៈដែលឆ្នាំ ២០២២ ភាគរយគ្រួសារដែលទទួលសេវាសំរាមមានចំនួន៦,៣% និងភាគរយគ្រួសារមិនទទួលសំរាម ៩៣,៧%។

**ក្រាហ្វិក ៩៥. ភាគរយគ្រួសារដែលទទួលសេវាសំរាម**




#### ខ. ទីតាំងទុកដាក់សំរាម និងផលប៉ះពាល់ពីកាចាក់សំរាម

ក្រាហ្វិក ៩៦ ភាគរយគ្រួសារដែលមានទីតាំងទុកដាក់សំរាម និងផលប៉ះពាល់ពីកាចាក់សំរាម បានបង្ហាញថា ភាគរយគ្រួសារដែលមានទីតាំងដាក់សំរាមកន្លែងទុកសំរាមដែលរៀបចំដោយអាជ្ញាធរមានចំនួន ០,៦% នៅឆ្នាំ២០២៣ និងនៅឆ្នាំ២០២២ ក៏មានចំនួនដូចគ្នាដែរ ក្នុងចំណោម៦០០គ្រួសារ ដែលបានសម្ភាសន៍ ប៉ុន្តែភាគរយគ្រួសារដែលមានទីតាំងទុកសំរាមក្នុងបរិវេណលំនៅដ្ឋានមានចំនួន៦០,១%នៅឆ្នាំ ២០២៣ ខណៈដែលនៅឆ្នាំ ២០២២ មានចំនួន ៥៩,៦%។ ភាគរយគ្រួសារដែលទទួលរងផលប៉ះពាល់ដោយសារការទុកសំរាមមានចំនួន ០,៨%នៅឆ្នាំ ២០២៣ និងឆ្នាំ ២០២២មានចំនួន០,៩%។

### ក្រាហ្វិក ៩៦. ភាគរយគ្រួសារដែលមានទីតាំងទុកដាក់សំរាម និងផលប៉ះពាល់ពីកាចាក់សំរាម




## ៣.២.៣ ផលប៉ះពាល់ពីកាកសំណល់រោងសិប្បកម្មឬរោងចក្រ ការបង្ហូរកាកសំណល់ចូលក្នុងទឹក និងការបាញ់ថ្នាំសម្លាប់សត្វល្អិត

ក្រាហ្វិក ៩៧ បង្ហាញឲ្យឃើញថា ភាគរយគ្រួសារដែលទទួលរងផលប៉ះពាល់ពីការបង្ហូរកាកសំណល់ចូលក្នុងទឹក ការកាប់បំផ្លាញព្រៃឈើ និងការកាប់បំផ្លាញព្រៃលិចទឹកនៅក្នុងខេត្តកំពត និងខេត្តកែប។ ទិន្នន័យនេះបង្ហាញថា ពុំមានគ្រួសារទទួលរងផលប៉ះពាល់ការបង្ហូរកាកសំណល់ចូលក្នុងទឹកពីរោងចក្រ និងសិប្បកម្មផ្សេងៗ និងការកាប់បំផ្លាញព្រៃលិចទឹកទាំងឆ្នាំ ២០២២ និងឆ្នាំ២០២៣។ ភាគរយគ្រួសារដែលទទួលរងដោយថ្នាំសម្លាប់សត្វល្អិតមានចំនួនប្រហែល០,៦% នៅឆ្នាំ ២០២៣ និងឆ្នាំ២០២២មានចំនួនដូចគ្នានេះដែរ។ ភាគរយនៃការប្រើប្រាស់គីមីមានចំនួនប្រហែល ០,៥% ទាំងនៅឆ្នាំ ២០២២ និងឆ្នាំ ២០២៣ ខណៈដែលការកាប់បំផ្លាញព្រៃឈើមានការកើនពី០,១%ដល់០,២%ពីឆ្នាំ២០២២ទៅឆ្នាំ ២០២៣ និងផលប៉ះពាល់ក្រៅពីចំណុចរៀបរាប់ខាងលើនៅឆ្នាំ ២០២៣មានចំនួន០,៣%។

ក្រាហ្វិក ៩៧. ភាគរយគ្រួសារទទួលរងផលប៉ះពាល់ពី ការបង្ហូរកាកសំណល់ចូលក្នុងទឹក ការកាប់បំផ្លាញព្រៃឈើ និងការកាប់បំផ្លាញព្រៃលិចទឹក




## ៣.៣ គ្រោះមហន្តរាយ

គ្រោះមហន្តរាយគឺសំដៅទៅលើគ្រោះមហន្តរាយកើតឡើងដោយធម្មជាតិមានដូចជា ខ្យល់ព្យុះ រន្ទះបាញ់ ទឹកជំនន់ គ្រោះរាំងស្ងួត បាក់ច្រាំងទន្លេ ឬ ស្ទឹង ព្រែកជាដើម។ នៅក្នុងចំណោម ៦០០គ្រួសារដែលបានសម្ភាសន៍ គឺមានចំនួន៤៦៨ គ្រួសារ ស្មើនឹង ៧៨ភាគរយ ឆ្លើយថាទទួលរងគ្រោះដោយសារគ្រោះមហន្តរាយ និង គ្រួសារចំនួន ១៣៤ស្មើនឹង ២២ ភាគរយ ឆ្លើយថាពុំទទួលរងគ្រោះដោយសារគ្រោះមហន្តរាយខាងលើ។ រូបភាព ៣.១៥ បង្ហាញអំពីភាគរយគ្រួសារដែលទទួលរងគ្រោះដោយគ្រោះមហន្តរាយធម្មជាតិនៅឆ្នាំ២០២៣ ។

ក្រាហ្វិក ៩៨. ភាគរយគ្រួសារដែលទទួលគ្រោះមហន្តរាយនៅឆ្នាំ២០២៣ ក្នុងភូមិគោលដៅ




### ៣.៣.១ ការទទួលព័ត៌មានអំពីគ្រោះមហន្តរាយ

ក្រាហ្វិក ៩៩ បង្ហាញថា អំពីព័ត៌មានគ្រោះមហន្តរាយដែលគ្រួសារទទួលបានក្នុងចំណោមប្រជាជនដែលបានចុះសម្ភាសន៍ចំនួន ៦០០ គ្រួសារ។ តាមទិន្នន័យបានបង្ហាញថា គ្រួសារដែលទទួលបានព័ត៌មានគ្រោះមហន្តរាយតាមរយៈអាជ្ញាធរមូលដ្ឋានមានចំនួន ២៩% និងមិនបានទទួលព័ត៌មានមានរហូតដល់ ៧១%។ ព័ត៌មានគ្រោះមហន្តរាយតាមរយៈការផ្សាយតាមទូរទស្សន៍មាន ៣៤% និងមិនបានទទួលមានចំនួន ៦៦%។ ព័ត៌មានគ្រោះមហន្តរាយតាមរយៈវិទ្យុ ៩% និងមិនបានទទួលព័ត៌មានមានចំនួន ៩១%។ ព័ត៌មានគ្រោះមហន្តរាយតាមរយៈទូរស័ព្ទដៃមានចំនួន ២៦% និងមិនបានទទួលព័ត៌មាន ៧៤%។ ព័ត៌មានគ្រោះមហន្តរាយតាមរយៈសារទូរស័ព្ទផ្ទាល់៩% និងមិនបានទទួលព័ត៌មានមានចំនួន ៩១% ខណៈតាមរយៈកាសែតពុំទទួលបានព័ត៌មាន។ ព័ត៌មានគ្រោះមហន្តរាយតាមរយៈប្រភពព័ត៌មានផ្សេងៗ មានរហូតដល់ ៧៦% និងមិនបានទទួលព័ត៌មានមាន ២៤% ប៉ុណ្ណោះ។

## ក្រាហ្វិក ៩៩. ប្រភពព័ត៌មាននៃគ្រោះមហន្តរាយ




## ៣.៣.២ ប្រភេទនៃគ្រោះមហន្តរាយ

តារាង ៣០ និង ក្រាហ្វិក១០០ បង្ហាញថា ចំនួនគ្រួសារទទួលរងគ្រោះតាមប្រភេទនៃគ្រោះមហន្តរាយនៅក្នុងខេត្តព្រះសីហនុ និងខេត្តកោះកុង។ ប្រភេទនៃគ្រោះមហន្តរាយនោះរួមមាន ភ្លើងផ្ទះ គ្រោះរាំងស្ងួត ខ្យល់ព្យុះ ទឹកជំនន់ និង ជំងឺឆ្លងកូវីដ១៩ ។ ទិន្នន័យលំអិតមានបង្ហាញនៅក្នុងតារាង ៣០ និង ក្រាហ្វិក ១០០ ដូចខាងក្រោម។

**តារាង៣០. ចំនួនគ្រួសារទទួលរងគ្រោះតាមប្រភេទនៃគ្រោះមហន្តរាយ**

| ប្រភេទគ្រោះមហន្តរាយ | ចំនួនគ្រួសារ | ភាគរយ |
|---|---|---|
| ភ្លើងឆេះ | 1 | 0.2 |
| រាំងស្ងួត | 11 | 1.8 |
| ខ្យល់ព្យុះ | 29 | 4.8 |
| ទឹកជំនន់ | 11 | 1.8 |
| កូវីដ១៩ | 22 | 3.7 |
| សរុប | | |

**តារាង៣១. ចំនួនអ្នកឆ្លងជំងឺកូវីដ១៩**

| ភេទ | ចំនួន (នាក់) | ភាគរយ |
|---|---|---|
| ប្រុស | 18 | 50 |
| ស្រី | 18 | 50 |
| សរុប | 36 | 100 |

*សំគាល់÷ ចំណាយគិតជាមធ្យមសម្រាប់ព្យាបាលកូវីដ ១៩ ប្រហែល២.៥០០ ដុល្លារអាមេរិកក្នុងម្នាក់។*

ក្រាហ្វិក ១០០ បង្ហាញអំពីភាគរយគ្រួសារទទួលរងគ្រោះដោយសារខ្យល់ព្យុះ មានចំនួន៤,៨% ឆ្លងជំងឺកូវីដ១៩ មានចំនួន៣,៧% ទទួលរងគ្រោះដោយសារគ្រោះរាំងមានចំនួន១,៨% រងគ្រោះដោយសារទឹកជំនន់មានចំនួន ១,៨% និង ភ្លើងឆេះផ្ទះមានចំនួន០,៨% ក្នុងចំណោមគ្រួសារដែលបានផ្តល់ចម្លើយទាំង៦០០គ្រួសារ។

**ក្រាហ្វិក ១០០. ភាគរយគ្រួសារទទួលរងគ្រោះមហន្តរាយតាមប្រភេទនៃគ្រោះមហន្តរាយឆ្នាំ២០២៣**



### ៣.៣.៣ ការប៉ាន់ស្មានការខូចដោយសារគ្រោះមហន្តរាយ

ការប៉ាន់ស្មានការខូចខាតដោយសារគ្រោះមហន្តរាយឆ្នាំ២០២៣ មានចំនួនទឹកប្រាក់ប្រហែល ១០០,៦៩០ដុល្លារអាមេរិក។ ការចំណាយដោយសារកូវីដ១៩ មានទឹកប្រាក់ចំណាយប្រហែល៩០.០០០ ដុល្លារ (៨៩,៤%) ខ្យល់ព្យុះចំណាយប្រហែល៣.៦៥០ដុល្លារ (៣,៦%) គ្រោះរាំងស្ងួតចំណាយប្រហែល ៣.៥០៥ដុល្លារ (៣,៥%) គ្រោះទឹកជំនន់ ២.០៣៥ដុល្លារ (២,០%) និងភ្លើងឆេះចំណាយប្រហែល ១.៥០០ដុល្លារ (១,៥%)។

**តារាង៣២. ការប៉ាន់ស្មានការខូចខាតដោយសារគ្រោះមហន្តរាយឆ្នាំ២០២៣**

| ប្រភេទគ្រោះមហន្តរាយ | ចំនួនគ្រួសារ | ការខូចខាតគិតជាប្រាក់ US$ |
|---|---|---|
| ភ្លើងឆេះ | 1 | 1,500 |
| រាំងស្ងួត | 11 | 3,505 |
| ខ្យល់ព្យុះ | 29 | 3,650 |
| ទឹកជំនន់ | 11 | 2,035 |
| កូវីដ១៩ | 22 | 90,000 |
| **សរុប** | | **100,690** |

**ក្រាហ្វិក ១០១. ភាគរយនៃការខូចខាតដោយសារគ្រោះមហន្តរាយឆ្នាំ២០២៣គិតជាដុល្លារ**



## ៣.៤ ការប្រែប្រួលអាកាសធាតុ

### ៣.៤.១ ស្ថានភាពទឹកភ្លៀង

ក្រាហ្វិក ១០២ បង្ហាញឲ្យឃើញថា ស្ថានភាពភ្លៀងធ្លាក់តាមការចំណាំរបស់ប្រជាជនដែលបានផ្ដល់ចម្លើយអំឡុងពេលសម្ភាសន៍ក្នុងចំណោមមេគ្រួសារចំនួន ៦០០នាក់។ តាមចម្លើយបង្ហាញថា ចំនួនមេគ្រួសារ៧%បានឆ្លើយថាមានភ្លៀងទៀងទាត់ មេគ្រួសារចំនួន៨៣%បានឆ្លើយថាមានភ្លៀងមិនទៀងទាត់ និងមានចំនួន ១០% ពួគគាត់បានឆ្លើយថា មិនប្រាកដដោយសារពួកគាត់មិនបានកំណត់សំគាល់វល់គិតពីការងារប្រកបមុខរបរចិញ្ចឹមជីវិត។

**ក្រាហ្វិក ១០២ ស្ថានភាពទឹកភ្លៀង**




### ៣.៤.២ ស្ថានភាពសីតុណ្ហភាព

តារាង ៣.៩ និង ក្រាហ្វិក ១០៣ បង្ហាញថាចំនួនមេគ្រួសារ ៣៥៨ នាក់ (៦០%) បានឆ្លើយថាសីតុណ្ហភាពមានកម្ដៅខ្លាំង ខណៈដែលមានចំនួនមេគ្រួសារ ២00 នាក់ (៣៣%) បានឆ្លើយថាសីតុណ្ហភាពមានកម្ដៅល្មមអាចទ្រាំបាន និង ចំនួនមេគ្រួសារ ២៦នាក់ (៤%) បានឆ្លើយថា ត្រជាក់ខ្លាំង និង គ្រួសារដែលបានឆ្លើយថាត្រជាក់ល្មមមានចំនួន ១៦នាក់ (៣%) ។

### តារាង៣៣. ចំនួនមេគ្រួសារដែលបានផ្ដល់ចម្លើយទាក់ទងអាកាសធាតុ

| សីតុណ្ហភាព | ចំនួនគ្រួសារ | ភាគរយ |
|---|---|---|
| ក្ដៅខ្លាំង | 358 | 60 |
| ត្រជាក់ខ្លាំង | 26 | 4 |
| ក្ដៅល្មម | 200 | 33 |
| ត្រជាក់ល្មម | 16 | 3 |
| សរុប | 600 | 100 |

### ក្រាហ្វិក ១០៣. ស្ថានភាពសីតុណ្ហភាព



### ក. គណនា P-value ទាក់ទងអាកាសធាតុ

នៅក្នុងចំណោមមេគ្រួសារ ៦០០នាក់ គឺមានមេគ្រួសារ ៤៨% ដែលបានឆ្លើយថាអាកាសធាតុក្តៅនៅឆ្នាំ២០២២នៅក្នុងខេត្តកោះកុង និងខេត្តព្រះសីហនុ តាមរយៈការសម្ភាសន៍ផ្ទាល់។ នៅឆ្នាំ ២០២៣ ក៏បានសាកសួរលើមេគ្រួសារចំនួន ៦០០នាក់ដូចគ្នា បានសួរអំពីអាកាសធាតុតាមការសំគាល់របស់គាត់នៅក្នុងភូមិដែលគាត់រស់នៅ។ មេគ្រួសារចំនួន៣៥៨ នាក់ ក្នុងចំណោម ៦០០នាក់ បានឆ្លើយថា ឆ្នាំ ២០២៣នេះ អាកាសធាតុក្តៅខ្លាំង។ ឆ្លងតាមចម្លើយខាងលើ តើអាកាសធាតុខេត្តកំពត និង ខេត្តកែប ដែលបានសម្ភាសន៍លើមេគ្រួសារដែលរស់នៅតំបន់នោះ មានស្ថានភាពអាកាសធាតុដូចគ្នានៅក្នុងខេត្តកោះកុង និងខេត្តព្រះសីហនុដែរឬទេ? ប្រសិនបើកម្រិតនៃភាពជឿជាក់ (Confidence level) ៩៥% ។ ខាងក្រោមនេះ ជាការបកស្រាយតាមវិធីសាស្រ្តគណនា p-value បញ្ជាក់អំពីស្ថានភាពអាកាសធាតុនៅក្នុងខេត្តកំពតនិងខេត្តកែបតាមលទ្ធផលដែលបានរកឃើញ។

ផ្អែកតាមសម្មតិកម្មខាងលើ យើងអាចគណនា p-value ដូចខាងក្រោម÷

$H_0: p = 0.48$ ; $H_a: p \neq 0.48$ ; $n = 600$; $x = 358$; $\hat{p}$=0.60; $p_0$=0.48; $q_0$=0.52

*បញ្ជាក់* $\hat{p} = \frac{x}{n} = \frac{358}{600} = 0.60$; $q_0 = 1 - 0.48 = 0.52$

**ក្រាហ្វិក ១០៤. លទ្ធផលនៃការគណនា** p-value



តាមរយៈ Confidence Interval 95% និង Two tail test យើងអាចគណនា Area in the left ($A_L$)=0.95+ 0.025=0.975 ។ ផ្អែកតាមតារាង Z score table បើ $A_L$=0.975 →Z=±1.96

**តារាង៣៤. Z score table**

| z | .00 | .01 | .02 | .03 | .04 | .05 | .06 | .07 | .08 | .09 |
|---|---|---|---|---|---|---|---|---|---|---|
| 0.0 | .5000 | .5040 | .5080 | .5120 | .5160 | .5199 | .5239 | .5279 | .5319 | .5359 |
| 0.1 | .5398 | .5438 | .5478 | .5517 | .5557 | .5596 | .5636 | .5675 | .5714 | .5753 |
| 0.2 | .5793 | .5832 | .5871 | .5910 | .5948 | .5987 | .6026 | .6064 | .6103 | .6141 |
| 0.3 | .6179 | .6217 | .6255 | .6293 | .6331 | .6368 | .6406 | .6443 | .6480 | .6517 |
| 0.4 | .6554 | .6591 | .6628 | .6664 | .6700 | .6736 | .6772 | .6808 | .6844 | .6879 |
| 0.5 | .6915 | .6950 | .6985 | .7019 | .7054 | .7088 | .7123 | .7157 | .7190 | .7224 |
| 0.6 | .7257 | .7291 | .7324 | .7357 | .7389 | .7422 | .7454 | .7486 | .7517 | .7549 |
| 0.7 | .7580 | .7611 | .7642 | .7673 | .7704 | .7734 | .7764 | .7794 | .7823 | .7852 |
| 0.8 | .7881 | .7910 | .7939 | .7967 | .7995 | .8023 | .8051 | .8078 | .8106 | .8133 |
| 0.9 | .8159 | .8186 | .8212 | .8238 | .8264 | .8289 | .8315 | .8340 | .8365 | .8389 |
| 1.0 | .8413 | .8438 | .8461 | .8485 | .8508 | .8531 | .8554 | .8577 | .8599 | .8621 |
| 1.1 | .8643 | .8665 | .8686 | .8708 | .8729 | .8749 | .8770 | .8790 | .8810 | .8830 |
| 1.2 | .8849 | .8869 | .8888 | .8907 | .8925 | .8944 | .8962 | .8980 | .8997 | .9015 |
| 1.3 | .9032 | .9049 | .9066 | .9082 | .9099 | .9115 | .9131 | .9147 | .9162 | .9177 |
| 1.4 | .9192 | .9207 | .9222 | .9236 | .9251 | .9265 | .9279 | .9292 | .9306 | .9319 |
| 1.5 | .9332 | .9345 | .9357 | .9370 | .9382 | .9394 | .9406 | .9418 | .9429 | .9441 |
| 1.6 | .9452 | .9463 | .9474 | .9484 | .9495 | .9505 | .9515 | .9525 | .9535 | .9545 |
| 1.7 | .9554 | .9564 | .9573 | .9582 | .9591 | .9599 | .9608 | .9616 | .9625 | .9633 |
| 1.8 | .9641 | .9649 | .9656 | .9664 | .9671 | .9678 | .9686 | .9693 | .9699 | .9706 |
| 1.9 | .9713 | .9719 | .9726 | .9732 | .9738 | .9744 | .9750 | .9756 | .9761 | .9767 |
| 2.0 | .9772 | .9778 | .9783 | .9788 | .9793 | .9798 | .9803 | .9808 | .9812 | .9817 |
| 2.1 | .9821 | .9826 | .9830 | .9834 | .9838 | .9842 | .9846 | .9850 | .9854 | .9857 |
| 2.2 | .9861 | .9864 | .9868 | .9871 | .9875 | .9878 | .9881 | .9884 | .9887 | .9890 |
| 2.3 | .9893 | .9896 | .9898 | .9901 | .9904 | .9906 | .9909 | .9911 | .9913 | .9916 |
| 2.4 | .9918 | .9920 | .9922 | .9925 | .9927 | .9929 | .9931 | .9932 | .9934 | .9936 |
| 2.5 | .9938 | .9940 | .9941 | .9943 | .9945 | .9946 | .9948 | .9949 | .9951 | .9952 |
| 2.6 | .9953 | .9955 | .9956 | .9957 | .9959 | .9960 | .9961 | .9962 | .9963 | .9964 |
| 2.7 | .9965 | .9966 | .9967 | .9968 | .9969 | .9970 | .9971 | .9972 | .9973 | .9974 |
| 2.8 | .9974 | .9975 | .9976 | .9977 | .9977 | .9978 | .9979 | .9979 | .9980 | .9981 |
| 2.9 | .9981 | .9982 | .9982 | .9983 | .9984 | .9984 | .9985 | .9985 | .9986 | .9986 |
| 3.0 | .9987 | .9987 | .9987 | .9988 | .9988 | .9989 | .9989 | .9989 | .9990 | .9990 |
| 3.1 | .9990 | .9991 | .9991 | .9991 | .9992 | .9992 | .9992 | .9992 | .9993 | .9993 |
| 3.2 | .9993 | .9993 | .9994 | .9994 | .9994 | .9994 | .9994 | .9995 | .9995 | .9995 |
| 3.3 | .9995 | .9995 | .9995 | .9996 | .9996 | .9996 | .9996 | .9996 | .9996 | .9997 |
| 3.4 | .9997 | .9997 | .9997 | .9997 | .9997 | .9997 | .9997 | .9997 | .9997 | .9998 |

ប្រភព÷ JAY L. DEVORE, *Probability and Statistics for Engineering and the Sciences, Sixth Edition,* JAY L. DEVORE, 2004.

$$Z_c = \frac{\hat{p}-p_0}{\sqrt{\frac{p_0 q_0}{n}}} = \frac{0.60-0.48}{\sqrt{\frac{0.48*0.52}{600}}} = 5.72$$

ដូច្នេះ $Z_c = 5.72 > Z = 1.96$ → **Reject $H_0$**។

តាមលទ្ធផលខាងលើបានបង្ហាញថា ស្ថានភាពអាកាសធាតុនៅក្នុងខេត្តកំពត និងខេត្តកែបឆ្នាំ ២០២៣ ពិតជាក្តៅជាងអាកាសធាតុនៅក្នុខេត្តកោះកុង និងខេត្តព្រះសីហនុនៅឆ្នាំ ២០២២ ពិតប្រាកដមែន។

# ជំពូក ៤
# របកគំហើញ និង សន្និដ្ឋាន

## ៤.១ របកគំហើញ

តាមរយៈការសិក្សាស្រាវជ្រាវ នៅក្នុងគម្រោងអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២៣នៅតាមខេត្តគោលដៅទាំង២គឺ ខេត្តកំពត និងខេត្តកែប ផ្អែកលើទិន្នន័យ៣ប្រភេទគឺ ទិន្នន័យទី១ ទិន្នន័យទី២ និងទិន្នន័យពីផ្កាយរណប។ ទិន្នន័យទី១ គឺជាប្រភេទទិន្នន័យ ដែលប្រមូលបាន តាមរយៈការសម្ភាសន៍នៅក្នុងខេត្តគោលដៅទាំង២ដែលមានចំនួន៦០០គ្រួសារ។ ទិន្នន័យទី២ គឺ ទិន្នន័យដែលក្រសួងស្ថាប័នផ្សេងៗបានផលិតចេញ។ ទិន្នន័យពីផ្កាយរណប គឺទិន្នន័យដែលបានតាមរយៈការចែករំលែកពីអង្គការ NASA តាមរយៈផ្កាយរណប Sentinel 2។ ដូច្នេះលទ្ធផលនៃការសិក្សាស្រាវខាងលើបានបង្ហាញនូវរបកគំហើញតាមរយៈនៃទិន្នន័យនីមួយៗដូចខាងក្រោម÷

### ៤.១.១ របកគំហើញផ្អែកលើទិន្នន័យទី១

#### ក. ប្រជាសាស្ត្រ

តាមលទ្ធផលនៃការចុះស្រង់ទិន្នន័យនៅក្នុងខេត្តកំពត និងខេត្តកែបបានរកឃើញនូវទាក់ទងនឹង បញ្ហាប្រជាសាស្ត្រតាមរយៈការសម្ភាសន៍មេគ្រួសារមានដូចខាងក្រោម÷

- ភាគរយមេគ្រួសារដែលដឹកនាំដោយបុរសមានភាគរយច្រេនជាងស្ត្រី និងភាគច្រើនស្ថិតនៅក្នុង ក្រុមអាយុចាប់ពី ៤០ដល់៥៩ឆ្នាំ
- ទំហំសមាជិកគ្រួសារជាមធ្យមខេត្តកែប ៤,៥ នាក់ និង ខេត្តកំពត ៤,៣នាក់ និងសរុបខេត្តទាំង ២គិតជាមធ្យមគឺ ៥,៥នាក់
- ភាគរយនៃជនចំណាកស្រុកក្នុងប្រទេសមានភាគរយច្រើនជាងចំណាកស្រុកទៅក្រៅប្រទេស និងមូលហេតុនៃចំណាកស្រុកគឺស្វែងរកការងារធ្វើ
- ភាគរយនៃការចូលរួមកម្លាំងពលកម្មក្នុងវិស័យសេដ្ឋកិច្ចគឺភាគរយនៃការចូលរួមកម្លាំងពលកម្ម ក្នុងវិស័យសេវាកម្មខ្ពស់ជាងគេ បន្ទាប់មកវិស័យកសិកម្ម និងទាបជាងគេគឺវិស័យឧស្សាហកម្ម។ ចំពោះ អ្នកដែលធ្វើការងារផ្នែកឯកជនខ្មែរមានភាគរយខ្ពស់ជាងគេ។

#### ខ. បរិស្ថាន

តាមលទ្ធផលនៃការចុះស្រង់ទិន្នន័យនៅក្នុងខេត្តកំពត និងខេត្តកែបបានរកឃើញនូវទាក់ទងនឹង បញ្ហាបរិស្ថានតាមរយៈការសម្ភាសន៍មេគ្រួសារមានដូចខាងក្រោម÷

- ភាគរយនៃគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់មានជាង៩០%

- សេវាប្រមូលសំរាមនៅក្នុងខេត្តទាំង២ឆ្នាំ២០២៣មានប្រហែល ៩,៤% និងតីតាំងទុកសំរាមនៅក្នុងបរិវេណផ្ទះមានប្រហែល៦០%

- ភាគរយគ្រួសារដែលទទួលរងផលប៉ះពាល់ដោយសារការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិតមានជាង១ភាគរយ និងផលប៉ះពាល់ដោយការកាប់បំផ្លាញព្រៃឈើមាន០,២%។

**គ. គ្រោះមហន្តរាយ**

តាមលទ្ធផលនៃការចុះស្រង់ទិន្នន័យនៅក្នុងខេត្តកំពត និងខេត្តកែបបានរកឃើញនូវទាក់ទងនឹងបញ្ហាគ្រោះមហន្តរាយតាមរយៈការសម្ភាសន៍មេគ្រួសារមានដូចខាងក្រោម÷

- ភាគរយគ្រួសារប្រហែល៧៨% ទទួលរងគ្រោះមហន្តរាយ ហើយការទទួលព័ត៌មានពីប្រភពផ្សេងៗមានភាគរយខ្ពស់ប្រហែល៧៦%។ ទទួលព័ត៌មានពីប្រភពអាជ្ញាធរ ទូរទស្សន៍ និងទូរស័ព្ទដៃ មានភាគរយពី២៤% ដល់៣៤%

- ភាគរយនៃគ្រួសារដែលរងគ្រោះដោយសារខ្យល់ព្យុះ និងឆ្លងជំងឺកូវីដ១៩ មានភាគខ្ពស់ជាងគេ ក្នុងចំណោមគ្រោះមហន្តរាយដទៃទៀត។ ភាគរយនៃទំហំគិតជាទឹកប្រាក់នៃការរងគ្រោះដោយសារជំងឺកូវីដ១៩មានការចំណាយច្រើនជាងគេ (៨៩,៤%) ហើយបន្ទាប់មកខ្យល់ព្យុះ (៣,៦%) និងគ្រោះរាំងស្ងួត (៣,៥%)។

**ឃ. ការប្រែប្រួលអាកាសធាតុ**

តាមលទ្ធផលនៃការចុះស្រង់ទិន្នន័យនៅក្នុងខេត្តកំពត និងខេត្តកែបបានរកឃើញនូវទាក់ទងនឹងបញ្ហាប្រែប្រួលអាកាសធាតុដែលទទួលបានតាមរយៈការសម្ភាសន៍មេគ្រួសារមានដូចខាងក្រោម÷

- ភាគរយស្ថានភាពទឹកភ្លៀងមិនទៀងទាត់មានភាគរយខ្ពស់ជាងគេប្រហែល ៨៣%

- ស្ថានភាពសីតុណ្ហភាពក្តៅខ្លាំងមានភាគរយខ្ពសប្រហែល៦០%។

## ៤.១.២ របកគំហើញផ្អែកលើទិន្នន័យទី២

តាមរយៈការសិក្សាស្រាវជ្រាវ នៅក្នុងគម្រោងអង្កេតភពផែនដី នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២៣ ដោយផ្អែកលើទិន្នន័យទី២ ដូចខាងក្រោម÷

**ក. ស្ថានភាពប្រជាសាស្ត្រ**

- កំណើនប្រជាជនទូទាំងពិភពលោកបានកើនឡើង ៣ដងពីឆ្នាំ១៩៦២ ដល់ ២០៣៥។ ចំនួនប្រជាជននៅឆ្នាំ១៩៦២ មានចំនួន ២.៩៩៦ លាននាក់បានកើនឡើងនៅឆ្នាំ ២០៣៥ មានចំនួន៨.៨៤៧ លាននាក់ និងនៅឆ្នាំ ២០៥០ បានកើនឡើងដល់ ៩.៦៨៧ លាននាក់។

- កំណើនប្រជាជនកម្ពុជាបានកើនឡើងជាង ៣ដងពីឆ្នាំ១៩៦២ ដល់ ២០៣៥។ ចំនួនប្រជាជននៅឆ្នាំ១៩៦២ មានចំនួន ៥.៧លាននាក់បានកើនឡើងនៅឆ្នាំ២០៣៥ មានចំនួន ១៩.៨លាននាក់។ ចំនួនប្រជាជនក្នុងតំបន់ឆ្នេរសមុទ្រនឹងកើនឡើងជិត២ដងពីឆ្នាំ១៩៩៨ មានចំនួន ៨៤៥ពាន់នាក់បានកើនដល់ ១,៤លាននាក់ ឆ្នាំ ២០៣៥ ខណៈដែលខេត្តកំពតបានកើនឡើងពី ៥២៨,៥ពាន់នាក់នៅឆ្នាំ ១៩៩៨ កើនដល់៧៥៩,៥ពាន់នាក់ នៅឆ្នាំ២០៣៥ និងខេត្តកែបបានកើនឡើងពី២៨,៦ ពាន់នាក់នៅឆ្នាំ ១៩៩៨ កើនដល់ ៥៤,៦ ពាន់នាក់នៅឆ្នាំ ២០៣៥។

- ដង់ស៊ីតេប្រជាជននៅទូទាំងប្រទេសឆ្នាំ ១៩៩៨ មានចំនួន ៦៤នាក់ក្នុង១គីឡូម៉ែត្រក្រឡា នឹងកើនឡើងដល់ ១១១នាក់ក្នុង១គីឡូម៉ែត្រក្រឡានៅឆ្នាំ ២០៣៥ ខណៈដែលខេត្តកំពតបានកើនពី១០៨នាក់ក្នុង១គីឡូម៉ែត្រក្រឡានៅឆ្នាំ ១៩៩៨ កើនដល់ ១៥៥នាក់ក្នុង១គីឡូម៉ែត្រក្រឡានៅឆ្នាំ ២០៣៥ និងខេត្តកែបបានកើនឡើងពី ៨៥នាក់ក្នុង១គីឡូម៉ែត្រក្រឡា នៅឆ្នាំ១៩៩៨ កើនដល់ ១៦២នាក់ក្នុង១គីឡូម៉ែត្រក្រឡានៅឆ្នាំ២០៣៥។

- ប្រជាជនប្រហែល ៣,៦% នៃប្រជាជនពិភពលោកដែលបានធ្វើចំណាកស្រុក។ ជនអន្តោប្រវេសន៍ចូលទៅក្នុងទ្វីបអាស៊ី និងទ្វីបអឺរ៉ុបមានចំនួនច្រើនជាងគេ ហើយមានចំនួនតិចជាងគេ គឺនៅទ្វីបអូសេអានី ខណៈដែលប្រទេសកម្ពុជាការផ្លាស់ប្តូរទីកន្លែងរស់នៅពីមុន ឬចំណាកស្រុកមានការធ្លាក់ចុះពី៣១% នៅឆ្នាំ១៩៩៨ មកត្រឹម២២% នៅឆ្នាំ២០១៩។

- និន្នាការនៃការចូលរួមកម្លាំងពលកម្ម នៅក្នុងវិស័យសេដ្ឋកិច្ចបានថយចុះពីផ្នែកកសិកម្ម និងបានកើនឡើងផ្នែកឧស្សាហកម្ម និងសេវាកម្មទាំងថ្នាក់ជាតិ និងខេត្តទាំង២ខាងលើ។

## ខ. តំបន់ទីប្រជុំជន និងលំនៅដ្ឋាន

### ខ១. តំបន់ទីប្រជុំជន

- ចំនួនប្រជាជនដែលរស់នៅតំបន់ទីប្រជុំជននៅលើពិភពលោកនៅឆ្នាំ២០៣៥ អាចកើនលើស ៦០% និងចំនួនប្រជាជនកម្ពុជាដែលរស់នៅទីប្រជុំជននៅឆ្នាំ២០៣៥ អាចកើនលើសពី ៤០%។

- ចំនួនប្រជាជនដែលរស់នៅតំបន់ទីប្រជុំជន នៅក្នុងខេត្តកំពត បានកើនឡើងពី៨,៦%នៅឆ្នាំ១៩៩៨ កើនដល់ ១០,២%នៅឆ្នាំ២០១៩ និងខេត្តកែបបានកើនឡើងពី ១៤%នៅឆ្នាំ១៩៩៨ កើនដល់ជិត៨០% នៅឆ្នាំ២០១៩។

### ខ២. លំនៅដ្ឋាន

លំនៅដ្ឋានៅក្នុងប្រទេសកម្ពុជានៅឆ្នាំ ២០២១ មានចំនួនប្រហែល ៣,៥លានលំនៅដ្ឋាន ខណៈដែលខេត្តកំពតមានចំនួន១៥៤,៩ពាន់លំនៅដ្ឋាន និងខេត្តកែបមានចំនួន ៩.០៦៧លំនៅដ្ឋាន។

## គ. បរិស្ថាន

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវ ដែលបានរកឃើញនូវបញ្ហាទាក់ទងនឹងបរិស្ថានមានដូចខាងក្រោម÷

### គ១. ការប្រមូលសំរាម និងកាកសំណល់

- សេវាប្រមូលសំរាមទូទាំងប្រទេសមានគ្រួសារប្រហែល ៥០៥.៣២៥ គ្រួសារ (១៣,១%) ដែលទទួលសេវាប្រមូលសំរាមក្នុងចំណោមគ្រួសារ ៣,៨លាននៅឆ្នាំ២០២១ ខណៈដែលខេត្តកំពតមានប្រហែល ៤,១% ដែលបានទទួលសេវាប្រមូលសំរាមក្នុងចំណោមគ្រួសារសរុប ១៦១.២៩៨ និងខេត្តកែបមានប្រហែល៨% នៃគ្រួសារសរុបចំនួន៩.៨៩៨ នៅឆ្នាំ២០២១។
- កាកសំណល់រឹង និងសំណល់រាវនឹងមានការកើនឡើងដោយសារកំណើនប្រជាជនអាចកើនដល់ ១៩,៨លាននាក់នៅឆ្នាំ២០៣៥ ជាពិសេសនៅរាជធានីភ្នំពេញ។
- តំបន់ការពារធម្មជាតិមានផ្ទៃដីប្រមាណ ៥,៩ លានហិកតា ខណៈដែលគម្របព្រៃឈើបានធ្លាក់ចុះពី ៧៣% នៅឆ្នាំ ១៩៦៥ មកត្រឹម ៤៧% នៅឆ្នាំ ២០១៨។
- និន្នាការនៃការប្រើប្រាស់ទឹកស្អាតមានការកើនឡើងពី២៩% នៅឆ្នាំ១៩៩៨ ទៅ ៧៣% ឆ្នាំ២០១៩ សម្រាប់ទូទាំងប្រទេស ហើយខេត្តកំពត និងខេត្តកែបក៏មាននិន្នាការកើនឡើងដែរ។
- និន្នាការនៃការប្រើប្រាស់បង្គន់អនាម័យទាំងថ្នាក់ជាតិ (៨៤%) ខេត្តកំពត (៨២%) និងខេត្តកែប ៧៥% ក៏មានការកើនឡើងផងដែរ។

### គ២. តំបន់ការពារ

- ផ្ទៃដីនៃតំបន់ការពារសត្វព្រៃមានប្រហែល ៧៨% នៃផ្ទៃដីតំបន់ការពារសរុបដែលមានជាង៥,៩ លានហិកតារបស់ប្រទេសកម្ពុជា។
- គម្របព្រៃឈើបានថយចុះពី៧៣,៥% មកត្រឹម ៤៦,៨៦% ពីឆ្នាំ ១៩៦៥ ដល់ឆ្នាំ២០១៨។

### គ៣. ទឹកស្អាត

- ភាគរយគ្រួសារនៃប្រជាជនកម្ពុជាប្រហែល ៧៣% មានទឹកស្អាតប្រើប្រាស់ ខណៈដែលខេត្តកំពតមានចំនួន ៥៣% និង ខេត្តកែបមាន ៥៩%។

## ឃ. គ្រោះមហន្តរាយ

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវ បានរកឃើញទាក់ទងនឹងគ្រោះមហន្តរាយមានដូចខាងក្រោម÷

### ឃ១. គ្រោះមហន្តរាយធម្មជាតិ

- គ្រោះមហន្តរាយធម្មជាតិនៅលើពិភពលោក ដែលមានទំហំធំជាងគេ គឺគ្រោះមហន្តរាយទឹកជំនន់មានទំហំធំជាងគេ (៥៦%) និងធ្វើឱ្យមនុស្សស្លាប់ច្រើនជាងគេ ក្នុងចំណោមគ្រោះមហន្តរាយផ្សេងៗទៀត ប៉ុន្តែទំហំការខូចខាតគិតជាទឹកប្រាក់គឺគ្រោះមហន្តរាយដោយសារព្យុះមានទំហំទឹកប្រាក់ធំជាងគេ។

- នៅក្នុងប្រទេសកម្ពុជាគ្រោះមហន្តរាយធម្មជាតិដែលមានដូចជា គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត បាក់ច្រាំងឬដីចូលទន្លេ រន្ទះបាញ់ និងខ្យល់កន្ត្រាក់ពិតជាបានកើតឡើង ប៉ុន្តែគ្រោះមហន្តរាយដោយសាររន្ទះបាញ់បានធ្វើឱ្យប្រជាជនស្លាប់ច្រើនជាងគេ។ ក្រៅពីនេះទៀត ក៏មានគ្រោះថ្នាក់ដែលបានបង្កដោយអគ្គីភ័យផងដែរ។

### ឃ២. គ្រោះមហន្តរាយដោយសារជំងឺឆ្លង

-ចំនួនប្រជាជននៅលើពិភពលោកបានឆ្លងជំងឺកូវីដ១៩ មានចំនួន ៧៧១,៤ លាននាក់ ស្លាប់អស់ចំនួនជិត ៧ លាននាក់ គិតត្រឹមថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ ខណៈដែលប្រទេសកម្ពុជាមានអ្នកឆ្លងជំងឺកូវីដ១៩មានចំនួនជិត ១៤ ម៉ឺននាក់ និងស្លាប់ជាង ៣ ពាន់នាក់ គិតត្រឹមថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ ។ ក្រៅពីជំងឺឆ្លងកូវីដ១៩ ក៏មានជំងឺឆ្លងផ្សេងទៀតដែលបានកើតឡើងមានដូចជា ជំងឺគ្រុនឈាម និងជំងឺផ្តាសាយបក្សីផងដែរ។

### ឃ៣. គ្រោះមហន្តរាយដោយសារសង្គ្រាម

- ចំនួនទាហានដែលប្រយុទ្ធស្លាប់សរុបនៅក្នុងសង្គ្រាមលោកលើកទី១ និងសង្គ្រាមលោកលើកទី២ មានចំនួនសរុប ២៤,៧លាននាក់ និងទាហានរងរបួសចំនួនសរុប៤៦,២លាននាក់ និងជនស៊ីវិលស្លាប់សរុបមានចំនួន ៥១,៨ លាននាក់ ។

- ប្រជាជនកម្ពុជាបានស្លាប់ដោយសារសង្គ្រាមជាច្រើននាក់ចាប់តាំងពីឆ្នាំ ១៩៧០មក និងបានបន្សល់ទុកគ្រាប់មីនជាច្រើនរហូតដល់សព្វថ្ងៃ។ ចំនួនសរុបគ្រាប់មីន និងសំណល់ជាតិផ្ទុះពីឆ្នាំ ១៩៩២ដល់ឆ្នាំ ២០២៣ គឺមានគ្រាប់មីនថ្មើជើងចំនួន ១.១៦៨.៤៣៦ គ្រាប់មីនគោន ២៦.២៥៧ និងសំណល់ជាតិផ្ទុះ ៣.០៧១.៨៩៩ ព្រមទាំងបង្កឱ្យមនុស្សស្លាប់ដោយសារមីននិងសំណល់ជាតិផ្ទុះសរុប ២៨.៦៨៨នាក់។

## ខ. ការប្រែប្រួលអាកាសធាតុ

បើទោះបី នៅក្នុងការអនុវត្តគម្រោងនេះ ពុំទាន់មានឧបករណ៍ណាទំនើបសម្រាប់ស្រង់ទិន្នន័យតាមរយៈផ្កាយរណប ឬ ដ្រូនពិតមែន តែតាមរយៈការសិក្សាស្រាវជ្រាវនៃប្រភពទិន្នន័យដែលប្រមូលបានពីក្រសួងធនធានទឹក និងឧតុនិយម ព្រមទាំងប្រភពផ្សេងៗរកឃើញថា:

- កំពស់ទឹកភ្លៀងមានការថយចុះ

- កំពស់ទឹកទន្លេមេគង្គក៏មានការថយចុះ

- ភ្លៀងធ្លាក់មិនទៀងទាត់

- សីតុណ្ហភាពមានការប្រែប្រួលជាពិសេសមានកម្តៅខ្លាំងខុសពីប្រក្រតី

-ការប្រែប្រួលអាកាសធាតុធ្វើឲ្យមានគ្រោះមហន្តរាយកើតឡើងដូចជាទឹកជំនន់ ហើយបើគិតជាតម្លៃនៃការខូចខាតនៅឆ្នាំ២០០៩ មានទំហំទឹកប្រាក់ចំនួនប្រហែល ១៣២ លានដុល្លារអាមេរិក។ លើសពីនេះទៀត ចំពោះការយល់ដឹងអំពីផលប៉ះពាល់នៃការប្រប្រួលអាកាធាតុរបស់ប្រជាជនកម្ពុជា មានតែជាង ៣០% ប៉ុណ្ណោះ។

## ៤.១.៣ របកគំហើញផ្អែកលើទិន្នន័យតាមផ្កាយរណប

ឆ្លងតាមការចែករំលែកទិន្នន័យតាមរយៈផ្កាយរណប Sentinel2 របស់អង្គការណាសា បានបង្ហាញអំពីការរកឃើញដូចខាងក្រោម÷

- ស្ថានភាពផ្ទៃដីគ្របដណ្តប់របស់ប្រទេសកម្ពុជានៅឆ្នាំ២០២២ គឺមានផ្ទៃដីគ្របដណ្តប់ដោយផ្ទៃទឹក (Water) មានប្រហែល ២០% គ្របដណ្តប់ដោយដើមឈើ (Tree) មានប្រហែល ៣៦% គ្របដណ្តប់ដោយទឹកជំនន់ (Flooded) ០,៨% គ្របដណ្តប់ដោយដាំដំណាំ (Crop) មានប្រហែល ២៨% គ្របដណ្តប់ដោយដីដែលបានសាងសង់សំណង់ផ្សេងៗ (Built) មានប្រហែល ៦% និងដីវាលឬ វាលស្មៅ (Rangeland) មានប្រហែល ៩%។

- ស្ថានភាពផ្ទៃដីគ្របដណ្តប់របស់ប្រទេសវៀតណាមនៅឆ្នាំ២០២២ គឺមានផ្ទៃដីគ្របដណ្តប់ដោយផ្ទៃទឹក (Water) មានប្រហែល ១៧% គ្របដណ្តប់ដោយដើមឈើ (Tree) មានប្រហែល ៤៤% គ្របដណ្តប់ដោយទឹកជំនន់ (Flooded) ០,៥% គ្របដណ្តប់ដោយដាំដំណាំ (Crop) មានប្រហែល ២២% គ្របដណ្តប់ដោយដីដែលបានសាងសង់សំណង់ផ្សេងៗ (Built) មានប្រហែល ៦% និងដីវាលឬ វាលស្មៅ (Rangeland) មានប្រហែល ១១%។

- ស្ថានភាពផ្ទៃដីគ្របដណ្តប់របស់ប្រទេសឡាវនៅឆ្នាំ២០២២ គឺមានផ្ទៃដីគ្របដណ្តប់ដោយផ្ទៃទឹក (Water) មានប្រហែល ១០% គ្របដណ្តប់ដោយដើមឈើ (Tree) មានប្រហែល ៤១% គ្របដណ្តប់ដោយទឹកជំនន់ (Flooded) ០,៤% គ្របដណ្តប់ដោយដាំដំណាំ (Crop) មានប្រហែល ២៩% គ្របដណ្តប់ដោយដីដែលបានសាងសង់សំណង់ផ្សេងៗ (Built) មានប្រហែល ៧% និងដីវាលឬ វាលស្មៅ (Rangeland) មានប្រហែល ១២%។

-ស្ថានភាពផ្ទៃដីគ្របដណ្តប់របស់ប្រទេសថៃនៅឆ្នាំ២០២២ គឺមានផ្ទៃដីគ្របដណ្តប់ដោយផ្ទៃទឹក (Water) មានប្រហែល ២១% គ្របដណ្តប់ដោយដើមឈើ (Tree) មានប្រហែល ៣៥% គ្របដណ្តប់ដោយទឹកជំនន់ (Flooded) 0,៥% គ្របដណ្តប់ដោយដាំដំណាំ (Crop) មានប្រហែល ២៧% គ្របដណ្តប់ដោយដីដែលបានសាងសង់សំណង់ផ្សេងៗ (Built) មានប្រហែល ៥% និងដីវាលឬ វាលស្មៅ (Rangeland) មានប្រហែល ១១%។

## ៤.២ សន្និដ្ឋាន

តាមរយៈលទ្ធផលនៃអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ២០២៣ ផ្អែកតាមទិន្នន័យទី១ ទិន្នន័យទី២ និងទិន្នន័យបានតាមរយៈផ្កាយរណប ព្រមទាំងទិន្នន័យដែលប្រមូលបានពីប្រភពផ្សេងៗដទៃទៀតបានបង្ហាញអំពីរបកគំហើញនូវលក្ខណៈប្រជាសាស្ត្រទាក់ទងកំណើន ការចូលរួមកម្លាំងពលកម្មក្នុងវិស័យសេដ្ឋកិច្ច ចំណាកស្រុក ការកើនឡើងតំបន់ទីប្រជុំជនតាមរយៈការកើនឡើងនៃលំនៅដ្ឋាន ផលប៉ះពាល់លើបរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុនៅកម្រិតថ្នាក់សកល ថ្នាក់តំបន់ ថ្នាក់ជាតិ និងខេត្តទាំង២ដែលបានចុះប្រមូលទិន្នន័យឆ្នាំ២០២៣នេះ។ លើសពីនេះទៀតរបាយការណ៍នេះបានបង្ហាញនូវគ្រោះមហន្តរាយដោយសារសង្គ្រាម ដែលរបាយការណ៍មុនៗពុំបានបង្ហាញជូននោះទេ។ តាមរបកគំហើញនេះ អាចសន្និដ្ឋានថា បញ្ហាប្រជាសាស្ត្រ បរិស្ថាន គ្រោះមហន្តរាយធម្មជាតិ គ្រោះមហន្តរាយដោសារសង្គ្រាម និងការប្រែប្រួលអាកាសធាតុពិតជាបានកើតឡើងនៅក្នុងសកលលោក ប្រទេសនៅក្នុងតំបន់ ក្នុងប្រទេសកម្ពុជាយើង និងនៅក្នុងខេត្តទាំង២ ដែលបានសិក្សាស្រាវជ្រាវគឺខេត្តកែប និងខេត្តកំពតដែលស្ថិតនៅក្នុងក្របខណ្ឌនៃធ្វើអង្កេតនេះពិតប្រាកដមែន។ ដូច្នេះដើម្បីដោះស្រាយបញ្ហាខាងលើ គឺត្រូវរៀបចំគោលនយោបាយ និងផែនការសកម្មភាពសម្រាប់មានវិធានការបង្ការផ្សេងៗស្របតាមការអភិវឌ្ឍ និងការប្រែប្រួលអាកាសធាតុជាសកល។

សរុបមក លទ្ធផលនេះ បានបង្ហាញអំពីសមិទ្ធិផលថ្មីមួយទៀតលើកទី ៥ បន្ទាប់ពីបានធ្វើការវិភាគរបាយការណ៍ឆ្នាំ២០១៩ មក នៅក្នុងគម្រោងអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ កន្លងទៅ ហើយទិន្នន័យនេះ ពិតជាមានសារៈប្រយោជន៍យ៉ាងសំខាន់ដល់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងការរៀបចំគោលនយោបាយជាតិ និងការធ្វើផែនការ ដែលទាក់ទងនឹងប្រជាសាស្ត្រ បរិស្ថាន គ្រោះមហន្តរាយដែលបានកើតឡើង និងការប្រែប្រួលអាកាសធាតុ បន្ថែមពីលើទិន្នន័យពីប្រភពផ្សេងៗទៀតដែលបានសិក្សាស្រាវជ្រាវដោយស្ថាប័នជាតិ និងអន្តរជាតិដែលមានស្រាប់។

# ឯកសារយោង

## ក.ឯកសារយោងជាភាសាខ្មែរ


១. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ÷ *ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការឆ្នាំ២០០២។

២. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ÷ *របាយការណ៍ទូទៅនៃការធ្វើអង្កេតប្រជារាស្ត្រកម្ពុជាចន្លោះជំរឿនឆ្នាំ២០០៤* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ឆ្នាំ២០០២។

៣. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ÷ *ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ឆ្នាំ២០០៩។

៤. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ÷ *អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣ របាយចុងក្រោយ* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ឆ្នាំ២០១៣។

៥. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ÷ *ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ តួលេខបណ្តោះអាសន្ននៃចំនួនប្រជាជនសរុប* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ឆ្នាំ២០១៣។

៦. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ÷ *សៀវភៅកម្រងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ២០១៧* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ឆ្នាំ២០១៨។

៧. មន្ទីរផែនការរាជធានី ខេត្ត÷ *ទិន្នន័យមូលដ្ឋាន* ឆ្នាំ២០១៩, ២០២០និង ២០២១, មន្ទីរផែនការរាជធានី ខេត្ត។

៨. គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ÷ *របាយការណ៍ស្តីពីការងារគ្រប់គ្រងគ្រោះមហន្តរាយរយៈពេល ៦ ខែ តុលា ឆ្នាំ២០២២*, គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

៩. គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ÷ *របាយការណ៍ស្តីពីការងារគ្រប់គ្រងគ្រោះមហន្តរាយរយៈពេល ៦ ខែ តុលា ឆ្នាំ២០២៣*, គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

១០. ក្រសួងធនធានទឹក និងឧតុនិយម÷ *របាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារ លើវិស័យធនធានទឹក និងឧតុនិយម ក្នុងប្រចាំឆ្នាំ២០១៦*,ក្រសួងធនធានទឹក និងឧតុនិយម។

១១. ក្រសួងធនធានទឹក និងឧតុនិយម÷ *របាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារ លើវិស័យធនធានទឹក និងឧតុនិយម ក្នុងប្រចាំឆ្នាំ២០១៧*,ក្រសួងធនធានទឹក និងឧតុនិយម។

១២. ក្រសួងធនធានទឹក និងឧតុនិយម÷ *របាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារ លើវិស័យធនធានទឹក និងឧតុនិយម ក្នុងប្រចាំឆ្នាំ២០១៨*,ក្រសួងធនធានទឹក និងឧតុនិយម។

១៣. ក្រសួងធនធានទឹក និងឧតុនិយម÷ *របាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារ លើវិស័យធនធានទឹក និងឧតុនិយម ក្នុងប្រចាំឆ្នាំ២០១៩*,ក្រសួងធនធានទឹក និងឧតុនិយម។

១៤. ក្រសួងធនធានទឹក និងឧតុនិយម÷ *របាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារ លើវិស័យធនធានទឹក និងឧតុនិយម ក្នុងប្រចាំឆ្នាំ២០២០,* ក្រសួងធនធានទឹក និងឧតុនិយម។
១៥. ក្រសួងធនធានទឹក និងឧតុនិយម÷ *របាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារ លើវិស័យធនធានទឹក និងឧតុនិយម ក្នុងប្រចាំឆ្នាំ២០២១,* ក្រសួងធនធានទឹក និងឧតុនិយម។
១៦. ក្រសួងធនធានទឹក និងឧតុនិយម÷ *របាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារ លើវិស័យធនធានទឹក និងឧតុនិយម ក្នុងប្រចាំឆ្នាំ២០២២,* ក្រសួងធនធានទឹក និងឧតុនិយម។
១៧. ក្រសួងធនធានទឹក និងឧតុនិយម÷ *របាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារ លើវិស័យធនធានទឹក និងឧតុនិយម ក្នុងប្រចាំឆ្នាំ២០២៣,* ក្រសួងធនធានទឹក និងឧតុនិយម។
១៨. ក្រសួងបរិស្ថាន÷ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី ៣ ឆ្នាំ២០២០,* ក្រសួងបរិស្ថាន។
១៩. ក្រសួងបរិស្ថាន÷ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី ៤ ឆ្នាំ២០២១,* ក្រសួងបរិស្ថាន។
២០. វិទ្យាស្ថានជាតិស្ថិតិ÷ *សៀវភៅកម្រងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ ២០១៧,* វិទ្យាស្ថានជាតិស្ថិតិ។
២១. អាជ្ញាធរមីនកម្ពុជា÷ *ចំនួនជនរងគ្រោះដោយគ្រាប់មីន និង ដោយសារគ្រាប់ ពីឆ្នាំ១៩៩២ - ២០២៣តាមរាជធានី ខេត្ត,* អាជ្ញាធរមីនកម្ពុជា។

## ខ.ឯកសារយោងជាភាសាអង់គ្លេស

1. National Institute of Statistics, Ministry of Planning, *General Population Census of Cambodia 2008, Analysis of the Census Results, Report 12 Population Projection of Cambodia, Phnom Penh,* National Institute of Statistics, Ministry of Planning 2011.
2. National Institute of Statistics, Ministry of Planning, *Reclassification of Urban Areas in Cambodia 2011, Phnom Penh,* National Institute of Statistics, Ministry of Planning 2011.
3. United Nations, Department of Economic and Social Affairs, Population Division 2022. *World Population Prospects 2022*, United Nations, Online Edition.
4. Ministry of Environment, *A Third Study Understanding Public Perception of Climate Change in Cambodia, Knowledge, Attitude, and Practice (KAP3),* Ministry of Environment, 2020.
5. JAY L. DEVORE, *Probability and Statistics for Engineering and the Sciences, Sixth Edition,* JAY L. DEVORE, 2004.

6. National Institute of Statistics, Ministry of Planning, *Population Projection in Cambodia 2020, Phnom Penh,* National Institute of Statistics, Ministry of Planning 2020.
7. United Nations, Population Division, Department of Economic and Social Affairs, *World Population Prospects 2022, Summary of Results*, United Nations, Population Division, Department of Economic and Social Affairs, New York, 2022.
8. UN Migration, *World Migration Report 2022*, 2022, UN Migration.
9. Ministry of Planning, *Cambodia Millennium Development Goals Report 2003,* Ministry of Planning, Phnom Penh, November 2003.

## គ. ឯកសារយោងជាគេហទំព័រ ( Website )

1. RELIEFWEB, *2021 Global Natural Disaster Assessment Report,* [website], 14 October 2022, https://reliefweb.int/report/world/2021-global-natural-disaster-assessment-report. (Accessed 7 December 2022).
2. World Health Organization (WHO), *WHO Coronavirus (COVID-19) Dashboard,* [website], 19 October 2023, https://covid19.who.int/?mapFilter=cases. (Accessed 19 October 2023), (Accessed 25 December 2023).
3. Worldometer, *Current World Population Clock: 8.1 Billion People (LIVE, 2023),* [website], 19 October 2023, www.worldometers.info/worldpopulation/#:~:text= World%20 Population%20Clock%3A%208.1%20Billion, (LIVE%2C%202023) %20-%20Worldometer. (Accessed 19 October 2023).
4. 2010-2022 Macrotrends LLC*, World Urban Population 1960-2022* , [website], 2023, https://www.macrotrends.net/countries/WLD/world/urban-population, (accessed 25 December 2023).
5. ចំណេះដឹងទូទៅ, *បរិស្ថាន ការអភិវឌ្ឍ* [website],27 September 2018. https://www.khsearch.com/qna/8284. (Accessed 21 August 2023).
6. ក្រសួងបរិស្ថាន, *តំបន់ការពារធម្មជាតិ* [website], 15 March 2021. https://www.moe. gov.kh /index/29971. (Accessed 23 August 2023).

7. REPERES, *World War I Casualty,* [website], November 2018.
https://www.census.gov/history/pdf/reperes112018.pdf.
*(Accessed 24 October 2023).*

8. The National WWII Museum New Orleands, *World War II,* [website],
https://www.nationalww2museum.org/students-teachers/student-resources/research-starters/research-starters-worldwide-deaths-world-war.
*(Accessed 24 October 2023).*

9. ESRI, *Sentinel-2 Land Cover Explorer*, [website], 2017, https://livingatlas.arcgis.com/landcoverexplorer/#mapCenter=111.962%2C29.33%2C6&mode=step&timeExtent=2017%2C2022&year=2017&renderingRule=0, ESRI.
*(Accessed 24 October 2023).*

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# បញ្ជីសំណួរការចុះស្រង់ទិន្នន័យ
# នៅក្នុងខេត្តកែប និងខេត្តកំពតសម្រាប់
# អនុវត្តគម្រោងការងារក្រុមសង្កេតការណ៍ភពផែនដី
# នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២៣

## (សម្រាប់មេភូមិ)


**រៀបចំដោយ៖**

អង្គភាពក្រុមសង្កេតការភពផែនដី

វិទ្យាស្ថានជាតិស្ថិតិ

ក្រសួងផែនការ



រាជធានីភ្នំពេញ ខែ ............ ឆ្នាំ ២០២៣

**១. ព័ត៌មានសម្គាល់៖**

រាជធានី/ខេត្ត............................................... ☐☐

ក្រុង/ស្រុក/ខណ្ឌ........................................... ☐☐

ឃុំ/សង្កាត់................................................... ☐☐

ភូមិ/មណ្ឌល................................................. ☐☐

ទីប្រជុំជន/ជនបទ.......................................... ☐☐

កាលបរិច្ឆេទចុះស្រង់ទិន្នន័យៈ ថ្ងៃទី ........ ខែ ........... ឆ្នាំ ២០២៣

ឈ្មោះមេភូមិ ........................................ភេទ ............ អាយុ........

លេខទូរស័ព្ទមេភូមិ ...................................

ឈ្មោះមន្ត្រីសម្ភាសន៍ ................................................

២. **ព័ត៌មានអំពីគ្រួសារក្នុងភូមិ៖**

| ល.រ | ប្រភេទទិន្នន័យ | ២០២២ | ២០២៣ |
|---|---|---|---|
| ១ | ចំនួនប្រជាជនសរុប | | |
| ២ | ចំនួនគ្រួសារសរុប | | |
| ៣ | ចំនួនគ្រួសារទទួលបានទឹកស្អាត | | |
| ៤ | ចំនួនគ្រួសារដែលប្រើប្រាស់អគ្គិសនី | | |
| ៥ | ចំនួនគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់ | | |
| ៦ | ចំនួនប្រជាជនធ្វើការក្នុងវិស័យកសិកម្ម | | |
| ៧ | ចំនួនប្រជាជនធ្វើការក្នុងវិស័យឧស្សាហកម្ម | | |
| ៨ | ចំនួនប្រជាជនធ្វើការក្នុងវិស័យសេវាកម្ម | | |
| ៩ | ចំនួនរោងចក្រសហគ្រាសដែលមានកម្មករចាប់ពី ១៥នាក់ឡើង | | |

៣. **ព័ត៌មានអំពីគ្រោះមហន្តរាយ ៖**

៣.១ តើប្រជាជនក្នុងភូមិបានទទួលព័ត៌មានគ្រោះមហន្តរាយពីប្រភពណាខ្លះ ?

ក. គ្មាន.......................................... ☐

ខ. មាន .......................................... ☐

១. តាមរយៈអាជ្ញាធរមូលដ្ឋាន........... ☐

២. តាមរយៈទូរទស្សន៍..................... ☐

៣. តាមរយៈវិទ្យុ.............................. ☐

៤. តាមរយៈការទំនាក់ទំនងទូរសព្ទដៃ.................................... ☐
៥. តាមរយៈការផ្ញើសារតាមប្រព័ន្ធទូរសព្ទដៃ............................ ☐.
៦. តាមការសែត............................................................... ☐
៧. តាមប្រភពផ្សេង (បញ្ជាក់)............................................ ☐

៣.២ តើមានចំនួនសម្ភារៈប៉ុន្មានដែលខូចខាត ដោយសារខ្យល់ព្យុះ ឬ ខ្យល់កន្ត្រាក់ ដែរ ឬ ទេក្នុងឆ្នាំ ២០២៣ កន្លងមក? បើគ្មាន សូមចុះលេខសូន្យ " ០ "

ក. ចំនួនផ្ទះសម្បែងដែលខូចខាត ☐ គិតជាប្រាក់ដុល្លារ ☐
ខ. ចំនួនយានយន្តដែលខូចខាតៈ ម៉ូតូ ☐ ឡាន ☐ គិតជាប្រាក់ដុល្លារ ☐
គ.ចំនួនសម្ភារៈខូចខាតផ្សេងៗ (បញ្ជាក់)...................................... ☐
គិតជាប្រាក់ដុល្លារ ☐

៣.៣ តើមានជនរងគ្រោះដោយសាររន្ទះបាញ់ប៉ុន្មាននាក់ក្នុងឆ្នាំ ២០២៣ កន្លងមក ? បើគ្មាន សូមចុះលេខសូន្យ " ០ " ☐

៣.៤ តើមានចំនួនគ្រួសារប៉ុន្មានទទួលរងគ្រោះដោយសារទឹកជំនន់ដែរ ឬ ទេក្នុងឆ្នាំ ២០២៣ កន្លងមក? បើគ្មាន សូមចុះលេខសូន្យ " ០ " ☐
សរុបការខូចខាតគិតជាប្រាក់ដុល្លារ ☐

៣.៥ តើមានចំនួនគ្រួសារប៉ុន្មានដែលខ្វះខាតទឹកប្រើប្រាស់ ដោយសារគ្រោះរាំងស្ងួតក្នុងឆ្នាំ ២០២៣ កន្លងមក? បើគ្មាន សូមចុះលេខសូន្យ " ០ " ☐
សរុបការខូចខាតគិតជាប្រាក់ដុល្លារ ☐

៣.៦ តើមានចំនួនគ្រួសារប៉ុន្មានដែលធ្លាប់ទទួលរងគ្រោះដោយសារបាក់ច្រាំងទន្លេ ស្ទឹង ព្រែក ... ក្នុងឆ្នាំ ២០២៣ កន្លងមកដែរ ឬ ទេ? បើគ្មាន សូមចុះលេខសូន្យ " ០ " ☐
សរុបការខូចខាតគិតជាប្រាក់ដុល្លារ ☐

## ៤. ផលប៉ះពាល់បរិស្ថានក្នុងភូមិ

៤.១ ចំនួនគ្រួសារដែលទទួលរងផលប៉ះពាល់ពីកាកសំណល់ សិប្បកម្ម ឬ រោងចក្រ ☐
៤.២ ចំនួនគ្រួសារដែលរងផលប៉ះពាល់ការបង្ហូរទឹកសំអុយ ☐

## ៥. ការប្រែប្រួលអាកាសធាតុ

៥.១ តើតាមការកត់សំគាល់របស់លោកពូអ្នកមីងឃើញថាមានការប្រែប្រួលទាក់ទងនឹងអាកាសធាតុដូចម្តេចដែរ ?

| | | | | |
|---|---|---|---|---|
| ក. សីតុណ្ហភាព | ប្រែប្រួល | ☐ | មិនប្រែប្រួល | ☐ |
| ខ. ទឹកភ្លៀង | ទៀងទាត់ | ☐ | មិនទៀងទាត់ | ☐ |
| គ. គ្រោះរាំងស្ងួត | មានរាំងស្ងួត | ☐ | មិនមានរាំងស្ងួត | ☐ |

ឧបសម្ព័ន្ធ២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# បញ្ជីសំណួរការចុះស្រង់ទិន្នន័យ នៅក្នុងខេត្តកំពត និងខេត្តកែប សម្រាប់ អនុវត្តគម្រោងការងារក្រុមសង្កេតការណ៍ភពផែនដី នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២៣

## (សម្រាប់គ្រួសារ)

## រៀបចំដោយ៖

អង្គភាពក្រុមសង្កេតការភពផែនដី
វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

រាជធានីភ្នំពេញ ឆ្នាំ ២០២៣

**១. ព័ត៌មានសម្គាល់៖**

រាជធានី/ខេត្ត.............................................. ☐☐

ក្រុង/ស្រុក/ខណ្ឌ.......................................... ☐☐

ឃុំ/សង្កាត់.................................................. ☐☐

ភូមិ/មណ្ឌល................................................ ☐☐

ទីប្រជុំ/ជនបទ ............................................ ☐☐

កាលបរិច្ឆេទចុះស្រង់ទិន្នន័យ: ថ្ងៃទី ........... ខែ ..... ឆ្នាំ ២០២៣

ឈ្មោះអ្នកតបសម្ភាសន៍ ..........................................

លេខទូរស័ព្ទអ្នកតបសម្ភាសន៍ ..................................

ឈ្មោះមន្ត្រីសម្ភាសន៍ .............................................

**២. ព័ត៌មានទូទៅអំពីគ្រួសារ៖**

**២.១ ចំនួនសមាជិកគ្រួសារ (២០២២)**

ឈ្មោះមេគ្រួសារ ....................................... ភេទ .......... អាយុ ..........

| សមាជិកអចិន្ត្រៃយ៍ | | | សមាជិកចំណាកស្រុក | | | ចំណាកស្រុកក្នុប្រទេស | | | ចំណាកស្រុកក្រៅប្រទេស | | |
|---|---|---|---|---|---|---|---|---|---|---|---|
| សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| | | | | | | | | | | | |

**២.១.១ មុខរបរចម្បងរបស់សមាជិកគ្រួសារក្នុងរយៈពេល ១២ ខែ កន្លងមក(២០២៣)**

ក. ចំនួនសមាជិកក្នុងគ្រួសារធ្វើការក្នុងវិស័យកសិកម្ម (ដាំដំណាំ និងចិញ្ចឹមសត្វ) ៖

ប្រុស ☐ ស្រី ☐ សរុប ☐

ខ. ចំនួនសមាជិកក្នុងគ្រួសារធ្វើការនេសាទ៖

ប្រុស ☐ ស្រី ☐ សរុប ☐

គ. ចំនួនសមាជិកក្នុងគ្រួសារធ្វើការក្នុងវិស័យឧស្សាហកម្ម៖ ប្រុស ☐ ស្រី ☐ សរុប ☐

ឃ. ចំនួនសមាជិកក្នុងគ្រួសារធ្វើការក្នុងវិស័យសេវាកម្ម៖ ប្រុស ☐ ស្រី ☐ សរុប ☐

**២.១.២ ចំនួនសមាជិកគ្រួសារធ្វើការងារក្នុងផ្នែកណាមួយក្នុងរយៈពេល ១២ ខែ កន្លងមក(២០២៣)**

ក.រដ្ឋាភិបាល ប្រុស ☐ ស្រី ☐ សរុប ☐

ខ. អង្គភាពស្វយ័ត ប្រុស ☐ ស្រី ☐ សរុប ☐

គ. ផ្នែកឯកជនខ្មែរ ប្រុស ☐ ស្រី ☐ សរុប ☐

ឃ.ផ្នែកឯកជនបរទេស ប្រុស ☐ ស្រី ☐ សរុប ☐

ង. ស្ថាប័នមិនយកប្រាក់ចំណេញ ប្រុស ☐ ស្រី ☐ សរុប ☐
ច. ផ្នែកគ្រួសារ ប្រុស ☐ ស្រី ☐ សរុប ☐
ឆ.ស្ថានទូត/ស្ថាប័នអន្តរជាតិ និងភ្នាក់ងារអភិវឌ្ឍន៍ និងជំនួយបរទេស
ប្រុស ☐ ស្រី ☐ សរុប ☐
ជ. ផ្សេងៗ.................................ប្រុស ☐ ស្រី ☐ សរុប ☐

### ២.១.៣ ចំនួនសមាជិកគ្រួសារចំណាកស្រុកក្នុងប្រទេសចាប់ពី ៦ខែឡើងទៅ (២០២៣)

| ឈ្មោះ រាជធានី ខេត្ត | មូលហេតុ | សរុប | ប្រុស | ស្រី |
|---|---|---|---|---|
| ១. | | | | |
| ២. | | | | |
| ៣. | | | | |
| ៤. | | | | |
| ៥. | | | | |

### ២.១.៤ ចំនួនសមាជិកគ្រួសារចំណាកស្រុកក្រៅប្រទេសចាប់ពី ៦ខែឡើងទៅ (២០២៣)

| ឈ្មោះប្រទេស | មូលហេតុ | សរុប | ប្រុស | ស្រី |
|---|---|---|---|---|
| ១. | | | | |
| ២. | | | | |
| ៣. | | | | |
| ៤. | | | | |
| ៥. | | | | |

### ២.២ មុខរបររបស់សមាជិកគ្រួសារ (២០២៣)

| មុខរបរចម្បងៗ | ចំនួនសមាជិកគ្រួសារដែលបានចូលរួម | | |
|---|---|---|---|
| | សរុប | ប្រុស | ស្រី |
| ១. | | | |
| ២. | | | |
| ៣. | | | |
| ៤. | | | |
| ៥. | | | |
| **សរុប** | | | |

## ៣. ព័ត៌មានបរិស្ថានអំពីគ្រួសារ

១=មាន ២=គ្មាន

| ល.រ | ប្រភេទប៉ះពាល់បរិស្ថាន | ២០២២ | ២០២៣ |
|---|---|---|---|
| ១ | បង្គន់អនាម័យ | | |
| ២ | សេវាប្រមូលសំរាម | | |
| ៣ | ទីតាំងចោលសំរាមក្នុងភូមិ | | |
| ៤ | ទីតាំងទុកដាក់សំរាមនៅក្នុងបរិវេណផ្ទះ | | |
| ៥ | ផលប៉ះពាល់ពីការចោលសំរាម | | |
| ៦ | ផលប៉ះពាល់ពីកាកសំណល់សិប្បកម្ម/រោងចក្រ | | |
| ៧ | ផលប៉ះពាល់បង្ហូរទឹកសំអុយចូលក្នុងទឹក | | |
| ៨ | ផលប៉ះពាល់ថ្នាំបាញ់សម្លាប់សត្វល្អិត | | |
| ៩ | ផលប៉ះពាល់ការប្រើប្រាស់ជីគីមី | | |
| ១០ | កាប់បំផ្លាញព្រៃឈើ | | |
| ១១ | កាប់បំផ្លាញព្រៃលិចទឹក | | |
| ១២ | ផ្សេងៗ (បញ្ជាក់) | | |

## ៤. គ្រោះមហន្តរាយ

### ៤.១ តើអ្នកបានទទួលព័ត៌មានគ្រោះមហន្តរាយពីប្រភពណាខ្លះ? ☑

ក. គ្មាន.................................... ☐

ខ. មាន.................................... ☐

១. តាមរយៈអាជ្ញាធរមូលដ្ឋាន.................................. ☐

២. តាមរយៈទូរទស្សន៍.......................................... ☐

៣. តាមរយៈវិទ្យុ.................................................. ☐

៤. តាមរយៈការទំនាក់ទំនងទូរសព្ទដៃ........................ ☐

៥. តាមរយៈការផ្ញើសារតាមប្រព័ន្ធទូរសព្ទដៃ................. ☐

៦. តាមការសែត.................................................. ☐

៧. តាមប្រភពផ្សេង (បញ្ជាក់)................................. ☐

**៤.២ តើគ្រួសារអ្នកធ្លាប់ទទួលរងគ្រោះដោយសារខ្យល់ព្យុះ ឬ ខ្យល់កន្ត្រាក់ ដែរ ឬ ទេក្នុងឆ្នាំ ២០២៣ កន្លងមក?**

បាទ/ចាស ☐ ទេ ☐

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៤.៣)*

ក. ខូចខាតផ្ទះសម្បែង ☐

ខ. ខូចខាតទ្រព្យសម្បត្តិ (កង់, ម៉ូតូ, ឡាន...) ☐

គ. សមាជិកគ្រួសារទទួលរងរបួស ប្រុស ☐ ស្រី ☐ សរុប ☐

ឃ. សមាជិកគ្រួសារទទួលរងគ្រោះដល់ស្លាប់ ប្រុស ☐ ស្រី ☐ សរុប ☐

ង. ផ្សេងៗសូមបញ្ជាក់(.....................................................) ☐

សរុបការខូចខាតគិតជាប្រាក់ដុល្លារ ☐

**៤.៣ តើសមាជិកគ្រួសារអ្នកធ្លាប់ទទួលរងគ្រោះដោយសាររន្ទះបាញ់ដែរ ឬ ទេក្នុងឆ្នាំ២០២៣ កន្លងមក?**

បាទ/ចាស ☐ ទេ ☐

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៤.៤)*

ក. សមាជិកគ្រួសារទទួលរងរបួស ប្រុស ☐ ស្រី ☐ សរុប ☐

ខ. សមាជិកគ្រួសារទទួលរងគ្រោះដល់ស្លាប់ ប្រុស ☐ ស្រី ☐ សរុប ☐

**៤.៤ តើមានសត្វពាហនៈនៅក្នុងគ្រួសារអ្នកដែលទទួលរងគ្រោះដោយសាររន្ទះបាញ់ដែរ ឬ ទេក្នុងឆ្នាំ ២០២៣ កន្លងមក?**

បាទ/ចាស ☐ ទេ ☐

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៤.៥)*

ក. ចំនួនសត្វពាហនៈស្លាប់ ☐

ខ. ចំនួនសត្វផ្សេងៗដែលស្លាប់សូមបញ្ជាក់(................................................) ☐

**៤.៥ តើគ្រួសារអ្នកធ្លាប់ទទួលរងគ្រោះដោយសារទឹកជំនន់ដែរ ឬ ទេក្នុងឆ្នាំ ២០២៣ កន្លងមក?**

បាទ/ចាស ☐ ទេ ☐

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៤.៦)*

ក. ខូចខាតផ្ទះសម្បែង ☐

ខ. ខូចខាតដំណាំកសិកម្ម ☐

គ. ប៉ះពាល់ដល់សត្វពាហនៈ ☐

ឃ. ផ្សេងៗសូមបញ្ជាក់(.....................................................) ☐

សរុបការខូចខាតគិតជាប្រាក់ដុល្លារ ☐

៤.៦ តើគ្រួសារអ្នកធ្លាប់ទទួលរងគ្រោះដោយសារគ្រោះរាំងស្ងួត ឬ ខ្វះខាតទឹក ដែរ ឬ ទេក្នុងឆ្នាំ ២០២៣ កន្លងមក?

បាទ/ចាស ☐ ទេ ☐

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៤.៧)*

ក. ខូចខាតដំណាំកសិកម្ម ☐

ខ. ប៉ះពាល់ដល់សត្វពាហនៈ ☐

គ. ខ្វះទឹកប្រើប្រាស់ក្នុងគ្រួសារ ☐

ឃ. ផ្សេងៗសូមបញ្ជាក់(.......................................................) ☐

សរុបការខូចខាតគិតជាប្រាក់ដុល្លារ ☐

៤.៧ តើគ្រួសារអ្នកធ្លាប់ទទួលរងគ្រោះដោយសារបាក់ច្រាំង ទន្លេ បឹង ស្ទឹង ព្រែក ក្នុងឆ្នាំ ២០២៣ កន្លងមកដែរ ឬ ទេ?

បាទ/ចាស ☐ ទេ ☐

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៤.៨)*

ក. បាត់បង់ផ្ទះសម្បែង ☐

ខ. បាត់បង់អាយុជីវិត ☐

គ. ផ្សេងៗសូមបញ្ជាក់(.......................................................) ☐

សរុបការខូចខាតគិតជាប្រាក់ដុល្លារ ☐

៤.៨ តើគ្រួសារអ្នកធ្លាប់ទទួលរងគ្រោះ ដោយសារភ្លើងឆេះព្រៃក្នុងឆ្នាំ ២០២៣ កន្លែងមកដែរ ឬទេ?

បាទ/ចាស ☐ ទេ ☐

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៤.៩)*

ក. បាត់បង់ផ្ទះសម្បែង ☐

ខ. បាត់បង់អាយុជីវិត ☐

គ. ខូចខាតដំណាំ ស្រែចំការ ☐

ឃ. ផ្សេងៗសូមបញ្ជាក់(.......................................................) ☐

សរុបការខូចខាតគិតជាប្រាក់ដុល្លារ ☐

៤.៩ តើគ្រួសារអ្នកធ្លាប់ទទួលរងគ្រោះ ដោយសារជំងឺរាតត្បាត COVID19 ក្នុង ឆ្នាំ ២០២៣ កន្លងមកដែរឬទេ?

បាទ/ចាស ☐ ទេ ☐

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៥)*

ក. សមាជិកគ្រួសារឆ្លងជំងឺCOVID19 ប្រុស ☐ ស្រី ☐ សរុប ☐

ខ. សមាជិកគ្រួសារបាត់បង់អាយុជីវិត ប្រុស ☐ ស្រី ☐ សរុប ☐

គ. សមាជិកគ្រួសារជាសះស្បើយ ប្រុស ☐ ស្រី ☐ សរុប ☐

## ៥. ការប្រែប្រួលអាកាសធាតុ

**៥.១ តើក្នុងឆ្នាំ ២០២៣ កន្លងមក ស្ថានភាពទឹកភ្លៀងយ៉ាងដូចម្តេចដែរនៅក្នុងភូមិ?**

ក. ទៀងទាត់ ☐

ខ. មិនទៀងទាត់ ☐

គ. ទៀងទាត់ខ្លះ មិនទៀងទាត់ខ្លះ ☐

**៥.២ តើសីតុណ្ហភាពក្នុងឆ្នាំ ២០២៣ កន្លងមក មានលក្ខណៈយ៉ាងដូចម្តេចដែរនៅក្នុងភូមិ?**

ក. ក្តៅខ្លាំង ☐

ខ. ត្រជាក់ខ្លាំង ☐

គ. ក្តៅល្មម ☐

ឃ. ត្រជាក់ល្មម ☐

# តារាង Standard Normal Curve Areas

| Z | 0.00 | 0.01 | 0.02 | 0.03 | 0.04 | 0.05 | 0.06 | 0.07 | 0.08 | 0.09 |
|---|---|---|---|---|---|---|---|---|---|---|
| 0.0 | 0.50000 | 0.50399 | 0.50798 | 0.51197 | 0.51595 | 0.51994 | 0.52392 | 0.52790 | 0.53188 | 0.53586 |
| 0.1 | 0.53983 | 0.54380 | 0.54776 | 0.55172 | 0.55567 | 0.55962 | 0.56356 | 0.56749 | 0.57142 | 0.57535 |
| 0.2 | 0.57926 | 0.58317 | 0.58706 | 0.59095 | 0.59483 | 0.59871 | 0.60257 | 0.60642 | 0.61026 | 0.61409 |
| 0.3 | 0.61791 | 0.62172 | 0.62552 | 0.62930 | 0.63307 | 0.63683 | 0.64058 | 0.64431 | 0.64803 | 0.65173 |
| 0.4 | 0.65542 | 0.65910 | 0.66276 | 0.66640 | 0.67003 | 0.67364 | 0.67724 | 0.68082 | 0.68439 | 0.68793 |
| 0.5 | 0.69146 | 0.69497 | 0.69847 | 0.70194 | 0.70540 | 0.70884 | 0.71226 | 0.71566 | 0.71904 | 0.72240 |
| 0.6 | 0.72575 | 0.72907 | 0.73237 | 0.73565 | 0.73891 | 0.74215 | 0.74537 | 0.74857 | 0.75175 | 0.75490 |
| 0.7 | 0.75804 | 0.76115 | 0.76424 | 0.76730 | 0.77035 | 0.77337 | 0.77637 | 0.77935 | 0.78230 | 0.78524 |
| 0.8 | 0.78814 | 0.79103 | 0.79389 | 0.79673 | 0.79955 | 0.80234 | 0.80511 | 0.80785 | 0.81057 | 0.81327 |
| 0.9 | 0.81594 | 0.81859 | 0.82121 | 0.82381 | 0.82639 | 0.82894 | 0.83147 | 0.83398 | 0.83646 | 0.83891 |
| 1.0 | 0.84134 | 0.84375 | 0.84614 | 0.84849 | 0.85083 | 0.85314 | 0.85543 | 0.85769 | 0.85993 | 0.86214 |
| 1.1 | 0.86433 | 0.86650 | 0.86864 | 0.87076 | 0.87286 | 0.87493 | 0.87698 | 0.87900 | 0.88100 | 0.88298 |
| 1.2 | 0.88493 | 0.88686 | 0.88877 | 0.89065 | 0.89251 | 0.89435 | 0.89617 | 0.89796 | 0.89973 | 0.90147 |
| 1.3 | 0.90320 | 0.90490 | 0.90658 | 0.90824 | 0.90988 | 0.91149 | 0.91309 | 0.91466 | 0.91621 | 0.91774 |
| 1.4 | 0.91924 | 0.92073 | 0.92220 | 0.92364 | 0.92507 | 0.92647 | 0.92785 | 0.92922 | 0.93056 | 0.93189 |
| 1.5 | 0.93319 | 0.93448 | 0.93574 | 0.93699 | 0.93822 | 0.93943 | 0.94062 | 0.94179 | 0.94295 | 0.94408 |
| 1.6 | 0.94520 | 0.94630 | 0.94738 | 0.94845 | 0.94950 | 0.95053 | 0.95154 | 0.95254 | 0.95352 | 0.95449 |
| 1.7 | 0.95543 | 0.95637 | 0.95728 | 0.95818 | 0.95907 | 0.95994 | 0.96080 | 0.96164 | 0.96246 | 0.96327 |
| 1.8 | 0.96407 | 0.96485 | 0.96562 | 0.96638 | 0.96712 | 0.96784 | 0.96856 | 0.96926 | 0.96995 | 0.97062 |
| 1.9 | 0.97128 | 0.97193 | 0.97257 | 0.97320 | 0.97381 | 0.97441 | 0.97500 | 0.97558 | 0.97615 | 0.97670 |
| 2.0 | 0.97725 | 0.97778 | 0.97831 | 0.97882 | 0.97932 | 0.97982 | 0.98030 | 0.98077 | 0.98124 | 0.98169 |
| 2.1 | 0.98214 | 0.98257 | 0.98300 | 0.98341 | 0.98382 | 0.98422 | 0.98461 | 0.98500 | 0.98537 | 0.98574 |
| 2.2 | 0.98610 | 0.98645 | 0.98679 | 0.98713 | 0.98745 | 0.98778 | 0.98809 | 0.98840 | 0.98870 | 0.98899 |
| 2.3 | 0.98928 | 0.98956 | 0.98983 | 0.99010 | 0.99036 | 0.99061 | 0.99086 | 0.99111 | 0.99134 | 0.99158 |
| 2.4 | 0.99180 | 0.99202 | 0.99224 | 0.99245 | 0.99266 | 0.99286 | 0.99305 | 0.99324 | 0.99343 | 0.99361 |
| 2.5 | 0.99379 | 0.99396 | 0.99413 | 0.99430 | 0.99446 | 0.99461 | 0.99477 | 0.99492 | 0.99506 | 0.99520 |
| 2.6 | 0.99534 | 0.99547 | 0.99560 | 0.99573 | 0.99585 | 0.99598 | 0.99609 | 0.99621 | 0.99632 | 0.99643 |
| 2.7 | 0.99653 | 0.99664 | 0.99674 | 0.99683 | 0.99693 | 0.99702 | 0.99711 | 0.99720 | 0.99728 | 0.99736 |
| 2.8 | 0.99744 | 0.99752 | 0.99760 | 0.99767 | 0.99774 | 0.99781 | 0.99788 | 0.99795 | 0.99801 | 0.99807 |
| 2.9 | 0.99813 | 0.99819 | 0.99825 | 0.99831 | 0.99836 | 0.99841 | 0.99846 | 0.99851 | 0.99856 | 0.99861 |
| 3.0 | 0.99865 | 0.99869 | 0.99874 | 0.99878 | 0.99882 | 0.99886 | 0.99889 | 0.99893 | 0.99896 | 0.99900 |
| 3.1 | 0.99903 | 0.99906 | 0.99910 | 0.99913 | 0.99916 | 0.99918 | 0.99921 | 0.99924 | 0.99926 | 0.99929 |
| 3.2 | 0.99931 | 0.99934 | 0.99936 | 0.99938 | 0.99940 | 0.99942 | 0.99944 | 0.99946 | 0.99948 | 0.99950 |
| 3.3 | 0.99952 | 0.99953 | 0.99955 | 0.99957 | 0.99958 | 0.99960 | 0.99961 | 0.99962 | 0.99964 | 0.99965 |
| 3.4 | 0.99966 | 0.99968 | 0.99969 | 0.99970 | 0.99971 | 0.99972 | 0.99973 | 0.99974 | 0.99975 | 0.99976 |
| 3.5 | 0.99977 | 0.99978 | 0.99978 | 0.99979 | 0.99980 | 0.99981 | 0.99981 | 0.99982 | 0.99983 | 0.99983 |
| 3.6 | 0.99984 | 0.99985 | 0.99985 | 0.99986 | 0.99986 | 0.99987 | 0.99987 | 0.99988 | 0.99988 | 0.99989 |
| 3.7 | 0.99989 | 0.99990 | 0.99990 | 0.99990 | 0.99991 | 0.99991 | 0.99992 | 0.99992 | 0.99992 | 0.99992 |
| 3.8 | 0.99993 | 0.99993 | 0.99993 | 0.99994 | 0.99994 | 0.99994 | 0.99994 | 0.99995 | 0.99995 | 0.99995 |
| 3.9 | 0.99995 | 0.99995 | 0.99996 | 0.99996 | 0.99996 | 0.99996 | 0.99996 | 0.99996 | 0.99997 | 0.99997 |

| Z | 0.00 | 0.01 | 0.02 | 0.03 | 0.04 | 0.05 | 0.06 | 0.07 | 0.08 | 0.09 |
|---|---|---|---|---|---|---|---|---|---|---|
| -3.9 | 0.00005 | 0.00005 | 0.00004 | 0.00004 | 0.00004 | 0.00004 | 0.00004 | 0.00004 | 0.00003 | 0.00003 |
| -3.8 | 0.00007 | 0.00007 | 0.00007 | 0.00006 | 0.00006 | 0.00006 | 0.00006 | 0.00005 | 0.00005 | 0.00005 |
| -3.7 | 0.00011 | 0.00010 | 0.00010 | 0.00010 | 0.00009 | 0.00009 | 0.00008 | 0.00008 | 0.00008 | 0.00008 |
| -3.6 | 0.00016 | 0.00015 | 0.00015 | 0.00014 | 0.00014 | 0.00013 | 0.00013 | 0.00012 | 0.00012 | 0.00011 |
| -3.5 | 0.00023 | 0.00022 | 0.00022 | 0.00021 | 0.00020 | 0.00019 | 0.00019 | 0.00018 | 0.00017 | 0.00017 |
| -3.4 | 0.00034 | 0.00032 | 0.00031 | 0.00030 | 0.00029 | 0.00028 | 0.00027 | 0.00026 | 0.00025 | 0.00024 |
| -3.3 | 0.00048 | 0.00047 | 0.00045 | 0.00043 | 0.00042 | 0.00040 | 0.00039 | 0.00038 | 0.00036 | 0.00035 |
| -3.2 | 0.00069 | 0.00066 | 0.00064 | 0.00062 | 0.00060 | 0.00058 | 0.00056 | 0.00054 | 0.00052 | 0.00050 |
| -3.1 | 0.00097 | 0.00094 | 0.00090 | 0.00087 | 0.00084 | 0.00082 | 0.00079 | 0.00076 | 0.00074 | 0.00071 |
| -3.0 | 0.00135 | 0.00131 | 0.00126 | 0.00122 | 0.00118 | 0.00114 | 0.00111 | 0.00107 | 0.00104 | 0.00100 |
| -2.9 | 0.00187 | 0.00181 | 0.00175 | 0.00169 | 0.00164 | 0.00159 | 0.00154 | 0.00149 | 0.00144 | 0.00139 |
| -2.8 | 0.00256 | 0.00248 | 0.00240 | 0.00233 | 0.00226 | 0.00219 | 0.00212 | 0.00205 | 0.00199 | 0.00193 |
| -2.7 | 0.00347 | 0.00336 | 0.00326 | 0.00317 | 0.00307 | 0.00298 | 0.00289 | 0.00280 | 0.00272 | 0.00264 |
| -2.6 | 0.00466 | 0.00453 | 0.00440 | 0.00427 | 0.00415 | 0.00402 | 0.00391 | 0.00379 | 0.00368 | 0.00357 |
| -2.5 | 0.00621 | 0.00604 | 0.00587 | 0.00570 | 0.00554 | 0.00539 | 0.00523 | 0.00508 | 0.00494 | 0.00480 |
| -2.4 | 0.00820 | 0.00798 | 0.00776 | 0.00755 | 0.00734 | 0.00714 | 0.00695 | 0.00676 | 0.00657 | 0.00639 |
| -2.3 | 0.01072 | 0.01044 | 0.01017 | 0.00990 | 0.00964 | 0.00939 | 0.00914 | 0.00889 | 0.00866 | 0.00842 |
| -2.2 | 0.01390 | 0.01355 | 0.01321 | 0.01287 | 0.01255 | 0.01222 | 0.01191 | 0.01160 | 0.01130 | 0.01101 |
| -2.1 | 0.01786 | 0.01743 | 0.01700 | 0.01659 | 0.01618 | 0.01578 | 0.01539 | 0.01500 | 0.01463 | 0.01426 |
| -2.0 | 0.02275 | 0.02222 | 0.02169 | 0.02118 | 0.02068 | 0.02018 | 0.01970 | 0.01923 | 0.01876 | 0.01831 |
| -1.9 | 0.02872 | 0.02807 | 0.02743 | 0.02680 | 0.02619 | 0.02559 | 0.02500 | 0.02442 | 0.02385 | 0.02330 |
| -1.8 | 0.03593 | 0.03515 | 0.03438 | 0.03362 | 0.03288 | 0.03216 | 0.03144 | 0.03074 | 0.03005 | 0.02938 |
| -1.7 | 0.04457 | 0.04363 | 0.04272 | 0.04182 | 0.04093 | 0.04006 | 0.03920 | 0.03836 | 0.03754 | 0.03673 |
| -1.6 | 0.05480 | 0.05370 | 0.05262 | 0.05155 | 0.05050 | 0.04947 | 0.04846 | 0.04746 | 0.04648 | 0.04551 |
| -1.5 | 0.06681 | 0.06552 | 0.06426 | 0.06301 | 0.06178 | 0.06057 | 0.05938 | 0.05821 | 0.05705 | 0.05592 |
| -1.4 | 0.08076 | 0.07927 | 0.07780 | 0.07636 | 0.07493 | 0.07353 | 0.07215 | 0.07078 | 0.06944 | 0.06811 |
| -1.3 | 0.09680 | 0.09510 | 0.09342 | 0.09176 | 0.09012 | 0.08851 | 0.08691 | 0.08534 | 0.08379 | 0.08226 |
| -1.2 | 0.11507 | 0.11314 | 0.11123 | 0.10935 | 0.10749 | 0.10565 | 0.10383 | 0.10204 | 0.10027 | 0.09853 |
| -1.1 | 0.13567 | 0.13350 | 0.13136 | 0.12924 | 0.12714 | 0.12507 | 0.12302 | 0.12100 | 0.11900 | 0.11702 |
| -1.0 | 0.15866 | 0.15625 | 0.15386 | 0.15151 | 0.14917 | 0.14686 | 0.14457 | 0.14231 | 0.14007 | 0.13786 |
| -0.9 | 0.18406 | 0.18141 | 0.17879 | 0.17619 | 0.17361 | 0.17106 | 0.16853 | 0.16602 | 0.16354 | 0.16109 |
| -0.8 | 0.21186 | 0.20897 | 0.20611 | 0.20327 | 0.20045 | 0.19766 | 0.19489 | 0.19215 | 0.18943 | 0.18673 |
| -0.7 | 0.24196 | 0.23885 | 0.23576 | 0.23270 | 0.22965 | 0.22663 | 0.22363 | 0.22065 | 0.21770 | 0.21476 |
| -0.6 | 0.27425 | 0.27093 | 0.26763 | 0.26435 | 0.26109 | 0.25785 | 0.25463 | 0.25143 | 0.24825 | 0.24510 |
| -0.5 | 0.30854 | 0.30503 | 0.30153 | 0.29806 | 0.29460 | 0.29116 | 0.28774 | 0.28434 | 0.28096 | 0.27760 |
| -0.4 | 0.34458 | 0.34090 | 0.33724 | 0.33360 | 0.32997 | 0.32636 | 0.32276 | 0.31918 | 0.31561 | 0.31207 |
| -0.3 | 0.38209 | 0.37828 | 0.37448 | 0.37070 | 0.36693 | 0.36317 | 0.35942 | 0.35569 | 0.35197 | 0.34827 |
| -0.2 | 0.42074 | 0.41683 | 0.41294 | 0.40905 | 0.40517 | 0.40129 | 0.39743 | 0.39358 | 0.38974 | 0.38591 |
| -0.1 | 0.46017 | 0.45620 | 0.45224 | 0.44828 | 0.44433 | 0.44038 | 0.43644 | 0.43251 | 0.42858 | 0.42465 |
| 0.0 | 0.50000 | 0.49601 | 0.49202 | 0.48803 | 0.48405 | 0.48006 | 0.47608 | 0.47210 | 0.46812 | 0.46414 |